ទស្សនាវដ្តី

# រាជបណ្ឌិត្យសភាកម្ពុជា

## Royal Academy of Cambodia Review

## Revue de l'Académie Royale du Cambodge

ឆ្នាំទី ០១ លេខ ២ ខែកក្កដា ឆ្នាំ២០១០ No. 2 July 2010



ISBN 1234 5 6789

នាយកការផ្សាយ

បណ្ឌិត **ជា ណោង**

និពន្ធនាយក

បណ្ឌិត **អ៊ាប បុណ្ណា**

លេខាធិការដ្ឋាន

លោក ជួ ច័ន្ទជារី

លោក សួន សុខា

លោកស្រី ម៉ែន សុជាតិ

បណ្ឌិត នួយ ចាន់ឌួន

ផ្នែកហិរញ្ញវត្ថុ

លោក អ៊ឹ ប៊ុម

លោក លី សុធីរត្ន

បច្ចេកទេសកុំព្យូទ័រ

លោក **លឹម សេងឌី**

លោក **យិន ពោ**

លោក **ម៉ិន ឧត្តា**

លោក **ចឿន សុត្ថា**

អក្ខរាវិរុទ្ធ

លោក **ជួរ គារី**

លោក **មាឃ បូរ៉ា**

ទីផ្សារ និងចែកផ្សាយ

លោក **ហេង ហុកវេន**

លោក **តាំង ស៊ិន**

លោក **អាត ធារ៉ា**

លោក **ម៉ុង ស៊ាងអ៊ីម**

ទីប្រឹក្សា

បណ្ឌិត **ខ្លួត ធីតា**

បណ្ឌិត **ស៊ីន សំណាង**

បណ្ឌិត **ព្រុំ ម៉ល់**

បណ្ឌិត **ច័ន្ទ សំណព្វ**

បណ្ឌិត **នេត បារ៉ុម**

បណ្ឌិត **សេ់ ចន្ទ្រាបុត្រ**

បណ្ឌិត **សំ សោភាន់**

បណ្ឌិត **ស៊ុំ ឈុំប៊ិន**

គណៈកម្មការស្រាវជ្រាវ និង និពន្ធ

បណ្ឌិត **អ៊ុច ច័ន**

បណ្ឌិត **ប៉ែន ប៊ុនពីង**

បណ្ឌិត **សាបូ អូហ្សាណូ**

បណ្ឌិត **សោម សុមុនី**

បណ្ឌិត **សុខ ទូច**

បណ្ឌិត **នូ ចាន់សុភី**

បោះពុម្ពផ្សាយ

បណ្ឌិត **ព្រុំ ទេវី**

លោកស្រី **តាំង មុយគា**

លោក **សាន សុរាជនិត**

# អារម្ភកថា

ជិតមួយទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័សស្ទើរគ្រប់វិស័យ ក្នុងនោះវិស័យអប់រំបណ្តុះបណ្តាលនិងស្រាវជ្រាវបានលេចឡើងផងដែរនៅក្នុងចំណោមវិស័យសំខាន់ៗជាច្រើនទៀត។

ការរីកចម្រើននេះ គឺជាលទ្ធផលនៃការខិតខំប្រឹងប្រែងរបស់ប្រមុខដឹកនាំនៃរាជរដ្ឋាភិបាលរួមនិងប្រជាជនកម្ពុជា ដែលជាប្រជាជនដ៏ឧស្សាហ៍ព្យាយាម តស៊ូអំណត់អត់ធន់ ជម្នះរាល់ឧបសគ្គពុះពាររុញនាវាកម្ពុជាធ្វើដំណើរក្នុងចរន្តរីកចម្រើននៃពិភពលោក។

ស្ថាប័នរាជបណ្ឌិត្យសភាកម្ពុជា បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលបញ្ញវន្តជាន់ខ្ពស់របស់ជាតិ ហើយបច្ចុប្បន្នពួកគេកំពុងតែក្លាយទៅជាពលស្រាវជ្រាវយ៉ាងសំខាន់។

ទស្សនាវដ្តីវិទ្យាសាស្ត្ររាជបណ្ឌិត្យសភាកម្ពុជាបង្កើតឡើង ដើម្បីជួយសម្រួលដល់បណ្តាអ្នកស្រាវជ្រាវជំរុញឱ្យគេមានឆន្ទៈស្រាវជ្រាវប្រកបដោយសុក្រិតភាព និង ត្រឹមត្រូវតាមក្រឹត្យក្រមវិទ្យាសាស្ត្រ។

ទស្សនាវដ្តីនេះ ជាចំណងដៃមួយសម្រាប់អ្នកស្រាវជ្រាវទាំងអស់មានឱកាសបង្ហាញនូវស្នាដៃស្រាវជ្រាវរបស់ខ្លួន ជាពិសេសចុះផ្សាយនូវអត្ថបទស្រាវជ្រាវរបស់បេក្ខជនបណ្ឌិតដែលបណ្តុះបណ្តាលនៅរាជបណ្ឌិត្យសភាកម្ពុជា។

គណៈកម្មការទស្សនាវដ្តីវិទ្យាសាស្ត្រនៃរាជបណ្ឌិត្យសភាកម្ពុជា សង្ឃឹមថាទស្សនាវដ្តីនេះនឹងក្លាយទៅជាឯកសារស្រាវជ្រាវមួយយ៉ាងសំខាន់ ហើយវាក៏ជាម៉ែត្រមួយសម្រាប់វាស់រាល់កិច្ចការស្រាវជ្រាវទាំងអស់នេះនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែសុក្រឹត និង ប្រកបដោយគុណភាពវិទ្យាសាស្ត្រ។

គណៈកម្មការយើងខ្ញុំរង់ចាំការរិះគន់ស្ថាបនាពីសំណាក់មិត្តអ្នកអានគ្រប់មជ្ឈដ្ឋាន ដែលបានជួយផ្តល់យោបល់កែលម្អ ចំពោះកង្វះខាតនិងការធ្លាំធ្លងដែលអាចកើតមានឡើងទាំងលើខ្លឹមសារនិងបច្ចេកទេស ដើម្បីឱ្យទស្សនាវដ្តីវិទ្យាសាស្ត្រនេះក្លាយទៅជាប្រយោជន៍ដ៏សកម្ម ក្នុងការរួមចំណែកអភិវឌ្ឍប្រទេសជាតិយើង។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩

**គណៈកម្មការទស្សនាវដ្តីរាជបណ្ឌិត្យសភាកម្ពុជា**

# មាតិកា


១_សូរវិទ្យា និង សទ្ទវិទ្យា (នៅ ស៊ុន) ........ ១

២_ប្រវត្តិនៃការប្រើប្រាស់និងការវិវត្តនៃកម្មវាចក:តាមរយៈសិលាចារឹកសម័យមុនអង្គរ និង អង្គរ (មាឃ បូរ៉ា) ........ ១១

៣_អវិជ្ជមានបទនិងអវិជ្ជមានស័ព្ទក្នុងការស្ថាបនាន័យ (ជួរ គារី) ........ ២២

៤_អន្តេបទ/_ម_/នៅក្នុងភាសាខ្មែរទំនើប (វង្ស មេង) ........ ៤០

៥_ស្ថានីយបន្ទាយគូនៅកម្ពុជានិងវៀតណាម (ធុយ ចាន់ធួន) ........ ៤៣

៦_គោលនយោបាយការបរទេសរបស់សហភាពសូវៀតចំពោះប្រទេសកម្ពុជា ១៩៥៦_១៩៧៩ (ចាន់ ប៊ុន្នី) ........ ៥៦

៧_ការជ្រះបញ្ហាំងនៅលើដំណើរការនីតិកម្មនៅកម្ពុជា (គិន ភា) ........ ៧០

៨_ទស្សនវិជ្ជាព្រះពុទ្ធសាសនាមហាយាននៅសម័យមហានគរ(ក្លាន់ ផុល) ........ ៨២

៩_តម្លៃរបស់មនុស្សក្នុងសតវត្សទី២១ (ជា មុនីឫទ្ធិ) ........ ៨៦

១០_សាមគ្គីខ្មែររស់ (អ៊ុក សៅបុល) ........ ៩៥

# សូរវិទ្យា និង សទ្ទវិទ្យា

(Phonetics & Phonology)



បណ្ឌិត **នៅ ស៊ុន**

មន្ត្រីនាយកដ្ឋានស្រាវជ្រាវគរុកោសល្យ

នៃក្រសួងអប់រំ យុវជន និងកីឡា

## សូរវិទ្យា

### និយមន័យ

ក្នុងន័យទូទៅនិងដោយខ្លី សូរវិទ្យាសិក្សាពីសូរក្នុងចរន្តសម្តី(សិក្សាពីសូរសម្តី)។ សូរវិទ្យាសិក្សាពីសូរទាំងឡាយនៃសកម្មភាពសម្តីក្នុងលក្ខណៈរូបី ដោយមិនអាស្រ័យទៅនឹងមុខងារតួនាទីភាសាវិទ្យា (ដែលជាវិទ្យាសាស្ត្រសង្គម) បានន័យថា សូរវិទ្យាទាក់ទងទៅនឹងវិទ្យាសាស្ត្រពិត ដូចជា រូបវិទ្យា ជីវវិទ្យា សរីរវិទ្យា (physiology) កាយវិភាគវិទ្យា (anatomy) ជាដើម ដោយសារតែសូរវិទ្យា សិក្សាលើសូរក្នុងទិដ្ឋភាពរូបសាស្ត្រ។

យើងគប្បីស្គាល់ថាអ្វីជាសម្តីអ្វីជាសកម្មភាពសម្តី និងអ្វីជាភាសាជាមុនសិន ព្រោះជាធម្មតាតែងតែមានការយល់ច្រឡំគ្នាទៅលើអ្វីជាសម្តីអ្វីជាភាសា គឺបានន័យថា សម្តីគឺជាភាសា ភាសាគឺជាសម្តី។

### អ្វីជា សម្តី?

តាមបែបភាសាវិទ្យា សម្តីមានន័យថាជាបាតុភូតរូបសាស្ត្រ(physical phenomenon) ដែលមានលក្ខណៈរូបី ហើយមានការប្រែប្រួលទៅតាមឆន្ទៈមនុស្ស ឬ តាមលក្ខណៈរូបសាស្ត្ររបស់មនុស្ស។ សម្តីត្រូវការអ្នកនិយាយប្រាប់ (អ្នកបកស្រាយ) អ្នកស្តាប់(អ្នកទទួល) និងកម្មវត្ថុសម្រាប់និយាយ ។ ការនិយាយក្នុងចិត្ត (និយាយក្នុងពោះ) និងការចារឹកជាអក្សរ (ឯកសារសរសេរ)ក៏ត្រូវបានគេចាត់ទុកថាជា"សម្តី"ដែរ។ សម្តី គឺជាដំណើរការ (process) នៃការនិយាយ (សកម្មភាពសម្តី) និងជាលទ្ធផលនៃការនិយាយ (សមិទ្ធផលសម្តី ដែលក្នុងនោះមានការកត់ត្រាក្នុងលំនឹក (memory) និងក្នុងសំណេរ) ។

ជាធម្មតា គេតែងតែកំណត់ចរិតលក្ខណៈ (characteristic) របស់សម្តីឱ្យមានភាពខុសប្លែកពីចរិតលក្ខណៈរបស់ភាសាដែលជាកូដ ហើយមានលក្ខណៈជាសង្គមជាក្រឹត្យក្រមមួយ ជាកំណត់ជាប្រព័ន្ធនៃវិធានទាំងឡាយសម្រាប់ការប្រើប្រាស់

និងការផ្ដុំសូរភាសា។ សម្ដីនិងភាសាបង្កើតបានជាធាតុភូតរួមរបស់ភាសាមនុស្ស និង របស់ភាសាណានីមួយជាកំណត់ និង នៅក្នុងស្ថានភាពនៃភាសានោះ។សម្ដីគឺជាបុគ្គលកម្ម(personnification) និងជាសមិទ្ធផលរបស់ភាសា ដែលមានវត្តមានក្នុងសម្ដី ហើយតាមរយៈសម្ដីតែប៉ុណ្ណោះ ដែលភាសាអាចបំពេញមុខងារជាមធ្យោបាយសម្រាប់បម្រើការទាក់ទង។ ប្រសិនបើភាសាជាមធ្យោបាយ ឬជាឧបករណ៍សម្រាប់បម្រើការទាក់ទងនោះសម្ដីគ្រាន់តែជាទិដ្ឋភាពនៃទំនាក់ទំនងនោះ ហើយកើតចេញមកពីមធ្យោបាយសម្រាប់ទំនាក់ទំនងនោះ។ សម្ដីនាំភាសាចូលទៅក្នុងបរិបទនៃការប្រើប្រាស់ បានន័យថា សម្ដីយកធាតុទាំងឡាយរបស់ភាសាទៅប្រើប្រាស់ ក្នុងសកម្មភាពសម្ដី។ សម្ដីមានលក្ខណៈរូបីនិងគ្មានភាពច្រំដែល ដែលផ្ទុយពីភាសាដែលមានលក្ខណៈអរូបីនិងមានជាថ្មីឡើងវិញ (abstract & reproductive)។ សម្ដីមានលក្ខណៈជាក់ស្ដែង ចំណែកឯភាសាមានលក្ខណៈជាសក្ដានុភូត (មិនឃើញជាក់ស្ដែង)។ សម្ដីអភិវឌ្ឍឡើងនៅក្នុងកាល (times) ហើយកកើតឡើងនៅក្នុងអាកាស(space)ចំណែកភាសាចៀសវាងចេញពីទំនាក់ទំនងទាំងពីរនេះ (ទំនាក់ទំនងកាលអាកាស)។ សម្ដីមានលក្ខណៈមិនមានទីបញ្ចប់ ចំណែកភាសា ប្រព័ន្ធភាសាមានទីបញ្ចប់ (ជាឧទាហរណ៍ បើគិតពីប្រព័ន្ធទំនាក់ទំនងឋានានុក្រម ប្រព័ន្ធភាសាមានទំនាក់ទំនងត្រឹមតែពីសទ្ធតាទៅសម្ព័ន្ធពាក្យ កន្សោមពាក្យតែប៉ុណ្ណោះ)។ សម្ដីមានលក្ខណៈជាសម្ភារៈ តែសម្ដីកើតចេញពីសញ្ញានៃការបន្លឺ ដែលគេអាចទទួលបានដោយវិញ្ញាណ (គេអាចទទួលបានដោយត្រចៀក ដោយភ្នែក ដោយកាយជាដើម) ចំណែកប្រព័ន្ធភាសាបញ្ចូលក្នុងខ្លួនវានូវឯកតាទាំងឡាយដូចគ្នានឹងឯកតាសម្ដីតែក្នុងលក្ខណៈអរូបី។ សម្ដីជាខ្លឹមសារ ចំណែកភាសាជាទម្រង់។ សម្ដីមានលក្ខណៈសកម្មនិងមានឋាមភាព ចំណែកប្រព័ន្ធភាសា ជាទូទៅ មានលក្ខណៈអកម្មនិងនិចលភាព (statique)។ សម្ដីមានចលនា ចំណែកភាសានៅស្ទើរមិនមានចលនា។ សម្ដីមានលក្ខណៈជាខ្សែបន្ទាត់ (être en ligne) ចំណែកភាសាមានការរៀបចំជាកម្រិតលំដាប់ថ្នាក់។ សម្ដីមានបំណងទៅរកការប្រមូលផ្ដុំពាក្យក្នុងចរន្តសម្ដី ចំណែកភារកិច្ចរបស់ភាសាគឺ រក្សាទុកការដាក់ពាក្យឱ្យនៅដាច់ពីគ្នា។ សម្ដីគឺជាភាពបន្តបន្ទាប់គ្នានៃពាក្យចំណែកភាសាពេលដែលចូលទៅក្នុងសម្ដី វាធ្វើឱ្យពាក្យទាំងនោះមានលំដាប់ជាឋានានុក្រមវិញ។

សម្ដីមានលក្ខណៈជាអត្តនោម័ត ដោយសារតែសម្ដីជាស្នាដៃសេរីរបស់ឯកត្តបុគ្គលបានន័យថា បុគ្គលម្នាក់ៗ យកសម្ដីទៅប្រើបាស់ទៅតាមបុគ្គលភាពនិងពុទ្ធិរបស់ខ្លួនទៅតាមសង្គមឬស្ថានភាពចិត្តសាស្ត្រ

របស់ខ្លួនជាដើម ចំណែកភាសាគឺជាសមិទ្ធផលសង្គម ហើយសង្គមយកវាមកប្រើប្រាស់ ដូច្នេះភាសាមានលក្ខណៈសត្យានុម័តមិនផ្អែក ឬ មិនអាស្រ័យនឹងអ្នកនិយាយ (អ្នកផលិតសម្តី) នោះទេ។ សម្តីប្រព្រឹត្តទៅតាមឆន្ទៈអ្នកនិយាយ ចំណែកភាសាមិនប្រព្រឹត្តទៅតាមឆន្ទៈ អ្នកប្រើប្រាស់ឡើយ បានន័យថា អ្នកប្រើប្រាស់ភាសាត្រូវគោរព និងអនុវត្តតាមគោលការណ៍ភាសា។ សម្តីស្តែងឱ្យឃើញនូវបទពិសោធន៍របស់ឯកត្តបុគ្គល ចំណែកភាសាវិញក្នុងប្រព័ន្ធនៃការបង្ហាញន័យកំណត់បទពិសោធន៍របស់សមូហភាពនិងបង្ហាញពីរូបភាពរបស់ជនជាតិដែលនិយាយភាសានោះ។ សម្តីត្រូវបានគេយកទៅនិយាយទៅកាន់បុគ្គលណាមួយជាកំណត់ ចំណែកភាសាមិនបានត្រូវគេយកទៅប្រើប្រាស់សម្រាប់បុគ្គលណាមួយដោយចំពោះនោះឡើយ។ សម្តីអាស្រ័យទៅនឹងបរិបទនិងស្ថានភាពទំនាក់ទំនង ចំណែកភាសាមានភាពឯករាជ្យពីស្ថានភាពនៃទំនាក់ទំនង។ សម្តីមានការប្រែប្រួល ចំណែកភាសាបើមិនគិតភ្ជាប់នឹងគ្រាមភាសានោះទេ ក្នុងរយៈពេលនៃអត្ថិភាពរបស់វាមិនមានការប្រែប្រួលឡើយ។ សម្តីអនុញ្ញាតឱ្យមានធាតុមិនរៀបរយនិងធាតុដែលកើតឡើងដោយចៃដន្យមួយចំនួន ដែលខុសពីភាសាដែលកើតឡើងពីនិយ័តកម្មនៃឯកតា និង ទំនាក់ទំនងនៃឯកតាទាំងនោះ។ សម្តីត្រូវបានគេយកបញ្ចូលក្នុងកម្មវត្ថុនៃសកម្មភាពនិងអាចត្រូវបានគេពិនិត្យដោយឈរលើសភាវគតិភាពឬអគតភាព ចំពោះភាសាវិញមិនទទួលយកមាន សភាវគតិ ភាពនេះទេ។

### អ្វីជាសកម្មភាពសម្តី?

ជាសម្បទាផ្ទាល់របស់មនុស្ស (សម្រាប់តែមនុស្សប៉ុណ្ណោះ) ក្នុងការបញ្ចេញនិងបង្ហាញគំនិត និងក្នុងការធ្វើទំនាក់ទំនងដោយសូរផ្ទាល់មាត់ (សម្រាប់សម្តីផ្ទាល់មាត់) និងដោយប្រើប្រាស់ប្រព័ន្ធសំណេរ (សញ្ញាអក្សរ)។ ដូចគ្នានឹងសម្តីដែរ សកម្មភាពសម្តីត្រូវការនូវកត្តាបីយ៉ាងខាងលើនេះ (អ្នកនិយាយអ្នកស្តាប់និងកម្មវត្ថុសម្រាប់និយាយ)។

### អ្វីជាភាសា?

ផ្ទុយពីសម្តីភាសាមានលក្ខណៈអរូបី កើតមានតែក្នុងសង្គមមនុស្សមានមុខងារជាមធ្យោបាយ ឬជាឧបករណ៍សម្រាប់ទាក់ទងមិនអាចប្រែប្រួលទៅតាមឆន្ទៈមនុស្ស។ ភាសាជាគ្រឿងផ្សំ (ធាតុ) របស់សម្តី ព្រោះក្នុងសម្តី គេយកធាតុភាសាមកប្រើប្រាស់ទៅតាមក្បួនខ្នាតភាសានីមួយៗ។

ដោយសារតែមានការខុសប្លែកគ្នារវាងសម្តីនិងភាសានេះហើយ ទើបគេបែងចែកការសិក្សាពីសូរ (សម្តីភាសា) ជាពីរផ្នែកគឺ សូរវិទ្យា (phonetics) និង សទ្ទវិទ្យា (phonology)។

# សូរវិទ្យា និង សទ្ទវិទ្យា

(Phonetics & Phonology)



បណ្ឌិត **នៅ ស៊ុន**

មន្ត្រីនាយកដ្ឋានស្រាវជ្រាវគរុកោសល្យ

នៃក្រសួងអប់រំ យុវជន និងកីឡា

## សូរវិទ្យា

### និយមន័យ

ក្នុងន័យទូទៅនិងដោយខ្លី សូរវិទ្យាសិក្សាពីសូរក្នុងចរន្តសម្តី(សិក្សាពីសូរសម្តី)។ សូរវិទ្យាសិក្សាពីសូរទាំងឡាយនៃសកម្មភាពសម្តីក្នុងលក្ខណៈរូបីដោយមិនអាស្រ័យទៅនឹងមុខងារតួនាទីភាសាវិទ្យា (ដែលជាវិទ្យាសាស្ត្រសង្គម) បានន័យថា សូរវិទ្យាទាក់ទងទៅនឹងវិទ្យាសាស្ត្រពិត ដូចជា រូបវិទ្យា ជីវវិទ្យា សរីរវិទ្យា (physiology) កាយវិភាគវិទ្យា (anatomy) ជាដើម ដោយសារតែសូរវិទ្យា សិក្សាលើសូរក្នុងទិដ្ឋភាពរូបសាស្ត្រ។

យើងគប្បីស្គាល់ថាអ្វីជាសម្តីអ្វីជាសកម្មភាពសម្តី និងអ្វីជាភាសាជាមុនសិន ព្រោះជាធម្មតាតែងតែមានការយល់ច្រឡំគ្នាទៅលើអ្វីជាសម្តីអ្វីជាភាសា គឺបានន័យថា សម្តីគឺជាភាសា ភាសាគឺជាសម្តី។

**អ្វីជា សម្តី ?**

តាមបែបភាសាវិទ្យា សម្តីមានន័យថាជាបាតុភូតរូបសាស្ត្រ(physical phenomenon) ដែលមានលក្ខណៈរូបី ហើយមានការប្រែប្រួលទៅតាមចន្ទៈមនុស្ស ឬ តាមលក្ខណៈរូបសាស្ត្ររបស់មនុស្ស។ សម្តីត្រូវការអ្នកនិយាយប្រាប់ (អ្នកបកស្រាយ) អ្នកស្តាប់(អ្នកទទួល) និងកម្មវត្ថុសម្រាប់និយាយ ។ ការនិយាយក្នុងចិត្ត (និយាយក្នុងពោះ) និងការចារឹកជាអក្សរ (ឯកសារសរសេរ) ក៏ត្រូវបានគេចាត់ទុកថាជា"សម្តី"ដែរ។ សម្តី គឺជាដំណើរការ (process) នៃការនិយាយ (សកម្មភាពសម្តី) និងជាលទ្ធផលនៃការនិយាយ (សមិទ្ធផលសម្តី ដែលក្នុងនោះមានការកត់ត្រាក្នុងលំនឹក (memory) និងក្នុងសំណេរ) ។

ជាធម្មតា គេតែងតែកំណត់ចរិតលក្ខណៈ (characteristic) របស់សម្តីឱ្យមានភាពខុសប្លែកពីចរិតលក្ខណៈរបស់ភាសាដែលជាកូដ ហើយមានលក្ខណៈជាសង្គមជាក្រឹត្យក្រមមួយ ជាកំណត់ជាប្រព័ន្ធនៃវិធានទាំងឡាយសម្រាប់ការប្រើប្រាស់

លោក ទ្រូបេតស្កយ (Troubetskoy) ភាសាវិទូជាតិរុស្ស៊ី ជាអ្នកនិពន្ធស្នាដៃភាសាវិទ្យាដ៏ល្បីមួយឈ្មោះថា"គោលការណ៍សទ្ទវិទ្យា"(Principles of Phonology) ឱ្យនិយមន័យសូរវិទ្យាថា ជាវិទ្យាសាស្ត្ររបស់សូរទាំងឡាយ ដែលជាផ្នែកមួយនៃរូបធាតុ (material) របស់សកម្មភាពសម្ដីរបស់មនុស្ស (Troubetskoy N.S. Principles of Phonology, 1939 សូរវិទ្យា ជាទូទៅសិក្សាពីកន្សោមលទ្ធភាពសូររបស់មនុស្ស (សិក្សាតែសូរភាសាមនុស្ស) តាមរយៈភាសា ធម្មជាតិ ។

ម្យ៉ាងទៀត កាលណាគេសិក្សាពីសូរវិទ្យា គេត្រូវតែចែកឱ្យបានជ្រះស្រឡះរវាងសូរ និង សញ្ញាអក្សរ ដោយហេតុថា សញ្ញាអក្សរមួយមិនអាចជាតំណាងឱ្យសូរមួយឬក៏សូរមួយមិនអាចតាងដោយតួអក្សរមុយបានគ្រប់ពេលនោះឡើយ បានន័យថាជួនកាលសញ្ញាមួយអាចជាតំណាងសូរពីរឬក៏ច្រើនឬសូរពីរអាចតាងដោយសញ្ញាតែមួយក៏មាន ឧ.ក្នុងភាសាខ្មែរក្នុងពាក្យ [ko:] ពាក្យនេះ យើងឃើញមានសញ្ញា "ក" (គេសរសេរបែបនេះ ដោយគេសន្មតថាស្រៈ "អ" គ្មានរូប ហើយកប់ក្នុងតួព្យញ្ជនៈ "ក") តែមួយគត់ តែមានសូរពីរ គឺសូរ [k] និងសូរស្រៈ [ɒ:] ក្នុងពាក្យ "កក" ឃើញមានសញ្ញាពីរ តែមានសូរបី : [k]+[ɒ:]+[k] ក្នុងពាក្យ "សម្ដី" មាន សញ្ញាបួនមានសូរប្រាំ : [s]+[ɒ]+[m]+[d]+[ei] ដូចគ្នាដែរ ក្នុងភាសាបារាំងពាក្យ temps មានប្រាំសញ្ញា តែមានសូរពីរ [tã] ពាក្យ peu មានសញ្ញា បីតែ មានសូរពីរ [pø] ។

## ប្រភេទសូរវិទ្យា

គេចែកសូរវិទ្យាជាប្រភេទសូរវិទ្យាប្រៀបធៀប ដែលសិក្សាដោយធ្វើការប្រៀបធៀបសូររបស់ភាសាពីរឬក៏ច្រើន។ មានសូរវិទ្យាមួយប្រភេទទៀតដែលសិក្សាសូរក្នុងលក្ខណៈពិសេសរបស់សូរក្នុងភាសាឬគ្រាមភាសាណាមួយជាកំណត់។ សូរវិទ្យាប្រវត្តិសាស្ត្រ សិក្សាពីការវិវត្តសូរភាសាក្នុងចរន្តប្រវត្តិសាស្ត្រសង្គម។ សូរវិទ្យាពណ៌នាឬសូរវិទ្យានិចលភាព សិក្សាការវិវត្តសូរក្នុងអំឡុងពេលជាកំណត់ណាមួយ។

## មែកធាងសូរវិទ្យា

គោលការណ៍នានាសម្រាប់ធ្វើការបែងចែករវាងមែកធាងសូរវិទ្យាអាចកំណត់ទៅតាមធម្មជាតិស្មុគស្មាញនៃសូរនិងនានាភាពនៃវិធីសាស្ត្រ ដែលគេយកមកធ្វើការពណ៌នា។ តាមទម្លាប់ពីមុនមកគេចែកសូរវិទ្យាជាពីរមែកធាង : **សូរវិទ្យាបន្លឺ** (phonetique articulatoire)ឬសូរវិទ្យាសរីរសាស្ត្រ (phonetique physiologique)។ សូរវិទ្យាប្រភេទនេះ សិក្សាពីចលនាប្រដាប់បន្លឺក្នុងពេលបន្លឺសូរ។ ***សូរវិទ្យាអាគូស្ទិចឬសូរវិទ្យារូបវិទ្យា*** ដែលសិក្សាពី

ការបន្សាយសំឡេង ដោយរំញ័រខ្យល់និងពីរបៀបដែលរំញ័រខ្យល់នោះទៅប៉ះត្រចៀកអ្នកស្ដាប់។

***សូរវិទ្យាពិសោធន៍*** ប្រើប្រាស់ឧបករណ៍នានាសម្រាប់បំពេញឬបន្ថែមតឹកតាងសម្រាប់ត្រចៀក និងសម្រាប់ការសង្កេតដោយផ្ទាល់ក្នុងការសិក្សាពីដំណើរការកកើតនិងទទួលសំឡេង។ មានវិធីសាស្ត្រច្រើនរបស់សូរវិទ្យាពិសោធន៍ ដូចជា វិធីប្រើថតក្រអូមមាត់ (palate- graphie) វិទ្យុសាស្ត្រ (radiographie) ជាដើមដែលជួយដល់ការស្រាយបញ្ជាក់ពីកាយវិភាគនិងសរីរវិទ្យារបស់ប្រដាប់បន្លឺសំឡេង។ សូរវិទ្យាពិសោធន៍ទទួលការចម្រើនឡើងក្រោយពីឆ្នាំ១៩៣០ ដោយសារការកើតឡើងនូវឧបករណ៍ដែលប្រកបដោយគុណភាពមួយចំនួន ដូចជាអូស៊ីលោក្រាប ស្ប៉ិចតូក្រាប សូណូក្រាប។ ក្នុងការសិក្សាសូរវិទ្យារបស់យើងនៅពេលនេះគឺផ្ដោតជាសំខាន់ទៅលើលក្ខណៈទូទៅនៃសូរវិទ្យាបន្លឺ ឬសូរវិទ្យាសរីរសាស្ត្រសទ្ទវិទ្យា ទិដ្ឋភាព និងធាតុនានានៃវិទ្យាសាស្ត្រទាំងពីរនេះ។ បន្ទាប់មកយើងធ្វើការសិក្សាដោយចំពោះទៅលើសូរវិទ្យា និងសទ្ទវិទ្យាភាសាខ្មែរ។

## សូរវិទ្យាបន្លឺ ឬសូរវិទ្យាសរីរសាស្ត្រ

### និយមន័យ

សូរវិទ្យាបន្លឺសិក្សាពីសូរដែលគេប្រើប្រាស់ក្នុងសកម្មភាពសម្ដីរបស់មនុស្សដែលបង្កើតឡើងដោយប្រដាប់បញ្ចេញសំឡេងក្នុងនោះមានខ្សែសំឡេង លំហូរខ្យល់ពីសួត កន្ទើត ជាដើម។ សូរនីមួយៗ កើតឡើងបានដោយសកម្មភាពនៃប្រដាប់បន្លឺសូររបស់មនុស្ស ដោយមានទំនាក់ទំនងស្មុគស្មាញជាមួយនឹងប្រព័ន្ធមជ្ឈមណ្ឌលប្រសាទនានា។ លំហូរខ្យល់ដែលចេញពីសួតធ្វើឱ្យខ្សែសំឡេងដែលនៅក្នុងបំពង់ក (ប្រភពសំឡេង) ញ័រឡើង ហើយទៅប៉ះនឹងសរីរៈសម្រាប់បញ្ចេញសំឡេងនៅក្នុងប្រឡង់មាត់និងច្រមុះ (ដោយការបិទបបូរមាត់ ឬ ដោយសារបបូរមាត់ខិតជិតគ្នារវាងអណ្ដាត និង ក្រអូមជាដើម ដែលជាប្រភពសូរបន្លឺសូរ)។ សូរស្រៈកើតឡើងពីរំញ័រនិងការប្រឹងរបស់ខ្សែសំឡេង។ ព្យញ្ជនៈលឺ ឬ ឃោសៈកើតឡើងដោយសារការចូលរួមរបស់ខ្សែសំឡេង និងការបិទឬការខិតជិតគ្នានៃប្រដាប់បន្លឺ ក្នុងប្រឡង់មាត់និងច្រមុះ។ ព្យញ្ជនៈថ្លង់ ឬ អឃោសៈ កើតឡើងដោយគ្មានការចូលរួមពីខ្សែសំឡេងគឺ កើតឡើងតែដោយសារការបិទ និង ការខិតជិតគ្នារបស់ប្រដាប់បន្លឺក្នុងប្រឡង់មាត់ និង ច្រមុះ ។

សារធាតុអាគូស្ទិច(អានុភាពសំឡេង) អាស្រ័យទៅលើទំហំនិងទម្រង់កន្ទើតដែលមានតួនាទីជារ៉េសូណង់ (resonance) ។

### ស្រៈ និង ចំណាត់ថ្នាក់ស្រៈ

កាលណាគេនិយាយពីសូរសម្ដី ឬ សូរភាសាគេផ្ដោតជាសំខាន់ទៅលើសូរស្រៈនិងសូរព្យញ្ជនៈ។

## អ្វីជាស្រៈ?

ស្រៈជាសទ្ទតា (phoneme) ដែលមានលក្ខណៈសូរខុសពីព្យញ្ជនៈ។ សូរស្រៈកើតឡើងដោយរំញ័រខ្ទប់នៃខ្យល់ក្នុងបំពង់កហើយខ្យល់នោះរត់ដោយសេរី ដោយគ្មានអ្វីរាំងខ្ទប់ច្ចងកាត់ប្រទ្បង់មាត់។ ភាពផ្សេងៗ គ្នានៃសូរស្រៈកើតឡើងដោយការប្រែប្រួលទម្រង់រ៉េសូណង់របស់មាត់។ ការប្រែប្រួលនេះបណ្តាលមកពីការផ្លាស់ទីរបស់អណ្តាត បបូរមាត់ កន្ទើត ជាដើម។ ដោយសារការប្រែប្រួលទម្រង់រ៉េសូណង់របស់មាត់និងបម្លាស់ទីរបស់សាច់ដុំទាំងឡាយមាន អណ្តាត បបូរមាត់ និងកន្ទើតជាដើមនោះ ទើបគេធ្វើចំណាត់ថ្នាក់សូរស្រៈដូចខាងក្រោម:

## ស្រៈបិទ និង ស្រៈបើក

ស្រៈបិទ គឺជាប្រភេទស្រៈដែលក្នុងពេលបន្លឺចលនាអណ្តាតឡើងទៅលើ ហួសពីអ័ក្សកណ្តាលនៃប្រទ្បង់មាត់។ ស្រៈបិទមាន : [i],[u],[y] ក្នុងភាសាបារាំង ស្រៈ [i:], [i], [ei], [ai], [ɛi],... ក្នុងភាសាខ្មែរស្រៈ [ɯ] ក្នុងភាសារុស្ស៊ីជាដើម។ ស្រៈបិទភាគច្រើន មានទីបន្លឺនៅត្រង់ក្រអូមមាត់ (ស្រៈក្រអូម)។ ចំណែកឯស្រៈបើកគឺជាស្រៈដែលក្នុងការបន្លឺចលនាអណ្តាតមិនឡើងហួសពីអ័ក្សកណ្តាលនៃប្រទ្បង់មាត់។

## ស្រៈខ្លី និង ស្រៈវែង

គេហៅថាស្រៈខ្លី នៅពេលដែលការបន្លឺសូរស្រៈនោះរយៈពេលនៃការបន្លឺខ្លីជាងបើប្រៀបធៀបរយៈពេលបន្លឺសូរស្រៈដទៃទៀត។ក្នុងចំណោមស្រៈទាំងអស់ ស្រៈបិទច្រើនមានសូរខ្លីជាងស្រៈបើក ដូចជា ក្នុងភាសាបារាំងសូរស្រៈ [i] ខ្លីជាងសូរស្រៈ [e] ហើយ [e] ខ្លីជាងសូរស្រៈ [a] ជាដើម។ ក្នុងភាសាបារាំង ស្រៈចុងព្យាង្គ (final) ជាស្រៈខ្លី បើធៀបនឹងស្រៈក្នុងទីតាំងដទៃទៀតនៃព្យាង្គ។ ក្នុងភាសាមួយចំនួន ក្នុងនោះមានភាសាខ្មែរផងដែរ គេឃើញវត្តមានស្រៈខ្លីនៅក្នុងព្យាង្គខ្សោយគឺព្យាង្គដែលមិនទទួលការសង្កត់សំឡេង (stress) ដូចជាក្នុងភាសាខ្មែរក្នុងពាក្យ"កករ "សូរស្រៈ [ɒ:] ក្នុងព្យាង្គទីមួយដែលជាព្យាង្គខ្សោយឮសូរកញ្ជក់ខ្លីជាងសូរស្រៈ [ɒ:] ក្នុងព្យាង្គទីពីរដែលជាព្យាង្គខ្លាំងឬព្យាង្គដែលទទួលការសង្កត់សំឡេងក្នុងពាក្យ "ពពក"សូរស្រៈ [ɔ:] ក្នុងព្យាង្គទីមួយឮកញ្ជក់ខ្លីជាងស្រៈ [ɔ:] ក្នុងព្យាង្គទីពីរ។ ផ្ទុយពីស្រៈខ្លី ស្រៈវែងមានរយៈពេលបន្លឺសូរវែងជាង។ ស្រៈវែងភាគច្រើនជាស្រៈបើក។

ក្នុងភាសាមួយចំនួនគេឃើញមានគូស្រៈខ្លី-វែង។ ការណ៍ដែលគេអាចចាត់ទុកថា ស្រៈមានគូខ្លី_វែង ដោយសារតែមានការប្រឈមគ្នានៃរយៈពេលបន្លឺ។ ក្នុងភាសាអង់គ្លេស គេឃើញមានការ

ប្រឈមគ្នារវាងការបន្លឺសូរស្រៈខ្លី [i] ក្នុងពាក្យ "sit" [sit] និង សូរស្រៈវែង [iː] ក្នុងពាក្យ "seat" [siːt]។ ក្នុងភាសា អ៊ីតាលី គូខ្លី_វែង រវាង សូរ [a] ក្នុង [pala] (ប៉ែល) និង [a] ក្នុង [palla] (បាល់)។ ក្នុងភាសាសំស្ក្រឹត គេក៏ឃើញមានគូខ្លី_វែងរបស់ស្រៈដែរ ដូចជា [a] – [ā], [i] – [ī], [u] – [ū] ជាដើម។

## ចំណាត់ថ្នាក់ស្រៈតាមចលនាអណ្ដាត

ទៅតាមចលនាអណ្ដាត ចលនាមុខក្រោយ និងលើក្រោមក្នុងការបន្លឺ គេអាចបែងចែកស្រៈជា ស្រៈមុខ ស្រៈកណ្ដាល ស្រៈក្រោយ ស្រៈលើ ស្រៈកណ្ដាល និង ស្រៈក្រោម។ ក្នុងភាសាខ្មែរសូរស្រៈ [iː], [i] ជាដើមជា ស្រៈមុខផង ជាស្រៈលើផង ព្រោះថា ក្នុងការបន្លឺ បើគិតតាមចលនាលាតរបស់អណ្ដាត (ចលនាទៅមុខទៅក្រោយរបស់អណ្ដាត) យើងឃើញថា ចលនាអណ្ដាតរុញមកខាងមុខ។ បើគិតតាមចលនាជាខ្សែបញ្ឈររបស់អណ្ដាត (ចលនាលើក្រោម) គេឃើញចលនាអណ្ដាតឡើងលើហួសអ័ក្សកណ្ដាលនៃប្រឡង់មាត់។ ស្រៈ [u] និង [uː] (ក្នុងភាសាខ្មែរ) ជាស្រៈក្រោយ និងជាស្រៈលើ។ ក្នុងការបន្លឺសូរស្រៈទាំងពីនេះ ឃើញថា ចលនាអណ្ដាតរុញទៅក្រោយនិងទៅខាងលើ ចំណែកឯស្រៈ [ɯ] និងស្រៈ [ɯː] (ក្នុងភាសាខ្មែរ) ត្រូវបានគេចាត់ជាស្រៈកណ្ដាលនិងជាស្រៈលើ។ ស្រៈ [ɨ] ក្នុងភាសារុស្ស៊ីជាស្រៈកណ្ដាលនិងជាស្រៈលើ។ ក្នុងភាសារុស្ស៊ីស្រៈ [ɛ] ត្រូវបានគេចាត់ជាស្រៈមុខ (បើគិតតាមចលនាលាតនៃអណ្ដាត) និងជាស្រៈកណ្ដាល (បើគិតតាមចលនាលើក្រោមនៃអណ្ដាត) ចំណែកឯស្រៈ [o] ក្នុងភាសារុស្ស៊ីដដែលជាស្រៈក្រោយ (បើគិតតាមចលនាលាតរបស់អណ្ដាត) និងជាស្រៈកណ្ដាល (បើគិតតាមចលនាលើក្រោមនៃអណ្ដាត)។ ស្រៈ [aː] និង ស្រៈ [a] ក្នុងភាសាខ្មែរជាស្រៈមុខ (បើគិតតាម ចលនាលាតរបស់អណ្ដាត) និងជាស្រៈក្រោម (បើគិតតាមចលនាលើក្រោមនៃអណ្ដាត)។ ស្រៈ [a] ក្នុងភាសារុស្ស៊ីវិញជាស្រៈកណ្ដាល(បើគិតតាមចលនាលាតរបស់អណ្ដាត) ជាស្រៈក្រោម (បើគិតតាមចលនាលើក្រោមនៃអណ្ដាត)។ តាមអ្វីដែលបានពណ៌នាពីខាងលើ គេអាចតាងចំណាត់ថ្នាក់ទូទៅនៃសូរស្រៈតាមចលនាអណ្ដាត ដូចរូបភាពខាងក្រោម។

## ចំណាត់ថ្នាក់សូរស្រៈតាមចលនាអណ្ដាត

***(លក្ខណៈទូទៅ)***

| ចលនាលាត \ ចលនាលើ_ក្រោម | មុខ | កណ្ដាល | ក្រោយ |
|---|---|---|---|
| លើ | /i/ | /ɯː/ | /u/ |
| កណ្ដាល | /e/ | | /o/ |
| ក្រោម | | /a/ | |

## សូរព្យញ្ជនៈ

សូរព្យញ្ជនៈជាសូរ ដែលក្នុងការបន្លឺមានប្រទះនឹងឧបសគ្គឬទំនប់ (ទាំងអស់ក្តីឬក៏ខ្លះៗក្តី) ដែលកើតឡើងនៅក្នុងចំណុចមួយឬក៏ច្រើននៃប្រដាប់បន្លឺ។ វត្តមាននៃឧបសគ្គឬទំនប់ទៅលើដំណើរខ្យល់បង្កឱ្យមានស្នូរ (bruit) ដែលបង្កើតបានជាសូរព្យញ្ជនៈឬជាធាតុនៃសូរព្យញ្ជនៈ។ ដោយសារតែស្នូរនេះទាក់ទងនឹងការបិទឬការគៀតប្រដាប់បន្លឺក្រោយពីការបន្លឺសូរស្រៈឬទាក់ទងនឹងការបើកប្រដាប់បន្លឺនៅពេលមុនបន្លឺសូរស្រៈ គេអាចហៅសូរព្យញ្ជនៈ ដែលបន្លឺក្រោយពីការបន្លឺសូរស្រៈថាជាព្យញ្ជនៈសូរលេប (implosive) ឯសូរព្យញ្ជនៈបន្លឺឡើងមុនពេលបន្លឺសូរស្រៈគេហៅថាព្យញ្ជនៈសូរបំពង (explosive)។ ឧទាហរណ៍ [kọk] "កុក" យើងឃើញថា សូរ /k/ មុនពេលបន្លឺសូរស្រៈ [ọ] មានលក្ខណៈជាសូរផ្ទុះ ឯសូរ [k] ក្រោយពីការបន្លឺសូរស្រៈ [ọ] មានលក្ខណៈជាសូរលេប។

ជាទូទៅ គេមិនអាចចាប់បានច្បាស់លាស់នូវសូរព្យញ្ជនៈ នៅពេលដែលព្យញ្ជនៈនោះនៅដាច់តែឯកឯងពីសូរស្រៈនោះឡើយ។

ក្នុងសូរវិទ្យាបន្លឺ គេបែងចែកព្យញ្ជនៈជាប្រភេទផ្សេងគ្នាទៅតាមរបៀបបន្លឺ(ឬរបៀបដែលខ្យល់ធ្លងកាត់ឧបសគ្គ) និងទៅតាមចំណុចនៃចលនាប្រដាប់បន្លឺ។ ទៅតាមរបៀបបន្លឺគេចែកព្យញ្ជនៈជា ១) _ព្យញ្ជនៈលឺ (ឃោសៈ) និងព្យញ្ជនៈថ្លង់(អឃោសៈ) អាស្រ័យទៅលើរំញ័រខ្សែសំឡេងឬក៏អត់ ២) _ព្យញ្ជនៈមាត់និងព្យញ្ជនៈច្រមុះគឺ នៅពេលដែលកន្ទើតបាំងជិតឬក៏បើកចំហលំហូរខ្យល់ទៅក្នុងជ្រលងច្រមុះ។ ៣) _ព្យញ្ជនៈខ្លាំង និងព្យញ្ជនៈខ្សោយអាស្រ័យទៅលើកម្រិតតនៃការប្រឹងរបស់សាច់ដុំប្រដាប់បន្លឺសំឡេង។ បើយោលទៅតាមកម្រិតនៃទំនប់ខ្យល់ គេចែកព្យញ្ជនៈជា : (ក) _ព្យញ្ជនៈស្ទះ (occlusive)ដែលសម្គាល់ដោយការបិទជិតប្រដាប់បន្លឺសំឡេងនិងលំហូរខ្យល់ទាំងស្រុងតែម្តង (ខ) _ព្យញ្ជនៈបង្ហូរ (fricative or cons-trictive) សម្រាប់ព្យញ្ជនៈបែបនេះ គេឃើញមានតែការគៀតលំហូរសំឡេងតែប៉ុណ្ណោះ (គ) _ព្យញ្ជនៈបង្ហូរគ្រេដុស (affricative) ជាព្យញ្ជនៈដែលក្នុងការបន្លឺសូរលំហូរខ្យល់លាយទាំងស្ទះផង លាយទាំងបង្ហូរផង (ឃ) _ព្យញ្ជនៈញ័រ (vibrant) សម្រាប់ព្យញ្ជនៈបែបនេះលំហូរខ្យល់ត្រូវបង្អាក់ដោយការបិទជិតក្នុងរយៈពេលខ្លី ហើយជាប់ៗគ្នានៃប្រដាប់បន្លឺសំឡេង (ង) _ព្យញ្ជនៈខាង (lateral) ជាព្យញ្ជនៈដែលក្នុងការបន្លឺលំហូរខ្យល់រត់សងខាងប្រដាប់បន្លឺសំឡេងដែលបិទជិតទាំងស្រុងត្រង់ចំណុចកណ្តាល (ច) _ព្យញ្ជនៈកន្លះឬស្រៈកន្លះក្នុងការបន្លឺព្យញ្ជនៈបែប

នេះគេឃើញថា លំហូរខ្យល់រាំងស្ទៀតជាងការបន្លឺស្រៈ។ សរុបសេចក្តីមក ព្យញ្ជនៈដែលក្នុងការបន្លឺលំហូរខ្យល់ត្រូវកាត់ផ្តាច់ដោយឧបសគ្គឬទំនប់ខ្យល់ព្យញ្ជនៈនោះមានឈ្មោះថា ជាព្យញ្ជនៈស្ទះ ព្យញ្ជនៈបង្ហូរគ្រដុស ព្យញ្ជនៈបង្ហូរនិងព្យញ្ជនៈញ័រ ហើយព្យញ្ជនៈ ទាំងនោះមានឈ្មោះថា ជាព្យញ្ជនៈខណៈ (consonnes mo-mentanées) ចំណែកឯព្យញ្ជនៈដទៃទៀត ដែលមានលក្ខណៈខុសពីនេះជាព្យញ្ជនៈសូរពំង (consonnes sonantes)។

សម្រាប់ព្យញ្ជនៈដើមក (consonne glottalisées) ចំណុចបន្លឺឬទំនប់ខ្យល់អាចស្ថិតនៅត្រង់ដើមកដែលអាចជាព្យញ្ជនៈស្ទះ និង ជាព្យញ្ជនៈបង្ហូរ។ ជាទូទៅ ព្យញ្ជនៈប្រភេទដទៃទៀតមានភាពខុសគ្នា ដោយសារតែលក្ខណៈធម្មជាតិនៃប្រដាប់ និងទីបន្លឺពីរសំខាន់ៗដែលជា អ្នកបង្កឱ្យមានទំនប់ខ្យល់ ប្រដាប់បន្លឺផ្នែកខាងលើក្នុងនោះមានបបូរមាត់ខាងលើធ្មេញមុខ ប៉ែកខាងលើចន្លោះរន្ធធ្មេញមុខ ខាងលើក្រអូម (ពិដានមាត់) មុខក្រអូមកណ្តាលក្រអូមក្រោយ ក្រអូមទន់ កន្ទើត (សៀវភៅវេយ្យាករណ៍ថ្នាក់ទី៥ របស់ក្រសួងអប់រំឆ្នាំ១៩៨៣ ចាត់ទុកថាជាទីបន្លឺ,ទំព័រ១) និងប្រដាប់បន្លឺផ្នែកខាងក្រោម (បបូរមាត់ឬធ្មេញមុខខាងក្រោមចុងអណ្តាត ខាងខ្នងនៃចុងអណ្តាត ខ្នងអណ្តាតខាងមុខ កណ្តាល ឬខាង ក្រោយ។

យោលទៅតាមលក្ខណៈធម្មជាតិ ប្រដាប់បន្លឺផ្នែកខាងលើ (ទីបន្លឺ) គេចែកព្យញ្ជនៈជាព្យញ្ជនៈបបូរមាត់ ព្យញ្ជនៈធ្មេញ (ទន្តជៈ-dental) ព្យញ្ជនៈចន្លោះធ្មេញ (alvéolaire) ព្យញ្ជនៈក្រអូមមុខ ព្យញ្ជនៈក្រអូមកណ្តាល ព្យញ្ជនៈក្រអូមក្រោយ និង ព្យញ្ជនៈកណ្ឋជៈ (guttural ou vélaire) ដែលប្លែកពីអនុប្រភេទព្យញ្ជនៈមួយចំនួនដែលបញ្ចេញសូរដោយប្រដាប់បន្លឺផ្នែកខាងក្រោម។

ព្យញ្ជនៈបបូរមាត់អាចជាព្យញ្ជនៈ ដែលបន្លឺដោយបបូរមាត់ទាំងពីរ ដូចជា [b], [p], [m] ជាដើមឬជាព្យញ្ជនៈ ដែលបន្លឺដោយបបូរមាត់ និងធ្មេញ ដូចជាសូរព្យញ្ជនៈ [в] (v),[ф] (f) ក្នុងភាសារុស្ស៊ីជាដើម។ ព្យញ្ជនៈធ្មេញអាចចែកជាព្យញ្ជនៈអណ្តាត_ធ្មេញ ដូចជា [d], [dh], [t], [th], [n] ក្នុងភាសាសំស្ក្រឹត និង ព្យញ្ជនៈធ្មេញ_ធ្មេញ (ចន្លោះធ្មេញ) ដូចជា /s/ ក្នុងភាសាសំស្ក្រឹត និងរុស្ស៊ីជាដើម។

យោលទៅលើការសិក្សាផ្នែកអាគូស្ទិច គេមានការលំបាកក្នុងការកំណត់សំឡេងព្យញ្ជនៈណាស់ ជាពិសេស ពួកព្យញ្ជនៈស្ទះ។ ពិបាកកំណត់សូរព្យញ្ជនៈថែមទៀតនោះ គឺនៅពេលដែលព្យញ្ជនៈប្រភេទនោះផ្សំជាមួយសូរស្រៈ (ព្យញ្ជនៈដើមព្យាង្គក៏ដូចជាចុងព្យាង្គ) ។

## *តារាងបំណែងចែកសូរព្យញ្ជនៈក្នុងភាសាសំស្ក្រឹត (ជាឧទាហរណ៍)*

| | អឃោសៈ | | | ឃោសៈ | | |
|---|---|---|---|---|---|---|
| | | ស្ទះ | | | ស្ទះ | |
| | បង្ហូរ | គ្មានខ្យល់ | មានខ្យល់ | គ្មានខ្យល់ | មានខ្យល់ | ច្រមុះ |
| កណ្ឋជៈ | | K | kh | g | gh | ṅ |
| ក្រអូម (តាលុជៈ) | ś | C | Ch | j | jh | ñ |
| សូរក្នុងក្បាល (មុទ្ធជៈ) | ṣ | Ṭ | Ṭh | ḍ | ḍh | ṇ |
| ធ្មេញ | s | T | Th | d | dh | n |
| បបូរមាត់ | | P | Ph | b | bh | m |
| ចម្រុះ | ḥ | | | | h | ṃ |

*តារាងព្យញ្ជនៈភាសាសំស្ក្រឹតនេះដកស្រង់ចេញពីសៀវភៅវេយ្យាករណ៍សំស្ក្រឹត របស់លោក សង់ វ៉ារ៉ែន*

***(Grammaire du Sanskrit de Jean Varenne.Collection Que sais-je? 1979)***

# ប្រវត្តិនៃការប្រើប្រាស់និងការវិវត្តនៃកម្មវាចកៈ តាមរយៈសិលាចារឹកសម័យមុនអង្គរនិងអង្គរ



លោក **មាឃ បូរ៉ា**

បេក្ខជនបណ្ឌិតផ្នែកភាសាវិទ្យា

នៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

នៅក្នុងការសិក្សាស្រាវជ្រាវទៅលើសិលាចារឹកកន្លងមកយើងឃើញមានស្នាដៃជាច្រើនបានសិក្សាដោយផ្តោតទៅលើផ្នែកប្រវត្តិសាស្ត្រ ការបកប្រែសិលាចារឹក ការធ្វើវចនានុក្រម និង ការសិក្សាវិភាគវែកញែកទៅតាមជំនាញដែលស្មេរចង់បាន។ ហេតុដូច្នេះហើយ ទើបយើងលើកយកប្រធានបទ **"ប្រវត្តិនៃការប្រើប្រាស់និងការវិវត្តនៃកម្មវាចកៈ"** នេះយកមកធ្វើការសិក្សាស្រាវជ្រាវទៅលើសិលាចារឹកសម័យមុនអង្គរនិងអង្គរនេះ ដើម្បីធ្វើការត្រិះរិះពិចារណា ថាតើការប្រើប្រាស់លក្ខណៈកម្មវាចកៈបែបណានិងជាពិសេសសម្រាប់អ្នកសិក្សាខាងភាសាវិទ្យាខ្មែរអាចស្គាល់ពីលក្ខណៈសម្ព័ន្ធនៃសម័យកាលនោះដោយយកមកធ្វើការប្រៀបធៀបជាមួយការប្រើប្រាស់លក្ខណៈកម្មវាចកៈនៅក្នុងភាសាខ្មែរបច្ចុប្បន្ន។

### ១-ប្រវត្តិនៃការប្រើប្រាស់កម្មវាចកៈ

តាមរយៈការសិក្សាស្រាវជ្រាវទៅលើសិលាចារឹកកន្លងមក យើងឃើញថា កម្មវាចកៈមានការប្រើប្រាស់តាំងពីសម័យមុនអង្គរនិងសម័យអង្គរមកម្ល៉េះ ហើយការប្រើប្រាស់កម្មវាចកៈនេះមានការប្រែប្រួលរូបសាស្ត្រ និង មានការប្រើពាក្យជំនួយ ផងដែរ។

### ១.១-ការប្រើប្រាស់កម្មវាចកៈសម័យមុនអង្គរ

តាមរយៈសិលាចារឹកសម័យមុនអង្គរ យើងឃើញថា មានការប្រើប្រាស់កម្មវាចកៈស្ទើរតែគ្រប់សិលាចារឹកទាំងអស់។ ភាសាខ្មែរគ្មានទម្រង់ពាក្យដូចជាភាសា អង់គ្លេស បារាំងទេ ក៏ប៉ុន្តែទោះបីភាសាខ្មែរគ្មានទម្រង់ពាក្យ ដូចភាសាឥណ្ឌូអឺរ៉ុប ក៏ដោយ ក៏នៅសម័យមុនអង្គរ គេប្រើប្រាស់ល្បះ

កម្មវាចកៈ ដូចភាសាបារាំងឬអង់គ្លេស ផងដែរ។ មិនតែប៉ុណ្ណោះ កិរិយាសកម្មមួយចំនួនមានការប្រែប្រួលផងដែរ នៅពេលចងជាល្បះជាមួយពាក្យឯទៀត សម្រាប់បង្កើតល្បះកម្មវាចកៈ។

**១.១.១_ការប្រែប្រួលរូបសាស្ត្រ**

យើងសង្កេតឃើញថា សម័យមុនអង្គរមានការប្រើល្បះដែលមានលក្ខណៈកម្មវាចកៈ ដោយការប្រើប្រាស់អន្តបទ [_អ ម/ន_] និង [_អ៊ ម/ន_] **ផ្សំជាមួយកិរិយាសព្ទ** ដើម្បីបង្កើតជាពាក្យកម្លាយដែលជាកិរិយាសព្ទសម្រាប់សម្គាល់លក្ខណៈ កម្មវាចកៈ។

**ឧទាហរណ៍១ : ក្ញុំ អំនោយ ជំអញ ឭ ត វ្រះ កម្រតាង៑ អញ មហាគណបតិ** kñuṃ aṃnoy jaṃ añ ai ta vraḥ kamratāṅ añ mahā gaṇapati. K.600N,611A.D,I.2 មានន័យថា"អ្នកបម្រើអំណោយដោយមន្ត្រីជំអញចំពោះអាទិទេព មហាគណបតិ"[7]។ តាមរយៈ ឧទាហរណ៍នេះ យើងសង្កេតឃើញថា រូបសាស្ត្រ **"អំនោយ"** ជាពាក្យកម្លាយចេញពីកិរិយាសព្ទ**"ឲយ"** ដែលជារូបសាស្ត្រនៃកិរិយាសព្ទដែលប្រើជាកម្មវាចកៈ នៅក្នុងសម័យមុនអង្គរ។ នៅក្នុងល្បះនេះ យើងឃើញថា មានការផ្លាស់ប្តូរទីតាំងនៃប្រធានគឺពាក្យ "មន្ត្រី**ជំអញ**" ស្ថិតនៅខាងក្រោយ កិរិយាសព្ទ**"អំនោយ"**ដែលបានក្លាយទៅជាកម្មហៅថា កម្មភ្នាក់ងារ (ធ្វើអំពើ)។ ចំណែកឯពាក្យ **"ក្ញុំ"** ស្ថិតនៅពីមុខកិរិយាសព្ទដែលមានមុខងារជាប្រធានក្នុងលក្ខណៈសម្គាល់កម្មវាចកៈ (រងអំពើ) នៅក្នុងល្បះ។ ជាពិសេសកិរិយាសព្ទ **"ឲយ"** នេះបានផ្លាស់ប្តូររូបសាស្ត្ររបស់ខ្លួនតាមរយៈអន្តបទ /_អ ម/ន_/ មកជាពាក្យ **"អំនោយ"** វិញ ហើយ **"អំនោយ"** នៅក្នុងល្បះនេះមិនមែនជា **"នាមសព្ទ"** ទេ គឺជាកិរិយាសព្ទដែលមានលក្ខណៈកម្មវាចកៈ។ ប្រសិនបើ ពាក្យ **"អំនោយ"** ជានាមសព្ទដែលមាន ន័យថា **"ការឱ្យ"** ឬមានន័យថា **"ទាន"** នោះល្បះនេះគ្មានកិរិយាសព្ទទេ។ ហេតុដូច្នេះគេអាចធ្វើការសន្និដ្ឋានបានថា ពាក្យ **"អំនោយ"** កាលពីសម័យមុនជា កិរិយាសព្ទប្រកបដោយន័យកម្មវាចកៈ។ ពាក្យ **"អំនោយ"** ដែលជានាមសព្ទគឺជាពាក្យដែលកកើតឡើងអស់ពេលយ៉ាងយូរបន្តិចម្តងៗ ក្លាយមកជានាមសព្ទ ដូចសិលាចារឹកប្រាសាទឱឡោក បានសរសេរថា **អំនោយ បោញ មិត្រ សិង ត វ្រះ [កម្រតា]ង៑ អញ ស្រីនៃមិសេស្វរ** aṃnoy poñ mitra siṅtavraḥ çrī naimiçeçvara K.808, VII-VIII A.D.I.6 មានន័យថា អំណោយរបស់បោញមិត្រសិង (ថ្វាយ) ចំពោះអាទិទេពស្រីនៃមិសេស្វរ។

ម្យ៉ាងទៀត គេអាចនិយាយបានថា នាមសព្ទ **"អំនោយ"** បានកកើតឡើងដោយសារកិរិយាសព្ទ

[7] សូមមើល ឡុង សៀម: ***វចនានុក្រមខ្មែរបុរាណ***(តាមសិលាចារឹកសតវត្សទី៦_៨),ភ្នំពេញ, ឆ្នាំ២០០០, ទំព័រ២៧។

ដែលមានន័យកម្មវាចកៈ។ បើកាលណាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈទេនោះ គួរតែលោកសរសេរថា **"ជំអញ ឱយ ក្នុំ ញ ត ប្វះ កម្រ តាង អញ មហាគណបតិ** ដែលមានន័យថាមន្ត្រីជំអញឱ្យអ្នកបម្រើចំពោះអាទិទេពមហាគណបតិ" នេះទើបសមថាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈនោះ។

**ឧទាហរណ៍២ : ស្រេ អំនោយ ពោញ ត គុិ មាស/** amṇoy poñ ta gui mās K.493,671A.D.,l.19[២] មានន័យថា ស្រែបានផ្តល់ដោយពោញមានប្រវែងមួយមាស។ នៅក្នុងល្បះនេះ យើងឃើញថា រូបសាស្ត្រ **"អំនោយ"** ជាពាក្យ កម្លាយចេញពីកិរិយាសព្ទ **"ឱយ"** តាមរយៈការផ្សំជាមួយអន្តេបទ/_អ'ម/ន_/ ហើយរូបសាស្ត្រ **"អំនោយ"** ជាកិរិយាសព្ទស្នូលនៅក្នុងល្បះ។ ដូច្នេះ យើងឃើញថា ល្បះនេះមានការផ្លាស់ប្តូរទីតាំងនៃប្រធានគឺពាក្យ **"ពោញ "**ដែលជាអ្នកធ្វើអំពើស្ថិតនៅខាងក្រោយកិរិយាសព្ទ **"អំនោយ"** ហើយវាបានក្លាយទៅជាកម្ម ហៅថា កម្មក្នាក់ងារ (ធ្វើអំពើ)។ ចំណែកឯពាក្យ **"ស្រេ"** ដែលជាអ្នករងអំពើ ស្ថិតនៅពីមុខកិរិយាសព្ទដែលមានមុខងារជាប្រធានក្នុងលក្ខណៈសម្គាល់កម្មវាចកៈ (រងអំពើ) នៅក្នុង ល្បះ។

ប្រសិនបើពាក្យ **"អំនោយ"** ជានាមសព្ទដែលមានន័យថា **"ការឱ្យ"** ឬមានន័យថា **"ទាន"** នោះ ល្បះនេះគ្មានកិរិយាសព្ទទេ។ ហេតុដូច្នេះ គេអាចធ្វើការសន្និដ្ឋានបានថា ពាក្យ **"អំនោយ"** កាលពីសម័យមុនជាកិរិយាសព្ទប្រកបដោយន័យកម្មវាចកៈ។ បើកាលណាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈទេនោះ គួរតែលោកសរសេរថា **ពោញ ឱយ ស្រេ ត គុិ មាស** ដែលមានន័យថា ពោញឱ្យស្រែ(មានប្រវែងមួយ)មាសនេះទើបសមថាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈនោះ។

***ឧទាហរណ៍៣ :* ស្រេ ត្នៃ កេត ត្រវាំង ពោញ *ភាគយុង ទំនុញ* ត ពោញ *ភទ្រវិសេស*** sre tṅai ket travaṅ poñ bha gayuṅ damṇuñ ta poñ bhadraviçeṣa K.22,VII.A.D,l.32[៣], ស្រែខាងកើតត្រពាំងពោញភាគយុងទិញដោយពោញភទ្រវិសេស។ តាមរយៈឧទាហរណ៍នេះ យើងអាចសង្កេតឃើញថា រូបសាស្ត្រ **"ទំនុញ"** ជាពាក្យកម្លាយចេញពីកិរិយាសព្ទ **"ទុញ"** ជារូបសាស្ត្រនៃកិរិយាសព្ទដែលប្រើជាកម្មវាចកៈ។ នៅក្នុងល្បះនេះ យើងឃើញថា មានការផ្លាស់ប្តូរទីតាំងនៃប្រធានគឺពាក្យ **"ពោញភទ្រ វិសេស"**ស្ថិតនៅខាងក្រោយកិរិយាសព្ទ**"ទំនុញ"** ដែលបានក្លាយទៅជាកម្មហៅថា កម្មក្នាក់ងារ(ធ្វើអំពើ)។ ចំណែកឯកន្សោមពាក្យ

---

[២] សូមមើល ឡុង សៀម: ***វចនានុក្រមខ្មែរបុរាណ***(តាមសិលាចារឹកសតវត្សទី៦_៨), ដ.ឯ.ម., ទំព័រ២៥៩។

[៣] សូមមើល ឡុង សៀម: ***វចនានុក្រមខ្មែរបុរាណ*** ដ.ឯ.ម., ទំព័រ ៣២៩។

**“ស្រែ ត្លៃ កេត ត្រវាំង បោញ្ញ ភាគយុង”**ស្ថិតនៅពីមុខកិរិយាសព្ទដែលមានមុខងារជាប្រធានក្នុងលក្ខណៈសម្គាល់កម្មវាចកៈ (រងអំពើ) នៅក្នុងល្បះ។ ជាពិសេសកិរិយាសព្ទ **“ទុញ្ញ”** នេះបានផ្លាស់ប្តូររូបសាស្ត្ររបស់ខ្លួនដោយផ្សំជាមួយអន្តបទ [-អ៊ំម/ន-] មកជាពាក្យកម្លាយ **“ទំនុញ្ញ”** វិញ ហើយពាក្យ **“ទំនុញ្ញ”** នៅក្នុងល្បះនេះមិនមែនជា **“នាមសព្ទ”** នោះទេ គឺជាកិរិយាសព្ទដែលមានលក្ខណៈកម្មវាចកៈ។ ប្រសិនបើពាក្យ **“ទំនុញ្ញ”** គឺ ជានាមសព្ទដែលមានន័យថា **“ទំនិញឬរបស់របរសម្រាប់ដោះដូរ ឬក៏របស់របរសម្រាប់លក់នោះ”**នោះល្បះនេះគ្មានកិរិយាសព្ទទេ។ ហេតុដូច្នេះ គេអាចធ្វើការសន្និដ្ឋានបានថា ពាក្យ **“ទំនុញ្ញ”** កាលពីមុនជាពាក្យកម្លាយចេញពី កិរិយាសព្ទ **“ទុញ្ញ”** ដែលជាកិរិយាសព្ទប្រកបដោយកម្មវាចកៈ។ បើកាលណាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈទេនោះ គួរតែលោកសរសេរថា **“បោញ្ញ កទ្រវីសេសទិញ្ញ ស្រែ ត្លៃ កេត ត្រវាំង បោញ្ញ ភាគយុង** ដែលមានន័យថា បោញ្ញកទ្រវីសេសទិញ្ញស្រែខាងកើតត្រពាំងបោញ្ញភាគយុងបែបនេះ ទើបសមថាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈនោះ។

តាមរយៈការបកស្រាយខាងលើ គេអាចធ្វើការសន្និដ្ឋានបានថា ភាសាខ្មែរកាលពីសម័យមុនអង្គរ មានការប្រើប្រាស់ល្បះដែលមានន័យកម្មវាចកៈ។ មិនតែប៉ុណ្ណោះសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម លោកបានសន្និដ្ឋានថា ភាសាខ្មែរអាចផ្តល់ឥទ្ធិពលរបស់ខ្លួននៅក្នុងការប្រើប្រាស់កិរិយាសព្ទបែបនេះទៅលើភាសាថៃនិងភាសាឡាវថែមទៀតផង។ តាមការវិភាគវែកញែកខាងលើ យើងអាចទាញរូបមន្ត:

| |
|---|
| ប្រធាន(រងអំពើ) + កិរិយាសព្ទ + កម្មភ្នាក់ងារ(ធ្វើអំពើ) |

## ១.១.២_លក្ខណៈនៃកម្មវាចកៈដោយការប្រែប្រួលនៅក្នុងសម្ព័ន្ធ

យើងខ្ញុំសង្កេតឃើញថា ល្បះដែលមានប្រើពាក្យជំនួយដើម្បីបញ្ជាក់លក្ខណៈកម្មវាចកៈក្នុងអត្ថបទសិលាចារឹកនានា នៅសម័យមុនអង្គរមាន

កាលពីសម័យមុនអង្គរ ល្បះដែលបញ្ជាក់ន័យនៃលក្ខណៈកម្មវាចកៈ លោកសរសេរដោយការប្រែប្រួលមុខងារនៅក្នុងសម្ព័ន្ធ និង ជាពិសេសលោកសរសេរដោយមានការបញ្ជាក់ពីពេលកន្លងទៅដោយប្រើពាក្យ**“មន /មានman/mān”** ដាក់ពីខាងឆ្វេងកិរិយាសព្ទស្នូលនៅក្នុងល្បះ។ ពាក្យ **“មន”** នេះវចនានុក្រមខ្មែរបុរាណ (តាមសិលាចារឹកសតវត្សទី ៦_៨) បានឱ្យនិយមន័យក្នុងន័យទី១ថា *“មានបានជាអត្ថិភាព ម៉ាវដែមសំដែងចេញនូវអតីតកាលពេញលេញ”*[៤] និងន័យទី២“ប្រើជាសន្ទាន

[៤] សូមមើល ឡុង សៀម: ***វចនានុក្រមខ្មែរបុរាណ*** ដ.ឯ.ម., ទំព័រ ៤៥៣។

ភ្ជាប់”[៥]។ ពាក្យ **“មន”** នេះភ្ជាប់ទៅជាមួយកិរិយាសព្ទ ដើម្បីជាជំនួយនៃលក្ខណៈសម្គាល់ន័យកម្មវាចកៈ។ ឧទាហរណ៍១ : ***ស្រេ មន ទុញ្ ត ភវកីត្តិ,*** sre man duñ ta bhavakīrtti K.22,VII. A.D,I.35[៦], មានន័យថា ស្រែមួយបានទិញដោយភវកីត្តិ។ តាមរយៈល្បះនេះ យើងសង្កេតឃើញថា **“ប្រធាន”** ជាអ្នករងអំពើ ហើយ **“កម្មបទ”** ជាអ្នកធ្វើអំពើ បានសេចក្ដីថា ពាក្យ ***“ភវកីត្តិ”*** នៅក្នុងល្បះនេះជាកម្មភ្នាក់ងារ (*ធ្វើអំពើ*) ហើយ ពាក្យ ***“ស្រេ”*** មានមុខងារនាទីជា **“ប្រធាន”** ជាអ្នករងអំពើ។ ដូច្នេះ យើងសន្និដ្ឋានថា ប្រសិនបើល្បះនេះមិនមែនជាកម្មវាចកៈទេនោះ បុព្វបុរសខ្មែរគួរសរសេរថា ***“ភវកីត្តិ មន ទុញ្ ស្រេ”*** វិញ នោះ ទើបសម ថា ល្បះដែលជាលក្ខណៈកត្តុវាចកៈធម្មតា ដែលមានទម្រង់ **ប្រធាន+កិរិយាសព្ទ+ កម្មបទ** នោះ។

ឧទាហណ៍២ : ***ស្រេ ផលទ មន ជាហ្វ ត កុរាក ជ្មេង*** sre phalada man jāhv ta kurāk jmeṅ K.493, 657A.D.,I.20[៧] មានន័យថា ស្រែផលទបានទិញដោយកុរាកជ្មេង។ តាមរយៈល្បះនេះ យើងសង្កេតឃើញថា**“ប្រធាន”** ជាអ្នករងអំពើ ហើយ **“កម្មបទ”** ជាអ្នកធ្វើអំពើ បានសេចក្ដីថាពាក្យ **“កុរាក ជ្មេង”** នៅក្នុងល្បះនេះជាកម្មភ្នាក់ងារ (*ធ្វើអំពើ*) ហើយពាក្យ ***“ស្រេ ផលទ”*** មាននាទីជា **“ប្រធាន”** ជាអ្នករងអំពើ។ ដូច្នេះ យើងសន្និដ្ឋានថា ប្រសិនបើល្បះនេះមិនមែនជាកម្មវាចកៈទេនោះ បុព្វបុរសខ្មែរគួរសរសេរថា **“កុរាក ជ្មេង មន ជាហ្វ ស្រេ ផលទ”** វិញ នោះទើបសមថាល្បះដែលជាលក្ខណៈកត្តុវាចកៈធម្មតាដែលមានទម្រង់ **ប្រធាន+កិរិយាសព្ទ +កម្មបទ**។

ឧទាហរណ៍៣ : ***ស្រេ មាន ជាហ្វ អំវិ ត វ្រះ កំម្រតាង៑ អញ្ កំម្រ៝តាង៑ ស្រុក*** sre mān jāhv aṃvi ta vraḥ kaṃmratāṅ añ kaṃmrā tāṅ sruk K.79, 639.A.D.I.8-9[៨] មានន័យថា ស្រែបានទិញដោយអភិបាលខេត្ត។ តាមរយៈឧទាហរណ៍នេះ យើងឃើញថា ពាក្យ ***“ស្រេ”*** មានមុខងារជាប្រធាន (*រងអំពើ*) នៅក្នុងល្បះ ហើយកន្សោមពាក្យ **“វ្រះ កំម្រតាង៑ អញ្ កំម្រតាង៑ ស្រុក”** មានមុខងារជាកម្មបទ (*ធ្វើអំពើ*) ទៅលើប្រធាននៅក្នុងល្បះ។ ដូច្នេះ យើងសន្និដ្ឋានថា ប្រសិនបើល្បះនេះមិនមែនជាកម្មវាចកៈទេនោះ បុព្វបុរសខ្មែរគួរសរសេរថា **“វ្រះ កំម្រតាង៑ អញ្ កំម្រតាង៑ ស្រុក មាន ជាហ្វ ស្រេ*** វិញ នោះទើបសមថា ល្បះដែលជាលក្ខណៈកត្តុវាចកៈធម្មតាដែលមានទម្រង់ **ប្រធាន+កិរិយាសព្ទ+កម្មបទ** នោះ។ ដូច្នេះ យើងអាចធ្វើការសន្និដ្ឋានបានថា នៅសម័យមុនអង្គរមាន

---

[៥] _ដ_ ទំព័រ ៤៥៣។

[៦] _ដ_ ទំព័រ ៣៣៦។

[៧] _ដ_ ទំព័រ ២៣៧។

[៨] សូមមើល ឡុង សៀម: ***វចនានុក្រមខ្មែរបុរាណ*** ដ.ង.ម.,ទំព័រ ២៣៧។

ការប្រើប្រាស់ល្បះដែលមានលក្ខណៈកម្មវាចកៈនេះ ដោយការប្រើពាក្យជំនួយដើម្បីបង្កើតល្បះដែលមានលក្ខណៈកម្មវាចកៈ។ ដូច្នេះ លក្ខណៈកម្មវាចកៈដោយការប្រើពាក្យជំនួយយើងអាចគោងរូបមន្តៈ

| |
|---|
| **ប្រធាន(រងអំពើ) + មន/មាន + កិរិយាសព្ទ + ត + កម្មភ្នាក់ងារ(ធ្វើអំពើ)** |

## ១.២_ការប្រើប្រាស់កម្មវាចកៈសម័យអង្គរ

តាមរយៈសិលាចារឹកសម័យអង្គរ យើងសង្កេតឃើញមានការប្រើប្រាស់កម្មវាចកៈ ដោយការប្រើអន្តេបទទម្រង់ [_អ៊ម/ន_] ផ្សំជាកិរិយាសព្ទដើមបង្កើតបានពាក្យកម្លាយដែលជាកិរិយាសព្ទសម្រាប់ប្រើប្រាស់ជាលក្ខណៈកម្មវាចកៈនិងមានការប្រើប្រាស់លក្ខណៈកម្មវាចកៈ ដោយមានពាក្យជំនួយផងដែរ។

### ១.២.១_ការប្រែប្រួលរូបសាស្ត្រ

យើងខ្ញុំសង្កេតឃើញថា សម័យអង្គរមានការប្រើល្បះ ដែលមានលក្ខណៈកម្មវាចកៈនេះ ដោយការប្រើប្រាស់អន្តេបទ [_អ៊ម/ន_] ផ្សំជាមួយកិរិយាសព្ទ ដើម្បីបង្កើតជាពាក្យកម្លាយដែលជាកិរិយាសព្ទសម្រាប់សម្គាល់លក្ខណៈកម្មវាចកៈ ដូចនៅសម័យមុនអង្គរផងដែរ។

ឧទាហរណ៍១ : ***អវី ត ប្លុ តទិង ទៅ ឧត្តរ ប្រសប ស្រេ ទំនុញ ច្លោញ វិទ្យាមយ*** "amvi ta plu tadin dau uttara prasap sre *damnuñ* chloñ vidyāmaya"[៦] K.843C, 1025 A.D., l.29, មានន័យថា *(ដីស្រែ)* ពីផ្លូវទទឹងទៅទិសឧត្តរហូតដល់ស្រែបានទិញដោយច្លោញវិទ្យាមយ។

តាមរយៈឧទាហរណ៍នេះ យើងសង្កេតឃើញថារូបសាស្ត្រ " **ទំនុញ**" ជាពាក្យកម្លាយចេញពីកិរិយាសព្ទ "**ទុញ**" ជារូបសាស្ត្រនៃកិរិយាសព្ទដែលប្រើជាកម្មវាចកៈនៅក្នុងសម័យអង្គរ។ នៅក្នុងល្បះនេះ យើងឃើញថា មានការផ្លាស់ប្តូរទីតាំងនៃប្រធានគឺពាក្យ "**ច្លោញ វិទ្យាមយ** "ស្ថិតនៅខាងក្រោយកិរិយាសព្ទ "**ទំនុញ**" ដែលបានក្លាយទៅជាកម្មហៅថាកម្មភ្នាក់ងារ (ធ្វើអំពើ)។ ចំណែកឯកន្សោមពាក្យ "**អវី ត ប្លុត ទិង ទៅ ឧត្តរ ប្រសប ស្រេ**" ស្ថិតនៅពីមុខកិរិយាសព្ទដែលមានមុខងារជាប្រធានក្នុងលក្ខណៈសម្គាល់កម្មវាចកៈ *(រងអំពើ)* នៅក្នុងល្បះ។ ជាពិសេស កិរិយាសព្ទ "**ទុញ**" នេះបានផ្លាស់ប្តូររូបសាស្ត្ររបស់ខ្លួន ដោយផ្សំជាមួយអន្តេបទ /អ៊ម/ន_/ មកជាពាក្យកម្លាយ "**ទំនុញ**"វិញ ហើយពាក្យ "**ទំនុញ**" នៅក្នុងល្បះនេះមិនមែនជា "**នាមសព្ទ**" ទេ គឺជាកិរិយាសព្ទដែលមានលក្ខណៈកម្មវាចកៈ។ ប្រសិនបើពាក្យ"**ទំនុញ**" គឺជានាមសព្ទដែលមានន័យថា "**ទំនិញ ឬ របស់របរសម្រាប់ដោះដូរ ឬក៏របស់របរសម្រាប់លក់នោះ**" នោះ ល្បះនេះគ្មាន

---

[៦] G. GOEDÈS : INSCPITIONS DU CAMBODGE, VOLUME VII, PARIS 1964, P.112.

កិរិយាសព្ទទេ។ ហេតុដូច្នេះ គេអាចធ្វើការសន្និដ្ឋានបានថា ពាក្យ **"ទំនុញ "** កាលពីមុនជាពាក្យកម្លាយចេញពីកិរិយាសព្ទ **"ទុញ"** ដែលជាកិរិយាសព្ទប្រកបដោយកម្មវាចកៈ។ បើកាលណាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈទេនោះ គួរតែលោកសរសេរថា **ថ្លោញ វិទ្យាមយ ទំនុញ អាំ ត ប្ដ តទិង ទៅ ឧត្តរ ប្រសប ស្រេ** ដែលមានន័យថា *ថ្លោញវិទ្យាមយបានទិញ (ដីស្រែ) ពីផ្លូវទទឹងទៅទិសឧត្តរហូតដល់ស្រែ* បែបនេះទើបសមថាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈនោះ។

**ឧទាហរណ៍២ : ស្រេ ជំនូន វាប បិ** sre jaṃnvan vāp pi K.780, XA.D.I.24[១០] មានន័យថា ស្រែបានជូនដោយវាប បិ។ តាមរយៈល្បះនេះ យើងសង្កេតឃើញថា រូបសាស្ត្រ **"ជំនូន"** ជាពាក្យកម្លាយ ចេញពីកិរិយាសព្ទ **"ជូន"** ជារូបសាស្ត្រនៃកិរិយាសព្ទដែលប្រើជាកម្មវាចកៈ។ នៅក្នុងល្បះនេះ យើងឃើញថាមានការផ្លាស់ប្តូរទីតាំងនៃប្រធានគឺពាក្យ **"វាប បិ"** ស្ថិតនៅខាងក្រោយកិរិយាសព្ទ **"ជំនូន"** ដែលបានក្លាយទៅជាកម្មហៅថា កម្មភ្ជាក់ងារ (ធ្វើអំពើ)។ ចំណែកឯពាក្យ **"ស្រេ"** ស្ថិតនៅពីមុខកិរិយាសព្ទដែលមានមុខងារជាប្រធាន ក្នុងលក្ខណៈសម្គាល់កម្មវាចកៈ(រងអំពើ) នៅក្នុងល្បះ។ ជាពិសេសកិរិយាសព្ទ **"ជូន"** នេះបានផ្លាស់ប្តូររូបសាស្ត្ររបស់ខ្លួន ដោយផ្សំជាមួយអន្តេបទ /អំ ម.ន_/ មកជាពាក្យកម្លាយ**"ជំនូន"** វិញ។ ប្រសិនបើពាក្យ**"ជំនូន"** គឺជានាមសព្ទដែលមានន័យថា **"ការជូន ឬ របស់របរ"** នោះ ល្បះនេះគ្មានកិរិយាសព្ទទេ។ ហេតុដូច្នេះ គេអាចសន្និដ្ឋានបានថាពាក្យ **"ជំនូន"** កាលពីមុនជាពាក្យកម្លាយចេញពីកិរិយាសព្ទ **"ជូន"** ដែលជាកិរិយាសព្ទប្រកបដោយកម្មវាចកៈ។ បើកាលណាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈទេនោះ គួរតែលោកសរសេរថា **វាប បិ ជូន** ស្រេ ដែលមានន័យថា *វាប បិ ជូនស្រែ* បែបនេះទើបសមថាភាសាខ្មែរគ្មានលក្ខណៈកម្មវាចកៈនោះ។ តាមរយៈការបកស្រាយឧទាហរណ៍ខាងលើគេអាចសន្និដ្ឋានបានថា ភាសាខ្មែរសម័យអង្គរមានការប្រើប្រាស់ល្បះ ដែលមានន័យកម្មវាចកៈ ដោយការយកអន្តេបទ [_អំ ម/ន_] ដើម្បីបង្កើតល្បះដែលមានន័យកម្មវាចកៈ។ ដូច្នេះ យើងអាចទាញរូបមន្ត :

| |
|---|
| **ប្រធាន(រងអំពើ) + កិរិយាសព្ទ + កម្មភ្ជាក់ងារ(ធ្វើអំពើ)** |

**១.២.២_លក្ខណៈនៃកម្មវាចកៈដោយប្រើពាក្យជំនួយ"តិ ti"**

តាមរយៈសិលាចារឹកសម័យអង្គរយើងសង្កេតឃើញមានការប្រើប្រាស់លក្ខណៈកម្មវាចកៈដោយការប្រើពាក្យ **"តិ "** ជារូបសាស្ត្រសម្រាប់ដាក់ពីខាងឆ្វេងកិរិយាសព្ទ ដើម្បីបង្កើតលក្ខណៈកម្មវាចកៈ។

[១០] G. GOEDÈS : INSCPITIONS DU CAMBODGE, VOLUME VI, PARIS 1954, P.151.

**ឧទាហរណ៍ : ភូមិ វគ្គិ ខ្មាប្ប តិ ទុញ វាប អំមូត.**
bhūmi vargga khmāpp *ti duñ* vāp amṃṛta[១១] K.265S,959A.D.l.23,មានន័យថា ដីភូមិរបស់អ្នកកាប់អុសបានទិញដោយមន្ត្រី (ឈ្មោះ) វាបអំមត។ តាមរយៈឧទាហរណ៍នេះ យើងឃើញថា ពាក្យ **"វាប អំមូត"** ដែលជាអ្នកធ្វើអំពើក្លាយជាកម្មបទនៅក្នុងល្បះ ដែលហៅថា កម្មភ្នាក់ងារ (ធ្វើអំពើ) ហើយកន្សោមពាក្យ **"ភូមិ វគ្គិ ខ្មាប្ប"** ដែលជាអ្នករងអំពើក្លាយជាប្រធានរបស់កិរិយាសព្ទ **"ទុញ"** ដែលភ្ជាប់ទៅដោយរូបសាស្ត្រ **"តិ"** នៅក្នុងល្បះ តែនៅរងអំពើដដែល។ ដូច្នេះ យើងអាចទាញរូបមន្ត:

| |
|---|
| **ប្រធាន(រងអំពើ) + តិ + កិរិយាសព្ទ + កម្មភ្នាក់ងារ(ធ្វើអំពើ)** |

**២_ការវិវត្តនៃលក្ខណ:កម្មវាចក:**

តាមការសិក្សាស្រាវជ្រាវ យើងខ្ញុំសង្កេតឃើញថា មានការវិវត្តនៃលក្ខណ:កម្មវាចក: នៅក្នុងភាសាខ្មែរដូចតទៅ។

**២.១_ការវិវត្តនៃលក្ខណ:កម្មវាចក: ដោយការប្រែប្រួលរូបសាស្ត្រ**

យើងខ្ញុំសង្កេតឃើញថា នៅក្នុងសម័យមុនអង្គរនិងសម័យអង្គរ ភាសាខ្មែរមានការប្រើល្បះដែលសម្គាល់លក្ខណ:កម្មវាចក: ដោយមានការប្រែប្រួលរូបសាស្ត្រ ដូច កិរិយាសព្ទ **"ដាហ្វ"** ទៅជា **"ដំនាហ្វ"** ដែលស្ថិតនៅក្នុងប្រភេទពាក្យជាកិរិយាសព្ទ ដូច កិរិយាសព្ទដើមដែរ។

**២.១.១_ការវិវត្តនៃលក្ខណ:កម្មវាចក: ដោយការប្រែប្រួលរូបសាស្ត្រពីសម័យមុនអង្គរមកសម័យអង្គរ**

ល្បះដែលមានលក្ខណ:កម្មវាចក: ដោយការប្រែប្រួលរូបសាស្ត្រ ពីសម័យមុនអង្គរមកដល់សម័យអង្គរ យើងសង្កេតឃើញថាមិនមានលក្ខណ:សម្គាល់ដោយមានភាពច្បាស់លាស់ទេ គ្រាន់តែសម័យមុនអង្គរល្បះមួយចំនួនធំដែលមានលក្ខណ:សម្គាល់កម្មវាចក: ដោយមានការប្រើភ្ជាប់ចុណ្ណសព្ទ[១២] "ត" នៅពីខាងមុខកិរិយាសព្ទដើម្បីភ្ជាប់ទៅនឹងកម្មបទ ដែលហៅថា **កម្មភ្នាក់ងារ**។

**ឧទាហរណ៍: ស្រែ ត្នៃ កេត ត្រវង់ បោញ ភាគយុង ទំនុញ ត បោញ ភទ្រវិសេស** sre tnai ket travaṅ poñ bhāgayuṅ damnuñ ta poñ bhadraviçeṣa K.22,VII. A.D,I.32[១៣], ស្រែខាង កើតត្រពាំងបោញភាគយុងទិញដោយបោញភទ្រវិសេស។ លុះមកដល់សម័យអង្គរ យើងសង្កេតឃើញថាល្បះដែលមានលក្ខណ:សម្គាល់កម្មវាចក:ដោយមិនមានការប្រើភ្ជាប់ចុណ្ណសព្ទ **"ត"** ដូចនៅសម័យមុនអង្គរឡើយ។

[១១] G. GOEDÈS : INSCPITIONS DU CAMBODGE, VOLUME IV, PARIS 1952, P.103.

[១២] យើងខ្ញុំ សូមប្រើបច្ចេកសព្ទ "ចុណ្ណសព្ទ" នេះ ត្រូវនឹងពាក្យបារាំងថា "**particule**" ដែលមិនមានន័យដោយខ្លួនឯង។

[១៣] សូមមើល ឡុង សៀម: ***វចនានុក្រមខ្មែរបុរាណ*** ដ.ឯ.ម., ទំព័រ ៣២៩។

ឧទាហរណ៍ : **ស្រែ ជំនួន វាប បិ** sre jamnvan vāp pi K.780, X.A.D.I.24[១៤] មានន័យថា ស្រែបានជូនដោយវាប បិ។

## ២.១.២_ការវិវត្តនៃលក្ខណៈកម្មវាចកៈដោយការប្រែប្រួលរូបសាស្ត្រពីសម័យអង្គរមកសម័យបច្ចុប្បន្ន

ល្បះដែលមានលក្ខណៈសម្គាល់កម្មវាចកៈ ដោយការប្រែប្រួលរូបសាស្ត្រពីសម័យអង្គរមកដល់សម័យបច្ចុប្បន្ននេះ យើងសង្កេតឃើញថា មិនមានការប្រើលក្ខណៈកម្មវាចកៈ ដោយការប្រើប្រាស់អន្តេបទ [_អ៊ុំម/ន_] ផ្សំជាមួយកិរិយាសព្ទដើម្បីបង្កើតជាពាក្យកម្លាយដែលជាកិរិយាសព្ទ សម្រាប់សម្គាល់លក្ខណៈកម្មវាចកៈ ដូចនៅសម័យមុនអង្គរ និងអង្គរទេ។ ដោយហេតុថា កិរិយាសព្ទដែលសម្គាល់កម្មវាចកៈនៅសម័យអង្គរក៏ដូចសម័យមុនអង្គរមកដល់បច្ចុប្បន្ននេះ រូបសាស្ត្រទាំងនេះបានក្លាយទៅជានាមសព្ទដូចរូបសាស្ត្រ **"អំនោយ"** បានក្លាយទៅជានាមសព្ទ **"អំណោយ"** ដែលមានន័យថា **"ទាន ឬកម្លាយ"**។

## ២.២_ការវិវត្តនៃលក្ខណៈកម្មវាចកៈដោយប្រើរូបសាស្ត្រជំនួយ ពីសម័យមុនអង្គរមក សម័យអង្គរ

ល្បះដែលមានលក្ខណៈសម្គាល់កម្មវាចកៈ ដោយប្រើរូបសាស្ត្រជំនួយនៅសម័យមុនអង្គរ យើងសង្កេតឃើញថាមានការប្រើរូបសាស្ត្រជំនួយដើម្បីសម្គាល់លក្ខណៈកម្មវាចកៈ នៅសម័យមុនអង្គរ ដោយការប្រើពាក្យ **"មន/មាន** man/ mān**"** ដាក់ពីខាងឆ្វេងកិរិយាសព្ទបង្គោលនៅក្នុងល្បះ (សូមមើលចំណុច **១.១.២_លក្ខណៈនៃកម្មវាចកៈដោយការប្រែប្រួលនៅក្នុងសម្ព័ន្ធ**)

លុះមកដល់សម័យអង្គរ ទើបយើងប្រទះឃើញមានការប្រើរូបសាស្ត្រជំនួយ ដើម្បីសម្គាល់ល្បះមានលក្ខណៈកម្មវាចកៈ ដោយការប្រើភ្ជាប់រូបសាស្ត្រ **"តិ"** ដែលមានទីតាំងនៅខាងឆ្វេងនៃកិរិយាសព្ទបង្គោលនៅក្នុងល្បះ។

**ឧទាហរណ៍ : ភូមិ វគ្គិ ខ្មាប្ប តិ ទុញ វាប អំម្ឫត.** bhūmi vargga khmāpp ti duñ vāp aṃmṛta[១៥] K.265 S, 959 A.D.I.23, មានន័យថា ដីភូមិរបស់អ្នកកាប់អុសបានទិញដោយវាបអំម្ឫត។ តាមរយៈឧទាហរណ៍នេះ យើងសង្កេតឃើញថា កន្សោមពាក្យ **"ភូមិវគ្គិខ្មាប្ប"** មានមុខងារជាប្រធាន (រងអំពើ) នៅក្នុងល្បះ ហើយកន្សោមពាក្យ **"វាបអំម្ឫត"** មានមុខងារជាកម្មបទ (ធ្វើអំពើ) នៅល្បះដែលហៅ ថាកម្មភ្នាក់ងារ។ ដូច្នេះ យើងអាចទាញរូបមន្ត :

| |
|---|
| **ប្រធាន(រងអំពើ) + តិ + កិរិយាសព្ទ + កម្មភ្នាក់ងារ(ធ្វើអំពើ)** |

[១៤] G. GOEDÈS : INSCPITIONS DU CAMBODGE, VOLUME VI, Op.cit, P.151.

[១៥] G. GOEDÈS : INSCPITIONS DU CAMBODGE, VOLUME IV, Op.cit, P.103.

## សេចក្ដីសន្និដ្ឋាន

ក្រោយពីបានសិក្សាវិភាគអំពីលក្ខណៈកម្មវាចកៈនៃភាសាខ្មែរនៅក្នុងសម័យបុរាណ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យតាមរយៈរូបសម្ព័ន្ធ រួចមកយើងខ្ញុំអាចសន្និដ្ឋានបានថាភាសាខ្មែរមានលក្ខណៈកម្មវាចកៈបែបខ្មែរ ដោយមានល្បះខ្លះមានទម្រង់ជាកត្តុវាចកៈ តែន័យរបស់វាមានលក្ខណៈបញ្ជាក់ពីកម្មវាចកៈនិងមានទម្រង់កម្មវាចកៈផងដែរ ដោយប្រើរូបសព្ទជំនួយ។

## គន្ថនិទ្ទេស


_ ច័ន្ទ សំណព្វ : " នាមខ្មែរគ្មានភេទនិងវចនៈទេ" នៅក្នុង : ***ទស្សនាវដ្ដីសង្គមសាស្ត្រ_មនុស្សសាស្ត្រ***, ឆ្នាំទី ៣៣, លេខ ៤២, ខែ មករា_កុម្ភៈ_មីនា ឆ្នាំ២០០៣។

_ ច័ន្ទ សំណព្វ : " ជុំវិញបញ្ហាបំលាស់ប្ដូរបំរើបំរាស់និងការបង្កើតពាក្យក្នុងភាសាខ្មែរទំនើប " នៅក្នុង : ***ទស្សនាវដ្ដីសង្គមសាស្ត្រ_មនុស្សសាស្ត្រ***, ឆ្នាំទី៣៣, លេខ៤៤, ខែកក្កដា_សីហា_កញ្ញា ឆ្នាំ ២០០៣។

_ ច័ន្ទ សំណព្វ : "វាក្យស័ព្ទនាម" នៅក្នុង : ***ទស្សនាវដ្ដីសង្គមសាស្ត្រ_មនុស្សសាស្ត្រ***, ឆ្នាំទី៣៤, លេខ ៤៦, ខែ មករា_កុម្ភៈ_មីនា ឆ្នាំ២០០៤។

_ ច័ន្ទ សំណព្វ : " ផ្នែកមួយនៃអក្ខរាវិរុទ្ធខ្មែរ " នៅក្នុង : ***ទស្សនាវដ្ដីសង្គមសាស្ត្រ_មនុស្សសាស្ត្រ***, ឆ្នាំទី៣៦, លេខ ៥៥, ខែ មេសា_ឧសភា_មិថុនា ឆ្នាំ២០០៦។

_ ច័ន្ទ សំណព្វ : " ព្យាង្គតំរួតក្នុងសម័យខេមរយានកម្ម" នៅក្នុង: ***ទស្សនាវដ្ដីសង្គមសាស្ត្រ_មនុស្សសាស្ត្រ***, ឆ្នាំទី៣៦, លេខ ៥៧, ខែ តុលា_វិច្ឆិកា_ធ្នូ ឆ្នាំ២០០៦។

_ ច័ន្ទ សំណព្វ : " ធាតុនៃវេយ្យាករណ៍ដែលប្រើសំរាប់បង្កើតពាក្យក្នុងភាសាខ្មែរ " នៅក្នុង: ***ទស្សនាវដ្ដីសង្គមសាស្ត្រ_មនុស្សសាស្ត្រ***, ឆ្នាំទី៣៧, លេខ ៥៨, ខែ មករា_កុម្ភៈ_មីនា ឆ្នាំ២០០៧។

_ ច័ន្ទ សំណព្វ : " ការកំណត់ប្រភេទពាក្យក្នុងភាសាខ្មែរ : តួនាទីនៃបុរេបទ ការ និងផ្នត់ចែក[_អំម/ណ_] / [_អំម/ន_]" នៅក្នុង ***: ទស្សនាវដ្ដីសង្គមសាស្ត្រ_មនុស្សសាស្ត្រ***, ឆ្នាំទី៣៧, លេខ ៥៨, ខែ មេសា_ ឧសភា_ មិថុនា ឆ្នាំ២០០៧។

_ ផែល ថោង :"កម្មវាចកៈក្នុងភាសាខ្មែរ", នៅក្នុង ***: ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា***, លេខ ០២ មិថុនា ២០០១។

- នៅ ស៊ិន : "ភាសាខ្មែរក្នុងចំណោមភាសាអ៊ីសូឡង់ និង ភាសាមិនមែនអ៊ីសូឡង់" នៅក្នុង: Sorn Samnang (Ed.) ***ខេមរវិទ្យា*** volume II, ១៩៩៩។

- ពុទ្ធសាសនបណ្ឌិត្យ ***: វចនានុក្រមខ្មែរ***, បោះពុម្ពគ្រាទី៥, ភ្នំពេញ, ឆ្នាំ១៩៦៧-៦៨។

-ព្រុំ ម៉ល់:"លទ្ធភាពបង្កើតពាក្យ និង ការបង្កើតពាក្យក្នុងភាសាខ្មែរ", នៅក្នុង ***: ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា***, លេខ ០២ មិថុនា ២០០១។

- ព្រុំ ម៉ល់:"អំពីលក្ខណៈវិនិច្ឆ័យរូបនិយម",នៅក្នុង ***: ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា,*** លេខ ០៣ ធ្នូ ឧសភា ២០០២។

-ព្រុំ ម៉ល់: " អំពីលក្ខណៈវិនិច្ឆ័យរូបនិយម", នៅក្នុង ***: ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា***, លេខ ០៣ ឧសភា ២០០២។

-ព្រុំ ម៉ល់ ***: មូលដ្ឋាននៃសង្គមភាសាវិទ្យា***, ផ្សាយដោយអ្នកនិពន្ធ, ភ្នំពេញ, ២០០៣។

-ព្រុំ ម៉ល់ ***: មូលដ្ឋាននៃ សូរវិទ្យា ស័ទ្ទតាវិទ្យា និង វិជ្ជាសទ្ទាន***, ផ្សាយដោយអ្នកនិពន្ធភ្នំពេញ, ២០០៣។

-ព្រុំ ម៉ល់ ***: មូលដ្ឋាននៃន័យកម្មវិទ្យាទូទៅ***, ផ្សាយដោយអ្នកនិពន្ធ ភ្នំពេញ, ២០០៣។

- ព្រុំ ម៉ល់: "ចំណុចគួរកត់សម្គាល់ ក្នុងភាសាខ្មែរបច្ចុប្បន្ន", នៅក្នុង ***: ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា,*** ឆ្នាំទី៤ លេខ ៤ ខែកញ្ញា គ.ស. ២០០៣។

-ព្រុំ ម៉ល់ ***: វេយ្យាករណ៍ទម្រង់និយម នៃភាសាខ្មែរទំនើប?*** ផ្សាយដោយអ្នកនិពន្ធ, ភ្នំពេញ, ២០០៦។

- មាឃ បូរ៉ា ***: ការស្រាវជ្រាវវេយ្យាករណ៍ភាសាខ្មែរបុរេអង្គរ,*** សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១, រាជបណ្ឌិត្យសភាកម្ពុជា, ២០០២។

- ឡុង សៀម : " អំពីកិត្យានុភាព និងការអភិវឌ្ឍន៍ភាសាខ្មែរ (ជាពិសេសតាមឯកសារភាសា មន-ខ្មែរ និង សិលាចារឹកកម្ពុជា)" នៅក្នុង : ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាម្ពុជា, លេខ០២ មិថុនា ២០០១។

- ឡុង សៀម: អំពីភាសាវិទ្យា និងភាសាខ្មែរ, មហាវិទ្យាល័យបុរាណវិទ្យា, ២០០០។

- ឡុង សៀម: បញ្ហាវចនសព្ទវិទ្យាខ្មែរ, ផ្សាយដោយអ្នកនិពន្ធ, ភ្នំពេញ ១៩៩៩។

- ឡុង សៀម: ស្ថាននាមវិទ្យាខ្មែរ, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ ១៩៩៧។

-វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា ***: វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ.*** ភ្នំពេញ.២០០៥។

- ឡុង សៀម:វចនានុក្រមខ្មែរបុរាណ (តាមសិលាចារឹកសតវត្សទី៦-៨), រោងពុម្ពភ្នំពេញ, ២០០០។

# អវិជ្ជមានបទនិងអវិជ្ជមានសព្ទក្នុងការស្ថាបនាន័យ



លោក ជួរ គារី

បេក្ខជនបណ្ឌិតផ្នែកភាសាវិទ្យា

នៃរាជបណ្ឌិត្យសភាកម្ពុជា

នៅក្នុងភាសាខ្មែរ ការប្រើប្រាស់វាចា ឬសំណេរដើម្បីទាក់ទងគ្នា មានបង្កប់ន័យផ្សេងៗយ៉ាងសម្បូរបែប។ ពេលខ្លះគូសន្ទនានិយាយបង្កប់ន័យជ្រៅជ្រះខ្លាំងពេក អាចធ្វើឱ្យគូសន្ទនារបស់ខ្លួនយល់មិនដល់ឬមិនយល់ន័យនៃកិច្ចសន្ទនានោះតែម្ដង។ ឧទាហរណ៍ពេលខ្លះ គេនិយាយប្រកបទៅដោយអវិជ្ជមានន័យនូវសំណើឬសំណូមពររបស់ខ្លួនទាំងស្រុង ប៉ុន្តែគូសន្ទនារបស់ខ្លួនមិនយល់ន័យទាំងនោះឡើយ។ ប្រការទាំងនេះបញ្ជាក់ថា អវិជ្ជមានន័យមានតួនាទីសំខាន់ខ្លាំងណាស់ ក្នុងជីវភាពប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប។

ដោយមើលឃើញពីសារៈសំខាន់នៃអវិជ្ជមានន័យនៅក្នុងការប្រាស្រ័យទាក់ទងគ្នានេះហើយ ទើបយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទស្ដីអំពីអវិជ្ជមានន័យ ដោយយកទ្រឹស្ដីអន្តរកម្មនិយម[១៦] មកធ្វើជាមូលដ្ឋាននៃការវិភាគដែលមានលក្ខណៈបែបអាតូមិក។

តើអ្វីទៅជាអន្តរកម្មនិយម?

អន្តរកម្មនិយមគឺជាទ្រឹស្ដីមួយក្នុងការវិភាគភាសាវិទ្យា។ នៅក្នុងក្របខ័ណ្ឌនេះ *«ន័យរបស់ឯកតាភាសាមួយ (ក្នុងន័យទូលាយ) កើតឡើងតាមរយៈអន្តរកម្មរវាងឯកតាភាសានោះជាមួយសហបទរបស់វានៅក្នុងបរិបទមួយកំណត់ច្បាស់លាស់»*[១៧]។ អន្តរកម្មនិយមជាលក្ខណៈចម្បង ដែលកើតចេញអំពីការប្រើប្រាស់ភាសា ហើយ ត្រូវបានប្រើនៅក្នុងចរន្តស្ថាបនិកនិយម។ ឧទាហរណ៍ បើ

[១៦] វាជាក្របខ័ណ្ឌនៃទ្រឹស្ដីវិភាគភាសាវិទ្យាខ្មែរដែលបានបង្កើតឡើងដោយក្រុមស្រាវជ្រាវខ្មែរ និង បរទេសដែលដឹកនាំដោយ ច័ន្ទ សំណព្វ ចាប់តាំងពីឆ្នាំ១៩៩៦។ ក្របខ័ណ្ឌនៃទ្រឹស្ដីនេះត្រូវបានប្រើជាមូលដ្ឋាននៅក្នុងការសិក្សា និង ការសរសេរសារណា និង និក្ខេបបទនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ហើយក៏ត្រូវស្រាវជ្រាវផងដែរចំពោះ សារណា និង និក្ខេបបទដែលដឹកនាំដោយសាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ នៅរាជបណ្ឌិត្យសភាកម្ពុជានិងនៅសាកលវិទ្យាល័យឯកជនទានា។

[១៧] សាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ (១៩៩៧-២០០២)។

យើងយកពាក្យ ***ស្តាំ*** មកវិភាគ យើងមិនទាន់ដឹងថាវាមានន័យយ៉ាងម៉េចទេ ទាល់តែវាចូលរួមក្នុងអន្តរកម្មជាមួយសហបទ ពោលគឺពាក្យទាំងឡាយដែលចូលរួមប្រើប្រាស់ជាមួយវា ទើបគេអាចយល់ន័យរបស់វាបាន។ ដូចជា ***ខាងស្តាំ*** និង ***ដៃស្តាំ*** មិនដូចគ្នាទេ ហើយ ***ដៃស្តាំ*** ទៀតសោតក៏មានន័យប្រែប្រួលទៅតាមបរិបទរបស់វាផងដែរ។ ឧទាហរណ៍ *កាលពីព្រឹកថ្ងៃម្សិលមិញមានជនមិនស្គាល់មុខម្នាក់បានបាញ់ដៃស្តាំលោកអភិបាលខេត្តរបួសជាទម្ងន់*។ តើពាក្យ ***ដៃស្តាំ*** ក្នុងឃ្លានេះជា ដៃរបស់លោកអភិបាលខេត្ត ឬក៏ជាអ្នកជំនិតរបស់លោកអភិបាលខេត្ត? ការសរសេរត្រឹមនេះ ពាក្យនេះមិនទាន់មានន័យពេញលេញនៅឡើយទេ ទាល់តែមានសហបទភ្ជាប់ជាមួយទៀត គឺគេអាចថា (ឃ្លាបន្ត) *បន្ទាប់ពីព្រឹត្តិការណ៍ដ៏អាក្រក់នោះគេក៏បានបញ្ជូនលោកអភិបាលខេត្តទៅព្យាបាលនៅឯមន្ទីរពេទ្យជាបន្ទាន់* ។ ឃ្លានេះ បញ្ជាក់ច្បាស់លាស់ថា អ្នកត្រូវរបួស គឺពិតជាលោកអភិបាលខេត្ត។ ប៉ុន្តែ បើគេបន្តឃ្លាដូច្នេះវិញ *ដឹងដំណឹងនេះភ្លាម លោកអភិបាលខេត្តបានបញ្ជូនក្រុមអង្គរក្សមួយក្រុមស្វែងរកជនដៃដល់*។ ឬអាចបន្តឃ្លាដូច្នេះក៏បាន *ដឹងដំណឹងនេះភ្លាម លោកអភិបាលខេត្តបានជួយបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យជាបន្ទាន់*[១៩] ។ នៅពេលមានសហបទចូលរួមជាអន្តរកម្មផង ទើបយើងអាចយល់បាននូវពាក្យ ***ដៃស្តាំ*** នេះមានន័យថាដូចម្តេច។

សូមបញ្ជាក់ថា តាមទ្រឹស្តីអន្តរកម្មនិយមដែលមានលក្ខណៈបែបស្ថាបនិកនិយម គេមិនអាចសន្និដ្ឋានថា មានន័យដែលកើតមុនឬឋិតនៅក្រៅឯកតាភាសានោះទេ។ **ន័យ** គឺកើតមានព្រមគ្នានឹងពេលគេប្រើប្រាស់ភាសា។ យ៉ាងណាមិញ គេអាចយល់ពីអវិជ្ជមានន័យបានតែតាមរយៈអវិជ្ជមានបទ ឬអវិជ្ជមានសព្ទ ដែលជាធាតុចាំបាច់នៃអន្តរកម្ម ហើយអន្តរកម្មនោះឯង ដែលជាយន្តការនៃការស្ថាបនាន័យ។ គោលការណ៍ជាសារវន្តនៃការវិភាគក្នុងនិក្ខេបបទនេះ គឺផ្អែកលើន័យសត្យានុម័តដែលជាន័យស្តែងឡើងតាមរយៈភាសា តែមិនមែនជាន័យដែលកើតឡើងតាមរយៈនៃការបកស្រាយ ឬការយល់ដឹងរបស់បុគ្គលណាម្នាក់នោះទេ។

***អវិជ្ជមានន័យ*** គឺជាន័យដែលកើតចេញពីអន្តរកម្មរបស់ឯកតាភាសា ដែលអាចជាអវិជ្ជមានបទនិងអវិជ្ជមានសព្ទ។ ចំណែកឯន័យបដិសេធ គឺជាន័យដែលកើតចេញពីប្រតិកម្មពីចេតនារបស់មនុស្សដែលត្រូវបានស្តែងចេញតាម

[១៩] ឧទាហរណ៍ខាងលើនេះដកស្រង់ពី ច័ន្ទ សំណព្វ ក្នុង ស្នាដៃអន្តរកម្មនិយម ២០០៧។

រយៈឃ្លាឬវាទរូប។ ឧទាហរណ៍ *គាត់មិនយល់ ខ្ញុំមិនយល់* ស្តែងពីអវិជ្ជមានន័យ ហើយអវិជ្ជមានន័យនេះ កើតឡើងពីអន្តរកម្មរវាងអវិជ្ជមានបទ (មិន) និងសហបទរបស់វា ពោលគឺ *(យល់)* ។ ដូចគ្នាដែរ គេនិយាយថា *ខ្ញុំមិនខ្វីធ្វើយល់ ខ្ញុំមិនព្រមថាយល់ ខ្ញុំមិនធ្វើ ខ្ញុំមិនក្រោក ខ្ញុំមិនឱ្យ* គឺជាឃ្លាដែលមានន័យបដិសេធ ដែលចេញពីប្រតិកម្មមនុស្ស ពីព្រោះមនុស្សនេះមានចេតនាមិនចង់ធ្វើកិច្ចការដែលគេតម្រូវឱ្យខ្លួនធ្វើ។

***បដិសេធន៍*** ស្តែងពីទំនាក់ទំនងអន្តរប្រធានដែលអាចជាករម្រៅភាសា[១៩]។ គួរកត់សម្គាល់ថា ការបដិសេធអាចនាំឱ្យគូសន្ទនាយល់ពីអវិជ្ជមានន័យដែលវាទករ (អ្នកនិយាយ) ចង់ប្រាប់ឱ្យដឹង។ ឧទាហរណ៍ តាមរយៈវាទរូប *គួរឱ្យស្តាយណាស់ ខ្ញុំមានគូដណ្តឹងទៅហើយ* គូសន្ទនាយល់ឃើញថា វាទករបដិសេធខ្លួនរួចទៅហើយ។ ម្យ៉ាងទៀត ការបដិសេធជាតម្លៃអវិជ្ជមានចំពោះគូសន្ទនាតែវាជាតម្លៃវិជ្ជមានរបស់វាទករទៅវិញ។

អវិជ្ជមានន័យដែលយើងលើកមកសិក្សានេះមានលក្ខណៈជាសត្យានុម័ត។ ហេតុនេះ វាមិនប្រែប្រួលទៅតាមបុគ្គលទេ។ ឧទាហរណ៍ យើងអាចនិយាយថា *ជំងឺអេដស៍ជាជំងឺធ្ងន់ដ៏កាចសាហាវបំផុត គេមិនអាចព្យាបាលវាបានទេ*។ ទាំងវាទករទាំងសហវាទករក៏យល់ថា ជំងឺនេះមិនអាចព្យាបាលជាបានទេ។

ការប្រើប្រាស់អវិជ្ជមានសព្ទ ពេលខ្លះធ្វើឱ្យដៃគូសន្ទនាមានភាពច្របូកច្របល់ក្នុងគំនិតព្រោះមិនយល់ន័យឬអាចធ្វើរឿងល្អឱ្យក្លាយជាអាក្រក់បានឬអាចធ្វើរឿងអាក្រក់ឱ្យក្លាយជាល្អវិញក៏បានដែរ។

កន្លងមក ការសិក្សាស្រាវជ្រាវទៅលើអវិជ្ជមានន័យនៅក្នុងភាសាខ្មែរ តាមរយៈអវិជ្ជមានបទនិងអវិជ្ជមានសព្ទនេះពុំទាន់មានការសិក្សាឱ្យបានពិស្តារ[២០] នៅឡើយទេ ហេតុដូច្នេះហើយ ទើបយើងសម្រេចចិត្តជ្រើសរើសយកប្រធានបទនេះមកសិក្សានៅក្នុងចំណោមប្រធានបទទាំង៥ ដែលបានដាក់ស្នើឡើង។

យើងស្គាល់ប្រធានបទនៃការស្រាវជ្រាវនេះច្បាស់លាស់ណាស់ ហើយយើងក៏មានវិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវរួចស្រេចទៅហើយដែរ។ ក៏ប៉ុន្តែការសន្យាអំពីរបកគំហើញ វាជាផ្លូវដ៏វែងឆ្ងាយមួយដែលយើងត្រូវធ្វើកិច្ចការ

[១៩] ជាបច្ចេកសព្ទប្រើនៅដេប៉ាតឺម៉ង់ភាសាវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីស្តែងពីអ្វីដែលភាសាបាំងហៅថា extralinguistique។ ក្នុងន័យនេះ បដិសេធន៍ឬការបដិសេធសំដៅយកប្រតិកម្មមួយដែលស្តែងចេញពីចេតនារបស់វាទករ (អ្នកពោល ហើយអះអាងថា សារដែលខ្លួនបានបញ្ចេញមកពិត) តាមរយៈកាយវិកាឬតាមរយៈពាក្យសម្តី។ល។

[២០] យើងគ្រាន់តែឃើញមានការផ្តល់និយមន័យជាប្រព័ន្ធទៅលើបច្ចេកសព្ទ អវិជ្ជមានបទ អវិជ្ជមានសព្ទ ទម្រង់អវិជ្ជមានគោលអវិជ្ជមាន។ល។ នៅក្នុងស្នាដៃស្រាវជ្រាវរបស់បណ្ឌិតច័ន្ទ សំណព្វ ប៉ុណ្ណោះ។

ស្រាវជ្រាវនេះ យ៉ាងហោចណាស់ក៏ក្នុងរយៈពេលបីឆ្នាំយ៉ាងតិចដែរ។

អ្វីៗ ដែលនៅមានលក្ខណៈស្រពិចស្រពិល សបញ្ជាក់ថា ប្រធានបទនេះជាប្រធានបទមួយថ្មី ដែលសម្មតិកម្មនឹងកើតចេញពីរបកគំហើញនៃការសិក្សាស្រាវជ្រាវចាប់ពីពេលនេះតទៅ។

ចំពោះគម្រោងលម្អិតនៃនិក្ខេបបទនេះ ខ្ញុំបាទបានបែងចែកជាបីជំពូកធំៗដែលមានជំពូកទីមួយទាក់ទងទៅនឹងការពិចារណានិងការស្វែងយល់ពីនិយមន័យនៃអវិជ្ជមានន័យតាមរយៈអន្តរកម្មនិយម ដែលជាមូលដ្ឋានគ្រឹះនៃការសិក្សាស្រាវជ្រាវប្រធានបទនៃនិក្ខេបបទនេះ។ ការស្វែងយល់ពីនិយមន័យនៃបច្ចេកសព្ទមួយចំនួនដែលជាពាក្យគន្លឹះសំខាន់ៗ គឺ ដើម្បីងាយស្រួលសិក្សានិងវិភាគនៅក្នុងជំពូកបន្ទាប់ៗទៀត។ ការឱ្យនិយមន័យបច្ចេកសព្ទសំខាន់ៗ ក្នុងជំពូកនេះមានបំណងឱ្យយើងបានស្គាល់និងយល់ច្បាស់ថាតើអ្វីទៅជា -អវិជ្ជមានសព្ទ -អវិជ្ជមានកម្ម -អវិជ្ជមានភាព -វិជ្ជមានភាព -គោលវិជ្ជមាន -ទម្រង់វិជ្ជមាន។ នៅក្នុងជំពូកនេះដែរ យើងខ្ញុំនឹងផ្តល់ជូនការវិភាគលើនិយមន័យដែលអ្នកនិពន្ធនីមួយៗ បានលើកឡើងនិងវិភាគទៅលើការរកឃើញនូវចំណុចថ្មីៗ តាមរយៈការស្រាវជ្រាវស្តីពីប្រធានបទនិក្ខេបបទនេះ។ ចំពោះជំពូកទីពីរវិញជាជំពូកមួយដែលផ្តោតទីលើការវិភាគអវិជ្ជមានបទមួយចំនួនដែលមានប្រើច្រើននៅក្នុងការប្រាស្រ័យទាក់ទងគ្នាជារៀងរាល់ថ្ងៃ។ *អវិជ្ជមានបទ*[៦៧] ស្តែងឡើងតាមឯកតាភាសា[៦៨] រួមជាមួយនឹងសហបទរបស់វាបង្កើតបានជាទម្រង់អវិជ្ជមានដែលអាចស្តែងឡើងជាអវិជ្ជមានន័យ និងវិជ្ជមានន័យ។

អវិជ្ជមានបទនេះ មានតួនាទីនៅក្នុងការបង្កើតឃ្លាដែលមានទម្រង់អវិជ្ជមាន ហើយដែលអាចបង្កើតជា វិជ្ជមានន័យឬអវិជ្ជមានន័យ ដោយអនុលោមទៅតាមសហបទរបស់វា។ ប្រសិនបើអវិជ្ជមានបទ ***មិន*** មានអន្តរកម្មជាមួយ ***ល្អ*** វាបង្កើតបានជាអវិជ្ជមានន័យ ដូចជានៅក្នុងឃ្លា ***វាមិនល្អទេ*** ។ ប៉ុន្តែបើ***មិន*** មានអន្តរកម្ម[៦៩]ជាមួយ ***អាក្រក់*** ដែលជាអវិជ្ជមានសព្ទវិញនោះ វាបង្កើតបាន ជាឃ្លាមួយដែលមានទម្រង់អវិជ្ជមានក៏មែនពិត តែវាស្តែងពីវិជ្ជមានន័យទៅវិញ ដូចមានឃ្លា ***វាមិនអាក្រក់*** ជាសក្ខីភាពបញ្ជាក់ស្រាប់។ កត្តា

---

[៦៧]សាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ បានកំណត់ពាក្យមួយចំនួនជាអវិជ្ជមានបទឱ្យសិក្សាដូចជា : *មិន ឥត ពុំ គ្មាន* យកមកសិក្សានៅក្នុងនិក្ខេបបទនេះ។

[៦៨]ឯកតាភាសាយើងសន្មតហៅពាក្យទាំងឡាយណាដែលចាត់ចូលទៅក្នុងអវិជ្ជមានបទនិងអវិជ្ជមានសព្ទ ហើយលើកយកមកសិក្សានៅក្នុងនិក្ខេបបទនេះ។

[៦៩]កត្តានេះបានរំលេចពីទ្រឹស្តីអន្តរកម្មនិយមដែលជាក្របខ័ណ្ឌមូលដ្ឋាននៃការស្រាវជ្រាវរបស់យើងខ្ញុំ។

នេះ បានរំលេចពីទ្រឹស្តីអន្តរកម្មនិយមដែលជាគ្រឹះ ខណ្ឌមូលដ្ឋាននៃការស្រាវជ្រាវរបស់យើងខ្ញុំ។

អវិជ្ជមានបទជាឯកតាភាសាមួយដែលមានលក្ខណៈជារូបសព្ទក្នុងជាវចនសព្ទដែលប្រើសម្រាប់ស្ថាបនាអវិជ្ជមានន័យ ឬ គ្រាន់តែបង្កើតជាទម្រង់អវិជ្ជមានតែប៉ុណ្ណោះ។ អវិជ្ជមានបទរួមមាន *មិន អត់ ឥត ពុំ គ្មាន ទេ* ។ល។ នៅក្នុងវេយ្យាករណ៍ប្រពៃណី គេហៅឃ្លាទាំងឡាយណាដែលមានអវិជ្ជមានបទនៅក្នុងនោះថា ជាឃ្លាអវិជ្ជមាន។ ក្នុងករណីនេះអវិជ្ជមានគឺគ្រាន់តែចង់សំដៅទម្រង់ឃ្លាប៉ុណ្ណោះ ដោយមិនគិតពីផ្នែកន័យនោះឡើយ។

ចំណែកឯជំពូកទីបីវិញ ជាជំពូកវិភាគទៅលើអវិជ្ជមានសព្ទ ដែលជាពាក្យប្រើសម្រាប់បង្កើតឃ្លាដែលមានទម្រង់វិជ្ជមាន តែវាបញ្ជាក់ពីអវិជ្ជមានន័យ។ ពាក្យទាំងនោះមានដូចជា : *ខុស អាក្រក់ ហាម ចាំតើ! ស្អែកជួយ!* ។ល។ អវិជ្ជមានសព្ទ[៦៤] ជាឯកតាភាសាដែលនៅក្នុងអន្តរកម្មជាមួយសហបទរបស់វាអាចបង្កើតជា វិជ្ជមានន័យឬអវិជ្ជមានន័យ។ បើស្ថិតក្នុងទម្រង់វិជ្ជមាន អវិជ្ជមានសព្ទបង្កើតបានជាអវិជ្ជមានន័យ តែបើនៅក្នុងទម្រង់អវិជ្ជមានវិញនោះ វាបែរជាបង្កើតបានជាវិជ្ជមានន័យទៅវិញ។

នៅចុងបញ្ចប់នៃនិក្ខេបបទនេះ មានសេចក្តីសន្និដ្ឋានមួយដែលផ្តោតជារួមទៅលើខ្លឹមសារនៃការស្រាវជ្រាវទាំងមូល។

**១_អំពីអវិជ្ជមានបទ *មិន***

ការសិក្សាពីអវិជ្ជមានបទ *(មិន,ពុំ,ឥត ។ល។)* ជាការសិក្សាពីការស្ថាបនាន័យ តាមរយៈ *វាទរូប*[៦៥] នៅក្នុងសំណង់ឃ្លាតាងដោយរចនាសម្ព័ន្ធទូទៅមួយ ដែលមានទម្រង់ (មិន+កិ., កិ.+មិន+ឈ្ន., ...)។ សូមបញ្ជាក់ថា យើងសិក្សាពីអវិជ្ជមានបទដែលមាននៅក្នុងល្បះ តែយើងមិនសិក្សាពីវាទរូបដែលមានអវិជ្ជមានបទទេ ព្រោះដើម្បីចៀសវាងនូវការភាន់ច្រឡំ ដោយយកន័យរបស់ឃ្លាធ្វើន័យរបស់អវិជ្ជមានបទ។ យើងនឹងសិក្សាផងដែរពីធាតុដែលសហបទរបស់អវិជ្ជមានបទនិងពីទីតាំងរបស់អវិជ្ជមានបទនៅក្នុងវាទរូប។

**១.១. សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ *មិន+កិ.***

យើងសិក្សាលើសំណុំពាក្យដែលរចនាសម្ព័ន្ធទូទៅមានទម្រង់ *មិន+កិ.* ក្នុងករណីនេះ អវិជ្ជមានបទ *(មិន, ពុំ*។ល។) មានទំនាក់ទំនងផ្ទាល់ទៅនឹង

[៦៤] សាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ បានកំណត់ពាក្យមួយចំនួនជាអវិជ្ជមានសព្ទឱ្យសិក្សាដូចជា : *ហាម ខុស អាក្រក់ ចាំតើ! ស្អែកជួយ!...*។

[៦៥] *វាទរូប* ប្រើនៅក្នុងទីនេះ និរុត្តិសាស្ត្ររបស់បណ្ឌិត ច័ន្ទ សំណព្វ ពោលគឺ ជាសំណុំពាក្យដែលត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ (ឃ្លា) ហើយមានន័យតែមួយនៅក្នុងបរិបទមួយកំណត់ច្បាស់លាស់។

កិរិយាសព្ទ ហើយអន្តរកម្មរវាងធាតុទាំងពីរ (អរិជ្ឈមានបទនិងកិរិយាសព្ទ) ស្តែងពីគោលអរិជ្ឈមាននៃកិរិយាសព្ទ ដោយវាបញ្ជាក់ពីអសុពលភាពរបស់ហេតុភេទ (ព្រឹត្តិការណ៍, សកម្មភាព, ស្ថានភាព។ល។) ដែលស្តែងឡើងតាមរយៈកិរិយាសព្ទនោះ ហើយហេតុភេទនោះមិនអាចចារឹកនៅក្នុង «កាលៈទេសៈ»[២៦] ឡើយ។ ក្នុងន័យនេះគេអាចនិយាយបានថា សំណង់ *មិន+កិ.* រំលេចចេញនូវអវត្តមាននៃហេតុភេទ ដែលស្តែងឡើងតាមរយៈកិរិយាសព្ទនោះ។ សូមមើលវាទរូបខាងក្រោម:

(១) *«អូនអញ្ជើញអ្នកណាហ្នឹង? គ្មានឈ្មោះអ៊ីចឹងបងមិនចូលទេ!... »*[២៧]។

តាមរយៈអត្ថបទវាទរូបនេះត្រូវបានប្រើនៅក្នុងបរិបទមួយដែលយុវជនម្នាក់និយាយហាក់ដូចជា កំពុងតែអាក់អន់ស្រពន់ចិត្តនឹងយុវតីម្នាក់ដោយអាការងឺក់ ពីព្រោះតែការអញ្ជើញរបស់យុវតី គ្មានចេញឈ្មោះយុវជន។

***មិន*** នៅទីនេះមានទំនាក់ទំនងទៅនឹងកិរិយាសព្ទ ***ចូល*** ដែលបញ្ជាក់ពីសកម្មភាពរបស់ប្រធាន ពោលគឺ ***បង*** ។ វាបង្ហាញពីគោលអរិជ្ឈមាននៃ ***ចូល*** មានន័យថា ចំពោះយុវជននោះ ***ចូល*** មិនអាចប្រព្រឹត្តទៅបានទេ ដោយសារតែគាត់ពុំឮឈ្មោះរបស់គាត់។ ដើម្បីវិភាគពីយន្តការនៃ ***មិន*** នៅក្នុងវាទរូបនេះ យើងខ្ញុំសូមតាង *ប0* ជាយុវតី ហើយតាង *ប'0* ជាយុវជន។

បើផ្អែកទៅលើទ្រឹស្តីវាទកម្មវិញនោះ យើងអាចធ្វើការបកស្រាយ ដូចទៅ:

ការសិក្សាជាប្រព័ន្ធតាមបែបវាទកម្មអាចឱ្យយើងយល់បានថា *ប0* តម្រូវឱ្យហេតុភេទ(ចូល) ប្រព្រឹត្តឡើងដោយ *ប'0*។ ប្រការនេះ បញ្ជាក់ថា ***ចូល*** អាចនឹងកើតមានឡើង ប្រសិនបើគ្មានការជំទាស់ពី *ប'0*។ ផ្ទុយទៅវិញ *ប0* មិនបានធ្វើឱ្យហេតុភេទ ***ចូល*** កើតមានឡើងនោះទេ។ អត្ថន័យនេះបានរំលេចចេញតាមរយៈការប្រើអរិជ្ឈមានបទទៅប្រើកិរិយាសព្ទ ***ចូល*** ។ ក្នុងន័យនេះ ***មិនចូល*** បញ្ជាក់ថា ចំពោះ *ប'0* ហេតុភេទដែលស្តែងដោយកិរិយាសព្ទ ***ចូល*** គ្មានសុពលភាព ហើយវាចារឹកនៅក្នុងគោលអរិជ្ឈមាន។ អភិកថានេះ មានបំណងបញ្ជាក់ពីតួនាទីរបស់អរិជ្ឈមានបទ ***មិន*** ផងនិងពីតម្លៃវាទកម្មដែលបានមកពីការសន្ទនារវាង *ប0* និង *ប'0*។ ប្រការនេះ បង្កើតឱ្យមានការប្រឈម គ្នាមួយរវាង *ប0* និង *ប'0* ចំពោះហេតុភេទតែមួយ គឺ ***ចូល***។

ដើម្បីឱ្យច្បាស់ពីយន្តការនៃ ***មិន*** នៅក្នុង

[២៦] ប្រើក្នុងន័យដែលត្រូវនឹងភាសាបារាំង espacetemps ។ សូមបញ្ជាក់ថា តាមទស្សនៈសាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ ដំណើរប្រព្រឹត្តទៅនៃហេតុភេទមួយ អាចជៀបទៅនឹងទីតាំងនិងពេលវេលាមួយជានិច្ច។

[២៧] ទូ ហាច: «ផ្កាស្រពោន»ភ្នំពេញ ១៩៤៧ ទំព័រ១។

សំណង់ឃ្លាប្រភេទខាងលើនេះ យើងនឹងលើកយកវាទរូប(២) ជាឧទាហរណ៍បង្ហាញជូនដូចក្រោមនេះ:

(២) *«ឯដីរនេះ បងមិនខ្លាចទេ បងរេះឡើងដើមឈើស្ទាក់ហើយ»*[២៨]។

វាទរូបនេះប្រើនៅក្នុងបរិបទមួយ ដែលសាមីខ្លួនពោលធានាអះអាងនៅចំពោះមុខនរណាម្នាក់(ប្អូនស្រី) ពីភាពអង់អាចក្លាហានរបស់ខ្លួនក្នុងការដើរព្រៃ។ ***មិន*** នៅក្នុងបរិបទនេះមានទំនាក់ទំនងជាមួយនឹង ***ខ្លាច***ដែលអន្តរកម្មរវាងធាតុទាំងពីរបញ្ជាក់ពីភាពក្លាហានរបស់ ***បង*** ហើយស្តែងពីវិជ្ជមានន័យ ទោះបី***ខ្លាច*** បញ្ជាក់ពីអវិជ្ជមានន័យក៏ដោយចុះ។ បាតុភូតនេះសបញ្ជាក់ឱ្យឃើញកាន់តែច្បាស់ថា***មិន***មានតួនាទីកំណត់គោលអវិជ្ជមាននៃខ្លាច។ ហេតុនេះ យើងអាចសន្និដ្ឋានបានថា គឺគោលអវិជ្ជមាននៃ ***ខ្លាច*** នេះហើយ ដែលនាំឱ្យមានការបង្កើតឡើងនូវវិជ្ជមានន័យហើយវិជ្ជមានន័យនេះអាចសម្រេចបានក៏ដោយ សារតែហេតុភេទ ***ខ្លាច*** មិនបានចារឹកទៅក្នុង«កាលៈទេសៈ»។

ចំពោះវាទរូប(១)ខាងលើវិញ ប្រសិនបើយើងជំនួសពាក្យ***មិន*** ដោយពាក្យ***កុំ*** វិញ យើងនឹងបានឃ្លា (១ក)ដូច្នេះ(១ក) *«អូនអញ្ជើញអ្នកណាហ្នឹង? គ្មានឈ្មោះ អីចឹងបងកុំចូលទេ ។...»*។

ឃ្លា(១ក)ខាងលើនេះ មិនសូវរលូនដូចវាទរូប(១)ទេ តែវាហាក់ដូចជាមិនបានរំលេចនូវភាពខុសគ្នាគួរឱ្យចាប់អារម្មណ៍ឡើយ ហេតុនេះយើងមិនសិក្សាពីវាទរូប(១ក) នៅពេលនេះទេ។ នៅក្នុងសំណុំពាក្យ មិន+កិ. យើងអាចសន្និដ្ឋានបានថា ការសម្រេចប្រើ ***មិន*** ឬ***កុំ***វាមិនអាស្រ័យទៅលើកត្តាន័យឬកត្តាសម្ព័ន្ធនោះទេ។ ដូច្នេះ ការនិយមប្រើ ***មិន*** ឬ ***កុំ*** អាចមានលក្ខណៈស្របទៅតាមប្លង់វាទកម្មដែលស្មេរមានបំណងជ្រើសរើសយកមកប្រើនៅក្នុងការនិយាយ ឬការសរសេររបស់ខ្លួន។

ដូចគ្នាដែរ ចំពោះវាទរូប(២)ប្រសិនបើយើងជំនួស***មិន*** ដោយ***កុំ***នោះ យើងនឹងបានវាទរូប(២ក) យ៉ាងដូច្នេះ *«ឯដីរនេះបងកុំខ្លាចទេ បងរេះឡើងដើមឈើស្ទាក់ហើយ»* ដែលវាមិនបង្កើតឱ្យមានចម្លែកន័យអ្វីផ្សេងពី ***មិន***នោះទេ។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ក៏យើងនៅតែមានការប្រុងប្រយ័ត្នថា ការដែលយើងមើលមិនឃើញនូវភាពខុសគ្នាគឺនៅក្នុងកម្រិតនៃតម្លៃរបស់វាទរូប។ ប៉ុន្តែយើងមិនអាចសន្និដ្ឋានបានថា ***មិន***ដូច ***កុំ***បានឡើយ។

**១.២.សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធ ទូទៅមានទម្រង់ មិន+កិ.១+កិ.២...**[២៩]

[២៨] នូ ហាច: ដ.ឯ.ម. ទំព័រ១២៣។

[២៩] ចំណុចរាយ គឺសម្គាល់ថា នៅមានកិរិយាសព្ទ(កិ.៣, កិ.៤ ...) ច្រើនបន្តបន្ទាប់គ្នាទៀត។

សំណង់ឃ្លាដែលមានរចនាសម្ព័ន្ធ (មិន+កិ.១+កិ.២+...) អវិជ្ជមានបទ (មិន,ពុំ។ល។) មានទំនាក់ទំនងមិនផ្ទាល់ទៅនឹង កិ.២ ដែលជាហេតុធ្វើឱ្យវាទរូបប្រភេទនេះច្នះបញ្ចាំងនូវទិដ្ឋភាពន័យមួយផ្សេងពីសំណង់ឃ្លាដែលអវិជ្ជមានបទ(មិន,ពុំ។ល។) មានទំនាក់ទំនងផ្ទាល់ទៅនឹង កិរិយាសព្ទ។ ដើម្បីឱ្យយល់ច្បាស់ពីយន្តការនៃ ***មិន*** នៅក្នុងសំណង់ឃ្លាប្រភេទខាងលើនេះ យើងនឹងលើកយកវាទរូប (៣) មកបង្ហាញជូនដូចតទៅនេះ

*(៣)« ...ព្រះស្ដេច កន និងសម្ដេចចៅ ហ៊្វាកៅ មិនអាចតស៊ូទប់ទល់បាន ក៏នាំពលរេហ៍រត់បន្តទៅមុខទៀតចូលតាមច្រកផ្លូវមួយចង្អៀត»* [៣០]។

វាទរូបនេះ បង្ហាញពីការបរាជ័យរបស់ព្រះស្ដេចកននិងបរិវារ ដែលមានកម្លាំងប្រយុទ្ធចាញ់ប្រៀបគូសត្រូវរបស់ខ្លួន។ ***មិន*** នៅក្នុងវាទរូបនេះ កាលណាអវត្តមាន កិ.១, នាំឱ្យ កិ.២ មានទំនាក់ទំនងផ្ទាល់ជាមួយនឹង ***មិន*** វិញ ហើយវាទរូបនេះនឹងមានអត្ថន័យផ្សេងពីវាទរូប(៣) ខាងលើទៅវិញ។ យើងខ្ញុំសូមលើកជាវាទរូប (៣ក) ដូច្នេះ :

*(៣ក)«...ព្រះស្ដេចកននិងសម្ដេចចៅហ៊្វាកៅមិនតស៊ូទប់ទល់ជាមួយកងទ័ពឧកញ៉ាមហាទេពដែលជាកងទ័ពរបស់ព្រះអង្គចន្ទរាជាទេ»*។

នៅក្នុងវាទរូប (៣) អវិជ្ជមានបទ ***មិន*** គ្មានទំនាក់ទំនង (ដោយផ្ទាល់) ទៅនឹងកិរិយាសព្ទ ***តស៊ូ*** ទេ ព្រោះថា វាទរូប(៣)នេះ មិនមែនចង់ស្ដែងថា ***មិនតស៊ូ*** នោះទេ។ ប៉ុន្តែ វាសបញ្ជាក់ឱ្យឃើញថា ការតស៊ូមិនអាចទប់ទល់បាន ពោលគឺតស៊ូដែរ តែមិនអាចទប់ទល់ឬយកជ័យជម្នះបាន។ ក្នុងន័យនេះហើយ ដែលយើងចង់បង្ហាញថា ***មិន*** គ្មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងកិរិយាសព្ទ ***តស៊ូ***។

ផ្ទុយទៅវិញ នៅក្នុងវាទរូប(៣ក) ***មិន*** មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងកិរិយាសព្ទ ***តស៊ូ*** ហើយតាមរយៈអន្តរកម្មរវាងធាតុទាំងពីរនេះ ( ***មិន*** និង ***តស៊ូ***) វាបានរំលេចចេញនូវអវិជ្ជមានន័យដែលអាចនាំទៅដល់អភិកថាមួយ គឺ *គ្មានការតស៊ូ* ខុសប្លែកទាំងស្រុងពីវាទរូប(៣)។

ដើម្បីឱ្យយល់ច្បាស់ពីភាពខុសគ្នានៃតួនាទីរបស់អវិជ្ជមានបទ ***មិន*** នៅក្នុងវាទរូបទាំងពីរខាងលើនេះ យើងខ្ញុំសូមអនុញ្ញាតលើកយកវាទរូប (៤) និង(៤ក) មកសិក្សាបន្ថែមទៀតដូចតទៅ :

*(៤)«តាំងពីម្ដាយក្មេកកុហកប្ដីនាងមក មាលាមិនហ៊ាននិយាយអ្វីទៀតទេ»* [៣១]។

---

[៣០] រស់ ចន្ត្រាបុត្រ : « ព្រះស្ដេចកន » ភ្នំពេញ បោះពុម្ព លើកទី២ ២០០៣ ទំព័រ១៧៣។

[៣១] បណ្ណាល័យខេមរា : « ម៉ែក្មេកខ្ញុំ » (រឿងរូបភាព) ភ្នំពេញ បណ្ណាល័យ ខេមរា ទំព័រ៩។ (រឿងនេះគ្មានឈ្មោះអ្នកនិពន្ធ និង ឆ្នាំបោះពុម្ពទេ)។

វាទរូបនេះប្រើនៅក្នុងបរិបទមួយដែលម្ដាយក្មេកធ្វើបាបកូនប្រសាស្រីធ្វើឱ្យនាងខ្លបខ្លាចមិនហ៊ាននិយាយស្ដីអ្វីទាំងអស់។

***មិន*** ក្នុងវាទរូបនេះ មានអន្តរកម្មជាមួយនឹង ***ហ៊ាន*** ហើយមានទំនាក់ទំនងដោយប្រយោលទៅនឹងកិរិយាសព្ទ*និយាយ* ។ នេះមានន័យថា មាលាមិននិយាយព្រោះតែខ្លួននាង *មិនហ៊ាន* ដោយសារខ្លាចម្ដាយក្មេក តែមិនមែនមានន័យថា ខ្លួននាងមិននិយាយនោះទេ។ ត្រង់នេះ ខ្ញុំសូមអនុញ្ញាតផ្ដល់ជាវាទរូប(៤ក) ដូច្នេះ :

(៤ក)« *តាំងពីម្ដាយក្មេកកុហកប្ដីនាងមក មាលាមិននិយាយអ្វីទៀតទេ»*។

ជាការពិតណាស់ដែល*មិនហ៊ាននិយាយ* ខុសពី*មិននិយាយ* ដោយហេតុថា*មិននិយាយ* គឺបញ្ជាក់ពីអវត្តមាន នៃ*និយាយ* ដោយជៀបទៅនឹង*វាទករ*[៣២] ដែលមិនបញ្ចេញវាចាថ្លាថ្លែង ហើយប្រការនេះគ្មានទាក់ទងទៅនឹងកត្តាអ្វីផ្សេងទៀតទេ។ ដោយឡែក*មិនហ៊ាននិយាយ* មិនមែនគ្រាន់តែមានន័យថា*មិននិយាយ* នោះទេ តែមានន័យថានិយាយមិនអាចធ្វើទៅបាន ព្រោះ*វាទករ* មិនហ៊ានដោយមានការខ្លាចរអារអ៊ីមួយ។ ប៉ុន្តែ បើគ្មានលក្ខខណ្ឌដែលធ្វើឱ្យខ្លួនខ្លាចនោះទេ *វាទករ* ប្រាកដជានឹងនិយាយមិនខានឡើយ។

**១.៣. សិក្សាពីសំណុំពាក្យដែលរចនាសម្ព័ន្ធទៅមានទម្រង់ កិ.+មិន+ឈ្នាក់**[៣៣]

មុននឹងសិក្សាពីសំណង់ឃ្លាក្នុងទម្រង់នេះ ខ្ញុំសូមជម្រាបថា តាមការសង្កេតនិងស្រាវជ្រាវរបស់យើងខ្ញុំ សំណង់ឃ្លា *កិ.+មិន+∅* ពុំមានឃើញប្រើនៅក្នុងភាសាខ្មែរទេ។ ក្នុងន័យនេះ យើងអាចសន្និដ្ឋានបានថា អវិជ្ជមានបទ ***មិន*** មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងធាតុដែលនៅខាងស្ដាំវា ព្រោះបើគ្មានធាតុខាងស្ដាំនេះ សំណង់ឃ្លាដែលមាន ***មិន*** មិនអាចកើតមានបានទេ។

**១.៣.១_ ឈ្នាក់ជាកិរិយាសព្ទ**

នៅក្នុងសំណង់ឃ្លាដែលមានលក្ខណៈសម្ព័ន្ធ កិ.+មិន+ឈ្នាក់ អវិជ្ជមានបទ *( មិន, ពុំ, ឥត។ល។)* មិនមានយន្តការទៅលើហេតុភេទ *(ព្រឹត្តិ ការណ៍, សកម្មភាព, ស្ថានភាព ។ល។)* ដែលស្ដែងឡើងតាមរយៈកិរិយាសព្ទ *និយាយ* ដែលស្ថិតនៅខាងឆ្វេងវានោះទេ ពោលគឺ វាពុំបញ្ជាក់ពីគោល

---

[៣២]*វាទករ* ប្រើក្នុងនិក្ខេបបទនេះ គឺសំដៅលើអ្នកដែលសរសេរ*វាទរូប (អ្នកនិពន្ធ)* ឬអ្នកដែលពោលបញ្ជាក់អះអាងពីខ្លឹមសារនៃវាចាខ្លួន។

[៣៣]បណ្ឌិត ច័ន្ទ សំណព្វ : ឈ្នាក់ *(អាចជាគុណនាម គុណកិរិយា កិរិយាវិសេស ពាក្យដែលបញ្ជាក់ពីទិដ្ឋភាពបំណែប)* មានតួនាទីបញ្ជាក់អ្វីមួយ*(ធ្វើឱ្យជាក់ច្បាស់)*។ *ឈ្នាក់* មានតួនាទីនៅក្នុងភាសាវិទ្យា តែវាមិនមែនជាបញ្ញត្តិដែលស្ដែងពីមុខងារពាក្យនៅក្នុងវេយ្យាករណ៍នោះទេ។

អរិជ្ជមាន[៣៤] នៃកិរិយាសព្ទ*និយាយ* នោះឡើយ។ ម្យ៉ាងទៀត យើងអាចយល់ឃើញថាអរិជ្ជមានបទមានអន្តរកម្មតែជាមួយ *ឈ្នាក់* ដែលបញ្ជាក់ពីទិដ្ឋភាពនៃធាតុដែលនៅខាងស្តាំរបស់វា ដោយរំលេចចេញជាបំណែកស្រាយមួយដែលមានលក្ខណៈជាតម្លៃអរិជ្ជមាន[៣៥]។ គឺនៅក្នុងន័យនេះហើយដែលយើងចង់សិក្សាពីតួនាទីនៃអរិជ្ជមានបទ ដើម្បីស្វែងយល់ពីអរិជ្ជមានន័យ។

តទៅនេះយើងខ្ញុំសូមលើកយកវាទរូបមួយចំនួនមកសិក្សាដូចតទៅ:

[៣៤] បណ្ឌិត ច័ន្ទ សំណព្វ : គោលអរិជ្ជមាន ជាកម្រៅនៃគោលវិជ្ជមាន ពោលគឺជាគោលដែលប្រឈមទៅនឹងគោលវិជ្ជមាននេះឯង។ ឧទាហរណ៍*មិនទៅ*គោលអរិជ្ជមាន ឬកម្រៅនៃ *ទៅ* ។ ដូចគ្នាដែរ*មិនអាក្រក់* ជាគោលអរិជ្ជមានឬជាកម្រៅនៃ*អាក្រក់*។ ដូច្នេះ គោលអរិជ្ជមានសុទ្ធតែស្តែងឡើងតាមរយៈអរិជ្ជមានកម្ម ពោលគឺតាមទម្រង់អរិជ្ជមាន ប៉ុន្តែវាមិនមែនសុទ្ធតែស្តែងពី អរិជ្ជមានន័យនោះទេ។

[៣៥] បណ្ឌិត ច័ន្ទ សំណព្វ : តម្លៃអរិជ្ជមាន អាចកើតឡើងបានតាមរយៈគោលអរិជ្ជមាននៃឯកត្តាភាសាមួយ បញ្ជាក់ពីអរិជ្ជមានភាពរបស់វា។ ប៉ុន្តែ*តម្លៃអរិជ្ជមាន* នៃឯកតាភាសាមួយមិនមែនសុទ្ធតែស្តែងពីអរិជ្ជមានន័យនោះទេ។ ឧទាហរណ៍ *តម្លៃអរិជ្ជមាន* នៃ*ល្អ* ត្រូវនឹង*អរិជ្ជមានន័យ* តែតម្លៃអរិជ្ជមានន័យនៃ*អាក្រក់* បញ្ជាក់វិជ្ជមានន័យ ។ ត្រង់នេះហើយដែលយើងយល់ដឹងពីវិជ្ជមានន័យឬអរិជ្ជមានបានតែតាមរយៈឯកតាភាសាដែលចូលរួមអន្តរកម្មជាមួយសហបទរបស់វានៅក្នុងយន្តការស្តាបនាន័យ។

*(៥)« ឱ! ប្រទេសណាបើជួបសង្គ្រាមហើយ សង្គមរស់នៅនឹងច្របូកច្របល់ អនាធិបតេយ្យ ពុករលួយ ចៀសមិនផុតឡើយ»* [៣៦]។

វាទរូបនេះ ត្រូវបានដកស្រង់ចេញពីបរិបទមួយដែល វាទករបង្ហាញឱ្យឃើញពីភាពអនាធិបតេយ្យ អំពើពុករលួយដែលបានកើតមានយ៉ាងប្រត្យក្សនៅក្នុងសង្គមក្នុងពេលដែលមានសង្គ្រាមកើតឡើង។

***មិន*** នៅក្នុងវាទរូបនេះមិនមានអន្តរកម្មជាមួយកិរិយាសព្ទដែលនៅខាងឆ្វេងវាទេ តែវាមានទំនាក់ទំនងដោយផ្ទាល់ទៅនឹង ***ផុត***ដែលបញ្ជាក់ពីទិដ្ឋភាពនៃ***ចៀស***។ ដោយសារតែមាន ***មិន*** នេះហើយទើបយើងយល់បានថា ចលាចលដែលបានរៀបរាប់ខាងដើមមុខតែនឹងកើតមានឡើងទោះណាជាគេខំចៀសយ៉ាងណាក៏ដោយ។ ដើម្បីឱ្យយល់ច្បាស់ពីអរិជ្ជមានបទ ***មិន*** នៅក្នុងវាទរូបដែលមានសំណង់ឃ្លា កិ.+មិន+ឈ្នាក់ នេះ យើងពិនិត្យពិចារណាទៅលើវាទរូប(៦) ខាងក្រោមនេះ:

*(៦)«...តាមពិតទៅត្រង់ចំណុចនេះ សូម្បីតែឯកសារពង្សាវតារខ្មែរ ដែលធ្លាប់មានទាំងប៉ុន្មានក៏បានសរសេរមិនចុះសម្រុងនឹងគ្នាដែរ»* [៣៧]។

[៣៦] ព្រាំ ឈាមន្តា : « រាត្រីមួយ » ភ្នំពេញ បោះពុម្ពលើកទី២ ២០០៣ ទំព័រសេចក្តីផ្តើម។

[៣៧] រស់ ចន្ទ្រាបុត្រ : « ព្រះស្តេចកន » ភ្នំពេញ បោះពុម្ព លើកទី២ ២០០៧ ទំព័រ II ។

តាមរយៈវាទរូបនេះ វាទករបានបញ្ជាក់ និងបង្ហាញពីកិច្ចការស្រាវជ្រាវរបស់វៀមច្បងមុនៗ និងសៀវភៅព្រះស្ដេចកននេះ ដែលគ្មានឯកភាពគ្នាចំពោះខ្លឹមសាររបស់ខ្លួនបានសរសេរ។

**មិន** នៅក្នុងវាទរូបនេះ មានទំនាក់ទំនងទៅនឹង***ចុះសម្រុង*** ដែលបញ្ជាក់ពីទិដ្ឋភាពរបស់ *សរសេរ* មានន័យថា បាតុភូតភាសាដែលស្ដែងឡើងតាមរយៈយន្តការរបស់ **មិន** នោះ ពុំបញ្ជាក់ពីបញ្ហា« *សរសេរឬមិនសរសេរ*» នោះទេ (ហេតុនេះ វាមិនបញ្ជាក់ពីគោលអវិជ្ជមានរបស់សរសេរទេ) តែវាបញ្ជាក់ពីបញ្ហា«*សរសេរ*» ដែលទិដ្ឋភាពរបស់វាមិនដូចគ្នា។ ចំណុចនេះសបញ្ជាក់ឱ្យឃើញថា យន្តការរបស់អវិជ្ជមានបទ **មិន** ប្រព្រឹត្ត ទៅនៅក្នុងគោលវិជ្ជមាននៃ «*សរសេរ*» ហើយគ្មានទំនាក់ទំនងផ្ទាល់ទៅនឹង«*សរសេរ*» នោះឡើយ។

នៅក្នុងសំណង់វាទរូបប្រភេទនេះ ធាតុដែលជាឈ្នាក់អាចមានច្រើនប្រភេទខុសៗគ្នាដែលមានជាអាទិ៍ *ផុត បាន ឃើញ*។ល។

ការសិក្សាពីអវិជ្ជមានបទ **មិន** ដែលមានទំនាក់ទំនងទៅនឹងឈ្នាក់ *បាន ឃើញ* ។ល។ មានលក្ខណៈដូចគ្នាទៅនឹងការសិក្សាពី **មិន** នៅក្នុងវាទរូប(៥)(៦)ដែរ។ ហេតុនេះ ដើម្បីចៀសវាងភាពច្រំដែល យើងខ្ញុំមិនធ្វើការវិភាគទៅលើ **មិន** ដូចដែលយើងខ្ញុំបានជម្រាបជូនមកហើយនោះទេ។ ប៉ុន្តែ យើងសាកល្បងរំលេចនូវយន្តការរបស់ **មិន** តាមរយៈការសិក្សាប្រៀបធៀបវាទរូប (៧) (៨) (៩) ខាងក្រោមនេះទៅនឹង (៧ក) (៨ក) (៩ក) ដូចតទៅ ៖

(៧) «*មេទ័ពព្រះចន្ទរាជាទាំងបី ខំប្រឹងវាយលុកឥតប្រណីដៃចូលទៅចាប់ព្រះស្ដេច កន តែចាប់មិនបាន...*»[៣៨]។

វាទរូបនេះ ប្រើនៅក្នុងបរិបទមួយដែលបង្ហាញពីព្រឹត្តិការណ៍ប្រយុទ្ធគ្នាយ៉ាងសកម្ម ដើម្បីចាប់ស្ដេចកន តែមិនបានសម្រេចជាលទ្ធផលឡើយ។

**មិន** នៅទីនេះ មានទំនាក់ទំនងជាមួយ ***បាន*** ដែលបញ្ជាក់ពីទិដ្ឋភាពរបស់កិរិយាសព្ទ ***ចាប់*** ពោលគឺវាបញ្ជាក់ ពីលទ្ធផលនៃ***ចាប់***ដែលតាមរយៈបរិបទនេះមានតម្លៃជាអវិជ្ជមាន។ នៅក្នុងវាទរូប(៧) នេះ ប្រសិនបើគ្មាន **មិន** ទេ នោះយើងនឹងបានឃ្លា (៧ក) ដូច្នេះ ៖

*[៣៩](៧ក) « *មេទ័ពព្រះចន្ទរាជាទាំងបីខំប្រឹងវាយលុកឥតប្រណីដៃ ចូលទៅចាប់ព្រះស្ដេចកន តែចាប់បាន...* »។ ឃ្លានេះមានភាពឆ្គងទាំងនៅក្នុងទិដ្ឋភាពសម្ពន្ធទាំងទិដ្ឋភាពន័យ។ ប្រការ

---

[៣៨] *រស់ ចន្ត្រាបុត្រ ៖ ដ.ឯ.ម. ទំព័រ១៧១។*

[៣៩] សញ្ញា* ដែលដាក់នៅពីមុខឃ្លា បញ្ជាក់ពីភាពខុសឆ្គងនៃឃ្លាឬជាការខ្វះខាតលំនឹងភាពនៃឃ្លា ដែលបានសង់ឡើង។

នេះអាចឱ្យយើងចោទជាសំណួរថា តើបញ្ហាដែលកើតមានឡើងមានទំនាក់ទំនងទៅនឹងអវិជ្ជមានបទយ៉ាងណាខ្លះ? មុននឹងឈានទៅដល់ការវិភាគលើចំណុចនេះ យើងខ្ញុំសូមបញ្ជាក់ថា ភាពគង់ឬភាពគ្មានលំនឹងនៃឃ្លានេះគឺ អាស្រ័យដោយការដាក់ឱ្យមានទំនាក់ទំនងរវាងឃ្លាទីមួយ «*មេទ័ពព្រះចន្ទរាជាទាំងបីខំប្រឹងវាយលុកឥតប្រណីដៃ ចូលទៅចាប់ព្រះស្តេចកន...*» និងឃ្លាទីពីរ «*តែចាប់បាន...*»។ គឺវត្តមាន ***តែ*** នៅក្នុងអវត្តមានភាពនៃ ***មិន*** នេះហើយ ដែលញាំងឱ្យមានបាតុភូតភាសា នេះឡើង។

ប្រសិនបើយើងចង់ឱ្យឃ្លាមានលំនឹងភាពវិញនោះ យើងអាចមានលទ្ធភាពពីរយ៉ាង ពោលគឺ ឬមួយបន្ថែម ***តែ*** ឬមួយបន្ថែមឃ្លាមួយផ្សេងទៀត។

ប្រសិនបើយើងត្រូវជំនួស ***តែ***ដោយ ***ហើយ*** វិញ យើងនឹងបានវាទរូប(៧ខ) ដូចខាងក្រោម:

(៧ខ) «*មេទ័ពព្រះចន្ទរាជាទាំងបី ខំប្រឹងវាយលុកឥតប្រណីដៃ ចូលទៅចាប់ព្រះស្តេចកន ហើយចាប់បាន...*»។ ប្រការដែលយើងបានដក ឬជំនួសធាតុនៅក្នុងឃ្លាឬវាទរូបនេះ គឺដើម្បីស្វែងយល់ពីយន្តការនៃធាតុ ដែលយើងចង់សិក្សា និងចង់រំលេចឱ្យឃើញពីអន្តរកម្មរវាងធាតុនានា ដែលផ្សំបង្កើតជាឃ្លា ឬជាវាទរូបមួយឡើង។

(៨) «*កងទ័ពស្តេចកនទ្រាំទ្រមិនបានដកទ័ពថយចេញទៅជាលំដាប់លំដោយ។ ចៅពញាយមរាជ យកបានមកវិញខេត្តបារាយណ៍ ជើងព្រៃកំពង់សៀម...*»[៦០]។ វាទរូបនេះ បង្ហាញដោយអ្នកពិពណ៌នា ពណ៌នាពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៅក្នុងបរិបទមួយ ដែលអ្នកធ្វើសង្គ្រាមមានអ្នកចាញ់មានអ្នកឈ្នះ។ ***មិន*** នៅទីនេះមានទំនាក់ទំនងជាមួយ ***បាន*** ដែលបញ្ជាក់ពីទិដ្ឋភាពរបស់កិរិយាសព្ទ ***ទ្រាំទ្រ*** ថាតើ ***ទ្រាំទ្រ*** យ៉ាងដូចម្តេច?។ ប្រសិនបើសំណុំពាក្យនៃវាទរូប (៨) នេះអវត្តមាន ***មិន*** យើងនឹងបានសំណុំពាក្យនៃឃ្លា(៨ក) ដូច្នេះ «*...ទ្រាំទ្របាន...*» ដែលវាបង្ហាញពីវិជ្ជមានន័យទៅវិញ។ នៅក្នុងវាទរូប (៧) និង (៨) សហបទរបស់ ***មិន*** មាន (*ចាប់ ទ្រាំទ្រ*និង *បាន*) ដែលយើងអាចធ្វើការពិចារណាបានថា កាលណាអវត្តមាន***មិន***សំណុំពាក្យនៃឃ្លា (៧ក) (៨ក) គឺ«*...តែចាប់បាន...*» និង «*...ទ្រាំទ្របាន...*»។ *បាន*[៦១] នៅពេលនេះ គឺជាកិរិយាសព្ទដែលខុសពី«*...តែចាប់មិនបាន...*»និង«*...ទ្រាំទ្រមិនបាន...*» ដែល *បាន* នៅពេលនេះជា *ឈ្នាក់* ដែលបញ្ជាក់ ពីទិដ្ឋភាពនៃ *ចាប់* ឬ *ទ្រាំទ្រ*។

(៩) «*...ក្នុងគ្រាបាក់ទ័ពនោះ នាម៉ឺនជំនិតស្លាយគ្រាព្រះស្រីជេដ្ឋាបានរត់បែកពីព្រះអង្គចុះ*

---

[៦០] *រស់ ចន្ត្រាបុត្រ: ដ.ឯ.ម. ទំព័រ៧៦។*

[៦១] ចំពោះសេចក្តីពិស្តារ សូមអាន ច័ន្ទ សំណព្វ (១៩៩៧): ការសិក្សាពីយន្តការនៃ ***បាន***ក្នុងភាសាខ្មែរទំនើប។

*មកដល់កណ្ដាលទន្លេខាងកើតមានខ្យល់ព្យុះទូកក៏លិចធ្លាក់ត្រាទៅបាតទន្លេរាវរកមិនឃើញ»*[៤២]។

វាទរូប(៩) វាទករបានបង្ហាញពីហេតុការណ៍ដ៏អាក្រក់មួយរបស់នាម៉ឺនម្នាក់ដែលបានចាក់ទ័ព ហើយធ្វើឱ្យជ្រុះត្រាបាត់ទៀត។ ***មិន*** នៅទីនេះមានទំនាក់ទំនងទៅនឹង***ឃើញ*** និង***រក*** ដែលវាមានតួនាទីយ៉ាងសំខាន់នៅក្នុងការស្ថាបនា អវិជ្ជមានន័យ។ នៅក្នុងវាទរូប (៩) ដដែល ប្រសិនបើអវត្តមាន***មិន*** យើងនឹងបានសំណុំនៃឃ្លាយ៉ាងដូច្នេះ «...*រាវរកឃើញ*...»។ យើងឃើញថា ពេលអវត្តមាន ***មិន*** សំណុំឃ្លានៃវាទរូបនេះមានអត្ថន័យទៅជាវិជ្ជមានន័យទៅវិញ។ សហបទរបស់ ***មិន*** នៅក្នុងវាទរូប(៩)នេះ គឺ ***រក*** និង ***ឃើញ*** ដែលជាពាក្យគួរពិចារណា ព្រោះថា ***ឃើញ*** អាចជាកិរិយាសព្ទផងអាចជាឈ្នាក់ ផង។

«...*រាវរកមិនឃើញ*...» *ឃើញ* នៅពេលនេះ បញ្ជាក់ពីទិដ្ឋភាពរបស់កិរិយាសព្ទ *រក* នាំឱ្យ *ឃើញ* ជាឈ្នាក់។ «...*រាវរកឃើញ*...» *ឃើញ* និង *រក* ផ្សំគ្នា បង្កើតបានជាកិរិយាសព្ទមួយ។

(១០) «... *ទឹកភ្នែករលៀមសាយខ្វាយលាបលនដែនថ្ពាល់ចាំងចោលព្រាល។ស្ទើរមើលមិនឃើញ»*[៤៣]។

វាទរូបនេះ វាទករបង្ហាញពីការរត់គេចខ្លួនពីកងសន្តិសុខដែលបម្រុងនឹងចាប់ខ្លួនគាត់នៅពេលរៀបនឹងឃ្លាតឆ្ងាយពីបងប្រុស ដែលបានជូនដំណើរដល់ចំណុចត្រូវបែកគ្នា។ *មិន*នៅទីនេះមានទំនាក់ទំនងនឹង*ឃើញ* និង*មើល* ដែលមានតួនាទីក្នុងការស្ថាបនាអវិជ្ជមានន័យ។

នៅក្នុងវាទរូប(១០)នេះ ប្រសិនបើ គ្មាន *មិន* យើងនឹងបានវាទរូបថ្មីមួយ គឺ «...*ស្ទើរមើលឃើញ*...» ដែលមានអត្ថន័យជាវិជ្ជមានន័យវិញ។

អ្វីដែលផ្ដល់ជាការលំបាកដល់ការស្រាវជ្រាវរបស់យើងនាពេលនេះ មិនមែនគ្រាន់តែការវិភាគទៅលើយន្តការរបស់ *មិន* តែប៉ុណ្ណោះទេ តែមានបញ្ហាជាច្រើនដែលត្រូវបំភ្លឺជុំវិញមុខងារ និងតួនាទីរបស់សហបទនៃ *មិន* ទៀត។ ជាក់ស្ដែង យើងមានចម្ងល់ថា តើ*ឃើញ* មានប្រភេទពាក្យជាអ្វី និងមានតួនាទីយ៉ាងដូចម្ដេចខ្លះ បើធៀបទៅនឹង *មើល* នោះ។

តាមទស្សនៈសាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ មានករណីពីរដែលយើងគួរពិភាក្សា- ទីមួយ *ឃើញ* ជាឈ្នាក់ដែលបញ្ជាក់ពីទិដ្ឋភាពរបស់ *រក* ដែលជាកិរិយាសព្ទ។ ក្នុងក្របខ័ណ្ឌនេះ អវិជ្ជមានបទ *មិន* គ្មានអន្តរកម្មជាមួយ*មើល* ទេ ប៉ុន្តែវាគ្រាន់តែមានអន្តរកម្មជាមួយ *ឃើញ* តែប៉ុណ្ណោះ។

---

[៤២] រស់ចន្ទ្រាបុត្រ: ដ.ឯ.ម. ទំព័រ១៦៦។

[៤៣] វែហម ត្រីស្នា: «ទោសអស់ជីវិត» ភ្នំពេញ ២០០០ទំព័រ១០។

_ទីពីរ *ឃើញ* អាចជាកិរិយាសព្ទស្ថិតក្នុងសំណង់មួយដែលជាទំនាក់ទំនងទៅនឹងប្រធាន រួមជាមួយកិរិយាសព្ទ *រាវ* ។ ក្នុងក្របខ័ណ្ឌនេះ យើងផ្តល់ជាអភិកថា ថា គេរាវរក...តែគេមិនឃើញ។

**១.៣.២_ឈ្នាក់ជាធាតុមួយដែលជាគុណកិរិយា/កិរិយាវិសេសន៍ ហើយវេយ្យាករណ៍ប្រពៃណីហៅថាគុណនាម**

ការសិក្សាខាងក្រោមនេះ ជាការសិក្សាពីអវិជ្ជមានបទ *មិន* នៅក្នុងវាទរូបមួយផ្សេងពីការសិក្សាខាងលើ។ គឺជាការសិក្សាពីអវិជ្ជមានបទ *មិន* ដែលមានទំនាក់ទំនងជាមួយនឹងធាតុដែលវេយ្យាករណ៍ប្រពៃណីយល់ថាជា គុណនាម ហើយធាតុនោះចារឹកនៅក្នុងអន្តរកម្មជាមួយនឹងកិរិយាសព្ទ ឬនាមសព្ទនៅខាងឆ្វេង *មិន* រំលេចបាននូវ អវិជ្ជមានន័យ។ ប៉ុន្តែ ប្រសិនបើគ្មាន *មិន* វិញនោះ វាទរូបប្រភេទនេះ បែរជាស្តែងពីវិជ្ជមានន័យទៅវិញ។ យើងលើកយកទម្រង់វាទរូបដែលមានរចនាសម្ព័ន្ធដូចខាងលើមកសិក្សាដើម្បីស្វែងយល់អវិជ្ជមានបទ *មិន* និងធាតុនៅជុំវិញវា ហើយដែលមានទំនាក់ទំនងនឹងគ្នាទៅវិញទៅមក។

(១១)*«...បើដំបូកនោះវិចរឹល ចៅហ្វាយខេត្តមានទុក្ខព្រួយដោយការងារនគរដើរមិនល្អ ឬដោយសារមានកើតជំងឺពេញស្រុក បើដំបូកនោះប្រេះបែកក្រហែង ចៅហ្វាយខេត្តត្រូវអស់បុណ្យ ឬត្រូវស្លាប់...»* [៤៤]។

វាទរូបនេះ បង្ហាញពីអក្ខតហេតុចម្លែកៗ ដែលកើតមានពីដំបូក ហើយមានជាប់ទាក់ទងទៅនឹងបុណ្យស័ក្តិរបស់ចៅហ្វាយខេត្ត។ វាទរូប (១១)នេះ ប្រសិនបើគ្មាន *មិន* យើងនឹងបានឃ្លា (១១ក) យ៉ាងដូច្នេះ :

*(១១ក)*«...បើដំបូកនោះវិចរឹល ចៅហ្វាយខេត្តមានទុក្ខព្រួយដោយការងារនគរដើរល្អ ឬដោយសារមានកើតជំងឺពេញស្រុក បើដំបូកនោះប្រេះបែកក្រហែងចៅហ្វាយខេត្តត្រូវអស់បុណ្យ ឬត្រូវស្លាប់...»*។ យើងឃើញថា ឃ្លា(១១ក)នេះ មានលក្ខណៈខុសឆ្គងទាំងផ្នែកសម្ព័ន្ធនិងទិដ្ឋភាពន័យ ព្រោះថា ផ្នែកទី១នៃឃ្លា (*...បើដំបូកនោះ វិចរឹល ចៅហ្វាយខេត្តមានទុក្ខព្រួយ* ) ត្រូវបានភ្ជាប់ទៅនឹងផ្នែកទី២នៃឃ្លា ( *ដោយការងារនគរដើរល្អ* ) តាមរយៈ *ដោយ* ហើយអ្វីដែលរំខានដល់ផ្នែកន័យនោះ គឺដោយសារតែទំនាក់ទំនងនៃផ្នែកទាំងពីរនៃឃ្លាមានលក្ខណៈមិនសមស្រប។ ប្រការនេះមកពីសំណុំពាក្យ *ការងារ* មិនអាចជាសហបទនៃសំណុំពាក្យ *ចៅហ្វាយខេត្តមានទុក្ខព្រួយ* នោះទេ ដោយហេតុថា *ដំណើរការនគរល្អ* មិនអាចជា

---

[៤៤] *សេចក្តីប្រាប្រុក្រ* : ជ.ឯ.ម. ទំព័រ១១៣។

មូលហេតុនៃទុក្ខព្រួយរបស់ចៅហ្វាយខេត្តឡើយ។ ហេតុដូច្នេះហើយបានជា *មិន* មានសារៈសំខាន់នៅក្នុងការបង្កើតឱ្យមានស្ថិរភាពផ្នែកន័យ ដូចមានវាទរូប(១១)បញ្ជាក់ស្រាប់។ ម្យ៉ាងទៀត បើយើងចង់ធ្វើឱ្យមានស្ថិរភាពផ្នែកន័យ ដោយរក្សាទុកនូវសំណុំពាក្យ *ដំណើរការនគរដើរល្អ* វិញនោះគេត្រូវតែប្តូរឬជំនួសធាតុ *សកម្មិចរិល*ដោយ *ដុះដាលឡើងខ្ពស់វិញ* គេនឹងបានវាទរូប(១១ខ)ដូចខាងក្រោម :

*(១១ខ)«...បើដំបូកនោះដុះដាលខ្ពស់ឡើងៗ ចៅហ្វាយខេត្តនឹងបានសុខសប្បាយ ដោយការងារនគរដើរល្អ...»*។ តាមរយៈវាទរូប (១១) (១១ក) និង (១១ខ) យើងអាចយល់បានថា អវិជ្ជមានបទ *មិន* មានតួនាទីយ៉ាងសំខាន់នៅក្នុងការកសាងអវិជ្ជមានន័យឬវិជ្ជមានន័យនៅក្នុងវាទរូបនីមួយៗ។ ព្រោះថាកាលណាអវត្តមាន *មិន* ធ្វើឱ្យទិដ្ឋភាពន័យ និង ទិដ្ឋភាពសម្ព័ន្ធនៃវាទរូបនីមួយៗមានការផ្លាស់ប្តូរដូចករណីខាងលើជាឧទាហរណ៍ស្រាប់។ សូមមើលវាទរូប (១២) ដូច ខាងក្រោម :

(១២) « ... *ប្រកពមិនដូវការមួយបាននិយាយថា...»*[៤៥]។

វាទរូបនេះបង្ហាញនូវព័ត៌មានដែលវាទករចង់ប្រាប់ទៅដល់អ្នកអាន។ *មិន* នៅក្នុងវាទរូបនេះមិនមានទំនាក់ទំនងជាមួយនឹងប្រកពទេ ប៉ុន្តែវាមានទំនាក់ទំនងទៅនឹង *ដូវការ* ដែលបញ្ជាក់លក្ខណៈឱ្យ *ប្រកព* គឺថា *ប្រកព* នោះយ៉ាងដូចម្តេច?។ ប្រសិនបើយើងដក *មិន* ចេញនោះវាទរូប(១២) នឹងទៅជា «... *ប្រកពដូវការមួយបាននិយាយថា...»*[៤៦] វាទរូបនេះជាវិជ្ជមានន័យដែលព័ត៌មានពេលនេះក្លាយទៅជាព័ត៌មានមានន័យស្របច្បាប់វិញ។ ដូច្នេះ តួនាទីរបស់ *មិន* នៅក្នុងល្បះមានសារៈសំខាន់ខ្លាំងណាស់ក្នុងការប្តូរអត្ថន័យរបស់វាទរូបនីមួយៗ។ សូមមើលវាទរូប (១៤) ដូចខាងក្រោម :

(១៣)*«ឱ!ចែកុំរកពេទ្យ! ពេទ្យគេមើលមិនពូកែ ដូចគ្រូខ្មែរទេ »*[៤៧]។

វាទរូបនេះបង្ហាញនូវពាក្យសម្តីរបស់ស្ត្រីម្នាក់បានណែនាំស្ត្រីម្នាក់ទៀតកុំឱ្យជឿលើគ្រូពេទ្យសម័យ គឺនិយាយឱ្យគាត់(ចែ) ជឿលើគ្រូខ្មែរវិញ។ វាទរូបនេះ ប្រសិនបើគ្មាន *មិន* យើងនឹងបានឃ្លា (១៣ក) ដូច្នេះ :

*(១៣ក) *«ឱ!ចែកុំរកពេទ្យ! ពេទ្យគេមើលពូកែដូចគ្រូខ្មែរទេ»*។ ឃ្លានេះមានភាពផ្ទុយគ្នាទាំងទិដ្ឋភាពសម្ព័ន្ធ និង ទិដ្ឋភាពន័យ នៅពេលដែល

---

[៤៥]កោះសន្តិភាព លេខ៦១៣៦ ថ្ងៃពុធ ទី៥ ខែកញ្ញា ឆ្នាំ២០០៧ ទំព័រ១_៥។

[៤៦] ***ដូវការ*** នៅពេលនេះ គឺជា *គុណនាម* ដែលបញ្ជាក់លក្ខណៈឱ្យ ***ប្រកព*** ដែលជា *នាម*។

[៤៧] នូ ហាច : ដ.ឯ.ម. ទំព័រ១១១។

អវត្តមាន *មិន* ធ្វើឱ្យន័យនិងទម្រង់ឃ្លាមានការផ្លាស់ប្តូរ។ ប្រសិនបើយើងធ្វើការផ្លាស់ប្តូរធាតុខ្លះនៅក្នុងផ្នែកទី១ យើងនឹងបានវាទរូបដូចខាងក្រោម :

*(១៣១) « នីរ៉ែ ចូរទៅរកពេទ្យ ! ពេទ្យគេមើលពូកែជាងគ្រូខ្មែរ»* ។

*វាទរូប(១៣១)* យើងសង្កេតឃើញថា មានភាពត្រឹមត្រូវទាំងទិដ្ឋភាពសម្ព័ន្ធទាំងទិដ្ឋភាពន័យ។ ដូច្នេះយើងអាចបញ្ជាក់បានថា នៅក្នុង*វាទរូប*ដែលមានអវិជ្ជមានបទ *មិន* ដូចខាងលើមានតួនាទីសំខាន់នៅក្នុងការស្ថាបនាន័យនិងសម្ព័ន្ធ។

*សូមមើលវាទរូប(១៤)* ដូចខាងក្រោម:

*(១៤) « ទេ តាប្រាក់មិនប្រឡាំទេ។ បើពុំនោះ តើគេនឹងតាំងគាត់ជាដង្វៅដើរព្រៃឯណាបាន!»*[៤៤] ។ នៅក្នុង*វាទរូប(១៤)*នេះ បង្ហាញពីមតិគាំទ្រ និងជឿជាក់ទៅលើសមត្ថភាពដើរព្រៃរបស់តាប្រាក់។

*មិន* នៅក្នុង*វាទរូប*នេះ មានទំនាក់ទំនងទៅនឹង *ប្រឡាំ* ដែលបញ្ជាក់លក្ខណៈឱ្យ *តាប្រាក់* ថា តើ *តាប្រាក់*គាត់យ៉ាងដូចម្តេច? គឺ *តាប្រាក់ គាត់មិនប្រឡាំទេ* នាំឱ្យ*វាទរូប* (១៤) នេះរំលេចចេញនូវវិជ្ជមានន័យ។ ម្យ៉ាងវិញទៀត ប្រសិនបើ *វាទរូប* (១៤)នេះគ្មាន *មិន*យើងនឹងបានឃ្លា(១៤ក) ដូច្នេះ:

**(១៤ក)« ទេ តាប្រាក់ប្រឡាំទេ។ បើពុំនោះ តើគេនឹងតាំងគាត់ជាដង្វៅដើរព្រៃឯណាបាន! »*។

យើងឃើញថាឃ្លា * *(១៤ក)* ពេលនេះ *ប្រឡាំ* មានទំនាក់ទំនងជាអន្តរកម្មជាមួយនឹង *តាប្រាក់*។ ប៉ុន្តែ ឃ្លា**(១៤ក)* នេះច្គងនៅពេលមានផ្នែកទី២នៃឃ្លា *(បើពុំនោះ តើគេនឹងតាំងគាត់ជាដង្វៅដើរព្រៃឯណាបាន!)*។ ប្រសិនបើយើងមិនយកផ្នែកទី២ ដែលជាសហបទនៃឃ្លានេះមកភ្ជាប់ជាមួយ*ទេ*យើងនឹង បាន*វាទរូប(១៤១)* ដូច្នេះ:

*(១៤១)« ទេ តាប្រាក់ប្រឡាំទេ »* *វាទរូប*នេះមានអត្ថន័យផ្ទុយពី*វាទរូប (១៤)* ទាំងស្រុង។ បានសេចក្តីថា កាលណាអវត្តមាន *មិន* *វាទរូប(១៤១)*នេះ ក្លាយទៅជាវិជ្ជមានន័យទៅវិញ។

*សូមមើលវាទរូប(១៥)* ដូចខាងក្រោម

*(១៥) « ព្រាហ្មណ៍បុរោហិតដែលយល់ការណ៍មិនស្រួល ចាប់ផ្តើមបកស្រាយ សុបិន នោះ ទៅតាមចំណង់ចំណូលចិត្តស្តេចកន...»*[៤៥] ។

*វាទរូប*នេះបង្ហាញឱ្យឃើញថា ព្រាហ្មណ៍បុរោហិត បានយល់ពីចំណង់ចំណូលចិត្តស្តេចកន ក៏បកស្រាយសុបិនបំភ្លៃ ទៅតាមសភាពជាក់ស្តែង ពីព្រោះ បើនិយាយបកស្រាយតាមក្បួនតម្រាត្រូវស្លាប់ខ្លួន។

---

[៤៤] នូ ហាច : ដ.ឯ.ម. ទំព័រ១៤៦។

[៤៥] *រស់ ចន្ត្រាបុត្រ : ដ.ឯ.ម. ទំព័រ៩៤*។

*មិន* នៅពេលនេះ មានទំនាក់ទំនងជាមួយ*ស្រួល* ដែល*ស្រួល* បញ្ជាក់លក្ខណៈឱ្យ*យល់ការណ៍* គឺ*យល់ការណ៍មិនស្រួល*។ វាទរូបនេះប្រសិនបើគ្មាន*មិន*យើងនឹងបានឃ្លា(១៥ក)ដូច្នេះ :

*(១៥ក) « *ព្រាហ្មណ៍បុរោហិតដែលយល់ការណ៍ស្រួល ចាប់ផ្ដើមបកស្រាយសុបិននោះទៅតាមចំណង់ចំណូលចិត្តស្ដេចកន...* »។

ឃ្លានេះ កាលណា *ស្រួល*មានទំនាក់ទំនងផ្ទាល់ជាមួយ *យល់ការណ៍* នាំឱ្យថ្កាំថ្កូងនូវទិដ្ឋភាពសម្ព័ន្ធនិងទិដ្ឋភាពន័យ។ ប្រការនេះ ប្រសិនបើយើងដក*ស្រួល* ចេញ យើងនឹងបានវាទរូប(១៥ខ) ដូច្នេះ :

(១៥ខ) « *ព្រាហ្មណ៍បុរោហិតដែលយល់ការណ៍ ចាប់ផ្ដើមបកស្រាយសុបិននោះទៅតាមចំណង់ចំណូលចិត្តស្ដេចកន...* »។

វាទរូបនេះ មានលក្ខណៈត្រឹមត្រូវទៅតាមទិដ្ឋភាពសម្ព័ន្ធនិងទិដ្ឋភាពន័យព្រោះតែគ្មាន*ស្រួល* នៅក្នុងវាទរូបបែបនេះ។

ដូចយើងបានឃើញស្រាប់ហើយ តាមរយៈឧទាហរណ៍ខាងលើ *មិន* មានតួនាទីសំខាន់ខ្លាំងណាស់នៅក្នុងវាទរូបនីមួយៗ។ វាទរូបខាងលើនេះ កាលណាគ្មាន *មិន* មានភាពច្របូកច្របល់ទាំងផ្នែកន័យនិងទាំងផ្នែកសម្ព័ន្ធ។

**គន្ថនិទ្ទេស**

ច័ន្ទ សំណព្វ : វាក្យស័ព្ទនាម ក្នុងទស្សនាវដ្ដី សង្គមសាស្ត្រ-មនុស្សសាស្ត្រ លេខ៤៦ ឆ្នាំ៣៤ ខែមករា កុម្ភៈ មីនា ឆ្នាំ២០០៤ ទំព័រ១២-១៥។

ច័ន្ទ សំណព្វ : ផ្នែកមួយនៃអក្ខរាវិរុទ្ធខ្មែរ ក្នុងទស្សនាវដ្ដី សង្គមសាស្ត្រ-មនុស្សសាស្ត្រ លេខ៥៥ ឆ្នាំ៣៦ ខែមេសា-ឧសភា-មិថុនា ឆ្នាំ២០០៦ទំព័រ៧ស្ទួន-១៤។

ច័ន្ទ សំណព្វ : ធាតុនៃវេយ្យាករណ៍ ដែលប្រើសម្រាប់បង្កើតពាក្យក្នុងភាសាខ្មែរ ក្នុងទស្សនាវដ្ដី សង្គមសាស្ត្រ-មនុស្សសាស្ត្រ លេខ៥៨ ឆ្នាំ៣៧ ខែមករា កុម្ភៈ មីនា ទំព័រ២៤-៣២។

ច័ន្ទ សំណព្វ : ការបង្កើតពាក្យ កម្ចីពាក្យ បម្រើបម្រាស់ពាក្យ (ឯកសារផ្ទៃក្នុង ដេប៉ាតឺម៉ង់ភាសាវិទ្យា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ) ២០០៨ ៨៨ទំព័រ។

ច័ន្ទ សំណព្វ : សំណេរនិងអក្ខរាវិរុទ្ធក្នុងយន្តការនៃការស្ថាបនាន័យ ហ្វូណន២០០៨ ១១២ទំព័រ។

ព្រុំ ម៉ល់ : មូលដ្ឋាននៃសង្គមភាសាវិទ្យា ភ្នំពេញ ២០០៣ ៣៩ទំព័រ។

ព្រុំ ម៉ល់ : មូលដ្ឋាននៃសូរវិទ្យា សទ្ទតាវិទ្យា និង វិជ្ជាសន្ទាន ភ្នំពេញ ២០០៣ ៨៤ទំព័រ។

ព្រុំ ម៉ល់ : មូលដ្ឋាននៃន័យកម្មវិទ្យាទូទៅ. ភ្នំពេញ ២០០៣ ៥៣ទំព័រ។

ពុទ្ធសាសនបណ្ឌិត្យ : វចនានុក្រមខ្មែរ. បោះពុម្ពគ្រាទី៥. ភ្នំពេញ. ឆ្នាំ១៩៦៧-៦៨។

វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា : វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ. ភ្នំពេញ. ២០០៥។

ការសែតកោះសន្តិភាព ឆ្នាំ២០០៧ លេខ៦១៣៦។

CHAN Somnoble/ Identit et variation des units de langue : tude dune srie dunits lexico-gramaticales du khmer contemporain/ thse de doctorat du nouveau rgime/ universit de Paris x-Nanterre/2002.

CHAN Somnoble/ Linguistique applique : systmatique des emplois de tw en khmer comtemporain/ mmoire de DEA/ Universit de Paris x-Nanterre/1998.

CHAN Somnoble/ Etude du fonctionnement de ba:n en khmer contemporain/ mmoire de Matrise/ Universit de Paris x- Nenterre/1997.

# អន្តបទ /_ម_/ នៅក្នុងភាសាខ្មែរទំនើប

**Infix /-m-/ in the Modern Khmer Language**



លោក **វង្ស មេង**
បេក្ខជនបណ្ឌិតផ្នែកភាសាវិទ្យា
នៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

សាស្ត្រាចារ្យ ព្រុំ ម៉ល់ បានគូសបញ្ជាក់ថា អន្តបទ /-ម-/ តាងរូបសព្ទដែលអាចប្រែជាកាឡូរូបសព្ទផ្សេងៗ គឺអាចចេញជា[-អ ់ម-],[-អិ ់ម-], ជា [-អ៊ិ ់ន-],...ទៅតាមករណី។[៥០] ចំណែក លោក ហ្វីលីព ណ័រមែន ជេនន័របានបង្ហាញថា អន្តបទ /-ម-/ មានកាឡូរូបសព្ទដែលមានការផ្លាស់ប្តូរស្ថិតនៅក្នុងទម្រង់ដូចជា **ញាញ់-ប្រមាញ់ ញីក-ប្រមឹក**។ នេះមានន័យថា /-រម-/ គឺជាកាឡូរូបសព្ទរបស់ /-ម-/។ លើសពីនេះ លោកបានបន្ថែមទៀតថា អន្តបទ នេះប្រើបានតែជាមួយ ព្យញ្ជនៈ ***ប គ ជ ច ក រ ល ស*** និងកន្សោមព្យញ្ជនៈ ***ផ ភ ធ ឈ ខ ឃ***។ លោកបានបន្តទៀតថា អន្តបទនេះបែកចេញជាពីរក្រុម គឺនាមភ្នាក់ងារ និង នាមលទ្ធផល។[៥១] ចំណែកលោកស្រី ជូឌីត ចាកុប បានបែងចែកមុខងារវេយ្យាករណ៍របស់អន្តបទនេះជាពីរក្រុម គឺនាមភ្នាក់ងារនិងហេតុកិរិយា។[៥២] រីឯលោក សៀល័រ វិញបានចែកមុខងារអន្តបទ /-ម-/ ជាបីផ្នែក គឺ: ទីមួយអន្តបទ /-ម-/ បង្កើតនាមសព្ទដែលភាគច្រើន គឺជានាមអរូបី,ទីពីរ អន្តបទ/-ម-/ បង្កើតហេតុកិរិយានិងសកម្មកិរិយា និងទីបីអន្តបទ/-ម-/ បង្កើតនាមភ្នាក់ងារពីកិរិយាសព្ទ។[៥៣] ដោយឡែក លោក អៀវ កើស វិញ លោកបានពិពណ៌នាថា

---

[៥០] ព្រុំ ម៉ល់ ***ភាសាវិទ្យាអនុវត្តន៍ : វេយ្យាករណ៍ទម្រង់និយមនៃភាសាខ្មែរទំនើប***ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ ទំព័រ៧។

[៥១] See: Philip Norman Jenner, ***Affixation in Modern Khmer***, Michigan: University Microfilms, Inc., Ph.D. dissertation, 1969, p.144-147.

[៥២] Judith M. Jacob, ***Cambodian Linguistics, Literature, and History***, David A. Smyth (ed.), University of London, pp.14-15.

[៥៣] Eric Schiller, "Khmer Nominalizing and Causativizing infixes" in ***SEALS II: papers from the 2nd meeting of the Southeast Asian Linguistics Society***, 1992, pp. 309-326.

អន្តបទ/-ម-/ អាចបង្កើតពាក្យកម្លាយជានាមសព្ទ កិរិយាសព្ទ និងគុណនាម។[៥៤]

ជាសរុប យើងអាចបែងចែកមុខងារវេយ្យាករណ៍អន្តបទ /-ម-/ ជាប្រាំប្រភេទ ដោយផ្អែកលើការវិភាគទិន្នន័យនៃអន្តបទចំនួនបួនរយមេពាក្យ។ ប្រភេទទាំងប្រាំនោះ គឺនាមភ្នាក់ងារ នាមសម្គាល់លទ្ធផលហេតុកិរិយា គុណនាមនិងកិរិយាវិសេសន៍។

**១.កាឡារូបសព្ទរបស់អន្តបទ** /-ម-/

លោកជែន ន័រ និងអ្នកស្រី ជូឌីត ចាកុប បានចាត់ទុកថា /-រម-/ជាកាឡារូបសព្ទ /-ម-/ ។[៥៥] រីឯសាស្ត្រាចារ្យ ព្រុំ ម៉ល់ បង្ហាញថាអន្តបទ/-ម-/ អាចមានកាឡារូបសព្ទ[-អ៌ម-], [-អ៊ិ៌ម-], [-អ៊ិ៌ន-] ។[៥៦]

ទាក់ទងទៅនឹងបញ្ហានេះលោកស្រី មី ច័ន្ទ បានពិពណ៌នាថា អន្តបទ /-ម-/ ត្រូវបញ្ចូលនៅក្នុងពាក្យបន្ទាប់ពីព្យញ្ជនៈទីមួយខាងស្តាំ ហើយនៅខណៈពេលដែលក្រុមព្យញ្ជនៈ «៣៣៣» មិនអាចកើតមានឡើងនោះ ស្រៈដែលត្រូវបញ្ចូលអាចជា [អ៌] ឬ [អ៊ិ៌] ទៅតាមក្រុមព្យញ្ជនៈ ពួក «អ» ឬ «អ៊ិ»ពួក ។[៥៧] អាស្រ័យហេតុនេះ អន្តបទ /-ម-/ ក្លាយជា [-អ៌ម-], [-អ៊ិ៌ម-] ទៅតាមបរិបទ។ លោកស្រី បានបន្តទៀតថា អន្តបទ /-ម-/ មានបញ្ជិកាពីរប្រភេទ គឺបញ្ជិកាបង្រួម (Constricted register) និងបញ្ជិកាពង្រីក (Expanded register)។ បញ្ជិកាបង្រួមមានឧទាហរណ៍ដូចជា : សូម>ស្មូម ,ចាំ > ច្មាំ, ច្លាក់ > ចម្លាក់, ច្បាំង > ចម្បាំង។ ចំណែកឯបញ្ជិកាពង្រីកមានឧទាហរណ៍ ដូចជា : លោក > ល្មោក, ដូញ > ឈ្មួញ, ឈ្លើយ ជម្លើយ, គ្រប់> គម្រប់, ខ្ជិល > កម្ជិល។

**២.មុខងារវេយ្យាករណ៍អន្តបទ** /-ម-/

**២.១. អន្តបទ / _ម_/សម្រាប់បង្កើតនាមភ្នាក់ងារ**

អន្តបទនេះ អាចបង្កើតនាមភ្នាក់ងារពីកិរិយាសព្ទបួស។

ឧ. ដឹក > ប្រមឹក, បាញ់ >ប្រមាញ់, ដើរ > ថ្មើរ, ចាំ > ច្មាំ, កាន់ > ខ្មាន់, សូម > ស្មូម។

---

[៥៤] សូមមើល : អៀវ កើស ***ភាសាខ្មែរ (ការល្បងពិនិត្យ ដោយរកហេតុផល)***បោះពុម្ពផ្សាយឡើងវិញដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ : រោងពុម្ពមិត្តភាពកម្ពុជា_ជប៉ុន ១៩៩៥ ទំព័រ ១៩៦_១៩៧។

[៥៥] Philip Norman Jenner, Affixation in Modern Khmer, op-cit., p. 144; and Judith M. Jacob, Cambodian Linguistics, Literature, and History, op-cit., p.66.

[៥៦] ព្រុំ ម៉ល់ ***ភាសាវិទ្យាអនុវត្តន៍: វេយ្យាករណ៍ទម្រង់និយមនៃភាសាខ្មែរទំនើប***ដ.ឯ.ម. ទំព័រ៧។

[៥៧] See: Marjory Meechan, ***Register in Khmer: The Laryngeal Specification of Pharyngeal Expansion***, M.A. thesis, Canada: University of Ottawa, 1992, pp.6-7. *(The /-m-/ is infixed into the word right after the first consonant. Where the /-m-/ infix would result in a non-permitted cluster, a 'restricted di-syllabe' is created involving the insertion of an epenthetic vowel. In the examples above, this vowel can occur as either [ù] or [ ] depending on its register. In words where the vowel of the base is in the constricted register, this vowel occurs in constricted register ([ ]). In words where the vowel of the base is n the expanded register, this vowel appears as either constricted ([ ]) or expanded register ([ù]) depending on the nature of the consonant intervening between the epenthetic vowel and the base vowel. If the consonant is voiceless or glottalized, the epenthetic vowel remains in constricted register. If the consonant is a sonorant the epenthetic vowel is realizêd in expanded register.)*

**២.២. អន្តបទ /-ម-/ សម្រាប់បង្កើតនាម លទ្ធផល**

អន្តបទ /-ម-/ បង្កើតនាមលទ្ធផលពីកិរិយាសព្ទឫសនិងគុណនាម។

ឧ. ក្រ > កម្រ, ខឹង > កំហឹង, ចូាយ > ចម្ងាយ, ជ្រក > ជម្រក, ផ្លាប់ > ទម្លាប់។

**២.៣. អន្តបទ /-ម-/ សម្រាប់បង្កើត ហេតុកិរិយា**

អន្តបទ /-ម-/ បង្កើតហេតុកិរិយាពីកិរិយាសព្ទឫសនិងគុណនាម។

ឧ. តិះ > ត្មិះ, លើស > ល្មើស, ចក់ > ច្មក់, ខ្ចាត់ > កម្ចាត់, ត្រង់ > តម្រង់, ក្ដៅ > កម្ដៅ, ខ្ទេច > កម្ទេច, ឈ្នះ > ជម្នះ, ជ្រាប > ជម្រាប, ត្រិះ > តម្រិះ។

**២.៤. អន្តបទ /-ម-/ សម្រាប់បង្កើត គុណនាម**

អន្តបទ /-ម-/ បង្កើតគុណនាមពីគុណនាមឫស ហើយគុណនាមកម្លាយពិពណ៌នាគុណនាមឫសឱ្យមានលក្ខណៈទូលំទូលាយនិងច្បាស់លាស់ឡើងថែមទៀត។

ឧ. លឿង > ល្មឿង[៥៨], សេញ > ស្មេញ[៥៩], សុយមុំយ ស្រមុំយ ឬស្មុយ[៦០]។

**២.៥. អន្តបទ /-ម-/ សម្រាប់កិរិយាវិសេសន៍**

អន្តបទ /-ម-/ បង្កើតកិរិយាវិសេសន៍ពីគុណនាមឫស

ឧ. ខ្វំរ > កម្វរ, ក្លា > កម្លា, ត្រង់ > តម្រង់, ត្រូវ > តម្រូវ, ស្ងុង > សម្ងុង។

[៥៨] ល្មឿង មាននៅក្នុងវចនានុក្រមខ្មែររបស់ពុទ្ធសាសនបណ្ឌិត្យ ហើយ ល្មឿង នេះគឺជាគុណនាម ដោយមានន័យថា «ដែលមានសម្បុរលឿង លាយ ចម្រុះដោយខៀវច្នុះលើប ឧ. សម្បុរខៀវល្មឿង។» សូមមើល : *វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ វចនានុក្រមខ្មែរ ភាគ ១ ភាគ ២* ១៩៦៧_៦៨ ភ្នំពេញ រោងពុម្ពកម្ពុជា ទំព័រ១១៤១។

[៥៩] ស្មេញឬស្មិញ គុ. ល្អិតញ៉ិកសិញ ឧ. ល្អិតស្មេញ។ ដដែល ទំព័រ១៤៦០។

[៦០] ស្មុយ គុ. ស្រមុយ, សុយមុំយ ដែលឡើងស្មូញមិនលើង, មិនស្អាត ស្រពោនស្រពាប់ ឧ. ពុកចង្កាស្មុយ, មុខស្មុយ។ ដដែល ទំព័រ១៤៥៩។

# ស្ថានីយបន្ទាយគូនៅកម្ពុជានិងវៀតណាម



លោក **ផុយ ចាន់ធួន**
បេក្ខជនបណ្ឌិតផ្នែកបុរាណវិទ្យា
នៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

អ្វីជាស្ថានីយបន្ទាយគូ? «**បន្ទាយគូ**» ពាក្យនេះត្រូវបានអ្នកស្រុកនៅតំបន់ដីក្រហម ភាគខាងកើតទន្លេមេគង្គបានស្គាល់និងនិទានត។ គ្នាវៀងរហូតមកអ្នកខ្លះហៅថា «បន្ទាយគូ» មួយចំនួនទៀតហៅថា «គូ» ឬ «បន្ទាយបរមបុរាណ»។ ពាក្យ «បន្ទាយគូ» «គូ» «បន្ទាយបរមបុរាណ» បានធ្វើការស្រាវជ្រាវជាលើកទីមួយ តាមរយៈរបាយការណ៍ របស់ក្រុមហ៊ុនចម្ការកៅស៊ូបារាំងក្នុងសម័យអាណានិគមបានឱ្យដឹងថា នៅពេលឈូសចាយដី ដើម្បីដាំដុះកៅស៊ូគេក៏បានជួបប្រទះនូវសំណង់ដីរាងមូល មានកំពែងព័ទ្ធជុំវិញមានគូរាងរង្វង់ខាងក្នុងបន្ទាប់ពីកំពែងមានប្រកចេញចូលនិងបរិវេណ ខាងក្នុងជាកន្លែងរស់នៅ[៦១]។

នៅពេលនោះហើយដែលអ្នកស្រាវជ្រាវបារាំងបានឱ្យឈ្មោះទីកន្លែងនោះថា "Village Rond"។ អ្នកស្រាវជ្រាវ អ្នកនិពន្ធ និង អ្នកអានខ្មែរយើងមួយចំនួន ដោយមិនបានសិក្សានឹងឃើញស្ថានីយទាំងនោះផ្ទាល់ក៏បានបកប្រែបន្តពីអត្ថបទបារាំងថា«**ភូមិមូល**» ទៅវិញ។

ម្យ៉ាងវិញអត្ថបទរបស់លោក ត្រឹង ងា ចុះផ្សាយក្នុងសៀវភៅប្រវត្តិសាស្ត្រខ្មែរ លោកមិនបានឃើញនូវទីតាំងស្ថានីយ និង កន្លែងកំណាយបុរាណវិទ្យាក្នុងឆ្នាំ១៩៦២ ដោយលោក **ប៉ែណា ភីលីបហ្គ្រូសលីយេ** ឡើយ។ ក៏ប៉ុន្តែនេះជាកំណត់ហេតុមួយដែលបានអះអាងអំពីស្ថានីយព្រែកជ្លូង។ ជាការពិតនោះវាមិនមានឈ្មោះស្ថានីយព្រែកជ្លូងទេ។ ព្រែកជ្លូងគ្រាន់តែជាតំបន់ខ្លង់រាប ដែលមានប្រភពទឹកជាច្រើន ហូរនាំទៅចាក់ព្រែកជ្លូង ក្នុងស្រុកជ្លូង ខេត្តក្រចេះ ហើយនាំច្រោះទឹកបន្តទៅទន្លេមេគង្គ។ តាមការស្រាវជ្រាវរបស់អ្នកនិពន្ធ

---

[៦១] Publications de l'École Française d'Extrême-Orient, *Tome XXX, 1930*

ស្ថានីយព្រែកច្លូងនោះ គឺជាស្ថានីយបន្ទាយគូដែលអ្នកស្រុកក្នុងតំបន់នោះហៅ។

ចំណែកនៅភាគខាងត្បូងនៃប្រទេសវៀត-ណាមវិញ គេបានហៅស្ថានីយទាំងនេះថា : **ហិន ចង់** (ដែលមានន័យថា បន្ទាយមានមនុស្សរស់នៅ)។ ស្ថានីយបុរាណវិទ្យាទាំងនេះត្រូវបានកត់សម្គាល់ ដោយមានសំណល់បុរាណវិទ្យាដូចជា បំណែកកុលាលភាជន៍ ឧបករណ៍ប្រើប្រាស់ធ្វើអំពីថ្មមានដូចជា ពូថៅនិងថ្មសំលៀងជាច្រើននៅរាយប៉ាយក្នុងបរិវេណផ្ទៃលើនិងនៅកប់ក្នុងដីរហូតដល់បច្ចុប្បន្ន។យោងទៅលើឧបករណ៍សម្ភារៈដែលបានបន្សល់ទុកនៅលើស្ថានីយបានធ្វើឱ្យអ្នកស្រាវជ្រាវដំបូងៗយល់ថាស្ថានីយនេះ ស្ថិតនៅក្នុងយុគថ្មរំលីង។




*រូបខាងលើលក្ខណៈមើលទាំងបីទិស (3D) នៃស្ថានីយជួន ស្នួល ក្នុងស្រុកស្នួល ខេត្តក្រចេះ*

*រូបខាងក្រោមលក្ខណៈមើលពីលើអាកាស នៃស្ថានីយជួន ស្នួល ក្នុងស្រុកស្នួល ខេត្តក្រចេះ*



### តំណាលរឿងព្រេងទាក់ទងនឹងស្ពានីយបន្ទាយគូ

តាមរយៈអ្នកស្រុកបានតំណាលរឿងដែលទាក់ទងទៅនឹងស្ថានីយបន្ទាយគូនេះឱ្យដឹងថា : មានបន្ទាយពីរកន្លែងស្ថិតនៅក្បែរគ្នា។ មួយមានឈ្មោះថា **បន្ទាយផ្គង** ជាទីស្នាក់អាស្រ័យរបស់ពួកសត្វផ្គង[៦២]។ បន្ទាយមួយទៀតឈ្មោះថា **បន្ទាយភ្នំលំពែង**មានទីតាំងនៅលើកំពូលភ្នំលំពែង។ បន្ទាយនេះជាកន្លែងមនុស្សរស់នៅ ដែលស្ថិតក្រោមការដឹកនាំរបស់មេកន្ទ្រាញដ៏ល្បីល្បាញមួយរូប ហើយនៅក្បែរបន្ទាយនោះមានភ្នំមួយទៀត ឈ្មោះថា **ភ្នំទទួល** ដែលមានកំពូលរាបស្មើ ជាទីកន្លែងជួបជុំពលសេនាមកពីបន្ទាយនានា ដើម្បីប្រឹក្សាអំពីការដឹកនាំ ឬប្រជុំបញ្ហាផ្សេងៗ។

ថ្ងៃមួយ សង្គ្រាមបានចាប់ផ្តើមឡើងរវាងបន្ទាយទាំងពីរ ដែលជាចម្បាំងរវាងមនុស្ស និងសត្វផ្គង។ មេកន្ទ្រាញនៃពលមនុស្សនៅភ្នំលំពែងបានកោះហៅពួកពលសេនាទាំងឡាយមកប្រជុំគ្នានៅលើកំពូលភ្នំទទួល ដើម្បីពិភាក្សាអំពីកលយុត្ត។ សង្គ្រាមបានផ្ទុះឡើង ពួកពលមនុស្សប្រើលំពែងធ្វើអំពីឫស្សីនិងដុំថ្មជាយុទ្ធភណ្ឌរបស់ខ្លួន (ដឹងពក្លាក់ជំនីក ពក្លាក់ឬពូថៅថ្ម[៦៣] ដែលសព្វថ្ងៃនៅរាយប៉ាយនៅលើស្ថានីយនោះ) ចំណែកសត្វផ្គង បានប្រើធ្មមានផ្លែព្រួញធ្វើអំពីដែកជាយុទ្ធភណ្ឌ។

ពពួកសត្វផ្គង ទទួលបានជ័យជម្នះក្នុងសង្គ្រាមលើកនេះ ដោយសារពួកគេប្រើព្រួញដែក។ មេកន្ទ្រាញពួកពលមនុស្សនៅភ្នំលំពែង កើតក្តីក្តៅក្រហាយមិនសប្បាយចិត្តជាខ្លាំងក៏ពិភាក្សានឹងពលសេនារបស់ខ្លួនដើម្បីរកកលយុត្តថ្មី ក្នុងការយកជ័យជម្នះទៅលើពួកសត្វផ្គងវិញ។ លទ្ធផលនៃការពិភាក្សាបានរកឃើញថា សត្វផ្គង ប្រើធ្នូផ្លែព្រួញដែក អាចឈ្នះសង្គ្រាមបាន ដូច្នេះដើម្បីទទួលបានជោគជ័យវិញ ពួកយើងជាមនុស្សត្រូវតែទៅលួចព្រួញដែកពីសត្វផ្គង ទើបអាចឈ្នះសង្គ្រាមបាន។

ពេលនោះពពួកមនុស្ស ក៏រកកលវិធីទៅពឹងសត្វស្វា ដើម្បីទៅលួចព្រួញដែកពីសត្វផ្គង។ មនុស្សនិងស្វាបានដាក់លក្ខខណ្ឌនឹងគ្នាថា ប្រសិនបើស្វាអាចលួចព្រួញដែកបាននោះ មនុស្សនឹងអនុញ្ញាតឱ្យស្វាស៊ីនូវធញ្ញជាតិ ដែលមនុស្សដាំបានទាំងប៉ុន្មាន។ បន្ទាប់ពីយល់ព្រមនឹងគ្នាហើយ សត្វស្វាក៏ចេញដំណើរទៅលួចព្រួញដែកពីសត្វផ្គង។

---

[៦២] ជាប្រភេទសត្វជើងបួន ដែលនៅតំបន់ខ្លះហៅថា **ក្តាន់ញ៉ែង** ទេវិញ វាមានរូបរាងដូចគ្នាទៅនឹងសត្វក្តាន់តែមានមាឌតូចប៉ុនសត្វកណ្តុរប្រែងមានទម្ងន់តិចជាង ជប់គីឡូក្រាម និងស៊ីស្មៅជាអាហារ។

[៦៣] ពូថៅថ្មនេះជាប្រភេទឧបករណ៍ថ្មរំលីង ដែលប្រទះឃើញនៅគ្រប់ស្ថានីយបន្ទាយគូ ក្នុងតំបន់ដីក្រហមនៅប្រទេសកម្ពុជា និងភាគខាងជើងវៀតណាម។

ស្វាលួចព្រួញដែកបានហើយក៏យកមកឱ្យមនុស្ស ដូចបំណង។ មនុស្សក្រោយពីបានព្រួញដែកហើយ ក៏ចាប់ផ្ដើមធ្វើសង្គ្រាមជាមួយសត្វដូចម្ដងទៀត។

ដោយសារព្រួញដែក មនុស្សក៏បានទទួល ជោគជ័យនៅក្នុងការធ្វើសង្គ្រាមជារៀងរហូត ហើយ មនុស្សក៏បានអនុញ្ញាតឱ្យសត្វស្វាស៊ីធញ្ញជាតិដែល ខ្លួនដាំបានទាំងអស់ដែរ។ ប៉ុន្តែដោយមនុស្សមាន ចិត្តលោភលន់និងដោយមានព្រួញដែកផងនោះ ទើបនៅពេលសត្វស្វាទៅស៊ីដំណាំ របស់ពួកគេ គេតែងតែដេញបាញ់និងដេញវាយវាជានិច្ច។ សត្វស្វាខឹងណាស់ ហើយតែងតែលួចស៊ីដំណាំ មនុស្សជានិច្ច[៦៤]។

រឿងនិទាននេះ បានបង្ហាញឱ្យយើងដឹងអំពី ការប្រើប្រាស់ឧបករណ៍ធ្វើអំពីថ្មធ្វើអំពីលោហធាតុ និងធ្វើអំពីឫស្សី។ ក៏ប៉ុន្តែវាគឺជារឿងនិទានមួយតែ ប៉ុណ្ណោះ។ តាមរយៈកំណាយបុរាណវិទ្យា ដែលបាន ធ្វើកន្លងមក យើងមិនបានជួបប្រទះប្រភេទលោហ ធាតុនិងឧបករណ៍ធ្វើអំពីឈើ ឬ ឫស្សីនោះទេ នេះប្រហែលជាមកពីលក្ខខណ្ឌរបស់ដីក្រហម ដែលសម្បូរទៅដោយជាតិអាស៊ីត ហើយបានធ្វើ ឱ្យលោហធាតុនិងអង្គធាតុសរីរាង្គ ត្រូវពុកផុយ រលួយអស់។

តែទោះជាយ៉ាងណាក៏ដោយ ក៏យើងទទួល បានគំនិតខ្លះៗអំពីការនិទាននេះ ដែលនាំឱ្យយើង អាចធ្វើការសន្និដ្ឋានបានថា ស្ថានីយបន្ទាយគូមាន ពាក់ព័ន្ធទៅនឹងសម័យលោហធាតុ។

ការបង្ហាញក្នុងអត្ថបទស្រាវជ្រាវនេះ គឺ ផ្ដោតទៅលើស្ថានីយបន្ទាយគូ នៅក្នុងតំបន់ដីក្រហម នាខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តបៀន ភឿក ក្នុងទំហំ ២០០x១៥០ គ.ម.។ រហូតដល់បច្ចុប្បន្ន នេះ ស្ថានីយបន្ទាយគូតំបន់ដីក្រហមភាគខាងកើត ទន្លេមេគង្គនៃប្រទេសកម្ពុជានិងភាគខាងត្បូងប្រទេស វៀតណាមត្រូវបានចុះបញ្ជីមានចំនួនរហូតទៅ ដល់៦៣ស្ថានីយ។

---

[៦៤] រឿងនិទាននេះ ជាការរៀបរាប់របស់លោកមេភូមិកន្ទួត ស្រុកមេមត់ ខេត្តកំពង់ចាមក្នុងឆ្នាំ ២០០០។ អ្នកនិពន្ធបាន រៀបរៀង ព្រេងកថានេះជាថ្មីឡើងវិញ។

Location of the Circular Earthwork Site




ខ្ពង់រាបដីក្រហមភាគខាងកើតទន្លេមេគង្គ ជាប្រភេទដីដែលធ្វើអុកស៊ីតកម្មរបស់ខ្លួនវា បន្ទាប់ពីបន្ទុះភ្នំភ្លើងនៅដើមស័កនៃផែនដី ហើយស្ថានីយបន្ទាយគូ ឃើញមានតាំងទីលើតំបន់ខ្ពង់រាបទាំងនោះ ក្នុងកម្រិតកម្ពស់ពី ៦៥ម. ទៅ ប្រហែល ១៨០ម. ខ្ពស់ជាងទឹកសមុទ្រ។

ស្ថានីយទាំងនោះមានសណ្ឋានរាងមូលជាប្រភេទតែមួយ ដោយបង្ហាញនូវកំពែងរបស់វាខាងក្រៅដែលខុសគ្នាស្រឡះទៅនឹងស្ថានីយនៅតំបន់អង្គរនិងស្ថានីយដែលនៅភាគកណ្តាល និង ខាងជើងចៀងខាងកើតប្រទេសថៃ។ យើងអាចថា ស្ថានីយភូមិមូលនៅតំបន់អង្គរ និង ស្ថានីយដែលនៅភាគកណ្តាល និង ខាងជើងចៀងខាងកើតប្រទេសថៃ ប្រហែលជាលទ្ធផលនៃការវិវត្តរបស់មនុស្ស ដែលផ្លាស់ទីពីតំបន់ខ្ពង់រាបចុះមកវាលទំនាប ដោយសារកំណើនប្រជាជន (មានស្ថានីយកើនច្រើននៅតំបន់ដីក្រហម) ហើយនាំឱ្យភោគផលនៅក្នុងតំបន់មានការចុះថយឬក៏ដោយបដិវត្តិនៃការរីកចម្រើនរបស់មនុស្សនៅតំបន់ដីក្រហម ដើម្បីកែច្នៃធម្មជាតិ តាមរយៈតំហាយនៃទឹកសមុទ្រនៅសម័យនោះ។

ម្យ៉ាងទៀតនៅក្នុងការសាងសង់ភូមិនៅតំបន់ទំនាប គេត្រូវលើកឡើងឱ្យខ្ពស់ផុតពីទឹកហេតុនេះហើយ ទើបយើងឃើញថា សំណង់ភូមិមូលនៅតំបន់អង្គរ គេបានយកដីចេញពីគូទឹកទៅដាក់លើផ្ទៃខាងក្នុងវិញ ដើម្បីជៀសឱ្យផុតពីទឹក។ ការវិវឌ្ឍ

នេះ យើងអាចសន្និដ្ឋានបានថា ជាប្រពៃណីបន្តពីស្ថានីយបន្ទាយគូនៃអរិយធម៌មេមត់ ទើបរហូតដល់សព្វថ្ងៃនេះ សំណង់ផ្ទះរបស់អរិយធម៌មន-ខ្មែរច្រើនសង់ឱ្យផុតពីទឹកដោយប្រើជើងសសរដែលយើងឃើញមាននៅតំបន់ភាគខាងត្បូងដីសណ្ដមេគង្គប្រទេសកម្ពុជានិងក្នុងប្រទេសថៃ។

ស្ថានីយបន្ទាយគូតូចបំផុតមានអង្កត់ផ្ចិត១១០ម. គឺស្ថានីយដីដែលមានទំហំប្រហែលជា ១ ហិកតា ហើយស្ថានីយ ដែលធំបំផុតនោះ គឺស្ថានីយត្របែកដែលមានអង្កត់ផ្ចិតរហូតដល់ ៤៤៧ម. មានទំហំប្រហែល ១៦ ហិកតា។ នេះជាវិសាលភាពបញ្ជាក់ពីវិជ្ជមាត្ររបស់ស្ថានីយបន្ទាយគូ ដែលត្រូវការកម្លាំងពលកម្មជាច្រើនសម្រាប់ស្ថាបនាស្ថានីយនីមួយៗ។

ដូច្នេះ ប្រព័ន្ធរដ្ឋបាលមួយដ៏ចាំបាច់ដែលត្រូវការមេដឹកនាំត្រឹមត្រូវក្នុងការចាត់ចែងកសាងស្ថានីយនីមួយៗ។ ប្រសិនបើយើងមើលស្ថានីយឡុកតាន់២ (Loctan 2) មានទំហំ ១០ហិកតា និងស្ថានីយត្របែក ដែលមានទំហំជាង ១៥ ហិកតានោះវិញ យើងឃើញថា រយៈពេលនៃការសាងសង់ស្ថានីយនីមួយៗ ត្រូវការយ៉ាងតិចបំផុតក៏ពីរខែដែរ។ ការដឹកនាំស្ថាបនាស្ថានីយទាំងអស់នេះប្រាកដជាមានមេក្រុម ឬ មេកុលសម្ព័ន្ធ ដែលសព្វថ្ងៃយើងអាចហៅថា ជាប្រមុខរដ្ឋក៏បាន។

ចំពោះការរស់នៅរបស់មេក្រុមនេះ យើងមិនអាចសន្និដ្ឋានបានថា នៅស្ថានីយណាមួយបានទេ ដោយប្រភេទរូបសាស្ត្រស្ថានីយមានលក្ខណៈដូចៗគ្នាទាំងអស់។ ស្ថានីយមួយចំនួនមានរូបសាស្ត្រល្អចម្លែកដោយមានកំពែងខ្ពស់ល្អ បាតគូជ្រៅ បរិវេណខាងក្នុងមានរាងជាបាតខ្ទះ។ ស្ថានីយមួយចំនួនតាំងទីនៅលើកំពូលរបស់ខ្លង់រាបខ្ពស់ៗដែលមានដូចជា ស្ថានីយជួនស្នួលលំពែង១ ឡុកតាន់២ (Loctan ២) ហើយដែលសព្វថ្ងៃនេះវានៅតែរក្សាបានភាពល្អដដែល បើយើងឈរពីលើស្ថានីយទាំងនោះ យើងអាចមើលឃើញនូវទិដ្ឋភាពដ៏ស្រស់ស្អាតរបស់ទេសភាពនៅជុំវិញស្ថានីយ។

បន្ទាយគូ បានបង្ហាញឱ្យឃើញនូវច្រកចេញចូលរហូតដល់ប្រាំពីរបែបខុសៗគ្នា ដែលស្ថានីយនីមួយៗមានច្រកមួយឬពីរ។ ច្រកធំជាច្រកសំខាន់សម្រាប់ការចេញចូលទូទៅ ឯច្រកតូចអាចជាច្រកសម្រាប់សត្វពាហនៈចេញចូល។របកគំហើញវត្ថុសិល្បៈជាច្រើនប្រភេទត្រូវបានប្រទះឃើញនៅលើស្ថានីយបន្ទាយគូ ដែលមានដូចជា កុលាលភាជន៍និងឧបករណ៍ប្រើប្រាស់ធ្វើអំពីថ្ម បញ្ជាក់ឱ្យឃើញថាសហគមន៍មនុស្សដែលរស់នៅក្នុងស្ថានីយទាំងនោះមានបច្ចេកទេសវិវត្តក្នុងការកសាងរដ្ឋ សហគមន៍របស់ខ្លួននៅក្នុងតំបន់ ដោយមានទំនាក់ទំនងផ្នែក:

### ក.កសិកម្មនិងឧស្សាហកម្ម

តឹកតាងនៃការដាំស្រូវត្រូវបានឃើញយ៉ាងច្បាស់នៅលើបំណែកកុលលាភាជន៍។ យើងឃើញស្លាកស្នាមគ្រាប់ស្រូវដែលមនុស្សនៅក្នុងអរិយធម៌នេះបានបន្សល់ទុក។ ក៏ប៉ុន្តែយើងមិនអាចសន្និដ្ឋានបានថា ជាប្រភេទស្រូវភ្អំ (ជាប្រភេទស្រូវបុកដាំនៅតំបន់ខ្ពង់រាប) ឬស្រូវស្រែទេ ដោយសំណល់សំបកអង្កាម ដែលនៅលាយជាមួយនឹងដីឥដ្ឋសម្រាប់ធ្វើក្អមថ្នាំង នោះវាមានសភាពរួញទៅតាមទំហំនៃដីឥដ្ឋនៅពេលដុត។ម្យ៉ាងទៀតប្រសិនបើយើងមើលទៅលើច្រកចេញចូលរបស់ស្ថានីយ ដែលជាទូទៅឃើញថា មានច្រកចេញចូលចំនួនពីរ ដោយច្រកមួយឆ្ពោះទៅរកប្រភពទឹកនិងច្រកមួយទៀតឆ្ពោះទៅទីវាលរបស់ខ្ពង់រាប ដែលអាចឱ្យយើងសន្និដ្ឋានបានថា ជាច្រកចេញចូលសម្រាប់ធ្វើកសិកម្ម ឬទំនាក់ទំនងផ្សេងៗ។

ប្រសិនបើ យើងមើលស្ថានភាពបច្ចុប្បន្ននេះវិញ ឃើញថាប្រជាជនដែលរស់នៅក្នុងតំបន់ខ្ពង់រាប គេដាំស្រូវចម្ការ ដែលជាប្រភពស្រូវសម្រាប់ទ្រទ្រង់ជីវិតរបស់ពួកគេប្រចាំឆ្នាំ ហើយប្រហែលប្រជាជននៅទីនោះ សព្វថ្ងៃបានបន្តប្រពៃណីដាំស្រូវភ្អំតាំងពីអតីតកាលមក។

ក្រៅពីដំណាំស្រូវ សត្វស្រុកប្រហែលជាត្រូវបានចិញ្ចឹមដូចគ្នានេះដែរ។ រហូតមកដល់បច្ចុប្បន្ននេះ មិនឃើញមានស្លាកស្នាមសំណល់ឆ្អឹង ស្នែងសត្វ ឬ សារធាតុសរីរាង្គអ្វីផ្សេងទៀតបន្សល់ទុកឡើយ ដោយសារសមាសធាតុដីនៅលើស្ថានីយទាំងនោះ សម្បូរជាតិអាស៊ីតខ្លាំង។ ប៉ុន្តែយើងអាចសន្និដ្ឋានបានថា ប្រហែលជាមានការចិញ្ចឹមសត្វដាក់នៅក្នុងគូដោយយើងឃើញថា បាតគូទំនងជាកន្លែងចិញ្ចឹម ឬ ជាក្រោល គោ ក្របី ឬក៏ជ្រូកច្រើនជាង។ ព្រោះថា គូមិនមែនជាប្រឡាយសម្រាប់ផ្ទុកទឹក ឬសម្រាប់បង្ហូរទឹកនោះទេ។

ឧបករណ៍ដីដុត ដែលយើងអាចសម្គាល់ថា "ខ្នារ" ជាប្រភេទឧបករណ៍សម្រាប់ដាក់អំបោះត្រូវបានរកឃើញនៅក្នុងស្ថានីយបន្ទាយគូ ដែលសបញ្ជាក់ឱ្យឃើញថា សហគមន៍មនុស្សនាពេលនោះមានបច្ចេកទេសខ្ពស់នៅក្នុងការផលិតអំបោះ។ ថ្វីបើយើងមិនឃើញមានអំបោះ ឬ ក្រណាត់នៅក្នុងស្ថានីយក៏ដោយ តែការរកឃើញ "ខ្នារ" បានបង្ហាញឱ្យយើងឃើញថា សហគមន៍នោះជាក្រុមមនុស្សដែលមានអរិយធម៌ខ្ពស់ មានសម្លៀកបំពាក់ត្រឹមត្រូវ។

តាមរយៈកំណាយបុរាណវិទ្យា មានកុលាលភាជន៍ជាច្រើនដែលយើងបានជួបប្រទះ ហើយដែលវាមានប្រភេទនិងទម្រង់ខុសៗពីគ្នាព្រមទាំងក្បាច់លម្អផ្សេងៗជាច្រើនទៀត។ កុលាលភាជន៍ទាំងនោះ គឺជាឧបករណ៍ចាំបាច់សម្រាប់

ប្រើប្រាស់ប្រចាំថ្ងៃ។ ចំពោះនៅក្នុងពេលបច្ចុប្បន្ននេះវិញ ក៏យើងឃើញមានការផលិត ក្អម ថ្នាំង នៅក្នុងខេត្តនិងតំបន់មួយចំនួនក្នុងប្រទេសកម្ពុជា ដោយនៅប្រើបច្ចេកទេសបុរាណដូចជា ក្លឹង ស្លឹក សម្រាប់ស្មូន ក្អម ថ្នាំងទាំងនោះដែរ។ យើងបានប្រទះឃើញក្លឹងមួយចំនួន នៅក្នុងស្ថានីយបន្ទាយគូ ដែលសបញ្ជាក់ឱ្យឃើញថា ពួកគេជាអ្នកស្មូនដ៏ពូកែ។ ជាងនេះទៅទៀត រាល់ស្ថានីយបន្ទាយគូ ទាំងអស់ កុលាលភាជន៍ត្រូវបានប្រទះឃើញច្រើនជាងឧបករណ៍ថ្ម។

ជំនីកពក្លាក់ឬដឹងពក្លាក់ដែលជាឧបករណ៍ប្រើប្រាស់ធ្វើអំពីថ្មត្រូវបានឃើញនៅរាយបាំយ លើគ្រប់ស្ថានីយបន្ទាយគូ ដែលយើងស្គាល់ បានថាជាប្រភេទពូថៅធ្វើអំពីថ្មនៅសម័យនោះ ហើយដែលបច្ចុប្បន្ននេះ អ្នកស្រុកក្នុងតំបន់មួយចំនួនយល់ថាជាកាំរន្ទះ។ ភស្តុតាងដែលបន្សល់ទុកទាំងនេះប្រាកដណាស់ថា វាជាប្រភេទឧបករណ៍ដែលគេបានផលិតសម្រាប់ប្រើនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេ។ ពូថៅថ្មធម្មតា ពូថៅថ្ម មានស្មា ថ្មសំលៀង និងផ្លែដឹង បានបង្ហាញថា ជាបុព្វការីជនដែលមានភាពប៉ិនប្រសប់នៅក្នុងការផលិតឧបក-រណ៍ប្រើប្រាស់ទាំងនោះ គឺជាអ្នកមានរបរកសិកម្ម។ ម្យ៉ាងទៀត យើងឃើញមានសំណល់អង្កាមនៅលើកុលាលភាជន៍ នេះបានបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា អរិយធម៌នេះមានប្រពៃណីដាំស្រូវជាយូរលង់ណាស់មកហើយ។



ផ្លែលំពែង



ផ្លែពន្លាក



ពូថៅថ្ម



ផ្លែព្រួញ



បំណែកភាជន៍ដែលមានក្បាច់

**ខ.គមនាគមន៍**

ប្រហែលសត្វពាហនៈ ជាមធ្យោបាយមួយយ៉ាងសំខាន់សម្រាប់គមនាគមន៍ និង របរកសិកម្មនាសម័យកាលនោះ។ ក្រៅពីនេះ ប្រភពទឹកដែលមានព្រែកថ្លុង ទន្លេចាម (ទន្លេដងណាយ) ដែលហូរចាក់ទៅទន្លេសៃហ្គុន ប្រហែលជាប្រភពយ៉ាងសំខាន់មួយទៀតសម្រាប់គមនាគមន៍។ ផ្លែពន្ទាកប្រហែលជាឧបករណ៍មួយសំខាន់ប្រើសម្រាប់កាប់ឬចាំងឈើធ្វើទូក ក៏ប៉ុន្តែយើងមិនមានស្លាកស្នាមរបស់ទូក ឬ ក្បូនសម្រាប់ធ្វើការបញ្ជាក់នោះទេ។ ទំនាក់ទំនងពីតំបន់មួយទៅតំបន់មួយពីស្ថានីយមួយទៅស្ថានីយមួយ ត្រូវបានធ្វើប្រហែលដោយមធ្យោបាយប្រើសត្វពាហនៈ ទូក ឬ ក្បូន នេះឯងសម្រាប់ដោះដូរទំនិញរវាងគ្នានឹងគ្នា។

**គ.ពាណិជ្ជកម្ម**

ការប្រើដែះឈ្លីកដោយមិនមានអំបិល ជារឿងមួយសំខាន់របស់អ្នកស្រុកភ្នំ នៅតំបន់ខ្ពង់រាបខាងកើតទន្លេមេគង្គ ប៉ុន្តែដែះឈ្លីកនេះមិនគ្រប់គ្រាន់ហើយក៏មិនអាចជួយឱ្យក្រុមមនុស្សនាសម័យកាលនោះមានសុខភាពល្អទេ។ជំនួញអំបិលប្រហែលជាមានរវាងអ្នកដែលរស់នៅឆ្ងាយពីសមុទ្រនិងអ្នកនៅជិតសមុទ្រ។ យើងបានប្រទះឃើញកុលាលភាជន៍ ដែលគេប្រើសម្រាប់ផលិតអំបិលនៅតាមស្ថានីយមួយចំនួនក្បែរសមុទ្រប្រទេសវៀតណាម។ ម្យ៉ាងទៀត ការដោះដូររបស់របរផ្សេងៗទៀតដូចជា ត្រីនិងគ្រឿងលម្អ ប្រហែលជាត្រូវធ្វើទំនាក់ទំនងទៅនឹងទន្លេសាបឬទន្លេមេគង្គដែលជាប្រភពត្រីដ៏សំខាន់ជាយូរលង់ណាស់មកហើយ។ វាពាក់ព័ន្ធទៅនឹងស្ថានីយនៅស្ទួង នៅពាមជាំងដែលអាចធ្វើដំណើរថ្លុងទន្លេ មកស្ថានីយចម្ការអណ្ដូង។ ម្យ៉ាងទៀត ចលនាទឹកសមុទ្រប្រហែលជា២០០០ឆ្នាំមុន ប្រហែលនៅខ្ពស់នៅឡើយ ដែលធ្វើឱ្យវិស័យគមនាគមន៍តាម ផ្លូវទឹកក្លាយជារឿងសំខាន់មួយ។

កងធ្វើអំពីកែវនិងអង្កាំ មិនអាចថា ជាការផលិតនៅលើស្ថានីយបន្ទាយគូបានទេ។ តាមរយៈការពិសោធទៅលើកងធ្វើអំពីកែវ នាំឱ្យយើងសន្និដ្ឋានបានថា ទំនាក់ទំនងពាណិជកម្មប្រាកដជាមាន។ យោងតាមលោក **គ្លូវើ** និងលោក **ហេនឌែសុន** (Glover and Henderson, 1995) បានបញ្ជាក់ឱ្យដឹងថា មានតំបន់បីដែលគេចាត់ទុកជាមជ្ឈមណ្ឌលផលិតកែវមុនដំបូង ហើយបាននាំចូលមកក្នុងតំបន់អាស៊ីអាគ្នេយ៍ ទីមួយនៅប្រទេសឥណ្ឌា ទីពីរនៅប្រទេសចិន និងទីបីនៅតំបន់មេឌីទែរ៉ាណេ។

តាមលទ្ធផល នៃការពិសោធទៅលើកងធ្វើអំពីកែវ ដែលបានមកពីកំណាយស្ថានីយក្រែក ៥២/៦២ ឃើញថាមានសមាសធាតុស្រដៀងគ្នា

ទៅនឹងបំណែកកងធ្វើអំពីកែវ ផលិតនៅប្រទេសឥណ្ឌា។ នេះជាសក្ខីកម្មមួយអាចសន្និដ្ឋាន ថាបុព្វការីជនដែលរស់នៅលើស្ថានីយបន្ទាយគូ មានទំនាក់ទំនងពាណិជ្ជកម្មជាមួយនឹងបរទេស។

**ឃ.សិល្បៈ**

ឧបករណ៍សិល្បៈថ្មសំឡេង បានរកឃើញជាច្រើននៅលើស្ថានីយបន្ទាយគូនៅឡុកនិញ និងនៅស្ថានីយហ្គ្រួលីយេ។អត្ថបទរបស់លោក**កុងដូមីណាស់** (G.Condominas) បានផ្តល់ព័ត៌មានថាការផលិតថ្មសំឡេង គឺយកតាមគំរូអរិយធម៌ Basonien ឬក៏ក្នុងសម័យដើមនៃយុគថ្មរំលីង (NeolithicTime) នៅឧបទ្វីបឥណ្ឌូចិន។ បន្ទះថ្មសំឡេងមានរាងទ្រវែង គឺជាឧបករណ៍តន្ត្រីមួយប្រភេទនៅដើមសម័យយុគថ្មរំលីង (សព្វថ្ងៃនេះ យើងឃើញថ្មសំឡេងនេះដាក់តាំងនៅក្នុងសារមន្ទីរជាតិភ្នំពេញ)។ វាអាចបញ្ជាក់ឱ្យយើងដឹងថា អរិយធម៌មេមត់បានរក្សាប្រពៃណីសិល្បៈរបស់ខ្លួនជាយូរអង្វែងណាស់មកហើយ។

ការសិក្សាអំពីស្ថានីយទាំងនោះបានផ្តល់ឱ្យយើងដឹងនូវការកត់សម្គាល់អំពីការតាំងនៅដ៏សម្បូរបែប ដែលមនុស្សសម័យមុននៅតំបន់នោះបានកសាងឡើង។ លក្ខខណ្ឌធម្មជាតិក្នុងតំបន់មានលក្ខណៈអំណោយផលដល់ការរស់នៅរបស់មនុស្សនៅទីនោះគ្មានព្យុះទឹកជំនន់ដូចតំបន់ដីសណ្តមេគង្គក្រោមទេ។ មានសីតុណ្ហភាពក្តៅសើមទៀតទាត់ មានប្រព័ន្ធទន្លេ ព្រែក បឹងត្រពាំង ខ្វាត់ខ្វែង មានជ្រលងភ្នំ ទំនាបតូចៗមានតំបន់ដីក្រហមសម្បូរជីវជាតិ រុក្ខជាតិ និងសត្វព្រៃជាច្រើន។ ប៉ុន្តែលក្ខខណ្ឌអំណោយផលរបស់ធម្មជាតិ ក៏បានផ្តល់នូវផលវិបាកខ្លះៗ ដល់ការរស់នៅរបស់មនុស្សដែរ ជាពិសេសនៅសម័យមុន ដូចជា ព្រៃក្រាស់នាំឱ្យមានការពិបាកនៅក្នុងការធ្វើដំណើរ មានសត្វព្រៃសាហាវ ដែលជាការគំរាមកំហែងដល់អាយុជីវិតអ្នករស់នៅទីនោះ។

ការសង់កំពែងជាសក្ខីកម្ម ដែលបុព្វបុរសធ្វើដើម្បីការពារសត្វសាហាវ មិនមែនសម្រាប់ការពារសត្រូវឡើយ ដោយស្ថានភាពកំពែងនៃស្ថានីយបន្ទាយគូ ទាំងនោះមានភាពងាយស្រួលចូលពីខាងក្រៅ ដូច្នេះនៅលើកំពូលកំពែងប្រហែលត្រូវបានធ្វើជារបងការពារ។

ដើម្បីស្ថិរភាព និង ការរីកចម្រើនរបស់ខ្លួន មនុស្សសម័យមុនបានកសាងទីជម្រកបន្ទាយគូនេះឡើង សម្រាប់ងាយស្រួលក្នុងកាការពារខ្លួនងាយស្រួលដល់ការប្រាស្រ័យទាក់ទងគ្នា ក្នុងកុលសម្ព័ន្ធក៏ដូចជារៀបចំការបរបាញ់ បេះផ្លែឈើ និងធ្វើកសិកម្មជាដើម។ ដោយហេតុនេះហើយស្ថានីយបន្ទាយគូភាគច្រើនត្រូវបានកសាងឡើងមាន លក្ខណៈប្រមូលផ្តុំជាក្រុម ដែលនៅក្នុងក្រុមនីមួយៗ មានទីតាំងស្ថិតនៅមិនឆ្ងាយប៉ុន្មានពីគ្នា។ ទាំងនេះវា

ច្ចះបញ្ជាំងឱ្យឃើញយ៉ាងច្បាស់ថា នៅសម័យមុន មនុស្សដែលរស់នៅក្នុងស្ថានីយទាំងនេះរេចះសាមគ្គីគ្នាជួយការពារគ្នាក្នុងសង្គមដែលច្ចះបញ្ជាំងឱ្យឃើញនូវអរិយធម៌មួយដ៏ពិសេស នៅក្នុង តំបន់។

កត្តាទាំងអស់នេះហើយ បានធ្វើឱ្យយល់កាន់តែច្បាស់ អំពីស្ថានីយបន្ទាយគូនៃអរិយធម៌មេមត់ ដែលជាការកសាងរដ្ឋដំបូងៗនៅក្នុងតំបន់។

អ្នកនិពន្ធសូមផ្តល់ជាយោបល់ឱ្យមានការស្រាវជ្រាវឱ្យកាន់តែស៊ីជម្រៅជាងនេះទៀត ជាពិសេស គួរយកបច្ចេកទេសវិទ្យាសាស្ត្រទំនើបដែលស្របទៅនឹងការរីកចម្រើននាពេលបច្ចុប្បន្ន ដូចជាការពិសោធកាបូន-១៤ (C-១៤) ដើម្បីឱ្យដឹងអាយុកាលរបស់ស្ថានីយឱ្យបានជាក់លាក់។ ជាងនេះទៅទៀត គួរធ្វើការសិក្សាបន្ថែមដោយផ្តោតទៅលើកាជន៍បរិស្ថាន និង កំណាយបុរាណវិទ្យាឱ្យបានច្រើនស្ថានីយទៀត។

## ឯកសារយោង (Bibliography)


### ១.គន្ថនិទ្ទេសជាភាសាជាតិ

- ជួន ណាត *វចនានុក្រមខ្មែរ* ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥១១ គ.ស.១៩៦៧

-ត្រឹង ងា *ប្រវត្តិសាស្ត្រខ្មែរ* សម្រាប់មធ្យមនិងឧត្តមសិក្សា ការផ្សាយរបស់អ្នកនិពន្ធ បោះពុម្ពលើកទី១ ចំនួន ២០០០ ក្បាល ភ្នំពេញ គ.ស. ១៩៧៣ ព.ស. ២៥១៧

- ធុយ ចាន់ធួន សារណាថ្នាក់បរិញ្ញាបត្រ ស្តីអំពី *ស្ថានីយភូមិមូល ហ្គេសលីយេនៅមេមត់, និង ឧបករណ៍ថ្មនៅសារមន្ទីរជាតិភ្នំពេញ,* ឆ្នាំ ១៩៩៩

- ធុយ ចាន់ធួន របាយការណ៍ប្រចាំឆ្នាំរបស់មជ្ឈមណ្ឌលបុរាណវិទ្យាមេមត់ ស្តីអំពី*ស្ថានីយភូមិមូលនៅមេមត់* ឆ្នាំ២០០០

- ធុយ ចាន់ធួន និង ហេង សុផាឌី របាយការណ៍ប្រចាំឆ្នាំរបស់មជ្ឈមណ្ឌលបុរាណវិទ្យាមេមត់ ស្តីអំពី *ស្ថានីយភូមិមូលនៅមេមត់,* ឆ្នាំ ២០០១

### ២.គន្ថនិទ្ទេសជាភាសាបរទេស (Bibliography in Foreign Languages)

-Albrecht Gerd, Miriam Nöel Haidle and Thuy Chanthourn,"Circular Earthwork Krek 52/62", Recent Research on Prehistory of Cambodia, Asian Perspectives, The Journal of Archaeology for Asia and the Pacific, November 2000.

- Do Nguyen Trung, *Di Tich Dat Dap Hinh Crong Binh Phuoc*, unpublished thesis, TP. Ho Chi Minh, 2003.

- Do Nguyen Trung, "Circular Earthworks in Bin Phuoc province" *Paper presented at the Conference on the Circular Earthworks in Phnom Penh, Cambodia* " November 1999.

- Groslier, Bernard-Philippe, *Archaeology Mundi Indochina*, Nagel Geneva, 1966a.

- Groslier, Bernard-Philippe "*Découvertes archéologiques récentes au Cambodge*", Kambuja, Phnom Penh, 1966b.

- Heang Leang Hong, "*The Pottery from the Groslier Circular Earthwork Site stored in the National Museum Phnom Penh* ", unpublished dissertation, Faculty of Archaeology, RUFA, Phnom Penh, Cambodia, 1999.

- Haidle, Miriam Nöel, Fragments of glass bangles from Krek 52/62 and their implications for the dating of the Memotian Culture, Asian Perspectives (in press), 2002.

- Haidle, Miriam Nöel, and Chanthourn Thuy, "*Fortresses? Ceremonial Centers? Villages? Circular Earthworks in Eastern Cambodia* " Proceeding of the 8th Conference of the European Association of South East Asian Archaeologists, Sarteano, Italy, 2-6 October 2000.

- Kojo Yasushi, and Pheng Sytha, *A newly discovered earthworks in Southeastern Cambodia*, Anthropological Science 105(3), 1997.

- Kojo Yasushi, and Pheng Sytha, *A preliminary investigation of a circular earthworks at Krek*, Southeastern Cambodia. Anthropological Science 106(3), 1997.

- Ly Vanna, *The Archaeology of Shell Matrix Sites, In the Central Floodplain of the Tonle Sab River, Central Cambodia*, (The Settlement Site of Samrong Sen and Its Cultural Complexity), unpublished thesis, at Sophia University, Japan, 2002.

- Malleret, Louis, *Ouverages circular en terre dans l'Indochine Mérionale*. Bulletin de l' École Française de l'Extrême-Orient 49, 1959.

- Manh Pham Duc, *The prehistoric lithopone at Loc Ninh* (Binh Phuoc-Vietnam). Paper presented at the Conference on Circular Earthworks in Cambodia, 14-19 November 1999, Phnom Penh, Cambodia.

- Mansuy Henri, *Station préhistoriques de Somrong Sen et de Long Prao* (Cambodge), Hanoi Vietnam, 1902.

- Moore Elisabeth, *Moated Sites in Early North East Thailand*, BAR International Series 400, Oxford, 1988.

- Mourer, Cécile and Roland Mourer, *The prehistoric industry of Laang Spean*, Province of Battambang, Cambodia. Archaeology and Physical Anthropology in Oceania5/2, 1970.

- Mourer, Roland, *Contribution a l'étude de la préhistoire du Cambodge*, in Recherches nouvelle sur le Cambodge, p. 143-195, ed. F. Bizot, Paris, École Française d'Extrême-Orient, 1994.

- Thuy Chanthourn, Inventory Circular Earthwork Sites in Vietnam, *Asian Scholarship Foundation*, Bangkok, Thailand, 2006.

- Thuy Chanthourn, Study Archaeological sites by aerial pictures, *The 7th Socio-Cultural Research Congress on Cambodia*, Phnom Penh 2005.

- - Thuy Chanthourn and San Soravnith, *Historical and Archaeological Sites in Ponhear Krek district, Kompong Cham Province*, Asia Research Network, Vol.2 No.2, Autumn 2005.

- Thuy Chanthourn, New Banteay Kou, Memotian Culture, *The 6th Socio-Cultural Research Congress on Cambodia* 18th – 20th November 2003, PP.371-382, Phnom Penh 2004.

- Thuy Chanthourn, VyaÆdhapura? or Indrapura? in Banteay Prey Nokor, Center for Khmer Studies, Siem Reap, Vol 7, 2005.

- Thuy Chanthourn, Report on the results of the Banteay Kou: Memotian Culture on November 2003 (English versions).

- Thuy Chanthourn, *"Preliminary study of the Memotian Culture"*, Siksacakr No. 5 December 2002 (English version).

- Thuy Chanthourn, "*Banteay Kou: Memotian Circular Earthwork*", Khmer prehistory, August 2002 (Khmer & English versions).

- Thuy Chanthourn, Newly Discovered Archaeological sites "The Popular magazine", 21st – 30th August 2002, pp. 32-33 (Khmer version).

- Thuy Chanthourn, Early Cave Settlement in Cambodia "The Popular magazine", 21st – 30th September 2002, pp. 33-34 (Khmer version).

- Thuy Chanthourn, Newly Banteay Kou: or Circular earthwork sites in Cambodia, *The Indo-Pacific Prehistory Association*, September 2002, pp. 273, Taiwan (English versions).

- Thuy Chanthourn, " *Groslier circular earthworks site in Memot district* ", The Stone tools in the National Museum Phnom Penh, unpublished dissertation, Faculty of Archaeology, RUFA, Phnom Penh, Cambodia, 1999.

- Thuy Chanthourn,"*Newly documented circular earthworks sites in Kampong Cham Province*", Paper presented at a Conference of the Center for Khmer Studies in Siem Reap, 2002.

- Thuy Chanthourn and Heng Sophady, "*Report on the results of the Memot Centre for Archaeology* ", Early 2000.

- Thuy Chanthourn and Heng Sophady, "*Report on the results of the Memot Centre for Archaeology* " Mid-2000 to early 2001.

- Thuy Chanthourn, Report on Circular Earthwork in Snoul District, 2004.

- Thuy Chanthourn, Report on Circular Earthwork sites in Southern, Vietnam, Asian Scholarship Foundation, 2006.

# គោលនយោបាយការបរទេសរបស់សហភាពសូវៀតចំពោះប្រទេសកម្ពុជា១៩៥៦_១៩៧៩



លោក **ចាន់ ប៊ុន្នី**

បេក្ខជនបណ្ឌិតផ្នែកប្រវត្តិវិទ្យា

នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១_ប្រវត្តិសង្ខេបនៃទំនាក់ទំនងកម្ពុជា_សូវៀត

ប្រទេសកម្ពុជាក៏ដូចជាបណ្ដាប្រទេសអាស៊ី អាហ្វ្រិក និងអាមេរិកឡាទីនដែរ សុទ្ធតែធ្លាប់ស្ថិតនៅក្រោមរបបអាណានិគមអឺរ៉ុបខាងលិច។ នៅក្រោយពេលទទួលបានឯករាជ្យពីនឹមអាណានិគមនិយម ប្រទេសទាំងនេះតែងស្វែងរកការគាំទ្រចំពោះឯករាជ្យ បូរណភាពដែនដីរបស់ខ្លួន និងសន្តិភាពពីប្រទេសមហាអំណាចណាមួយ។ បណ្ដាប្រទេសអាណានិគមចាស់។ (អេស្ប៉ាញ ព័រទុយហ្គាល់ អង់គ្លេស បារាំង ) សុទ្ធតែគាំទ្រដោយសហរដ្ឋអាមេរិក ដែលជាមហាអំណាចអាណានិគមថ្មី ហើយដែលប្រទេសក្រោមអាណានិគមមិនអាចពឹងពាក់បានឡើយ ដូច្នេះបណ្ដាប្រទេសទាំងនេះ (ប្រទេសក្រោមអាណានិគម) ត្រូវងាកទៅរកមហាអំណាចផ្សេងៗ ទៀត ដែលជាគូប្រជែងក្នុងអំឡុងសង្គ្រាមត្រជាក់[៦៥]។ ជាក់ស្ដែង ប្រទេសកម្ពុជាមិនអាចទៅពឹងពាក់សហរដ្ឋអាមេរិកបានឡើយ ព្រោះប្រទេសបារាំងស្ថិតនៅក្រោមឥទ្ធិពលនៃអាមេរិក។

សហភាពសូវៀត និង ប្រទេសកម្ពុជា បានបង្កើតទំនាក់ទំនងការទូតជាផ្លូវការនាថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៥៦[៦៦]។ នៅឆ្នាំដដែលនេះ ប្រទេសទាំងពីរ បានផ្ញើការផ្លាស់ប្ដូរស្ថានទូតទៅវិញទៅមក និងដំណើរទស្សនកិច្ចរបស់ប្រតិភូកម្ពុជា ដឹក

[៦៥] _ឯកសាររបស់សាស្ត្រាចារ្យបណ្ឌិត ស៊ិន សំណាង ក្នុងសិក្ខាសាលាថ្នាក់បណ្ឌិតវគ្គ១ នៃរាជបណ្ឌិត្យសភាកម្ពុជា 0៤ ធ្នូ ២00៨។

[៦៦] _*ទស្សនាការជាមិត្តភាព ១៩៥៦* ផ្សាយចេញពី ស្ថានទូតសូវៀតប្រចាំកម្ពុជា ១៩៥៨ បណ្ណសារដ្ឋានជាតិ ប្រអប់លេខ ៣១៦។

នាំដោយសម្តេចព្រះនរោត្តម សីហនុ ទៅកាន់សហភាពសូវៀត។ នៅក្នុងព្រះដំណើរទស្សនកិច្ចនេះ សម្តេចបានទទួលការសន្យាផ្តល់ជំនួយសេដ្ឋកិច្ច និងជំនួយផ្សេងៗទៀតពីសហភាពសូវៀត។

ប្រទេសកម្ពុជាបានប្រកាន់យកនូវនយោបាយអព្យាក្រឹតក្នុងទំនាក់ទំនងអន្តរជាតិរបស់ខ្លួន។ នៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៥៧ តាមរយៈសមាជជាតិលើកទី៤ បានសម្រេចជាឯកច្ឆន្ទដាក់បញ្ចូលនយោបាយនេះទៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ (ប្រកាសឱ្យប្រើនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥៧) ដោយបានចែងថា : *ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសអព្យាក្រឹត* ។[១៣] ចាប់ពីពេលនោះមកនយោបាយអព្យាក្រឹតនេះ បានស្ថិតនៅជាមូលដ្ឋានគ្រឹះនៃនយោបាយការបរទេសនៃសង្គមរាស្ត្រនិយម។

នៅឆ្នាំ១៩៥៧ សហភាពសូវៀត និង កម្ពុជាបានចុះហត្ថលេខាលើទំនាក់ទំនងពាណិជ្ជកម្មនិងសហប្រតិបត្តិការលើវិស័យវប្បធម៌ និង វិទ្យាសាស្ត្រ។ យ៉ាងណាមិញ សហភាពសូវៀតបានទទួលស្គាល់ព្រះរាជាណាចក្រកម្ពុជាក្រោយពេលដែលប្រទេសនេះទទួលបានឯករាជ្យពីប្រទេសបារាំងបានពីរឆ្នាំ និង កន្លះឆ្នាំបន្ទាប់ពីប្រទេសកម្ពុជាក្លាយជាសមាជិកអង្គការសហប្រជាជាតិ ។ ការចូលជាសមាជិកនៃអង្គការសហប្រជាជាតិ គឺក្នុងគោលបំណងដើម្បីឱ្យប្រជាជាតិនានាទទួលស្គាល់នូវឯករាជ្យ និង អធិបតេយ្យភាពរបស់រដ្ឋ។ មិនត្រឹមតែប៉ុណ្ណោះការចូលជាសមាជិកក្នុងអង្គការពិភពលោកនេះ ក៏ដើម្បីពង្រឹងកិត្យានុភាពជាតិផងដែរ។

នាទសវត្សរ៍ឆ្នាំ១៩៦០ ប្រតិភូកម្ពុជាដឹកនាំដោយសម្តេចព្រះ នរោត្តម សីហនុ បានយាងធ្វើទស្សនកិច្ចជាលើកទី២ ទៅកាន់សហភាពសូវៀត ដើម្បីពង្រឹងទំនាក់ទំនងសាមគ្គីភាពមិត្តភាព និង ឱ្យមានការធានាពីសហភាពសូវៀតចំពោះអព្យាក្រឹតភាពរបស់កម្ពុជា។

ទំនាក់ទំនងរវាងប្រទេសទាំងពីរបានបន្តរហូតដល់ឆ្នាំ១៩៧៣ ចាប់តាំងពីមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ពីតំណែងប្រមុខរដ្ឋថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ នោះមក។ ទំនាក់ទំនងការទូតក្នុងពេលដែលពួកខ្មែរក្រហមបានដណ្តើមអំណាចនាខែមេសា ឆ្នាំ១៩៧៥ ក៏ត្រូវកាត់ផ្តាច់ដែរ។ ហើយជាថ្មីម្តងទៀត ប្រទេសទាំងពីរបានភ្ជាប់ទំនាក់ទំនងការទូតឡើងវិញក្រោយឆ្នាំ១៩៧៩ បន្ទាប់ពីប្រទេសកម្ពុជាបានត្រូវរំដោះចេញពីរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥_៩៧៩)។

---

[១៣]_សាន សុភាវនិត : នយោបាយការបរទេសនៃប្រទេសកម្ពុជា ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧០ សារណាបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ជំនាន់ទី១ ផ្នែកប្រវត្តិវិទ្យា ឆ្នាំ២០០២ រាជបណ្ឌិត្យសភាកម្ពុជា ទំព័រ២៥។

ពេលនោះ សហភាពសូវៀតបានចូលមកជួយប្រទេសកម្ពុជាឱ្យរួចផុតពីភាពអត់ឃ្លាន និង ការកសាងប្រទេសឡើងវិញ។

## ២_គោលនយោបាយសហភាពសូវៀតចំពោះប្រទេសកម្ពុជា

### ក_សម័យសង្គមរាស្ត្រនិយម

គោលនយោបាយរបស់សហភាពសូវៀតនៅក្នុងពិភពលោកនាទសវត្សរ៍១៩៥០_១៩៦០ មានសកម្មភាពយ៉ាងខ្លាំងក្លា តែដោយឡែកនៅតំបន់ឥណ្ឌូចិនហាក់នៅមានកម្រិតទាប ដោយសារតែបញ្ហាប្រឈមជាច្រើនបានកើតមាននៅក្នុងទ្វីបអឺរ៉ុប។ ម្យ៉ាងទៀត នៅតំបន់នេះមានមហាប្រទេសកុម្មុយនីស្តមួយថ្មីបានកកើតឡើង ទន្ទឹមនឹងសហភាពសូវៀតគឺសាធារណរដ្ឋប្រជាមានិតចិន។ គោលដៅសំខាន់នៃការពង្រីកឥទ្ធិពលសូវៀតនៅក្នុងពិភពលោក គឺការផ្សព្វផ្សាយមនោគមវិជ្ជាកុម្មុយនីស្តឱ្យកាន់តែធំទូលាយឡើង។ ទំនាក់ទំនងរវាងបក្សកុម្មុយនិស្តសហភាពសូវៀតជាមួយនឹងបក្សកុម្មុយនីស្តឥណ្ឌូចិនបានធ្វើឡើងតាមរយៈបក្សកុម្មុយនីស្តចិន[៦៨]។ យ៉ាងណាមិញកាលពីសន្និសីទនៅទីក្រុងតេហេរ៉ង់ឆ្នាំ១៩៤៣ គណៈប្រតិភូសូវៀតបានប្រកាសថា : *"សហភាពសូវៀតនឹងមិនបណ្តោយឱ្យសម្ព័ន្ធមិត្តកុម្មុយនីស្តទាំងឡាយបង្ហូរឈាមដើម្បីរំដោះឥណ្ឌូចិនឡើយ ហើយក៏មិនចង់ឃើញប្រទេសបារាំងបង្កើតរបប អាណានិគមសាជាថ្មីនៅទីនោះដែរ"*[៦៩]។ មេដឹកនាំសហភាពសូវៀតបានធ្វើការទាមទារ ដើម្បីឱ្យប្រទេសឥណ្ឌូចិនទាំងអស់មានឯករាជ្យភាព។

ជ័យជម្នះរបស់ពួកកុម្មុយនីស្តចិន នៅឆ្នាំ១៩៤៩ បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើចលនាតស៊ូរបស់ប្រជាជននៅឥណ្ឌូចិន។ នៅប្រទេសកម្ពុជា សន្ធិសញ្ញាប្រគល់ឯករាជ្យត្រូវបានចុះហត្ថលេខា នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩ នាទីក្រុងប៉ារីស[៧០]។ ក្នុងអំឡុងពេលនេះ ឥទ្ធិពលរបស់

---

[៦៨]_សហភាពសូវៀតបានទទួលស្គាល់សាធារណរដ្ឋប្រជាមានិតចិននៅថ្ងៃទី២ ខែតុលា ឆ្នាំ១៩៤៩។ គឺមួយថ្ងៃ ក្រោយពីការប្រកាសបង្កើត សាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៩។

[៦៩]_ជៀប សុផល : ***សង្គ្រាមនិងសន្តិភាព របស់កម្ពុជា*** កត្តាតំបន់និងកត្តាសកល ១៩៤៥_១៩៩១ ភ្នំពេញ ២០០៥ ទំព័រ ២៤៣ នៅក្នុងអត្ថបទដើម : "*Teheran-Yalta-Potsdam documents*. Moscow, 1982, pp.35-36"។

[៧០]_សន្ធិសញ្ញានេះត្រូវបានចុះហត្ថលេខានៅប្រទេសបារាំង នាវិមានអេលីហ្សេ រវាងលោកវ៉ាំងសង់ អូរីយ៉ូល ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង និង ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីពង្សព្រះរាជតំណាងព្រះករុណាសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។ សន្ធិសញ្ញានេះរួមមាន២០មាត្រា និង មានឯកសារជាឧបសម្ព័ន្ធមួយចំនួនទៀតភ្ជាប់មកជាមួយ។

សហភាពសូវៀតនៅក្នុងប្រទេសឥណ្ឌូចិន នៅមានកម្រិតតិចតួចនៅឡើយ។ បន្ទាប់ពីការកើតឡើងនូវប្រទេសកុម្មុយនីស្តដ៏ធំមួយ គឺ "សាធារណរដ្ឋប្រជាមានិតចិន" និងការចុះហត្ថលេខាលើកិច្ចសហប្រតិបត្តិការសហភាពសូវៀត_ចិន នៅឆ្នាំ១៩៥០[៧៥] ប្រទេសឥណ្ឌូចិនបានក្លាយជាមជ្ឈមណ្ឌលនយោបាយ យោធាមិនមែនសម្រាប់តែសហភាពសូវៀតប៉ុណ្ណោះទេ ថែមទាំងសម្រាប់ចិនប្រជាមានិតផ្ទាល់ និងសហរដ្ឋអាមេរិកផងដែរ។

នៅទសវត្សរ៍ឆ្នាំ១៩៥០ បក្សកុម្មុយនីស្តឥណ្ឌូចិននិងសហភាពសូវៀត ប្រទេសប្រជាធិបតេយ្យទាំងឡាយ និងប្រជាជនទូទាំងសកលលោកនឹងធ្វើដំណើរទៅមុខជានិច្ច ដើម្បីតស៊ូប្រឆាំងនឹងការដុតភ្លើងសង្គ្រាមបង្កដោយពួកចក្រពត្តិនិយម។ ពេលនោះ សហភាពសូវៀតបានយកចិត្តទុកដាក់ចំពោះបញ្ហាវៀតណាម ហើយទំនាក់ទំនងរវាងប្រទេសទាំងពីរប្រព្រឹត្តទៅ ជាពិសេសតាមរយៈបក្សកុម្មុយនីស្តចិន។ ចំពោះប្រទេសកម្ពុជា សហភាពសូវៀតហាក់ដូចជាទុកដោយឡែកនៅឡើយ សូម្បីតែពួកកុម្មុយនីស្តខ្មែរក៏ដោយ។ ទំនាក់ទំនងជាផ្លូវការលើកទី១ រវាងសហភាពសូវៀតនិងកម្ពុជា បានកើតឡើងនៅក្នុងសន្និសីទក្រុង

[៧៥]_អ័ក្សមូស្គូ_ប៉េកាំង (Moscow-Peking Axis) បានបង្កើតឡើងសហភាពសូវៀតនិងប្រទេសចិន នៅថ្ងៃទី១៤ កុម្ភៈ១៩៥០

ហ្សឺណែវឆ្នាំ១៩៥៤[៧៦]។ នៅក្នុងសន្និសីទនេះ គណៈប្រតិភូសូវៀតបានយកចិត្តទុកដាក់យ៉ាងខ្លាំង ជាពិសេសចំពោះគណៈប្រតិភូចិននិងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម។ អ្នកស្រាវជ្រាវសូវៀតបានធ្វើការកត់សម្គាល់ថា "ឯកភាពនៃសកម្មភាពរបស់សហភាពសូវៀតនិងសាធារណរដ្ឋប្រជាមានិតចិន សំខាន់បំផុតគឺការរួបរួមគ្នាតស៊ូប្រឆាំងនឹងនយោបាយចក្រពត្តិនិយម។ ហេតុដូច្នេះហើយការការពារផលប្រយោជន៍របស់ចិន ត្រូវមាននៅក្នុងដំណោះស្រាយបញ្ហាអន្តរជាតិ ហើយបញ្ហាឥណ្ឌូចិនបានក្លាយទៅជាបញ្ហាតំបន់ដែលសហភាពសូវៀតបានចាប់អារម្មណ៍នៅលើឆាកនយោបាយអន្តរជាតិ។ ក្នុងឱកាសមុនពេលបើកសន្និសីទនាទីក្រុងមូស្គូបានកើតឡើងនូវជំនួបរវាងជូ អនឡាយ

[៧៦]_ជាសន្និសីទស្តីពីបញ្ហាប្រទេសឥណ្ឌូចិន គឺការបញ្ឈប់សង្គ្រាមនៅប្រទេសកម្ពុជា ឡាវ និង វៀតណាម ការធានាឯករាជ្យភាពនៃប្រទេសទាំងបី និង ការបែងចែកប្រទេសវៀតណាមជាពីរ តាមខ្សែស្របទី១៧ ប្រទេសឡាវបែងចែកជាតំបន់សាមនឿ និង ផុងសាលី និង កងទ័ពបរទេសទាំងអស់ត្រូវដកចេញពីទឹកដីកម្ពុជា ហើយរាល់កម្លាំងតស៊ូខ្មែរត្រូវដាក់អាវុធចុះ ហើយចូលរួមជាមួយរដ្ឋាភិបាល។ ប្រទេសចូលរួមក្នុងសន្និសីទនេះមាន ចក្រភពអង់គ្លេស សហភាពសូវៀត សហរដ្ឋអាមេរិក បារាំង សាធារណរដ្ឋប្រជាមានិតចិន កម្ពុជា ឡាវ វៀតណាម និង ប្រទេសពាក់ព័ន្ធមួយចំនួនទៀត។

ហូ ជីមិញ និង ម៉ូឡូតូវ ហើយគេបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការនៃប្រទេសទាំងបី"[៣៣]។ ដោយឈរលើគំនិតរបស់សហភាពសូវៀត ភាគីទាំងអស់បានមូលមតិគ្នាកំណត់ទិសដៅនៅក្នុងការរួមប្រជុំនាទីក្រុងហ្សឺណែវគឺធ្វើយ៉ាងណាដើម្បីកុំឱ្យមានការផ្ទុះសង្គ្រាមជាថ្មីម្តងទៀត ដែលអាចកើតមានឡើងដោយសារសហរដ្ឋអាមេរិកការពារសន្តិសុខ សន្តិភាពនៅឧបទ្វីបឥណ្ឌូចិន និង បង្កើតឡើងនូវលក្ខខណ្ឌល្អប្រសើរ ដើម្បីរំដោះប្រទេសវៀតណាមឱ្យបានទាំងស្រុង។

ក្នុងខណៈនេះ យើងឃើញថាទិសដៅដ៏សំខាន់របស់សហភាពសូវៀត ធ្វើយ៉ាងណាដើម្បីកុំឱ្យសហរដ្ឋអាមេរិកកសាង និង ពង្រីកមូលដ្ឋានយោធាថែមទៀតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ គណៈប្រតិភូសហភាពសូវៀត នៅក្នុងសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤ មិនជំទាស់នឹងសាធារណរដ្ឋប្រជាមានិតចិន និងបារាំងដែលយល់ព្រមឱ្យកងទ័ពវៀតណាមខាងជើងដកចេញពីកម្ពុជា រំសាយកងកម្លាំង "ខ្មែរឥស្សរៈ" ហើយទទួលស្គាល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលឯករាជ្យជាបណ្តោះអាសន្នពីបារាំងតាំងពីឆ្នាំ១៩៤៩ មកនោះ។

[៣៣]_ដៀបសុផល: ដ.ឯ.មទំព័រ២៤៥

បន្ទាប់ពីបានបង្កើតបក្សសម្ព័ន្ធយោធាសេអាតូ[៣៤](SEATO) នៅឆ្នាំ១៩៥៤ សហរដ្ឋអាមេរិកបានចាប់ផ្តើមអូសទាញឱ្យប្រទេសកម្ពុជាចូលជាសមាជិកនៃប្លុកយោធានេះ។ ឥរិយាបថនេះមិនឆ្លើយតបទៅនឹងជំហររបស់សហភាពសូវៀត សាធារណរដ្ឋប្រជាមានិតចិន និងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ដែលបានគាំទ្រនយោបាយអព្យាក្រឹតរបស់សម្តេច ព្រះនរោត្តម សីហនុ។ នារដូវក្តៅ ឆ្នាំ១៩៥៦ សម្តេច ព្រះនរោត្តម សីហនុ បានយាងធ្វើទស្សនកិច្ចនៅសហភាពសូវៀត។ នៅក្នុងកិច្ចចរចាគូភាគីទាំងពីរបានចុះហត្ថលេខាបង្កើតទំនាក់ទំនងការទូតនៃប្រទេសទាំងពីរ និង ប្តូរអគ្គរដ្ឋទូតទៅវិញទៅមក[៣៥]។ សហភាពសូវៀតបានសន្យាថានឹងជួយ

[៣៤]_អង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍ (South East Asia Treaty Organization) បង្កើតឡើងនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ ១៩៥៤ ដែលមានប្រទេសចំនួន៨ ជាសមាជិកបង្កើតឡើងនៅក្រុងម៉ានីល ប្រទេសហ្វីលីពីន ឯទីបញ្ជាការតាំងនៅ ក្រុងបាងកក (ថៃ)។

[៣៥]_*ព្រះរាជសារព្រះបាទសម្តេចព្រះនរោត្តម សុរាម្រិត* ព្រះចៅរាជអាណាចក្រកម្ពុជា ផ្ញើជូនឯកឧត្តម ក្លេម៉ង់វ៉ូរ៉ូជីឡូហ្វ ប្រធានាធិបតីនៃសាធារណរដ្ឋសង្គមនិយមសូវៀត ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៥៦ អំពីការតែងតាំងឯកឧត្តម **ឡេង ង៉ែត** ជាឯកអគ្គរាជទូតវិសាមញ្ញនៃព្រះរាជអាណាចក្រកម្ពុជា ប្រចាំក្រុងមូស្គូ។

ដល់ប្រទេសកម្ពុជានៅលើវិស័យសេដ្ឋកិច្ច និង បច្ចេកទេស។ នៅទីនេះ តួនាទីរបស់មូស្គូមានភាពមិនទូលំទូលាយ ព្រោះនៅឆ្នាំ១៩៥៥ ប្រទេសកម្ពុជា និង សហរដ្ឋអាមេរិក បានចុះហត្ថលេខាស្តីអំពីការជួយឧបត្ថម្ភវិស័យយោធា។ សហរដ្ឋអាមេរិកបានប្រឹងប្រែងធ្វើយ៉ាងណា ដើម្បីកុំឱ្យប្រទេសកម្ពុជាក្លាយទៅជាតំបន់ប្រឆាំងនឹងសហរដ្ឋអាមេរិក។

ក្នុងឱកាសដែលលោកនីគីតា គ្រូសចូវ បានទទួលបដិសណ្ឋារកិច្ចសម្តេចព្រះ នរោត្តម សីហនុ នៅទីក្រុងមូស្គូ នាឆ្នាំ១៩៥៦ លោកបានគូសបញ្ជាក់ថា ជានិច្ចកាលប្រជាជនសូវៀតតែងតែគាំទ្រអស់ពីចិត្តពីថ្លើម ចំពោះការតស៊ូរបស់ប្រជាជនកម្ពុជា ដើម្បីឯករាជ្យភាពរបស់ខ្លួន។ យើងស្វាគមន៍ចំពោះ នយោបាយរបស់ប្រទេសកម្ពុជា ដែលមិនចូលក្នុងបក្សសម្ព័ន្ធយោធាក្នុងទិសដៅការពារសុខសន្តិភាព។ នៅក្នុងទស្សនកិច្ចនេះ ប្រទេសទាំងពីរបានធ្វើសេចក្តីប្រកាសរួមដោយជ្រើសយកពាក្យល្អ ផ្អែមល្ហែម បញ្ជាក់ពីទិសដៅនយោបាយរួមនៃប្រទេសទាំងពីរ។

ក្នុងអំឡុងឆ្នាំ១៩៥៨_១៩៦០ ពេលដែលសហរដ្ឋអាមេរិកបានបង្ខំឱ្យប្រទេសកម្ពុជាបោះបង់គោលនយោបាយអព្យាក្រឹត ហើយពេលដែលរដ្ឋការក្រុងព្រៃនគរនិងបាងកកបានធ្វើវិទ្ធង្សនាដោយកម្លាំងយោធាតាមព្រំដែននិងបង្កចលាចលក្នុងវិស័យពាណិជ្ជកម្មរបស់កម្ពុជា សហភាពសូវៀតបានចេញមុខការពារអព្យាក្រឹតនៃប្រទេសកម្ពុជានិងធានាខុសត្រូវដើម្បីកុំឱ្យប្រទេសកម្ពុជាចូលជាសមាជិកសេអាតូ។ គោលនយោបាយរបស់កម្ពុជានៅពេលនោះ ឆ្លើយតបនឹងគោលជំហររបស់សហភាពសូវៀត និង ចិន។

ក្នុងខណៈនេះ ប្រទេសកម្ពុជាត្រូវការជាទីបំផុតនូវការគាំទ្រលើឆាកអន្តរជាតិ ចំពោះនយោបាយអព្យាក្រឹតរបស់ខ្លួន ជាពិសេសពីសំណាក់ ប្រទេសមហាអំណាច។ សហភាពសូវៀតក៏ដូច្នោះដែរ នយោបាយអព្យាក្រឹតរបស់ព្រះរាជាណាចក្រកម្ពុជាត្រូវចំណុចដែលខ្លួនចង់បាន ម្យ៉ាងទៀត សហភាពសូវៀតក៏មិនពេញចិត្តដែរ បើប្រទេសកម្ពុជាចាកចេញពីគោលជំហរនេះ ព្រោះប្រទេសកម្ពុជាជាសមាជិកដ៏សកម្មមួយនៃចលនាមិនចូលបក្សសម្ព័ន្ធ។ ហេតុដូច្នេះហើយ បន្ទាប់ពីមានការផ្ទុះឡើងនូវចលនាប្រឆាំងនឹងសម្តេចព្រះនរោត្តម សីហនុ នៅដើមឆ្នាំ១៩៥៩ មក ក្នុងនាមឱ្យរដ្ឋាភិបាលសហភាពសូវៀត ឯកអគ្គរដ្ឋទូតសហភាពសូវៀតប្រចាំទីក្រុងភ្នំពេញបានធ្វើសេចក្តីថ្លែងការណ៍មួយជូនចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលមានខ្លឹមសារថា : "រដ្ឋាភិបាលសហភាពសូវៀត ប្រកបដោយការយោគយល់ និង

មានមនោសញ្ចេតនាយ៉ាងខ្លាំង ចំពោះការប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និង ប្រជាជនកម្ពុជា ដើម្បីឯករាជ្យភាព និង ម្ចាស់ការក្នុងការដឹកនាំប្រទេសជាតិរបស់ខ្លួន"។ ឯកអគ្គរដ្ឋទូតសហភាពសូវៀតបានគូសបញ្ជាក់ទៀតថា "ប្រជាជនកម្ពុជាមិនឯកោឡើយនៅក្នុងការតស៊ូដ៏មានវីរភាពរបស់ខ្លួននេះ"[៣៦]។ ក្រោយមក លោក គ្រូសចូវ មេដឹកនាំសូវៀតបានផ្ញើសារលិខិត ពិសេសមួយថ្វាយសម្តេចព្រះ នរោត្តម សីហនុ ដែលមានអត្ថន័យកាន់តែច្បាស់និងដាច់ខាតអំពីឥរិយាបថសហភាពសូវៀតចំពោះប្រទេសកម្ពុជា។

អត្ថន័យខាងលើនេះ ក៏ត្រូវបាននិយាយឡើងវិញម្តងទៀតនៅពេលដែល សម្តេចព្រះ នរោត្តម សីហនុ បានយាងធ្វើទស្សនកិច្ចនៅសហភាពសូវៀតនាឆ្នាំ១៩៦០។ ហើយក្រៅពីនេះ មេដឹកនាំសហភាពសូវៀត បានប្រើទំនាក់ទំនងរវាងប្រទេសកម្ពុជា និង សហភាពសូវៀតជាឧបករណ៍ឃោសនានយោបាយរបស់ខ្លួនទៅក្នុងទំនាក់ទំនងជាមួយប្រទេស ដែលកំពុងធ្វើចលនារំដោះជាតិចេញពីនឹមអាណានិគមនិយម ជាពិសេស នៅពេលនោះ គឺជាពេលដែលប្រទេសអាហ្វ្រិកមួយចំនួនធំបានចាកចេញពីរបបអាណានិគមនិយម គេបានឱ្យឈ្មោះថា "ឆ្នាំអាហ្វ្រិក"។

នៅមូស្គូពុំបានបង្ហាញអ្វីជាដុំកំភួនបញ្ជាក់អំពីអត្ថន័យនៃប្រទេសទាំងពីរទេ ក្រៅពី មានលក្ខណៈឃោសនានយោបាយតែប៉ុណ្ណោះ ។ លោកគ្រូសចូវបានមានប្រសាសន៍ថា "ហេតុដូចម្តេចបានជាសហភាពសូវៀត និង កម្ពុជា ដែលជារដ្ឋមានរបបនាសម្ព័ន្ធសង្គមខុសគ្នា ហើយបានធ្វើសហប្រតិបត្តិការគ្នាប្រកបដោយជោគជ័យ? យើងអាចធ្វើដូច្នេះទៅកើត ពីព្រោះប្រទេសយើងទាំងពីរមានគោលជំហររួមគ្នា គឺការរួមរស់ដោយសន្តិភាពជាមួយគ្នាមិនលូកដៃក្នុងកិច្ចការផ្ទៃក្នុងគ្នាទៅវិញទៅមក ហើយប្រទេសទាំងពីរដឹកនាំនយោបាយថែរក្សា និង ការពារសន្តិភាពលើសកលលោក"។ រីឯលោក ប្រេសណែវ ក៏បានធ្វើការកត់សម្គាល់ផងដែរថា "ទំនាក់ទំនងល្អរវាងប្រទេសយើងទាំងពីរកើតឡើងបាន ព្រោះប្រជាជនកម្ពុជាក៏ដូចជាប្រជាជនដទៃទៀតនៅទ្វីបអាស៊ី មើលឃើញថាសហភាពសូវៀតជាមិត្តម្នាក់ដ៏ស្មោះត្រង់និងអាចទុកចិត្តបានរបស់ពួកគេ"[៣៧]។

ដំណើរទស្សនកិច្ចនេះមានអត្ថន័យសំខាន់សម្រាប់សម្តេចសីហនុ។ ភាគីខាងសហ ភាពសូវៀត

---

[៣៦] _ជៀប សុផល: *សង្គ្រាមនិងសន្តិភាពក្នុងពេញ២០០៥* ទំព័រ២៤៦

[៣៧] _ដ_ *ទំព័រ ២៥០ (ប្រាវដា ០២_១២_១៩៦០)* ។

នៅក្នុងការធ្វើសេចក្ដីប្រកាសរួមមួយ បានសម្ដែងការគាំទ្រនូវនយោបាយក្រៅប្រទេសរបស់ព្រះរាជាណាចក្រកម្ពុជា"។ ហើយជាលើកទី១ដែលសហភាពសូវៀតបានប្រកាសជាផ្លូវការនូវការគាំទ្រការតស៊ូរបស់ប្រទេសកម្ពុជា ដើម្បីការពារអធិបតេយ្យភាព និងបូរណភាពដែនដីរបស់ខ្លួន។ នៅខែមករា ឆ្នាំ១៩៦១ ទីក្រុងម៉ូស្គូ បានគាំទ្រដល់សំណើរបស់សម្ដេចព្រះ នរោត្តម សីហនុ ឱ្យបើកការប្រជុំជាអន្តរជាតិស្ដីអំពីបញ្ហាកម្ពុជា និង ឡាវ[៧៨]។ ក្នុងខណៈនេះ បើសម្ដេចព្រះ នរោត្តម សីហនុ មានទិសដៅរឹងមាំក្នុងទំនាក់ទំនងជាមួយនឹងសហភាពសូវៀតនោះ សហភាពសូវៀតបានត្រៀមខ្លួនជាស្រេចទៅហើយ ដើម្បីដើរតួដ៏សំខាន់មួយនៅក្នុងឥណ្ឌូចិន។ ក្នុងពេលជាមួយគ្នានោះ សហភាពសូវៀត បានចាប់ផ្ដើមឧបត្ថម្ភដល់កម្ពុជា ដូចជាយន្តហោះជាដើម។ល។ កាយវិការនេះបានធ្វើឱ្យកម្ពុជាមានគោលជំហររឹងមាំប្រឈមនឹងវៀតណាមខាងត្បូងនិងប្រទេសថៃ។

រវាងប្រទេសកម្ពុជា និង សូវៀត ទំនាក់ទំនងផ្សេងៗ មានលក្ខណៈប្រកបដោយមិត្តភាពតាមផ្លូវការ ប៉ុន្តែតាមពិតសុទ្ធតែមានលក្ខណៈប្រយ័ត្នប្រយែងបង្ក។ ពួកខ្មែរសុទ្ធតែត្រូវធ្វើឱ្យទាល់គំនិតដោយពួកស្លាវ[៧៩] និង ទៅវិញទៅមក ហើយទំនាក់ទំនងផ្ទាល់ខ្លួនរវាងម្ខាង និង ម្ខាងទៀតមានសភាពនឹងថ្កល់ គ្មានករម្រើកទៅមុខបន្តិចសោះ។ វាចេញជាលទ្ធផលថា ពួកអ្នកការទូតរុស្ស៊ី ដែលបំពេញមុខងារនៅប្រទេសកម្ពុជាមានការក្រហល់ក្រហាយចិត្ត ដោយនឹកស្ដាយក្រោយតិចតួច ហើយថា ពួកនិស្សិតខ្មែរនៅក្រុងម៉ូស្គូ ក៏ពិបាកនឹងសម្របខ្លួនតាមការរស់នៅរបស់សូវៀតដែរ។ ប៉ុន្តែ សហភាពសូវៀតបានគាំទ្រដោយខ្ជាប់ខ្ជួន ចំពោះអព្យាក្រឹតរបស់ខ្មែរ ហើយបានយល់ព្រមផ្ដល់ជំនួយយោធា សេដ្ឋកិច្ច និងវប្បធម៌អប់រំដល់ប្រទេសកម្ពុជាទៀតផង[៨០]។ ជំនួយរបស់សហភាពសូវៀតបានកំណត់ជួយកសាង "មន្ទីរពេទ្យ កម្ពុជា_សូវៀត" ដ៏ធំសម្បើមមួយដែលមានចំណុះ ៥០០គ្រែ និងសាលាបច្ចេកទេសជាន់ខ្ពស់មួយសម្រាប់និស្សិត ១០០០នាក់។ ជំនួយជាសំណង់ទាំងពីរនេះ ស្មើនឹងទឹកប្រាក់ចំនួន ៥០០លានរៀល។ គេត្រូវរាប់បញ្ចូលនូវជំនួយយោធាមួយដែរ គឺការផ្គត់ផ្គង់កាំភ្លើង

[៧៨]_ជ.ឯ.ម. ទំព័រ ២៥០_២៥១។

[៧៩]_ជនជាតិស្លាវខាងជើង រួមមានរុស្ស៊ី បេឡារូស អ៊ុយក្រែន

[៨០]_សារលិខិត ស្ដីពីការប្រគល់ និងទទួលគ្រឹះស្ថានសិក្សាបច្ចេកទេសជាន់ខ្ពស់ រវាងតំណាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសហភាពសូវៀត ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៦៤។

ដេ.សេ.អា (*សម្រាប់បាញ់យន្តហោះ*) យន្តហោះ មិច_១៥ និងមិច_១៧ វថយន្តកាមីញ៉ុង...។ល។ គេដឹងថា រដ្ឋាភិបាលសូវៀតបានយល់ព្រមផ្តល់ជំនួយរបស់ខ្លួនជាសំខាន់ដល់បណ្តាប្រទេសតតិយលោក ក្រោមទម្រង់ជាប្រាក់កម្ចីក្នុងរយៈពេលវែងនិងយកអត្រាការប្រាក់ទាប (២,៥ %) ហើយ ប្រទេសកម្ពុជាបានចុះកិច្ចសន្យាខ្ចីប្រាក់ចំនួន ១២ លានរូប្លដើម្បីធ្វើការកសាងទំនប់វារីអគ្គិសនីធំមួយនៅភ្នំកំចាយ[៦១]។ ប៉ុន្តែការសិក្សារបស់ពួកវិស្វករសូវៀតពុំបានសម្រេចជាលទ្ធផលទេនិងនាំទៅដល់ការបំភ្លេចចោលគម្រោងនេះទាំងស្រុង។

ពិតហើយ នយោបាយអាស៊ីរបស់វិមានក្រឹមឡាំងពុំមានភាពទន់ភ្លន់ដូចនយោបាយរបស់បាកាំងដឹហ្គោលនិយម ឬ ប្រទេសចិនម៉ៅនិយមឡើយ។ គេវិនិច្ឆ័យរឿងនេះតាមរយៈការគាបសង្កត់ផ្នែកការទូត ដែលបញ្ចេញឱ្យឃើញដោយគ្មានលទ្ធផល ដើម្បីជម្នះការបដិសេធរបស់ប្រទេសកម្ពុជា ដែលមិនព្រមចុះហត្ថលេខាលើ សន្ធិសញ្ញាក្រុងមូស្គូស្តីពីការហាមឃាត់មិនឱ្យធ្វើការសាកល្បងអាវុធនុយក្លេអ៊ែរក្នុងបរិយាកាស។ ប៉ុន្តែរឿងរ៉ាវដែលបង្ហាញឱ្យឃើញច្បាស់ជាងគេ ប្រហែលជាការធ្វើឱ្យខូចកិត្តិយសដល់ព្រះប្រមុខរដ្ឋរបស់កម្ពុជានៅឆ្នាំ១៩៦៥។ មុននឹងទ្រង់ត្រូវយាងឱ្យទៅចូលរួមក្នុងបុណ្យខួបបដិវត្តន៍ ខែតុលា លើកទី ៤៨ សម្តេច សីហនុ បានចាប់ផ្តើមព្រះរាជដំណើររបស់ព្រះអង្គ តាមរយៈ ទស្សនកិច្ចមួយនៅប្រទេសចិន និង ប្រទេសកូរ៉េ។ តែថា នៅថ្ងៃទី៨ ខែតុលា គឺមុនមួយថ្ងៃនៃព្រះរាជ ដំណើរចាកចេញពីទីក្រុងព្យុងយ៉ាងទៅទីក្រុងមូស្គូ ឯកអគ្គរដ្ឋទូតសូវៀតបានអញ្ជើញមកទូលថ្វាយព្រះអង្គឱ្យដឹងទាំងគំរោះគំរើយថា : *"ពួកមេដឹកនាំ សូវៀតកំពុងជាប់រវល់យ៉ាងខ្លាំង ហើយមិនអាចទទួលធ្វើបដិសណ្ឋារកិច្ចបានឡើយ"*[៦២]។ គ្មានការពន្យល់ណាមួយត្រូវបានធ្វើឡើង ទាំងផ្លូវការនិងមិនផ្លូវការសម្រាប់ជាការសុំទោសចំពោះការផ្តើនបំបាក់មុខនេះទេ ប៉ុន្តែតាមសម្មតិកម្មដែលលាន់ខ្ទរខ្ទារ គឺថាពួកសូវៀតមិនសប្បាយចិត្តនឹងសុន្ទរកថា ដែលសម្តេចថ្លែងនៅប្រទេសចិន ដោយក្នុងនោះ ព្រះអង្គបានបរិហាររិះគន់ពីភាពទន់ជ្រាយក្នុងការ ប្រឆាំងចក្រពត្តិរបស់ "បណ្តាប្រទេសខ្លះ" ដែលក្នុងនោះសហភាពសូវៀតទំនងជាលើកមកដាក់ ខ្លួនដែរ[៦៣]។

[៦១] _ Charles Meyer, *ក្រោយស្នាមញញឹមរបស់ខ្មែរ* ប្រែសម្រួលដោយទីយាយុ ក្នុងកាសែតរស្មីកម្ពុជា ឆ្នាំ២០០១ ទំព័រ១៩៥។

[៦២] Charles Meyer, *ក្រោយស្នាមញញឹមរបស់ខ្មែរ* ទំព័រ២២៥។

[៦៣] _ដ_ ទំព័រ២២៥។

ការខឹងក្រេវក្រោធរបស់សម្ដេចសីហនុ ដែលរួមចំណែកដោយរដ្ឋាភិបាល សភាទាំងពីរ ។ល។ មានលក្ខណៈពុះពារយ៉ាងខ្លាំង ហើយមួយភ្លែតនោះ កម្ពុជាមានបំណងធ្វើការកាត់ផ្ដាច់ទំនាក់ទំនងការទូតទៀតផង។ ប៉ុន្តែពួកសូវៀតនៅស្ងៀមធ្វើព្រងើយកន្តើយ ពួកកម្ពុជាទៅជាចាប់ស្រុះស្រួលភ្លាម ហើយមួយឆ្នាំក្រោយមកសម្ដេចព្រះប្រមុខរដ្ឋ និង ពួកមេដឹកនាំកម្ពុជាបានបង្កើនសមានចិត្តសម្ដែងឱ្យឃើញមិត្តភាពរឹតតែខ្លាំងឡើង ដែលពុំធ្លាប់មានសោះកាលពីមុនមក។ ហេតុដូច្នេះហើយ បានជាសហភាពសូវៀតជាប្រទេសតែមួយគត់ ដែលហ៊ានបំពេញនូវវិធានការក្រៅផ្លូវការផ្សេងៗ ដើម្បីបង្ហាញឱ្យឃើញការរំជួលចិត្តរបស់ខ្លួនចំពោះមុខការបង្ក្រាប ដែលអ្នករងគ្រោះសុទ្ធតែជាកម្លាំងឆ្វេងនិយម បន្ទាប់មកចំពោះមុខយុទ្ធនាការប្រឆាំងបដិវត្តន៍វៀតណាម ដោយមិនបង្កឱ្យមានការចោទប្រកាន់ជាទម្លាប់ថាជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងឡើយ។ ទន្ទឹមនឹងនោះ រដ្ឋាភិបាលកម្ពុជាពុំបានធ្វើសេចក្ដីថ្លែងការណ៍ណាមួយ ស្ដីពីការលុកលុយរបស់សូវៀតទៅលើប្រទេសចេកូស្លូវ៉ាគីទេ ហើយសម្ដេចព្រះ នរោត្តម សីហនុ បានឱ្យគេកាត់ចោលនូវការរិះគៀនផ្សេងៗ ដែលប្រឆាំងនឹងសកម្មភាពរបស់សូវៀតនេះចេញពីសារព័ត៌មានដែលរដ្ឋ ធ្វើជាតួបនីយកម្មទាំងអស់។

នាទសវត្សរ៍ឆ្នាំ ១៩៦០ ការផ្ដើមទាក់ទងជាមួយសហភាពសូវៀតបានកើនរឹតតែខ្លាំង។ នៅខែមេសា គណៈបេសកកម្មមួយបានត្រូវបញ្ជូនទៅកាន់ទីក្រុងមូស្គូ ដើម្បីសុំជំនួយចាំបាច់បំផុតមួយផ្នែកសម្ភារៈសឹករួមផ្សំនឹងការខ្ចីប្រាក់ជាយថាហេតុមួយក្នុងរយៈពេលយូរផង។ ប៉ុន្តែពួកមេដឹកនាំសូវៀតបានបង្ហាញឱ្យឃើញភាពស្ទាក់ស្ទើរយ៉ាងខ្លាំង ជាពិសេសក្នុងការផ្គត់ផ្គង់នាវាវ៉ឺដែត (នាវាល្បាត) បំពាក់ដោយអាវុធបាលីស្ទិក និង ភាពមិនច្បាស់លាស់ក្នុងការផ្គត់ផ្គង់អាវុធ និង គ្រាប់រំសេវដែលអាចយកមកប្រើប្រាស់ ដើម្បីវាយប្រយុទ្ធនឹងពួកបះបោរកុម្មុយនីស្ត[៩៤]។

សហប្រតិបត្តិការ រវាងសហភាពសូវៀតនិងប្រទេសកម្ពុជាបានបន្តទៅថ្ងៃមុខទៀត។ តាមសំណូមពររបស់ សម្ដេចព្រះ នរោត្តម សីហនុ នៅពាក់កណ្ដាលឆ្នាំ១៩៦៣ សហភាពសូវៀតបានរៀបចំជាស្រេចដើម្បីជួយធ្វើអន្តរាគមន៍ដល់កម្ពុជាដើម្បីមានសិទ្ធិធ្វើនាវាចរតាមដងទន្លេមេគង្គ និងសុវត្ថិភាពក្នុងការដឹកនាំទំនិញចូលកំពង់ផែកំពង់សោមពីសំណាក់រដ្ឋការក្រុងព្រៃនគរ ដែលបានចោទកម្ពុជាថា បានប្រើប្រាស់ផ្លូវនាវាចរទាំងនេះ

[៩៤] - Charles Meyer, *ក្រោយស្នាមញញឹមរបស់ខ្មែរ* ទំព័រ២៦២ ។

ដើម្បីដឹកនាំសព្វាវុធទៅកាន់វៀតណាមខាងត្បូង ជួយដល់កងទ័ពរំដោះជាតិវៀតណាម។

នៅខែមីនា ឆ្នាំ១៩៦៦ លោកសឺន សាន បានអញ្ជើញទៅទីក្រុងមូស្គូ សហភាពសូវៀតបានសន្យាជាថ្មីម្តងទៀត នូវការឧបត្ថម្ភដល់ប្រទេសកម្ពុជានូវសព្វាវុធ និង វិស័យផ្សេងៗទៀត។ ភាគីទាំងពីរបានប្រារព្ធពិធីបុណ្យខួបទី១០ នៃទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ ហើយនៅទីក្រុងមូស្គូបានបង្កើតសមាគមមិត្តភាព "កម្ពុជា-សហភាពសូវៀត"។ ក្នុងដំណាក់កាលនោះដែរ គឺជាពេលដែល "បដិវត្តន៍វប្បធម៌" ចិនកំពុងចេះសន្ធោសន្ធៅឡើង បានធ្វើឱ្យទំនាក់ទំនងកម្ពុជា-សូវៀតធ្លាក់ចុះ ហើយជាហេតុនាំឱ្យមានការខិតជិតគ្នាសាជាថ្មីរវាងប្រទេសកម្ពុជា និង សហរដ្ឋអាមេរិក។

### ១-សម័យសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)

តាមផ្លូវយាងត្រឡប់មកកាន់កម្ពុជាវិញ ដោយកាត់តាមមូស្គូ និង ក្រុងប៉េកាំង សម្តេចព្រះនរោត្តម សីហនុ បានទ្រង់ជ្រាបពីការទម្លាក់ព្រះអង្គពីតំណែងពីលោកប៉ូដហ្គ័រនី (Podgony) ប្រធានប្រេស៊ីដ្យូមជាន់ខ្ពស់សូវៀត និងលោក កូស៊ីហ្គីន (Kossyguine) ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រីសហភាពសូវៀត។ នៅពេលសម្តេចយាងមកដល់ក្រុងប៉េកាំង ព្រះអង្គមានលក្ខណៈរារែកក្នុងព្រះទ័យយ៉ាងខ្លាំង។ សម្តេចព្រះ នរោត្តម សីហនុ បានយាងត្រឡប់មកភ្នំពេញថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៥។ ព្រឹត្តិការណ៍នេះបានកម្ទេចចោលនូវរាល់គម្រោងនៃប្រទេសទាំងពីរ។

ថ្វីត្បិតតែមានការអះអាងថា ពួកកុម្មុយនីស្តខ្មែរពុំបានទាក់ទងដោយផ្ទាល់ជាមួយនឹងបក្សកុម្មុយនិស្តនៃសហភាពសូវៀតក្តី ក៏រហូតមកទល់នឹង ឆ្នាំ១៩៧០ ពួកកុម្មុយនីស្តខ្មែរទូទៅសុទ្ធតែជាអ្នកស្ថិតក្រោមឥទ្ធិពលសូវៀតផងដែរ។

ក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ពីអំណាចនាខែមីនា ឆ្នាំ១៩៧០ ទាំងប្រទេសបារាំង ទាំងសហភាពសូវៀតពុំបានទទួលស្គាល់រដ្ឋាភិបាលនិរទេសរបស់ព្រះអង្គទេ ដោយនៅរក្សាអ្នកតំណាងរបស់គេ នៅអមរដ្ឋាភិបាលសាធារណរដ្ឋនិយមរបស់ លន់ នល់ ដដែល។ សហភាពសូវៀត បានរក្សាស្ថានទូតរបស់ខ្លួនរហូតដល់ឆ្នាំ១៩៧៣។

ដោយលក្ខណៈប្រុងប្រយ័ត្នបំផុត ក្រុងមូស្គូបានដាក់ជំនួសឯកអគ្គរដ្ឋទូតរបស់ខ្លួននៅសាធារណរដ្ឋខ្មែរ ដោយការធារីម្នាក់ ហើយយល់ព្រមផ្តល់នូវការគាំទ្រ ចំពោះរណសិរ្សរួបរួមជាតិកម្ពុជាវិញ។ "អំពើក្បត់" នេះល្មមតែធ្វើឱ្យពួកអ្នកការទូតសូវៀត ដែលប្រចាំការនៅក្រុងភ្នំពេញនៅថ្ងៃទី១៧ មេសា ១៩៧៥ ត្រូវកងទ័ពខ្មែរនាំ

យកទៅទាំងបង្ខំជាមួយជនជាតិបរទេសផ្សេងៗ ទៀតទៅដាក់នៅក្នុងស្ថានទូតបារាំង ដែលពួកខ្មែរក្រហមបានជ្រើសរើសសម្រាប់ដាក់ន្លែងប្រមូលផ្ដុំពួកមិនមែនខ្មែរ[៩៥]។

**គ_សម័យកម្ពុជាប្រជាធិបតេយ្យ(១៩៧៥_១៩៧៩)**

ក្នុងអំឡុងពេលដែលប្រទេសកម្ពុជាគ្រប់គ្រងដោយពួកខ្មែរក្រហមពីឆ្នាំ១៩៧៥_១៩៧៩ នោះសហភាពសូវៀតជាអ្នកគាំទ្រពួកវៀតណាម និងពួកចិនប៉េកាំងគាំទ្រពួកខ្មែរក្រហម។ ក្នុងពេលនេះដែរ ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរត្រូវកាត់ផ្ដាច់ទាំងស្រុង។

**សន្និដ្ឋាន**

សរុបមក នយោបាយការបរទេសរបស់សហភាពសូវៀត ចំពោះប្រទេសកម្ពុជាពីឆ្នាំ១៩៥៦ ដល់ឆ្នាំ១៩៧៩ គឺទទួលបានលទ្ធផលវិជ្ជមានផងនិងអវិជ្ជមានផង ដោយសារតែមូលហេតុមួយចំនួនដូចជា ប្រទេសទាំងពីរស្ថិតនៅឆ្ងាយពីគ្នា ជាទំនាក់ទំនងរវាងមហាអំណាចមួយ និង ប្រទេសតូចមួយការយល់គ្នាក៏ពុំសូវបានល្អ ជាពិសេសដោយសារស្ថានការណ៍ក្នុងពិភពលោកមិនអនុគ្រោះដល់ទំនាក់ទំនងរវាងប្រទេសទាំងពីរផងដែរ។

ក្នុងដំណាក់កាលដំបូងនៃទំនាក់ទំនងរវាងប្រទេសទាំងពីរពុំមានលក្ខណៈស្មើមុខនឹងគ្នាឡើយ ដោយសហភាពសូវៀតជាមហាអំណាចសង្គមនិយមលើពិភពលោក ហើយមានបំណងពង្រីកឥទ្ធិពលរបស់ខ្លួននៅតាមបណ្ដាប្រទេសដែលទើបនឹងទទួលបានឯករាជ្យពីនឹមអាណានិគមឬកំពុងតែតស៊ូទាមទារឯករាជ្យពីនឹមអាណានិគមនិយមបរទេស។ ប្រទេសកម្ពុជាទើបតែនឹងទទួលបានឯករាជ្យបរិបូរណ៍ត្រឹមតែបីឆ្នាំប៉ុណ្ណោះ ហើយត្រូវរៀបចំនយោបាយការបរទេសដោយខ្លួនឯងគឺចង់បានការធានាពីមហាអំណាចណាមួយ ដើម្បីសេចក្ដីសុខ សន្តិភាពសម្រាប់ប្រទេសនិងប្រជាជនរបស់ខ្លួន។ ឯក្នុងដំណាក់កាលទី២ នៃទំនាក់ទំនងរវាងសហភាពសូវៀតនិងសាធារណរដ្ឋប្រជាមានិតកម្ពុជាមានលក្ខណៈខុសគ្នាត្រង់ថា ប្រទេស កម្ពុជាទើបតែងើបផុតពីរបបខ្មែរក្រហម ដែលដឹកនាំប្រទេសទៅរកភាពវិនាសអន្តរាយជិតបួនឆ្នាំ។ ពេលនោះ ប្រទេសកម្ពុជាត្រូវការជំនួយជាបន្ទាន់ ពីបរទេស ដើម្បីស្ដារនិងកសាងប្រទេសពីភាពខ្ទេចខ្ទាំដែលបន្សល់ដោយរបបខ្មែរក្រហម។ សហភាពសូវៀតជាប្រទេសទីមួយដែលបានចូលមកជួយប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៩ មក។

---

[៩៥] _ម៉ារតាំង អាឡិចសង់ឌ្រី : ***ជំងឺកម្ពុជា*** បកប្រែដោយ ទីឃាយុ ក្នុងកាសែតរស្មីកម្ពុជា ឆ្នាំ២០០? ទំព័រ១៩២ ។

គន្ថនិទ្ទេស

១_ឯកសារនិពន្ធភាសាខ្មែរ


_កែវ សំណាង: ***កំពូលមេដឹកនាំពិភពលោក ភាគ១_៣*** ភ្នំពេញ ១៩៩៩។

_ខៀវ ថារីកា: ***ទំនាក់ទំនងអន្តរជាតិ*** ឯកសារសម្រាប់សិក្សាស្រាវជ្រាវ ភ្នំពេញ ២០០១។

_មីខេយេវ យ: ***ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា*** បកប្រែដោយបណ្ឌិត ឡុង សៀម ម៉ូស្គូ ១៩៨៥ ។

_សីហនុ ន: ***អនុស្សាវរីយ៍ផ្អែមល្ហែមនិងជូរចត់*** ១៩៩៣។

_សីហនុ ន.និងប៉ែរណាដ៍ គ្រីស័រ ***:សម្តេចព្រះនរោត្តម សីហនុ រំលឹកប្រវត្តិរឿងដើមជាមួយថ្នាក់ដឹកនាំខ្លះនៅលើពិភពលោក*** Yohan Publication, Japan ១៩៩០។

_រីចាត សុទ្បា ***:កម្ពុជារបស់សម្តេចសីហនុ*** បកប្រែដោយទីយាយុ ក្នុងការសែតរស្មីកម្ពុជា។

_ហារីស្ហ និងជូលី មេតាហ៍: ***ហ៊ុន សែន: បុរសខ្លាំងរបស់កម្ពុជា*** បកប្រែដោយ កែ សឿន និងជួន នឿន ឆ្នាំ១៩៩៩។

_ជៀប សុផល:កម្ពុជា: ***សង្គ្រាមនិងសន្តិភាព*** (កត្តាតំបន់និងសកលលោក) ១៩៤៥_១៩៩១ ភ្នំពេញ ២០០៥។

_ម៉ារី អា. ម៉ារតាំង ***:ជំងឺកម្ពុជា*** បកប្រែដោយទីយាយុ ក្នុងការសែតរស្មីកម្ពុជា ឆ្នាំ២០០ ?។

_នីកូឡា រីហ្គោ: ***កម្ពុជាក្នុងព្យុះសង្ឃរា*** បកប្រែដោយទីយាយុ ក្នុងការសែតរស្មីកម្ពុជា ឆ្នាំ២០០០។

_សាល ម៉ែយេ ***:ក្រោយស្នាមញញឹមរបស់ខ្មែរ*** បកប្រែដោយទីយាយុ ក្នុងការសែតរស្មីកម្ពុជា ឆ្នាំ២០០១។

_ប៉ូល ជ្រែហ្ស ***:ប៉ុល ពត: មេពជ្ឈឃាត*** បកប្រែដោយទីយាយុ ក្នុងការសែតរស្មីកម្ពុជា ឆ្នាំ២០០២។

_បេន រៀនិន: ***របបប៉ុល ពត*** បកប្រែដោយទីយាយុ ក្នុងការសែតរស្មីកម្ពុជា។

_ណាយ៉ាន់ ចាន់ដា: ***បងប្អូនដែលជាសត្រូវ*** បកប្រែដោយទីយាយុ។

_សោម សេកកុមារ: ***វិបត្តិកម្ពុជា និងទំនាក់ទំនងជាមួយបរទេស*** ប៉ារីស ២០០០។

_វីឈ័រ ហ្វីលីព ***: កម្ពុជា: សោកនាដ្យកម្មមួយនៃសម័យយើង*** បកប្រែដោយទីយាយុ ក្នុងការសែតរស្មីកម្ពុជា ឆ្នាំ២០០៣។

_ដេវីឌ ចាណ្ឌល័រ ***: ប្រវត្តិសាស្ត្រខ្មែរ*** មជ្ឈមណ្ឌលខេមរសិក្សា ២០០៥

_ឌី ខាំបូលី ***: ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ*** (១៩៧៥_១៩៧៩) មជ្ឈមណ្ឌលឯកសារកម្ពុជា ២០០៧។

-សាន សុភាវនិត : ***នយោបាយការបរទេសនៃប្រទេសកម្ពុជា*** ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧០ សារណាបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ជំនាន់ទី១ នៃរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០០២។

-អេលីហ្សាបែត បែកយ័រ : ***ទឹកភ្នែកកម្ពុជា*** (ចំណងជើងដើម :**Les larmes du Cambodge. L'histoire d'un auto-génocide** ) បកប្រែដោយទី យាយុ ភ្នំពេញ ១៩៩៨?

## ២_ឯកសារនិពន្ធភាសាបរទេស

*-Chandler David P. -The Tragedy of Cambodian History,* ១៩៩១ ។

*A History of Cambodia,* ១៩៩១ ។

*-Corfield J.& Summers L., Historical Dictionary of Cambodia, 2003.*
*-Donald P. Whitaker, Judith M. Heimann & others, Area handbook for the Khmer Republic, 1973.*
*-Francois Im, Le Cambodge dans relation internationale, RAC. 2007*
*-Isaev M.P.,The Foreign Policy of the State of Indochina, Moscow, Nauka, 1989. (in Russian)*
*-Kobelev E., Kampuchea, 1985 (in Russian), pp.186-188 (Interview with Hun Sen, prime minister and Minister of Foreign affairs of RPK).*
*Miheev U.Y., History of Kampuchea, Moscow, Naouka, 1981. (in Russian)*
*-Michael Vickery, Cambodia : 1975-1982, 1984.*
*-Milton Osborne, Sihanouk : Prince of light , prince of darkness. Silkworms books,1994.*
*Mosiakov D.V., Cambodia, Moscow, 1991. (in Russian .*
*-Morris, Stephen J., Why Vietnam invaded Cambodia. Political culture & the causes of war., Stanford Univ. 1999.*
*-Mysliwiec, Eva, Kampuche : Punishing the poor (The International Isolation of Kampuchea), Oxfarm 1988.*
*-Sihanouk N., -My war with the CIA, 1973.*
*-War and Hope, 1980.*
*-Shawcross W., Sideshows, 1991.*
*-Smith M. Roger, Cambodia's Foreign Policy. Cornell University Press, New York,1965.*

# ការឆ្លុះបញ្ចាំងទៅលើដំណើរការនីតិកម្មនៅកម្ពុជា



លោក **គិន ភា**

បេក្ខជនបណ្ឌិតផ្នែកវិទ្យាសាស្ត្រនយោបាយ

នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១_សេចក្តីផ្តើម

នៅក្នុងសង្គមប្រជាធិបតេយ្យសេរី ប្រទេសជាតិមួយត្រូវគ្រប់គ្រងដោយច្បាប់ មិនមែនគ្រប់គ្រងដោយមនុស្សនោះទេ។ ការគ្រប់គ្រងដោយច្បាប់មិនទាន់គ្រប់គ្រាន់ទេ ច្បាប់ត្រូវឆ្លុះបញ្ចាំងពីបំណងប្រាថ្នារបស់ប្រជាជន និង តម្រូវការបច្ចុប្បន្នភាពរបស់សង្គមជាតិ មិនមែនសម្រាប់បម្រើអោយឆន្ទៈនិងបំណងប្រាថ្នារបស់ក្រុមជនមួយចំនួនតូច។ បើយោងតាមស្មារតីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានដាក់ចេញនូវយន្តការជាច្រើន ដើម្បីធានាដំណើរការប្រជាធិបតេយ្យសេរីនៅកម្ពុជា។ ក្នុងន័យនេះ សិទ្ធិសេរីភាព និង បញ្ញត្តិនៃប្រជាធិបតេយ្យសេរី មិនអាចត្រូវបានដកហូត ដោយច្បាប់បានឡើយ។

មាត្រា៥១ ថ្មីនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានកំណត់ឱ្យមានស្ថាប័នកំពូលបីដាច់ពីគ្នាគឺ ស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និង ស្ថាប័នតុលាការ ហើយស្ថាប័នទាំងបីនេះមានតួនាទី និងអំណាចខុសៗគ្នា។ រដ្ឋធម្មនុញ្ញបានកំណត់ថា ព្រឹទ្ធសភានិងរដ្ឋសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។

ដំណើរការកសាងច្បាប់នៅកម្ពុជា ត្រូវប្រើប្រាស់ពេលវេលា និង នីតិវិធីស្មុគស្មាញជាច្រើន។ អត្ថបទនេះនឹងធ្វើការបង្ហាញពីដំណើរការ និង នីតិវិធីទាំងឡាយ ក្នុងការកសាងច្បាប់នៅកម្ពុជា និងធ្វើការឆ្លុះបញ្ចាំងគោលការណ៍ និង ស្មារតីនៃច្បាប់ទាំងនោះ ដើម្បីប្រៀបធៀបទៅនឹងបំណងប្រាថ្នារបស់ប្រជាជននិងតម្រូវការបច្ចុប្បន្នភាពរបស់សង្គមជាតិ។

## ២_តើនរណាមានសិទ្ធិផ្តួចផ្តើមគំនិត ធ្វើច្បាប់?

យោងតាមមាត្រា៩១ ថ្មីនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានចែងថា: "*សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់*"។ ក្នុងន័យនេះ រដ្ឋធម្មនុញ្ញមិនកំណត់ថាតើសមាជិកព្រឹទ្ធសភា ឬ សមាជិករដ្ឋសភាប៉ុន្មានរូប ទើបមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់នោះទេ។ ប៉ុន្តែការសង្កេតជាទូទៅក្នុងអាណត្តិទី១ អាណត្តិទី

២ និងអាណត្តិទី៣នៃរដ្ឋសភា ច្បាប់ភាគច្រើនព្រាងឡើងដោយរាជរដ្ឋាភិបាល។ ដោយឡែក ព្រឹទ្ធសភា និងរដ្ឋសភាដែលត្រូវបានរដ្ឋធម្មនុញ្ញកំណត់ថាជាអង្គការតែមួយគត់ដែលមានអំណាចនីតិបញ្ញត្តិនោះគឺពុំបានរៀបចំសេចក្តីស្នើច្បាប់ណាមួយគួរអោយកត់សម្គាល់ឡើយគឺភាគច្រើនចាំតែពិភាក្សាអនុម័ត និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ដែលព្រាងឡើងដោយរដ្ឋាភិបាលតែប៉ុណ្ណោះ។

បើយោងតាមស្មារតីនៃរដ្ឋធម្មនុញ្ញបានកំណត់ថា អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និង សាលាជម្រះក្តី[៨៦]។ ក្នុងន័យនេះមានន័យថា ប្រជាពលរដ្ឋក៏មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ដែរ តែប្រជាពលរដ្ឋត្រូវប្រើសិទ្ធិរបស់ខ្លួនតាមរយៈតំណាងរាស្ត្រ។ រដ្ឋធម្មនុញ្ញបានចែងថា តំណាងរាស្ត្រនៅក្នុងរដ្ឋសភាជាតំណាងប្រជាជាតិខ្មែរទាំងអស់ ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ[៨៧]។ដូច្នេះ ប្រជាពលរដ្ឋនៅមណ្ឌលណាក៏ដោយនៅប្រទេសកម្ពុជាសុទ្ធតែអាចយកកង្វល់និងតម្រូវការរបស់ខ្លួនទៅឱ្យតំណាងរាស្ត្រ ដើម្បីជជែកពិភាក្សាក្នុងរដ្ឋសភាបានទាំងអស់។ បញ្ហានៅត្រង់ថា តើតំណាងរាស្ត្រអាចពាំនាំកង្វល់ តម្រូវការ និង ឆន្ទៈរបស់ប្រជាពលរដ្ឋ ទៅបញ្ចូលក្នុងច្បាប់ដែលខ្លួនធ្វើដែរទេ?

នៅក្នុងអាណត្តិកន្លងមក រាជរដ្ឋាភិបាល និងរដ្ឋសភាក៏ដូចជាព្រឹទ្ធសភាបានធ្វើច្បាប់ជាច្រើន ប៉ុន្តែប្រជាពលរដ្ឋភាគច្រើនមិនបានដឹងថា ច្បាប់នោះគេព្រាងឡើង ឬ ស្នើឡើងនៅពេលណាមានខ្លឹមសារយ៉ាងណានោះទេ រហូតដល់សេចក្តីព្រាងច្បាប់ និង សេចក្តីស្នើច្បាប់ទាំងនោះត្រូវបានលើកយកមកជជែកពិភាក្សា នៅក្នុងរដ្ឋសភាទើបប្រជាពលរដ្ឋបានដឹង។ ទោះបីជា រដ្ឋធម្មនុញ្ញបានកំណត់ថា តំណាងរាស្ត្រនៅក្នុងរដ្ឋសភាគឺ ជាតំណាងរបស់ប្រជាពលរដ្ឋក៏ដោយ ក៏ប្រជាពលរដ្ឋភាគច្រើនបាននិយាយថា តំណាងរាស្ត្រមួយចំនួនធំមិនតំណាងឱ្យគំនិត និង ឆន្ទៈរបស់ប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួនទេ។ ច្បាប់ជាច្រើនត្រូវបានគេព្រាងឡើងដោយស្ងាត់ៗ ហើយគេពិបាកនឹងរកសេចក្តីព្រាងច្បាប់ទាំងនោះណាស់។ មានតែអង្គការសង្គមស៊ីវិលមួយចំនួនប៉ុណ្ណោះ បានទទួលសេចក្តីព្រាងច្បាប់នោះ ហើយបានធ្វើការផ្លាស់ប្តូរនិងផ្តល់អនុសាសន៍ខ្លះៗ តែត្រូវបានគេកែលម្អតាមបន្តិចបន្តួចប៉ុណ្ណោះ។

### ៣_គោលការណ៍ច្បាប់

ទោះបីច្បាប់ត្រូវព្រាងឡើង ឬ ស្នើឡើងដោយសមាជិករដ្ឋសភាក្តី សមាជិកព្រឹទ្ធសភាក្តី ឬរាជរដ្ឋាភិបាលក្តីមិនបញ្ហាទេ ប៉ុន្តែកាលណាសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះត្រូវបញ្ជូនមករដ្ឋសភាហើយ គេត្រូវថតចម្លងសេចក្តីព្រាងច្បាប់

---

[៨៦] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មាត្រា ៥១ ថ្មី។

[៨៧] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មាត្រា ៧៧។

ឬសេចក្តីស្នើច្បាប់នោះ ជូនអ្នកតំណាងរាស្ត្រគ្រប់រូប ហើយអ្នកតំណាងរាស្ត្រត្រូវតែបង្ហាញសេចក្តីព្រាង ឬ សេចក្តីស្នើនោះជូនសាធារណជនក្នុងមណ្ឌលខ្លួន និង ជួបប្រជុំជាមួយប្រជាពលរដ្ឋនៅក្នុងមណ្ឌលរបស់ខ្លួន ដើម្បីពិភាក្សាសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះ។ អ្នកតំណាងរាស្ត្រគួរកត់ត្រាទស្សនៈ និង ហេតុផលនានា និងស្នើសុំឱ្យប្រជាពលរដ្ឋជ្រើសរើសគំនិតដ៏ប្រសើរបំផុតសម្រាប់លើកជាទឡ្ហីករណ៍ក្នុងការពិភាក្សានៅឯរដ្ឋសភា។

ច្បាប់ទាំងឡាយ ដែលរដ្ឋសភាយកទៅពិភាក្សា និង អនុម័ត ត្រូវតែមានគោលការណ៍ទាំងឡាយដូចជា ច្បាប់ត្រូវតែយុត្តិធម៌ ច្បាប់ថ្មីត្រូវតែស្របនឹងច្បាប់ទាំងឡាយ ដែលនៅជាធរមាន ច្បាប់ត្រូវតែគោរពសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ ច្បាប់ត្រូវតែងាយយល់ ច្បាប់ត្រូវតែអនុវត្ត ច្បាប់ត្រូវបម្រើផលប្រយោជន៍សម្រាប់មនុស្សគ្រប់រូប មិនមែនសម្រាប់បម្រើផលប្រយោជន៍ ឆន្ទៈ ឬ មហិច្ឆតារបស់មនុស្សមួយក្តាប់តូចណាមួយឡើយ ច្បាប់មិនយុត្តិធម៌គឺមិនមែនជាច្បាប់ទេ។ ពាក្យច្បាប់ទាំងឡាយត្រូវកំណត់និយមន័យឱ្យច្បាស់លាស់និងអាចយល់បាន ជៀសវាងការបកស្រាយខុសៗគ្នា ដែលនាំទៅដល់ការអនុវត្តខុសគ្នាទៅលើច្បាប់តែមួយ ដោយសារតែការបកស្រាយ និង ការយល់ឃើញខុសគ្នា។

**៤-ដំណើរការពិភាក្សាច្បាប់នៅរដ្ឋសភា**

ជាគោលការណ៍ សេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ទាំងឡាយ ដែលត្រូវបានរដ្ឋសភាលើកយកមកពិភាក្សាក្នុងសម័យប្រជុំពេញអង្គ ត្រូវឆ្លងកាត់ការពិភាក្សា និង ពិនិត្យពីគណៈកម្មការជំនាញនៃរដ្ឋសភាជាមុនសិន ទើបអាចចាត់ទុកថា ការធ្វើច្បាប់នេះប្រព្រឹត្តទៅតាមនីតិវិធីត្រឹមត្រូវ។ក្នុងដំណាក់កាលដំបូងនៅពេលដែលសេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាល បានបញ្ជូនដល់រដ្ឋសភា សេចក្តីព្រាងច្បាប់នោះត្រូវបានបញ្ជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា។ បន្ទាប់មកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវបញ្ជូនសេចក្តីព្រាងច្បាប់នោះទៅគណៈកម្មការជំនាញនីមួយៗ ពិនិត្យទៅតាមផ្នែកដែលបានទទួលខុសត្រូវដើម្បីពិនិត្យកែសម្រួល។

បទបញ្ជាផ្ទៃក្នុងរដ្ឋសភាឆ្នាំ១៩៩៣ បានកំណត់ថា សេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាលត្រូវបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាជាលិខិតលាយលក្ខណ៍អក្សរ ហើយត្រូវចែកជូនមកអ្នកតំណាងរាស្ត្រទាំងអស់ ព្រមទាំងសេចក្តីថ្លែងហេតុមកជាមួយផង។ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបញ្ជូនសេចក្តីព្រាងច្បាប់នោះ ទៅគណៈកម្មការតាមមុខជំនាញឱ្យពិនិត្យ។ កាលបើពិនិត្យរួចហើយប្រធាននៃគណៈកម្មការនោះត្រូវនាំយកយោបល់របស់គណៈកម្មការ មកជម្រាបជូនរដ្ឋសភា[៨៤]។

[៨៤] បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ឆ្នាំ១៩៩៣ ប្រការ ២១។

ទាក់ទងនឹងដំណើរការពិនិត្យ និងកែសម្រួលច្បាប់ទាំងឡាយក្នុងគណៈកម្មការជំនាញច្បាប់ទាំងឡាយត្រូវបានពិនិត្យ និងកែសម្រួលរួម រវាងសមាជិកគណៈកម្មការជំនាញ តំណាងក្រសួងសាមីដែលជាអ្នកធ្វើសេចក្ដីព្រាងច្បាប់ សមាជិករដ្ឋសភាដែលជាអ្នកស្នើច្បាប់និងក្រុមប្រឹក្សាអ្នកច្បាប់នៃរដ្ឋសភា។ ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយក៏សេចក្ដីព្រាងច្បាប់ខ្លះដែលមានការពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ឬ ផ្នែកផ្សេងៗ ទៀត គណៈកម្មការជំនាញនៃរដ្ឋសភាបានអញ្ជើញតំណាងសង្គមស៊ីវិល ឬ អ្នកដែលពាក់ព័ន្ធឱ្យមកចូលរួមប្រជុំ ដើម្បីផ្ដល់អនុសាសន៍ចំពោះសេចក្ដីព្រាងច្បាប់ទាំងនោះផងដែរ។

ទោះបីពុំបានទទួលយកទាំងអស់ក៏ដោយ ប្រសិនបើ រដ្ឋសភាបានទទួលយកខ្លះៗ ឬ បានធ្វើច្បាប់ឱ្យស្របតាមសេចក្ដីត្រូវការរបស់ប្រជារាស្ត្រដែលបានស្នើឡើងនោះ ជាដំណើរការមួយដ៏ប្រពៃនៃរដ្ឋសភាខ្មែរ ដែលមានចរិតលក្ខណៈប្រជាធិបតេយ្យដោយផ្ដល់ឱកាសដល់ប្រជាពលរដ្ឋ និង សង្គមស៊ីវិលបានចូលរួមក្នុងដំណើរការតាក់តែងច្បាប់ទាំងឡាយសម្រាប់សង្គមដូចប្រទេស ប្រជាធិបតេយ្យចាស់ទុំមួយចំនួន ដែលអាចធ្វើឱ្យច្បាប់ទាំងឡាយអាចការពារអ្នកទន់ខ្សោយក្នុងសង្គមបានយ៉ាងពិតប្រាកដ។

ដំណាក់កាលបន្ទាប់ពីគណៈកម្មការជំនាញរដ្ឋសភាសម្រេចលើសេចក្ដីព្រាងច្បាប់ ឬ សេចក្ដីស្នើច្បាប់ណាមួយហើយ សេចក្ដីព្រាងច្បាប់ ឬ សេចក្ដីស្នើច្បាប់នេះត្រូវគេបញ្ជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ដែលមានសមាជិក ១២ រូបជាអ្នកសម្រេចជាចុងក្រោយ ដើម្បីដាក់ចូលក្នុងរបៀបវារៈនៃសម័យប្រជុំពេញអង្គ។ នៅពេលដែលសេចក្ដីព្រាងច្បាប់ ឬ សេចក្ដីស្នើច្បាប់ទាំងឡាយ ត្រូវបានដាក់ចូលក្នុងរបៀបវារៈនៃសម័យពេញអង្គ ហើយដំណើរការពិភាក្សា និង អនុម័តលើសេចក្ដីព្រាងច្បាប់ តម្រូវឱ្យមានការសម្រេចពីអង្គសភាលើខ្លឹមសារច្បាប់ទាំងមូល ក្នុងសំឡេងភាគច្រើនជាដំបូងមុននឹងចាប់ផ្ដើមលើមួយមាត្រាម្ដងៗឬមួយជំពូកម្ដងៗនិងអនុម័តលើសេចក្ដីព្រាងច្បាប់ ឬ សេចក្ដីស្នើច្បាប់ទាំងមូលទៅតាមនីតិវិធីដែលមានចែងក្នុងប្រការ២៩ថ្មីនៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។

ក្នុងករណីដែលការបោះឆ្នោតអនុម័ត លើមាត្រាណាមួយឬលើជំពូកណាមួយមិនមានសំឡេងគាំទ្រភាគច្រើន ឬ មានការស្នើសុំពីសមាជិករដ្ឋសភាក្នុងចំនួនច្រើនឱ្យកែប្រែ ឬ លុបចោលមាត្រា ឬ ជំពូកណាមួយនោះ នោះប្រធានរដ្ឋសភាអាចសម្រេចបង្កើតគណៈកម្មការពិសេសដើម្បីពិភាក្សា និងកែសម្រួលលើមាត្រាឬជំពូកណាដែលមិនមានការគាំទ្រ ពីសមាជិករដ្ឋសភាភាគច្រើននោះ។ បន្ទាប់ពីមានការឯកភាពហើយ ទើបដាក់មាត្រាឬជំពូកនោះ ឱ្យអង្គសភាអនុម័តម្ដងទៀត។

ការអនុម័តរបស់រដ្ឋសភាលើសេចក្ដីព្រាងច្បាប់ ឬ សេចក្ដីស្នើច្បាប់ត្រូវធ្វើឡើងដោយមតិភាគច្រើនដាច់ខាត ២/៣។ ដូច្នេះដើម្បីសម្រេចបាននូវច្បាប់ណាមួយ គណបក្សសម្ព័ន្ធភាពក្នុង

រដ្ឋាភិបាល ត្រូវតែកៀងគរសំឡេងឱ្យគ្រប់ចំនួន ២/៣ តាមការចង់បានរបស់ខ្លួន។

### ៥_នីតិវិធីពិនិត្យ និងផ្ដល់យោបល់របស់ព្រឹទ្ធសភា

ដូចជារដ្ឋសភាដែរ ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ជាធរមាន[៩៩]។ ទោះជាបែបនេះក៏ដោយ តួនាទីរបស់ព្រឹទ្ធសភាកម្ពុជាក្នុងដំណើរការនីតិកម្មហាក់ដូចមិនសូវមានសារៈសំខាន់ប៉ុន្មានទេ រដ្ឋធម្មនុញ្ញផ្ដល់តួនាទីឱ្យស្ថាប័នព្រឹទ្ធសភាត្រឹមតែជាអ្នកពិនិត្យ និងផ្ដល់យោបល់លើសេចក្ដីព្រាងច្បាប់ ឬ សេចក្ដីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តរួចតែប៉ុណ្ណោះ ហើយក្នុងដំណើរការនេះ រដ្ឋធម្មនុញ្ញផ្ដល់ពេលវេលាដល់ព្រឹទ្ធសភាចំនួនមួយខែ បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកត្រឹមប្រាំពីរថ្ងៃ។

មាត្រា១១៣ ថ្មីនៃរដ្ឋធម្មនុញ្ញបានកំណត់ពីនីតិវិធីនេះយ៉ាងដូច្នេះថា ព្រឹទ្ធសភាពិនិត្យ និង ផ្ដល់យោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្ដីព្រាងច្បាប់ ឬ សេចក្ដីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួង ដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ បើជាការប្រញាប់ រយៈពេលនេះត្រូវបន្ថយមកនៅត្រឹមតែប្រាំពីរថ្ងៃ។

បើព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម ឬ ពុំបានឱ្យយោបល់សោះ ក្នុងរយៈពេលដែលបានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ។ បើព្រឹទ្ធសភាសុំឱ្យកែសម្រួលសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ។ រដ្ឋសភា ត្រូវពិនិត្យនិងសម្រេចតែត្រង់បទប្បញ្ញត្តិឬចំណុចណាដែលព្រឹទ្ធសភាសុំឱ្យសម្រួល ដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ។ ការបង្វិលមកវាងព្រឹទ្ធសភា និង រដ្ឋសភាត្រូវធ្វើក្នុងរយៈពេលមួយខែ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមតែពីរថ្ងៃ បើជាការប្រញាប់។

បើរដ្ឋសភាបដិសេធ ទុកឱ្យហួសរយៈពេលកំណត់ ឬ ពន្យារពេលដែលកំណត់ទុកសម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភា និង ព្រឹទ្ធសភាត្រូវបន្ថែមឱ្យស្មើគ្នាដែរ។ បើព្រឹទ្ធសភាបដិសេធសេចក្ដីព្រាងច្បាប់ ឬ សេចក្ដីស្នើច្បាប់នោះអសារបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបាន មុនរយៈពេលមួយខែទេ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើពិនិត្យពីថវិកាជាតិនិងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃបើជាការប្រញាប់។ក្នុងការពិនិត្យសេចក្ដីព្រាងច្បាប់ ឬ សេចក្ដីស្នើច្បាប់ជាលើកទីពីរនេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និង យកតាមមតិភាគច្រើនដាច់ខាត។ សេចក្ដីព្រាងច្បាប់ឬសេចក្ដីស្នើច្បាប់ណាដែលបានសម្រេចដូច

[៩៩] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ មាត្រា ៩៩ ថ្មី។

ខាងលើនេះហើយនោះនឹងត្រូវបានយកទៅប្រកាសឱ្យប្រើ។[៩០]

## ៦_ការចូលជាធរមាននៃច្បាប់

មាត្រា២៨ ថ្មីនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានចែងថា : "ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រម ប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័តនិងព្រឹទ្ធសភា បានពិនិត្យចប់សព្វគ្រប់រួចហើយ និង ទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តាមការស្នើសុំរបស់គណៈរដ្ឋមន្ត្រី"។ ដោយឡែក មាត្រា៩៣ថ្មីនៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ បានកំណត់ផងដែរថា : "ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេល១០ថ្ងៃគត់ក្រោយថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេល២០ថ្ងៃគត់ក្រោយថ្ងៃប្រកាសឱ្យប្រើ។ ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសឱ្យប្រើ។ ច្បាប់ដែលព្រះមហាក្សត្រ បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើត្រូវចុះក្នុងរាជកិច្ចនៅទូទាំងប្រទេសឱ្យទាន់តាមពេលវេលាកំណត់ខាងលើ"។

យោងតាមមាត្រាទាំងពីរខាងលើនៃរដ្ឋធម្មនុញ្ញ យើងឃើញថា ព្រះមហាក្សត្រទ្រង់គ្មានព្រះរាជសិទ្ធិ ក្នុងការបដិសេធលើការឡាយព្រះហស្តលេខាលើព្រះរាជក្រម ឬ ព្រះរាជក្រឹត្យនោះទេ។ នៅសហរដ្ឋអាមេរិក ប្រធានាធិបតី មានសិទ្ធិក្នុងការមិនចុះហត្ថលេខាប្រកាសឱ្យប្រើច្បាប់ ដែលអនុម័តដោយសភា (សភាតំណាងរាស្ត្រ និង ព្រឹទ្ធសភា)។ ប៉ុន្តែព្រះមហាក្សត្រកម្ពុជា ដែលទ្រង់មានព្រះរាជតួនាទីជាប្រមុខរដ្ឋនោះ បានត្រឹមតែចាំឡាយព្រះហស្តលេខាលើអ្វីដែលរដ្ឋសភា ឬ ក៏គណៈរដ្ឋមន្ត្រីដាក់ថ្វាយតែប៉ុណ្ណោះ។ ទន្ទឹមនឹងនោះដែរ គេអាចនឹងជួបផលវិបាកផងដែរ ប្រសិនបើព្រះរាជក្រម ឬ ព្រះរាជក្រឹត្យ មិនត្រូវបានព្រះមហាក្សត្រសព្វព្រះហឫទ័យ ហើយព្រះអង្គមិនឡាយព្រះហស្តលេខាលើ ព្រះរាជក្រម និង ព្រះរាជក្រឹត្យនោះ តើគេនឹងមានអំណាចអ្វីទៅបង្ខំព្រះអង្គឱ្យឡាយព្រះហស្តលេខា? ព្រោះរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានចែងថា អង្គព្រះមហាក្សត្រពុំអាចនរណារំលោភបំពានបានឡើយ។

## ៧_ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់

ក្រុមប្រឹក្សាធម្មនុញ្ញ ជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការពិនិត្យធម្មនុញ្ញភាពនៃច្បាប់។ មាត្រា ៩២ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ បានចែងថា:"*ការអនុម័តទាំងឡាយរបស់រដ្ឋសភាដែលផ្ទុយនឹងគោលការណ៍រក្សា ការពារ ឯករាជ្យ អធិបតេយ្យភាព បូរណភាពដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលប៉ះពាល់ដល់ឯកភាព*

[៩០] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ មាត្រា ១១៣ថ្មី។

*នយោបាយ ឬ ការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ នឹងត្រូវចាត់ទុកជាអាសារសូន្យ។ ក្រុមប្រឹក្សាធម្មនុញ្ញ ជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចពិនិត្យពីមោឃភាពនេះ"*។

មាននីតិវិធីពីរយ៉ាងចំពោះការពិនិត្យធម្មនុញ្ញភាពនៃច្បាប់។ គេអាចបញ្ជូនសេចក្ដីព្រាងច្បាប់ ឬ សេចក្ដីស្នើច្បាប់ ដែលអនុម័តដោយរដ្ឋសភា និង ពិនិត្យដោយព្រឹទ្ធសភារួចហើយ ទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពជាមុនសិនមុននឹងថ្វាយព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ។ រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ បានពិពណ៌នាពីនីតិវិធីនេះយ៉ាងដូច្នេះថា : *"ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា អ្នកតំណាងរាស្ត្រចំនួន ១/១០ ប្រធានព្រឹទ្ធសភាឬសមាជិកព្រឹទ្ធសភា១/១០ អាចបញ្ជូនសេចក្ដីព្រាងច្បាប់ទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុនសេចក្ដីព្រាងច្បាប់នោះត្រូវបានប្រកាសឱ្យប្រើ"*[៩១]។

ទន្ទឹមនឹងនេះដែរ ច្បាប់ដែលរដ្ឋសភាបានអនុម័តរួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខា ប្រកាសឱ្យប្រើត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេល ១០ ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឱ្យប្រើនិងនៅទូទាំងប្រទេសក្នុងរយៈពេល២០ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឱ្យប្រើ។ នេះបានន័យថា ច្បាប់ត្រូវបានប្រកាសឱ្យប្រើដោយគ្មានការត្រួតពិនិត្យធម្មនុញ្ញភាពឡើយ។ ប៉ុន្តែក្នុងករណីនេះត្រូវបានរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ចែងថា : *"ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភា ១/៤ តំណាងរាស្ត្រ១/១០ ឬតុលាការអាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ។ ប្រជារាស្ត្រមានសិទ្ធិ ប្ដឹងអំពីធម្មនុញ្ញភាពនៃច្បាប់បានតាមរយៈតំណាងរាស្ត្រ ឬ ប្រធានរដ្ឋសភា ឬ សមាជិកព្រឹទ្ធសភា ឬប្រធានព្រឹទ្ធសភា"*[៩២]។

ប៉ុន្តែទោះជាយ៉ាងនេះក្ដី ក្រុមប្រឹក្សាធម្មនុញ្ញមិនត្រូវបានបង្កើតរហូតដល់ខែឧសភា ឆ្នាំ១៩៩៨ ។ ច្បាប់ទាំងឡាយ ដែលរដ្ឋសភាអាណត្តិទី១ បានអនុម័ត គឺពុំបានឆ្លងកាត់ការត្រួតពិនិត្យធម្មនុញ្ញភាពដោយក្រុមប្រឹក្សាធម្មនុញ្ញនោះទេព្រោះដោយយោងទៅលើហេតុផល ដែលក្រុមប្រឹក្សាធម្មនុញ្ញពុំទាន់ត្រូវបានបង្កើត។ តែក្រោយពេលដែលក្រុមប្រឹក្សាធម្មនុញ្ញបង្កើតឡើងហើយក៏គេពុំឃើញមានស្ថាប័នមានសមត្ថកិច្ច (ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រ ១/១០ ប្រធានព្រឹទ្ធសភា សមាជិកព្រឹទ្ធសភា ឬតុលាការ) សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់ដែលត្រូវបានប្រកាសឱ្យប្រើនោះទេ។ ជាពិសេសបទបញ្ជាផ្ទៃក្នុងរដ្ឋសភាក៏មិនត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៅឡើយ។ បើតាម

---

[៩១] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣មាត្រា ១២១។

[៩២] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មាត្រា ១២២។

វាក្យខ័ណ្ឌទី២ មាត្រា១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ បានចែងថា : *"បទបញ្ញាផ្ទៃក្នុងរដ្ឋសភា បទបញ្ញាផ្ទៃក្នុងព្រឹទ្ធសភានិង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងត្រូវបានប្រកាសឱ្យប្រើ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចក្នុងរយៈពេលសាមសិបថ្ងៃយ៉ាងយូរថា តើបទបញ្ញាផ្ទៃក្នុងរដ្ឋសភា និង បទបញ្ញាផ្ទៃក្នុងព្រឹទ្ធសភាខាងលើស្របឬមិនស្របនឹងរដ្ឋធម្មនុ-ញ្ញ"*។

ក្នុងជំពូកទី១៧ ប្រការ៨៣ នៃបទបញ្ញាផ្ទៃក្នុងរដ្ឋសភា ឆ្នាំ១៩៩៣ ដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៥ បានចែងថា : "អាសនៈរបស់តំណាងរាស្ត្រដែលនៅទំនេរ ដោយសុំលាលែង ដោយបោះបង់ចោលការងារចំនួន ៣ ខែដោយគ្មានការអនុញ្ញាត ដោយមរណភាព ដោយប្រាសចាកសមាជិកភាពរដ្ឋសភាឬដោយប្រាសចាកសមាជិកភាពគណបក្សជាប់ឆ្នោតត្រូវបំពេញជំនួសដោយតំណាងរាស្ត្រថ្មី តាមលំដាប់លេខរៀងបន្ទាប់ដែលជ្រើសរើសក្នុងបញ្ជីបេក្ខជនឈរឈ្មោះតំណាងគណបក្សក្នុងមណ្ឌលជាមួយគ្នា" ។ បើយោងតាមប្រការនេះ ហាក់ដូចជាមានទំនាស់ទៅនឹងរដ្ឋធម្មនុញ្ញ ក៏ប៉ុន្តែក្រុមប្រឹក្សាធម្មនុញ្ញមិនបានប្រកាសថាផ្ទុយនឹងរដ្ឋធម្មនុញ្ញនោះទេ។

សូមពិចារណាលើចំណុចដែលចែងថា : "តំណាងរាស្ត្រ ប្រាសចាកសមាជិកភាពគណបក្សជាប់ឆ្នោតនាំឱ្យបាត់បង់អាសនៈនៅក្នុងរដ្ឋសភា"។ ក្នុងន័យនេះនឹងធ្វើឱ្យតំណាងរាស្ត្រ មានភាពរងារនិងខ្វះឯករាជ្យ ទោះបីតំណាងរាស្ត្រមានអភ័យឯកសិទ្ធិដែលផ្តល់ដោយរដ្ឋធម្មនុញ្ញក៏ដោយ។ បើដូច្នេះ តំណាងរាស្ត្រមិនហ៊ាននិយាយអ្វីខុសពីគោលបំណងរបស់ប្រធានគណបក្សនោះទេ ទោះបីគាត់មើលឃើញយ៉ាងច្បាស់ក្រឡែតថា គោលបំណងរបស់ប្រធានបក្សប៉ះពាល់នឹងផលប្រយោជន៍សាធារណៈយ៉ាងណាក៏ដោយ ព្រោះគាត់ខ្លាចបាត់បង់អាសនៈរបស់ខ្លួន។ ត្រង់ចំណុចនេះ ទាមទារឱ្យតំណាងរាស្ត្រហ៊ានលះបង់លាភសក្ការៈ និង បុណ្យស័ក្តិផ្ទាល់ខ្លួន ហើយងាកមកគិតគូរប្រយោជន៍សាធារណៈជាធំ ឬ មួយកែប្រែប្រព័ន្ធច្បាប់ ឬ កែទម្រង់គណបក្ស។

ម្យ៉ាងវិញទៀត វាក្យខ័ណ្ឌទី២ មាត្រា១២២ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានចែងថា : *"ប្រជារាស្ត្រ មានសិទ្ធិប្តឹងពីធម្មនុញ្ញភាពនៃច្បាប់ បានតាមរយៈតំណាងរាស្ត្រ ឬ ប្រធានរដ្ឋសភា ដូចដែលមានចែងក្នុងវាក្យខ័ណ្ឌខាងលើ"*។ ក្នុងន័យនេះបានន័យថា រដ្ឋធម្មនុញ្ញបានផ្តល់សិទ្ធិដល់ប្រជារាស្ត្រក្នុងការចូលរួមចំណែកអភិវឌ្ឍវិស័យច្បាប់ឱ្យមានលក្ខណៈប្រសើរឡើងឆ្ពោះទៅកាន់នីតិរដ្ឋពិតប្រាកដ។ ប៉ុន្តែអ្វីដែលជាបញ្ហាចោទនោះគឺថា តើក្នុងព្រះរាជាណាចក្រកម្ពុជា មានប្រជារាស្ត្រប៉ុន្មាននាក់ដែលស្គាល់ ឬ ដឹងពីក្រុមប្រឹក្សាធម្មនុញ្ញនោះ? សូម្បីតែមន្ត្រីរាជការខ្លះក៏ពុំបានស្គាល់ផងកុំថាឡើយតែប្រជារាស្ត្រសាមញ្ញ។

### ៤_ការអនុវត្តច្បាប់

ទោះជានៅមានកង្វះខាតខ្លះក៏ដោយក៏ច្បាប់មួយចំនួនត្រូវបានចេញឱ្យប្រតិបត្តិហើយដែរ ប៉ុន្តែបើយើងមើលពីការអនុវត្តច្បាប់វិញ នៅមានការខ្វះខាតជាច្រើនព្រោះថា អ្វីដែលច្បាប់បានចែងមកហើយនោះមិនត្រូវបានគេយកមកអនុវត្តឱ្យបានត្រឹមត្រូវនិងឱ្យបានទូទៅឡើយ។ ជួនកាលគេបានអនុវត្តហួសពីអ្វី ដែលច្បាប់បានចែងទៅទៀត ដែលវាជះឥទ្ធិពលមិនល្អដល់ប្រសិទ្ធភាពច្បាប់យ៉ាងពិតប្រាកដ។ មានពេលខ្លះអ្នកប្រតិបត្តិបានអនុវត្តច្បាប់នោះខុសនីតិវិធី ដែលវាបង្កើតជាបញ្ហាជាច្រើនហើយត្រូវបានដោះស្រាយដោយមិនបានដាច់ស្រេចទៀតផង។ គេក៏គួរផ្ដោតការយកចិត្តទុកដាក់ទៅលើមន្ត្រីអនុវត្តច្បាប់ដូចជា នគរបាល ទាហាន និងកងរាជអាវុធហត្ថ ដែលពួកគេទាំងនេះសុទ្ធតែជាអ្នកដែលច្បាប់បានប្រគល់សមត្ថកិច្ច ត្រូវតែប្រតិបត្តិច្បាប់ឱ្យបានខ្ជាប់ខ្ជួនប៉ុន្តែពេលខ្លះពួកគេធ្វើមិនទាន់បានត្រឹមត្រូវនៅឡើយទេ ហើយមន្ត្រីមានសមត្ថកិច្ចមួយចំនួនទៀតបានប្រព្រឹត្តអំពើខុសច្បាប់ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនរហូត ភ្លេចគិតដល់តួនាទី ឬក៏ធ្វើភ្លេចធ្វើមិនដឹងមិនឮ។ ចំណុចអវិជ្ជមានទាំងនេះបណ្ដាលមកពីការបណ្ដុះបណ្ដាលអំពីច្បាប់ វិន័យនៅមានកម្រិត អំពើពុករលួយក្នុងស្ថាប័នមានសមត្ថកិច្ច កង្វះបញ្ញត្តិច្បាប់ បទបញ្ជាសម្រាប់ការជ្រើសរើស និង និន្នាការសម្រាប់ធ្វើឱ្យអាជ្ញាធរមានសមត្ថកិច្ចមើលឃើញថា តួនាទីរបស់គេរឹតតែសំខាន់នៅក្នុងសង្គម និង ប្រជាជន ទៅតាមមធ្យោបាយមួយដ៏សមស្រប។

ការបណ្ដែតបណ្ដោយ ក្នុងការកែលម្អការអនុវត្តច្បាប់ ចំពោះមន្ត្រីទទួលបន្ទុកអនុវត្តច្បាប់នោះ នឹងនៅតែចោទជាបញ្ហា ដរាបណាគេមិនទាន់មានសមត្ថភាព ការអប់រំសីលធម៌ និងសុជីវធម៌រស់នៅក្នុងសង្គម ព្រមទាំងប្រាក់បៀវត្សរ៍មិនគ្រប់គ្រាន់សម្រាប់ការរស់នៅបានល្អទេនោះ។ និទណ្ឌភាពនឹងកើតមានឡើង ដោយសារការអនុវត្តហួសនីតិវិធីច្បាប់ទៅលើជនម្នាក់ ដោយមន្ត្រីអនុវត្តច្បាប់ឬភាពមិនអើពើនៅពេលចាប់ជនល្មើសបាន ហើយបណ្ដែតបណ្ដោយឱ្យមហាជនវាយសម្លាប់ ឬ ក៏ការមិនប្រព្រឹត្តតាមតួនាទីរបស់ខ្លួន វាអាចប្រែក្លាយទៅជាការរំលោភសិទ្ធិមនុស្សយ៉ាងខ្លាំងក្លាទៅវិញ។ ការដាក់ទណ្ឌកម្ម ឬ វិធានការខាងវិន័យ ក៏ជាប្រសិទ្ធភាពមួយក្នុងការពង្រឹងការអនុវត្តច្បាប់ ហើយនឹងអាចលុបបំបាត់នូវមន្ត្រីនគរបាលអសកម្មឬរំលោភច្បាប់ ឬ តួនាទីបានទៀតផង។

នៅកម្ពុជាយើងសព្វថ្ងៃ ការគោរព "ស.ជ.ណ" (សេចក្ដីជូនដំណឹង) របស់អ្នកធំ (ចៅហ្វាយនាយ) ខ្លាំងជាងច្បាប់ ថ្វីបើតាមផ្លូវច្បាប់"ស.ជ.ណ" មិនមែនជាលិខិតគតិយុត្តក៏ដោយ។ អំណាចឋានានុក្រមក្នុងករណីនេះ លែងជាប់ចំណងច្បាប់អ្វីប៉ុន្មានហើយដោយសារតែឥរិយាបថរបស់អ្នកក្រោមបង្គាប់ដែលចង់តែផ្គាប់ផ្គុនលុតក្រាប ដើម្បីឡើងបុណ្យស័ក្តិ ឬ រក្សាកន្លែងល្អរបស់ខ្លួន។ អំណាចឋានានុក្រមបណ្ដាលឱ្យមានឋានានុក្រមបុគ្គលជាប់នឹងឋានានុក្រមមុខងារ ដែលមិនអាចផ្ដាច់ពីគ្នាបានឡើយ ឬ ក្រៅម៉ោងធ្វើការ ឬ ក្រៅពេលបំពេញការងារក៏

ដោយក៏ទំនាក់ទំនងឯកជនរវាងនាយចៅហ្វាយ និង អ្នកក្រោមបង្គាប់ នៅតែបន្តរហូតតាមលំនាំ ឋានានុក្រមបុគ្គល ដូចក្នុងមុខងារដល់ក្នុងផ្ទះ ដល់ក្នុងគ្រួសារ ឬ កិច្ចការផ្ទាល់ខ្លួនរបស់ចៅហ្វាយនាយទៅទៀត[៩៣]។

ជាមួយគ្នានេះដែរ ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងអំណាចតុលាការ។ អំណាចតុលាការ គឺជាអំណាចមួយត្រូវតែឯករាជ្យ អព្យាក្រឹតនិងធានាបាននូវការកាត់ក្តីដោយយុត្តិធម៌ ដល់ភាគីនៃរឿងក្តីធានាបាននូវការគោរពសិទ្ធិនិងសេរីភាពជាមូលដ្ឋានរបស់មនុស្សគ្រប់រូប។ផ្ទុយទៅវិញ បើយើងពិនិត្យមើលអំណាចតុលាការ កម្ពុជាបច្ចុប្បន្ននៅមិនទាន់ត្រូវបានអនុវត្តឱ្យបានត្រឹមត្រូវ គ្រប់ជ្រុងជ្រោយទៅតាមការប្រគល់ឱ្យដោយច្បាប់នោះទេ រហូតធ្វើឱ្យប្រជាពលរដ្ឋបាត់បង់ការជឿទុកចិត្តទៅលើប្រព័ន្ធយុត្តិធម៌របស់ខ្លួន។ បញ្ហានេះទាក់ទងទៅនឹងឯករាជ្យភាព និង ភាពមិនប្រក្រតីរបស់ស្ថាប័នតុលាការ ដែលនៅតែជាបញ្ហាចាក់ស្រេះ និង ធ្វើឱ្យមានភាពល្អក់កករ ដល់ដំណើរការកសាងនីតិរដ្ឋនៅកម្ពុជា។

## ៩_សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ដំណើរការនីតិកម្មនៅកម្ពុជាឃើញថា មានការលំបាកណាស់ និង ត្រូវការចំណាយពេលវេលា ធនធានមនុស្ស និង សម្ភារៈយ៉ាងច្រើនមុននឹងសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់មួយក្លាយទៅជាច្បាប់ដែលអាចប្រើប្រាស់បាន និង មានប្រសិទ្ធភាពអាចបម្រើប្រយោជន៍សាធារណៈបាន។ ដូច្នេះ ច្បាប់ដែលស្ថាប័ននីតិបញ្ញត្តិផលិតបានហើយ គួរតែជាច្បាប់ដែលល្អអាចការពារសិទ្ធិប្រជារាស្ត្រទន់ខ្សោយនិងអាចធ្វើឱ្យសណ្តាប់ធ្នាប់សង្គមមានរបៀបរៀបរយល្អ ដែលអាចឱ្យសង្គមខ្មែរក្លាយជាសង្គមនីតិរដ្ឋអាចកាត់បន្ថយភាពក្រីក្រ និងនាំឱ្យសង្គមអភិវឌ្ឍតាមរយៈស្ថាប័ននីតិបញ្ញត្តិ ។ កិច្ចការដ៏ចម្បងនេះជាតួនាទីរបស់តំណាងរាស្ត្រដែលមានចំនួន១២៣ រូប ដែលរាស្ត្របោះឆ្នោតផ្តល់សេចក្តីទុកចិត្ត។

អ្នកតំណាងរាស្ត្រ គួរផ្តល់សេចក្តីសង្ឃឹមដល់ម្ចាស់ឆ្នោត និង ការពារអ្នកទាំងនោះក្នុងក្របខ័ណ្ឌនីតិបញ្ញត្តិ ដោយហ៊ានកែប្រែ និង អនុម័តច្បាប់យ៉ាងណាឱ្យស្របតាមឆន្ទៈរាស្ត្រ ដែលអាចបម្រើផលប្រយោជន៍រាស្ត្រគ្រប់ស្រទាប់ គឺមិនមែនធ្វើច្បាប់សម្រាប់ការពារផលប្រយោជន៍ក្រុមណាមួយ ឬ គណបក្សណាមួយនោះឡើយ។ ទោះបីពេលនេះការអនុវត្តច្បាប់មិនទាន់បានត្រឹមត្រូវតាមស្មារតីច្បាប់មួយរយភាគរយក៏ដោយ ប្រសិនបើមានច្បាប់ល្អនោះអាចជារបាំងសម្រាប់ការពារការប្រព្រឹត្តអំពើអាក្រក់ ហើយជាបណ្តើរៗ នឹងអាចឱ្យអ្នកអនុវត្តច្បាប់ និងប្រជារាស្ត្រខ្មែរនាំគ្នាគោរពច្បាប់ ដែលបានកំណត់ក្នុងច្បាប់ជាមិនខាន។ ច្បាប់ល្អគឺជាច្បាប់ដែលមានការចូលរួមផ្តល់មតិពីប្រជាពលរដ្ឋមកពីគ្រប់មជ្ឈដ្ឋាន។ ដូច្នេះ ក្នុងដំណើរការធ្វើច្បាប់គួរតែបើកទូលាយឱ្យសង្គមស៊ីវិល និងប្រជាពលរដ្ឋ

---

[៩៣] សាយ បូរី : ***វិទ្យាសាស្ត្ររដ្ឋបាល*** ភ្នំពេញ បណ្ណាគារអង្គរ ឆ្នាំ ២០០៧ ទំព័រ ១៤៧។

បានចូលរួមផ្តល់មតិ ហើយទទួលយកសេចក្តីស្នើ មតិទៅដាក់បញ្ចូលក្នុងសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់មុននឹងរដ្ឋសភាអនុម័ត។កស្តុតាងបញ្ជាក់អំពីរដ្ឋប្រជាធិបតេយ្យពិតប្រាកដនោះ គឺតំណាងរបស់រាស្ត្រត្រូវតែទទួលយកនិងអនុវត្តនយោបាយតាមបំណង និងសេចក្តី ត្រូវការរបស់ប្រជារាស្ត្រ។

ជាមួយគ្នានេះដងដែរ រដ្ឋសភាគួរតែទទួលយក និង អនុវត្តគោលនយោបាយមួយចំនួនទៀតដូចខាងក្រោមនេះ :

- រដ្ឋសភាគួរទទួលយកសេចក្តីស្នើច្បាប់ ដែលស្នើឡើងដោយអ្នកតំណាងរាស្ត្រ ទៅពិនិត្យទន្ទឹមគ្នានឹងសេចក្តី ព្រាងច្បាប់របស់រដ្ឋាភិបាល។

- រដ្ឋសភាគួរកំណត់នៅក្នុងច្បាប់ ឬ បទបញ្ជាផ្ទៃក្នុងឱ្យបានច្បាស់លាស់អំពីរយៈពេលសាធារណជន សង្គមស៊ីវិល ក្រុមពាក់ព័ន្ធផលប្រយោជន៍អាចផ្តល់មតិនិង អនុសាសន៍ទៅលើ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់មុនពេលដែលរដ្ឋសភាអនុម័ត។

- រដ្ឋសភា ឬ រដ្ឋាភិបាលគួរផ្សព្វផ្សាយច្បាប់ឱ្យបានទូលំទូលាយ បន្ទាប់ពីច្បាប់នោះ ត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឱ្យប្រើរួចរាល់ហើយ។ ប៉ុន្តែអ្វីដែលជាការចាប់អារម្មណ៍នៅកម្ពុជានោះ គឺថាអំណាចនីតិប្រតិបត្តិហាក់ដូចជាត្រូវបានផ្តល់នូវសិទ្ធិអំណាចដ៏ទូលំទូលាយក្នុងការបង្កើតវិធាននានា ដែលមានកម្លាំងបង្ខំឱ្យអនុវត្តដូចជាច្បាប់ដែលអនុម័តដោយរដ្ឋសភាដែរ។ ជាការពិត ហើយជាទូទៅស្ទើរតែគ្រប់ប្រទេសទាំងអស់នៅលើពិភពលោកយើងនេះ រដ្ឋសភាមិនអាចយកបទបញ្ញត្តិ និង បទដ្ឋាននានាទៅចែងក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ណាមួយឱ្យគ្រប់គ្រាន់ និងឱ្យហើយជាស្រេចនោះឡើយ។ ទាក់ទងនឹងច្បាប់មួយចំនួនដែលរដ្ឋសភាបានអនុម័តហើយនោះ រដ្ឋសភាតែងផ្តល់អំណាចឱ្យទៅនីតិប្រតិបត្តិក្នុងការធ្វើព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬ សារាចរផ្សេងៗ ដើម្បីបំពេញបន្ថែមខ្លឹមសារនៃច្បាប់ទាំងនោះ ក្នុងន័យធ្វើឱ្យមានភាពរលូនគ្រប់គ្រាន់ងាយស្រួលយកច្បាប់ទាំងនោះទៅអនុវត្តឱ្យមានប្រសិទ្ធភាព។ ប៉ុន្តែលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋាភិបាលមិនគួរធ្វើឡើងសម្រាប់អនុវត្តទៅលើបញ្ហាណាមួយដែលទាក់ទងដល់អាយុជីវិតប្រទេសជាតិនោះឡើយ។

**ឯកសារពិគ្រោះ**

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ ១៩៩៧
- ច្បាប់ស្តីពីគណបក្សនយោបាយ ឆ្នាំ ១៩៩៧
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

- បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- កៅ គីមហួន និង សំរាំង កំសាន្ត : ***លទ្ធិប្រជាធិបតេយ្យមូលដ្ឋាន នៅកម្ពុជា-ឱកាស ការប្រឈម និងទស្សនវិស័យទៅអនាគត***ភ្នំពេញCICP និងអង្គការហ្វ័រុមស៊ីដ
- កៅ គីមហួន វ៉ាន់ប៊ុនថេត និង លុយ ច័ន្ទសុជល : ***មុខនាទីនិងការប្រព្រឹត្តទៅនៃសភាកម្ពុជា : សមិទ្ធផលការ ប្រឈម និងទស្សនវិស័យទៅអនាគត***ភ្នំពេញ CICP ២០០១
- សាយ បូរី : ***វិទ្យាសាស្ត្ររដ្ឋបាល***ភ្នំពេញ បណ្ណាគារអង្គរ ២០០៧
- Claude Gilles Guor, ***Institutions Constitutionelles et Politiques du Cambodge***, Paris, Librairie Dalloz, 1965.
- Maurice Gaillard, ***Démocratie Cambodgienne: La Constitution du 24 septembre 1993,*** Paris, L'Harmattan, 1994.
- Raoul M. Jennar, ***Les constitutions du Cambodge***, Paris, La documentation française, 1994

# ទស្សនវិជ្ជាព្រះពុទ្ធសាសនាមហាយាន នៅសម័យមហានគរ



លោក ក្អាន់ ធុល

បេក្ខជនបណ្ឌិតផ្នែកទស្សនវិជ្ជា

នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១_សេចក្តីផ្តើម

ក្រោយពីព្រះពុទ្ធបរិនិព្វានទៅ សង្គាយនាជាបន្តបន្ទាប់បានកើតឡើង ដោយគោលបំណងទី១ ចង់រក្សាព្រះធម៌ឱ្យនៅគង់វង្សខ្លាចក្រែងបាត់បង់ដោយប្រការណាមួយ។ ឯគោលបំណងមួយទៀត គឺចង់ជៀងផ្ទាត់ព្រះធម៌ឱ្យស្អាតបរិសុទ្ធតែព្រះធម៌ព្រះពុទ្ធមួយប៉ុណ្ណោះ។ ប៉ុន្តែទោះជាមានការខិតខំប្រឹងប្រែងបែបនេះក៏ដោយ ក៏ព្រះពុទ្ធសាសនានៅតែបន្តរង្គោះរង្គើមិនឈប់ ដោយមកពីអ្នកកាន់ខ្លះប្រាថ្នាចង់គោរពប្រតិបត្តិធម៌វិន័យធូរស្រាល ឯអ្នកខ្លះទៀត ប្រាថ្នាចង់គោរពប្រតិបត្តិតាមធម៌វិន័យដើម(ធម៌វិន័យដែលព្រះពុទ្ធទ្រង់បានបង្រៀនដោយផ្ទាល់ព្រះអង្គ ព្រោះជាធម៌វិន័យ ល្អបរិសុទ្ធ ម៉ឺងម៉ាត់ និងហ្មត់ចត់ហើ យ អាចនាំសត្វលោកទៅកាន់ព្រះនិព្វានបាន)។ ដោយមានសេចក្តីប្រាថ្នាចង់បានបែបនេះ ទើបមកដល់រជ្ជកាលព្រះបាទ កនិស្ក(៧៨ ដល់ គ.ស. ១០៥ នៃ គ.ស.) ព្រះពុទ្ធសាសនាបែកចេញជា២និកាយធំៗឡើង គឺព្រះពុទ្ធសាសនាថេរវាទ និង ព្រះពុទ្ធសាសនាមហាយាន។ ព្រះពុទ្ធសាសនាថេរវាទ (ប្រកាន់តាមបែបបឋមសង្គាយនា) ឬ ពុទ្ធសាសនាអភិរក្ស ឬ អាចហៅម្យ៉ាងទៀតថា ទក្ខិណនិកាយក៏បាន។ និកាយនេះជាយានតូចចង្អៀត ព្រោះមានវិន័យតឹងរ៉ឹង ក្របានត្រាស់ដឹង មានគោលដៅទៅកាន់ព្រះនិព្វាន គោរពតាមព្រះត្រៃបិដក និង ព្រះពុទ្ធតែមួយអង្គគត់ គឺព្រះសម្មាសម្ពុទ្ធ ដែលទ្រង់ចូលព្រះនិព្វានទៅហើយ។ ប្រទេសដែលកាន់និកាយថេរវាទ រួមមាន ខ្មែរ សៀម ឡាវ ភូមា ឥណ្ឌា នេប៉ាល់ សិរីលង្កា ។ល។ ចំណែកឯ ព្រះពុទ្ធសាសនានិកាយមហាយានវិញ ផ្ទុយគ្នាទៅនឹងនិកាយ ថេរវាទ ដូចបាន រៀបរាប់ខាងលើ មានន័យថា និកាយមហា

យាន ឬ ហៅម្យ៉ាងទៀតថា ឧត្តរនិកាយ ជាយានធំទូលាយអាចផ្ទុកសត្វលោកបានច្រើន មានន័យថា ងាយស្រួលសម្រេចបានព្រះពោធិសត្វ[៦៤] គឺថាសត្វលោកគ្រប់ៗ រូបអាចសម្រេចបានព្រះពោធិសត្វនេះគ្រប់ៗគ្នា។ និកាយនេះមានគោលដៅទៅត្រឹមព្រះពោធិសត្វ មិនទៅដល់និព្វានដូចនិកាយថេរវាទ។ និកាយមហាយាន និយមធម៌ថ្មី គឺធម៌ដែលមានវិន័យធូរស្រាល ហើយគោរពប្រតិបត្តិតាមលទ្ធិអាចរិយវាទ (តាមគ្រូអាចារ្យរបស់ខ្លួនតៗគ្នា) មិនគោរពតាមពុទ្ធវាទ គឺថាព្រះត្រៃបិដកនោះ ដូចនិកាយថេរវាទទេ។ ដូចនេះ និកាយមហាយាន មិនគោរពព្រះសម្មាសម្ពុទ្ធ ដែលបានត្រាស់ដឹង ហើយដែលចូលនិព្វានទៅហើយនោះទេ ប៉ុន្តែ គោរពបូជាពហុពុទ្ធ (multiple Buddhas) និងព្រះពោធិសត្វ (Bodhisattvas)។ សព្វថ្ងៃប្រទេស ដែលកាន់ព្រះពុទ្ធសាសនាមហាយានរួមមាន ជប៉ុន, កូរ៉េ, ចិន, វៀតណាម, ទីបេតៈ។ល។

ចំពោះប្រទេសខ្មែរវិញបើតាមប្រវត្តិសាស្ត្រព្រះពុទ្ធសាសនាបានឱ្យដឹងថា ព្រះពុទ្ធសាសនាបានចូលមក សុវណ្ណ ភូមិ (ប្រទេសកម្ពុជា) តាំងពី ព.ស.វ.ទី៣ (ព.ស.២៣៤) មុនគ.ស. ៣០៩ឆ្នាំ៩៧ ឬស.វ.ទី៣[៦៥] មុនគ.ស.ដោយព្រះសោណកត្ថេរនិងព្រះឧត្តរត្ថេរ។ ព្រះពុទ្ធសាសនា ចូលមកស្រុកខ្មែរដំបូង គឺព្រះពុទ្ធសាសនាថេរវាទប្រើភាសាសំស្ក្រឹត ចម្រើនរុងរឿងជាពិសេសនៅ ស.វ.ទី៥-៦ក្នុងរជ្ជកាលកៅណ្ឌិន្យជ័យវរ្ម័ន និង រុទ្រវរ្ម័ន (សម័យនគរភ្នំ)។

គេបានដឹងថាព្រះពុទ្ធសាសនា មហាយានចូលមកស្រុកខ្មែរជាលើកដំបូងបំផុតក្នុងពង្សាវតារខ្មែរនៅសម័យចេនឡា ចុងស.វ.ទី៧[៦៦] ឬស.វ៨"

លុះមកដល់សម័យមហានគរ ពុទ្ធសាសនាមហាយាន បានចម្រើនខ្លង់ខ្លស់រហូតមកដល់សតវត្សទី១៣។ នៅក្នុងរជ្ជកាល ជ័យវរ្ម័នទី៧ ព្រះពុទ្ធសាសនាមហាយានបានរីកចម្រើនដល់កំពូលប្រាង្គប្រាសាទ រាជដ្ឋានមានកំពូលខ្ពស់ត្រដូចត្រដឹមស្កឹមស្កៃសុទ្ធសឹង លោកេស្វរៈសមន្តមុខពាសពេញព្រះរាជាណាចក្រខ្មែរ។ តាមប្រវត្តិព្រះពុទ្ធសាសនា យើងដឹងថា រជ្ជកាលស្តេចអង្គនេះ

[៦៤] អ្នកដែលមានចិត្ត ឬ មានសេចក្តីប្រាថ្នាជាប់នៅក្នុងពោធិសត្វ (ការត្រាស់ដឹងលោកុត្តរធម៌,ប្រាជ្ញាដែលព្រះសព្វញ្ញុពុទ្ធទ្រង់បានត្រាស់) គឺអ្នកដែលកំពុងខំប្រឹងបំពេញបារមីបម្រុងនឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ, បើទុកជាភ្លាត់ជាតិទៅកើតជាតិរច្ឆាន ក៏គង់នៅ ហៅថាពោធិសត្វដែរ ព្រោះមានបំណងនោះជាប់មិនបាត់។

[៦៥] ត្រឹង ងា *ប្រវត្តិសាស្ត្រខ្មែរ* ភ្នំពេញ ១៩៧៣ ទំព័រ ៨៧។

[៦៦] ត្រឹង ងា "*អរិយធម៌ខ្មែរ*" ភ្នំពេញ ?, បោះពុម្ពលើកទី៣, ១៩៧៤, ទំព័រ៦៨។

ជារដ្ឋកាលមួយ ដែលព្រះពុទ្ធសាសនាមហាយាន បានឡើងឋានៈជាសាសនារដ្ឋ ហើយបានចម្រើនរុងរឿងដល់កំពូលផុតស្តេចណា។ ទាំងអស់ ប៉ុន្តែក៏ជារដ្ឋកាលនៃទីបញ្ចប់របស់មហាយាន ផងដែរ។

តែទោះជាយ៉ាងនេះក៏ដោយក៏ព្រះពុទ្ធសាសនាមហាយាន បានបន្សល់ទុកនូវសមិទ្ធផលដ៏ច្រើន ដែលបង្ហាញឱ្យឃើញពីភាពរុងរឿងនៃប្រទេសជាតិតាមរយៈព្រះពុទ្ធសាសនាមហាយាននេះ។ តើព្រះពុទ្ធសាសនាមហាយានមានទស្សនវិជ្ជាយ៉ាងណា បានជាមានលទ្ធភាពធ្វើឱ្យប្រទេសខ្មែររុងរឿងបែបនេះ?

**២_ទស្សនវិជ្ជាមហាយាន**

**១_ទស្សនវិជ្ជានៅក្នុងជំនឿ**

**១១_ទ្រឹស្តីទូទៅ**

**-លក្ខណៈប្លែកគ្នារវាងមហាយាន និងថេរវាទ**

មហាយានជាពួកធម៌ថ្មី ដែលគេប្តូរគ្នាជាគូបដិបក្ខនឹងថេរវាទ ឬ ព្រះពុទ្ធសាសនាដើម ពាក្យដែលថាមហាយាន និង ថេរវាទនេះមានន័យផ្សេងៗគ្នាថា រទេះធំនិងរទេះតូច រទេះទាំងនេះគឺជាយានជំនិះដែលនាំសត្វទៅកាន់និព្វាន ហើយជួនកាលគេហៅថា ពោធិសត្វយាន។ មហាយានតាំងខ្លួនជាយានធំ ហើយហៅពួកមួយទៀតថាយានតូច។ ក្នុងពង្សាវតារសរសេរថា ពួកនេះកើតនៅវេលាដែលស្តេចកនិស្កសង្គាយនា។ ពួកនេះប្រហែលជាបានបែបផែនមកពីនាគាជ៊ិន ដែលកើតក្នុងពាក់កណ្តាលគ.ស.២០០ខាងដើម ឯលក្ខណៈដែលប្លែកគ្នានោះមានសេចក្តីដូចខាងក្រោមនេះៈ

១. ថេរវាទសម្តែងថា មនុស្សយើងត្រូវប្រាថ្នាយកព្រះអរហត្ត និង ព្រះនិព្វាន ឯមហាយានសម្តែងថា មនុស្សយើងត្រូវប្រាថ្នាយកទីជាពោធិសត្វដែលមានពោធិញ្ញាណជាទីបំផុត។

២. ថេរវាទថា ព្រះនិព្វាន នោះបានដោយ បុញ្ញកិរិយាវត្ថុ គឺ ទាន សីល និង ភាវនា ឯមហាយានថា បានដោយសទ្ធា និង សេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា មានព្រះពុទ្ធអមិតាភជាដើម។

៣. ថេរវាទថា ទីព្រះអរហត្ត បានដល់តែភិក្ខុ ទេ ឯមហាយានវិញថា នៅជាឃរាវាស ក៏គង់បានដល់ទី ពោធិសត្វដែរ។

៤. ថេរវាទថា ខ្លួនត្រូវទីពឹងខ្លួន គឺការកុសលដែលអ្នកណាបានធ្វើនឹងនាំអ្នកនោះឱ្យបានរួចចាកទុក្ខ ឯខាងមហាយានវិញថា ការកុសលរបស់ខ្លួនអាចនឹងផ្សាយដល់អ្នកដទៃ ឯទៀតបាន។

៥. ពួកនេះមានជំនឿទៅក្នុងកិរិយាគោរពរាប់អានដល់រូបក្នុងពិធីបុណ្យ (Rituals) ផ្សេងៗ ក្នុងការសូត្រធម៌ និងក្នុង វិធីវេទមន្ត[៩៣]។

[៩៣] លី_ហ៊ីណូក_ដ.ឯ.ម_ ទំព័រ១២៣_១២៩។

-ការគោរពបូជាចំពោះពហុពុទ្ធនិងព្រះពោធិសត្វ

នៅក្នុងព្រះពុទ្ធសាសនានិកាយថេរវាទ គោរពព្រះពុទ្ធសមណគោតម ដែលត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ហើយដែលចូលនិព្វានទៅហើយតែមួយអង្គគត់។ ប៉ុន្តែនៅក្នុងព្រះពុទ្ធសាសនានិកាយមហាយានវិញ គោរពបូជាចំពោះពហុពុទ្ធ និងព្រះពោធិសត្វ ដោយគេយល់ឃើញថា:

ក្នុងគំនិតពួកមហាយានថាព្រះពុទ្ធទាំងឡាយជារូបមិនមែនធម្មតា អាស្រ័យនៅដោយឈានដេរដាសពាសពេញគ្រប់កន្លែងក្នុងអាកាសប្រៀ ប ដូចជា ព្រះពុទ្ធភៃសជ្យគុរុ និង ព្រះពុទ្ធអមិតាភ ឯព្រះពុទ្ធអមិតាភនេះស្ថិតនៅទិសខាងលិច ក្នុងស្ថានសួគ៌ឈ្មោះ សុខាវតី។

ព្រះពុទ្ធ១អង្គមានកាយ៣ កាយ១ ហៅធម៌កាយ គឺកាយព្រះធម៌ បានដល់ពោធិ ឬ និព្វាណ កាយ១ទៀត ហៅថា សម្ភោគកាយ គឺកាយដែលប្រកបដោយសិរីសួស្តីជ័យមង្គលដែលព្រះពុទ្ធស្ថិតនៅក្នុងស្ថានសួគ៌៣ កាយ១ ទៀតហៅថា និម៌ាណកាយ គឺកាយជាមនុស្ស។

មានពោធិសត្វធំៗ ជាច្រើនដែលមិនចូលនិព្វាន នៅក្នុងលោកយើងនេះ ដើម្បីសង្គ្រោះដល់សត្វ ឯពោធិសត្វទាំងនេះមាន:

_អវលោកិតេស្វរ[៩៨] ឬបទ្មបាណិ ឬលោកេស្វរ ជាដើម គឺជាពោធិសត្វសង្គ្រោះ និងឱ្យសុខសប្បាយ។
_មញ្ជុស្រី ជាពោធិសត្វត្រួតត្រាខាងផ្លូវយុត្តិធម៌គង់លើរូបសីហ ហើយកាន់សៀវភៅ១ និងព្រះ ខាន់១។
_សមន្តភទ្រ គឺជាពោធិសត្វ អាណាព្យាបាលអ្នកកាន់សាសនា ដែលគេធ្វើជារូបគង់លើដំរី។
_មៃត្រេយ គឺ ព្រះពុទ្ធជាអនាគត ខាងមុខដែល នៅចាំរក្សាសាសនាដែលព្រះសមណគោតមបានផ្សាយ។
_ក្សិតិគភ៌គឺពោធិសត្វដែលស្រង់មនុស្សពីស្ថាននរក។
_វជ្របាណិ៍ គឺពោធិសត្វដែលមាន វជ្រ គឺ រន្ទះ ជាអាវុធក្នុងដៃដើម្បីការពារសាសនា។
_លោកេស្វរមានភរិយាឈ្មោះតារាគឺអ្នកស្រោចស្រង់។
_ប្រាជ្ញាបារមីតា គឺប្រាជ្ញាយ៉ាងឧត្តមដែលគេសន្មតឱ្យមានរូបរាងឡើងក៏ទៅជាតួនាងទេវធីតា១ទៅ[៩៩]។

---

[៩៨] អវលោកិតេស្វរ ឬអវលោកិតេស្វរៈ (សំ. _គូរ្គ អវលោ កិត "ដែលប្រមើលមើល"+ឦគ្វរ"ជាធំ"បា.ធៀបនឹងសំ. អវលោកិតិស្សរ ឬ ឱលោកិតិស្សរ) អ្នកដែលជាធំក្នុងការប្រមើលមើល ឬ ពិនិត្យមើលសេចក្តីសុខទុក្ខ និង ចរិយារបស់សត្វលោក។ នាមនៃពោធិសត្វ ដែលពួកពុទ្ធសាសនិកខាងមហាយានសន្មតដោយឧប្បត្តិកថាជាទេវតាវិសេសមួយអង្គជាអ្នកពិនិត្យមើលសុខទុក្ខជាដើម របស់សត្វលោកក្នុងសាសនានៃព្រះសក្យមុនីគោតម ព្រមទាំងមើលបីបាច់រក្សាសត្វលោកផង (ធៀបគ្នានឹងមហាព្រហ្ម ឬ វិស្ណុរបស់ពួកព្រាហ្មណ៍)។ គេច្រើនធ្វើមុខ៤ នៅកំពូលប្រាសាទ ឬ កំពូលចេតិយសម្គាល់ថាជាព្រះភ័ក្ត្រនៃអវលោកិតេស្វរៈដើម្បីការពារភយន្តរាយទាំងពួង, ប៉ុន្តែហៅតាមលទ្ធិព្រាហ្មណ៍ថា *មុខព្រហ្ម*។ ហៅ អវលោកេស្វរៈ ក៏បាន លោកេស្វរៈ ក៏បាន។

[៩៩] Mircea Eliade, *Buddhism and Asian history*, U.S.A. 1989. P. 217-219.

# តម្លៃរបស់មនុស្សក្នុងសតវត្សរ៍ទី២១



លោក **ជា មុនីឫទ្ធិ**
បេក្ខជនបណ្ឌិតផ្នែកទស្សនវិជ្ជា
នៃរាជបណ្ឌិត្យសភាកម្ពុជា

សតវត្សរ៍ទី២១ ជាសម័យកាលដែលមនុស្សបានងាកខ្លាំងមករកមនុស្សនិយម ស្របពេលដែលវិទ្យាសាស្ត្រ និង បច្ចេកទេសបានរីកចម្រើនយ៉ាងខ្លាំង។ ភាពរីកចម្រើននៃវិទ្យាសាស្ត្រ និង បច្ចេកទេសបានធ្វើឱ្យមនុស្សភាគច្រើនផ្ដល់តម្លៃទៅលើសម្ភារៈជាជាងការផ្ដល់តម្លៃដល់មនុស្ស។ ការប្រឡងប្រជែងផ្នែកសម្ភារៈបាននិងកំពុងធ្វើឱ្យសង្គមមនុស្សទទួលរងនូវការស្រុតចុះនៃតម្លៃមនុស្ស។ ដើម្បីផ្ដល់ជូនសង្គមនូវសន្តិភាព សន្តិសុខ យើងមិនអាចមើលរំលងពីការយល់ដឹងតម្លៃមនុស្សបានឡើយ។ តម្លៃមនុស្សបានទាក់ទងជាមួយនឹងសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ សីលញ្ញាណ និងសុខុមាលភាព។ កត្តាទាំង៤នេះ ជាយន្តការនៅក្នុងការផ្ដល់តម្លៃដល់មនុស្ស និងជានីតិវិធីជំរុញឱ្យមនុស្សស្គាល់ខ្លួនឯង និងគោរពខ្លួនឯង។



### ១_សិទ្ធិមនុស្ស

សិទ្ធិមនុស្ស គឺអ្វីៗដែលមនុស្សត្រូវមានជាចាំបាច់ដើម្បីរស់ឱ្យសមរម្យជាមនុស្ស[១០០]។ សិទ្ធិជាមូលដ្ឋានដែលមនុស្សមានជាស្រេចតាំងពីកំណើតមក គឺជីវិត និង សេរីភាព ហើយតម្រូវការចាំបាច់មួយទៀត គឺការរស់នៅប្រចាំថ្ងៃ ប្រកបដោយសុភមង្គល។ ទស្សនវិទូពន្លឺក្នុងសតវត្សរ៍ទី១៧ និងទី១៨ បានផ្តល់ន័យថា សិទ្ធិមនុស្ស គឺជាសិទ្ធិដែលមិនអាចកាត់ផ្តាច់បាន គឺជាសិទ្ធិធម្មជាតិ ដែលព្រះទ្រង់ប្រទាន។ នៅពេលបង្កើតសង្គមមនុស្ស គេមិនអាចបំផ្លាញសិទ្ធិទាំងនេះបានទេ ហើយគ្មានសង្គម ឬរដ្ឋាភិបាលណាអាចដកចេញ ឬ កាត់ផ្តាច់សិទ្ធិទាំងនោះបានឡើយ[១០១]។ សិទ្ធិដែលមិនអាចកាត់ផ្តាច់បានរួមមាន សេរីភាពក្នុងការនិយាយស្តី និង សម្តែងមតិ សេរីភាពក្នុងការកាន់សាសនា និងសម្បជញ្ញៈ សេរីភាពប្រជុំ និងសេរីភាពទទួលការការពារស្មើភាពគ្នានៅចំពោះមុខច្បាប់។ សិទ្ធិជាមូលដ្ឋានសំខាន់ៗរួមមានៈ

**-មូលដ្ឋានគ្រឹះទី១** គឺមនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាដោយគ្មានការរើសអើងក្នុងការទទួលបាននូវការការពារស្មើភាពពីច្បាប់និងជាពិសេសប្រឆាំងនឹងអំពើហិង្សាឬការគំរាមកំហែង។ លើសពីនេះទៅទៀត ច្បាប់ត្រូវការពារក្រុមជនដែលងាយរងគ្រោះដូចជាកុមារ មនុស្សចាស់ ស្ត្រី ជនភៀសខ្លួន ជនពនេចរ និងជនជាតិភាគតិច។

**-មូលដ្ឋានគ្រឹះទី២** គឺជនរងគ្រោះ (មនុស្សដែលទទួលនូវការបង្ខិតបង្ខំឬការធ្វើបាបដែលរួមទាំងផ្លូវកាយ និង ផ្លូវចិត្ត) ទាំងអស់ត្រូវទទួលបាននូវការប្រព្រឹត្តដោយសន្តានចិត្តល្អ និង ការគោរពព្រមទាំងកិច្ចការពារសុវត្ថិភាព និងរក្សាការសម្ងាត់របស់ពួកគេដោយមន្ត្រីមានសមត្ថកិច្ច។

**-មូលដ្ឋានគ្រឹះទី៣** គឺជនដែលទទួលរងនូវការបង្ក្រាប ត្រូវទទួលបាននូវសិទ្ធិការពារតាមផ្លូវច្បាប់។

**-មូលដ្ឋានគ្រឹះទី៤** គឺជនដែលត្រូវបានគេចាប់ខ្លួនត្រូវការពារដោយច្បាប់។ ក្នុងន័យនេះការចាប់ខ្លួនបុគ្គលណាម្នាក់ ត្រូវអនុវត្តតាមនីតិវិធីនិងស្របតាមគតិយុត្ត ដោយត្រូវប្រាកដថារាល់ការចាប់ខ្លួន គឺត្រូវនឹងនីតិវិធីនិងមិនមានការបង្ខិតបង្ខំតាមបែបអមនុស្សធម៌។

**-មូលដ្ឋានគ្រឹះទី៥** គឺជនដែលត្រូវបានចាប់ខ្លួន មានសិទ្ធិក្នុងការផ្តល់ព័ត៌មានទាន់ពេលវេលាដល់ក្រុមគ្រួសារ និង អ្នកការពារស្របច្បាប់ព្រមទាំងទទួលបាននូវជំនួយផ្នែកពេទ្យផងដែរ។

---

[១០០] ស្វាយ សុធីរ, ខៀវ វិជិត, និង នៅ កាស៊ី (ខែកក្កដា ឆ្នាំ ១៩៩៥): ***សិទ្ធិមនុស្ស (សាង្ខេប)***, វិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្ស, ទំព័រទី១។

[១០១] ក្រសួងឃោសនាសហរដ្ឋអាមេរិកៈ ***អ្វីទៅដែលគេហៅថាលទ្ធិប្រជាធិបតេយ្យ?***ភ្នំពេញ ខែតុលា ឆ្នាំ១៩៩១ ទំព័រទី៨។

រួមជាមួយនឹងសិទ្ធិមនុស្ស ត្រូវទទួលបាននូវតម្រូវការជាមូលដ្ឋានរបស់ខ្លួន ដើម្បីទទួលបាននូវតម្លៃជាមនុស្សរបស់ខ្លួន។ ទាក់ទងនឹងតម្រូវការរបស់មនុស្ស លោក Abraham Harold Maslow (១៩០៨-១៩៧២) បានពន្យល់តាមរយៈគំនូសបំប្រួញបែបជាសាជីដូចខាងក្រោម ៖




ប្រភព ៖ http://en.wikipedia.org/wiki/Maslow's_hierarchy_of_needs

តម្រូវការដែលបានបង្ហាញខាងលើជានិន្នាការដែលមនុស្សកំពុងបំពេញវា ដើម្បីឱ្យខ្លួនកាន់តែមានតម្លៃ។ ទាំងសិទ្ធិនិងទាំងតម្រូវការជាមូលដ្ឋាននេះ បានផ្តល់ឱ្យមនុស្សនូវតម្លៃរបស់ខ្លួននៅក្នុងសង្គម។ ការបំពេញតម្រូវការ ឬ ការទាមទារនូវតម្រូវការ ត្រូវតែរួមបញ្ចូលនូវការគោរពសិទ្ធិមនុស្សផងដែរ។

**២_លទ្ធិប្រជាធិបតេយ្យ**

តម្លៃមនុស្ស ទាក់ទងយ៉ាងជិតស្និទ្ធផងដែរជាមួយនឹងលទ្ធិប្រជាធិបតេយ្យ ព្រោះបញ្ញត្តិប្រជាធិបតេយ្យ ជាការរួមផ្សំរវាង ***ប្រជា*** និង ***អធិបតេយ្យ*** ។ ***ប្រជា*** គឺប្រជាជន ចំណែក ***អធិបតេយ្យ*** គឺភាពជាធំ ដូចនេះពាក្យ ប្រជាធិបតេយ្យ មានន័យថា ប្រជាជនមានភាពជាធំ។

ប្រជាធិបតេយ្យ ជាការទទួលស្គាល់ និងលើកតម្កើងនូវតម្លៃមនុស្ស តាមរយៈការផ្តល់នូវ

សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និង សេរីភាពក្នុងការជ្រើសរើស។ ការណ៍នេះប្រជាធិបតេយ្យបានរួមចំណែកនៅក្នុងការលុបបំបាត់អំពើហិង្សា និងការបិទសិទ្ធិសេរីភាព។ ប្រជាពលរដ្ឋមានសិទ្ធិចូលរួមទាំងអស់គ្នា ក្នុងការជ្រើសរើសអាជ្ញាធរដែលតំណាងឱ្យពួកគេក្នុងការប្រកបកិច្ចការទាំងឡាយណាដែលពួកគេមិនអាចចូលរួមធ្វើទាំងអស់គ្នាបាន។ របបប្រជាធិបតេយ្យ មិនបានទាមទារឱ្យប្រជាពលរដ្ឋទាំងអស់មានសិទ្ធិពេញលេញសម្រាប់ការិយាល័យសាធារណៈទេ តែមានសិទ្ធិចូលរួមយ៉ាងពេញទំហឹងក្នុងការជ្រើសរើសមន្ត្រី សម្រាប់ការិយាល័យសាធារណៈទាំងអស់នោះ។ ប្រជាពលរដ្ឋត្រូវការចៅក្រមដែលមានភាពល្អប្រសើរ ក្នុងការវិនិច្ឆ័យពីតម្លៃនៃបុគ្គលទាំងឡាយ។ ជាការពិតណាស់ដែលថា អ្នកក្រពីមុនពុំមានសិទ្ធិទាល់តែសោះ តែសម្រាប់របបនេះអ្នកក្រក៏មានសិទ្ធិចូលរួមសម្រេចវាសនាអនាគតប្រទេសជាតិ ដូចអ្នកមានដែរ តាមរយៈការបញ្ចេញមតិផ្ទាល់ខ្លួនក្នុងការបោះឆ្នោតជ្រើសរើសអ្នកដែលខ្លួនយល់ថា សមរម្យជាទីពំនាក់បាន។ ប្រជាធិបតេយ្យគួរតែប្រតិបត្តិនៅក្នុងរដ្ឋដែលមានទ្រង់ទ្រាយតូចដូចជាគ្រួសារ ជាហេតុនៃការអនុគ្រោះ មិនដែលជាថសម្រាប់សាធារណៈប្រសើរជាងឯកជន។ លក្ខណៈពិសេសដ៏ថ្លៃថ្លារបស់របបប្រជាធិបតេយ្យ គឺសីលធម៌ដ៏សម្បើមនៃប្រជាពលរដ្ឋ ដែលថ្នាក់ដឹកនាំបានផ្តល់តម្លៃដល់ប្រជាពលរដ្ឋទាំងមូល។ ស្ថិត នៅក្នុងចរន្តនៃលទ្ធិប្រជាធិបតេយ្យ បុគ្គលត្រូវតែមានសេរីភាពក្នុងការបញ្ចេញមតិ និង សេរីភាព នៅក្នុងការជ្រើសរើស។ សេរីភាព គឺជាលទ្ធភាពរបស់មនុស្សដែលធ្វើអ្វីមួយស្របទៅតាមបំណង និងចំណង់ចំណូលចិត្តរបស់គេ។ វាគឺជាសភាពមួយដែលមនុស្សមិនត្រូវបានកំណត់ព្រំដែន ដោយលក្ខខណ្ឌ ឬដោយការបង្ខិតបង្ខំណាមួយឡើយ ប៉ុន្តែវាស្ថិតនៅក្រោមការទទួលខុសត្រូវ[១០២]។

សេរីភាពក្នុងការបញ្ចេញមតិ គឺជាគោលការណ៍ចម្បង និង មិនអាចខ្វះបាននៅក្នុងលទ្ធិប្រជាធិបតេយ្យ ហើយច្បាប់ដែលចែងពីសេរីភាពសារព័ត៌មាន និង ការបញ្ចេញមតិត្រូវបានបង្កើតឡើងក្នុងការជំរុញឱ្យប្រជាពលរដ្ឋ និយាយរួមអ្នកវិទ្យាសាស្ត្រ និយាយដោយខ្សែកក្លាហានក្នុងការបញ្ចេញមតិ និងការពារមតិរបស់ខ្លួនប្រកបដោយហេតុផលច្បាស់លាស់ ស្របនឹងទស្សនៈរបស់ **សូក្រាត (Socrates)** បានអះអាង ថា *"សេចក្តីថ្លៃថ្នូរបំផុតរបស់មនុស្ស គឺការហាត់ពិចារណាដើម្បីស្វែងរកការពិត"*[១០៣]។ ក្នុងន័យនេះ បុគ្គលគ្រប់រូបមានសេរីភាព នៅក្នុងការគិតពិចារណាដើម្បីបង្ហាញសច្ចភាព។ ការលាក់បាំងសច្ចភាពគឺជាដំណើរដើរថយក្រោយ នៃការគិតពិចារណារបស់មនុស្ស។

---

[១០២] ខ្ពួត ធីតា: ***មូលដ្ឋានគ្រឹះទស្សនវិជ្ជា***, ភ្នំពេញ, ឆ្នាំ២០០៨ (បោះពុម្ពលើកទី៧), ទំព័រទី៥៦។

[១០៣] ចយ យីហាង: ***រៀនធ្វើទស្សនវិជ្ជា***, ភ្នំពេញ, ឆ្នាំ២០០៦, ទំព័រទី៩។

សេរីភាពក្នុងការជ្រើសរើសមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការអប់រំ ព្រោះការអប់រំជានីតិវិធីយ៉ាងល្អប្រសើរ នៅក្នុងការផ្តល់ចំណេះដឹងដល់បុគ្គលក្នុងការគិតពិចារណា និង អាចធ្វើការសម្រេចចិត្តរបស់ខ្លួនបានយ៉ាងច្បាស់លាស់។ នៅក្នុងការអប់រំ គេតែងនិយាយថា "ដាំដើមឈើ ១០ឆ្នាំទើបបានផល បណ្តុះបណ្តាលមនុស្សចាប់ពីពេលណាទទួលផលពីពេលនោះ" ជាគំនិតដែលបានពន្យល់យ៉ាងច្បាស់ពីការរីកចម្រើននៃចំណេះដឹងរបស់មនុស្ស។ ចំណេះដឹងជាមូលដ្ឋាននៅក្នុងការជ្រើសរើស ឬ ពិនិត្យឡើងវិញ ស្របទៅនឹងទស្សនៈរបស់ **ម៉ែរឡូ ប៉ុងទី** (Merleau-Ponty) ដែលមានអះអាងថា *"ទស្សនវិជ្ជាពិតប្រាកដគឺ រៀនមើលពិភពលោកឡើងវិញ"*[១០៤] ព្រោះការសិក្សាទស្សនវិជ្ជានឹងផ្តល់ឱ្យមនុស្សចេះគិតពិចារណាប្រកបដោយហេតុផលច្បាស់លាស់ដែលជាលទ្ធផលមនុស្សនឹងអាចធ្វើការជ្រើសរើស ដោយច្បាស់លាស់។

ជារួមសេរីភាពក្នុងការបញ្ចេញមតិ និង សេរីភាព នៅក្នុងការជ្រើសរើសជាមូលដ្ឋានគ្រឹះនៅក្នុងការ សម្រេចចិត្តរបស់បុគ្គល ស្របទៅនឹងគំនិតរបស់ **ដេកាត** (René Descartes ១៥៩៦-១៦៥០) ដែល បានអះអាងថា *"ខ្ញុំគិតហេតុនេះ ខ្ញុំមានអត្ថិភាព"*។

**៣_សីលញ្ញាណ**

មនុស្សមានតម្លៃដោយសារមនុស្សមានវិចារណញ្ញាណ។ គឺញាណនេះហើយដែលធ្វើឱ្យមនុស្សខ្ពស់ជាងសត្វនានា។ ប៉ុន្តែបើញាណនោះពោរពេញទៅដោយអំពើអសីលធម៌ បុគ្គលក៏គ្មានតម្លៃដែរ។ គេមានតម្លៃលុះត្រា គេមានសីលញ្ញាណហើយយកសីលញ្ញាណនោះទៅបម្រើសង្គមមនុស្ស។ បើគេមិនបម្រើសង្គមមនុស្សទេ មានន័យថា គេមិនបម្រើខ្លួនគេហើយគេក៏មិនមែនជាមនុស្សដែរ ហ្សង់ប៉ូលសាត្រ។ *Jean Paul Sartre* ពោលថា *"គេមិនមែនជាមនុស្សទេ ប្រសិនបើគេមិនបានរកឃើញ អ្វីមួយដើម្បីអ្វីដែលគេព្រមទទួលយកសេចក្តីស្លាប់"*[១០៥]។

បើតាមន័យខាងលើនេះ មុននឹងស្លាប់ទៅមនុស្សត្រូវបំពេញករណីយកិច្ច និង កាតព្វកិច្ច ដើម្បីរួមចំណែកសងគុណជាតិនិងមាតុភូមិ។ បើ ប្រព្រឹត្តផ្ទុយពីនេះ មនុស្សពិតជាគ្មានតម្លៃចំពោះជាតិ និង មាតុភូមិឡើយ។ បើដកសីលញ្ញាណចេញ មនុស្សអាចក្លាយជាសត្វមួយបែបដែលកាចឃោរឃៅ ព្រៃផ្សៃជាងសត្វតិរច្ឆាននានា ព្រោះសត្វតិរច្ឆានសម្លាប់គ្នាវាដោយសេចក្តីស្រេកឃ្លាន ដោយសភាវគតិឯមនុស្សសម្លាប់ពូជមនុស្សយ៉ាងវង្វេងដូចសង្គ្រាមលោកទាំងពីរលើក ឬ ដូចរបបប្រល័យពូជសាសន៍នៅកម្ពុជាជាដើម។

ដើម្បីឱ្យមនុស្សទទួលបាននូវសីលញ្ញាណ គេត្រូវហាត់ពិចារណាតាមបែបទស្សនវិជ្ជា។ ការ

---

[១០៤] ទុយ ណាស៊ីន : ***សាកល្បងបកស្រាយ_ពន្យល់អំពី ទស្សនវិជ្ជា***, ភ្នំពេញ, ឆ្នាំ១៩៧៤, ទំព័រទី៧៣។

[១០៥] ចយ យីហ៊ាង : ***ការស្រុតចុះតំលៃមនុស្ស***, ភ្នំពេញ, ១៩៩៧, ទំព័រទី៥។




ប្រភព : ចយ យីហ៊ាង, *វិធីវិទ្យាសាស្ត្រ*, ភ្នំពេញ, ឆ្នាំ២០០០

ពិចារណាតាមបែបទស្សនវិជ្ជា ជាការពិចារណាដែលវាយតម្លៃលើផល ដោយពិចារណារកហេតុរបស់វា ពិចារណាដែលស្វែងយល់សារជាតិ ដោយផ្អែកលើបាតុភូតនិងប្រវត្តិកកើត និងរីកចម្រើននៃវត្ថុ។ ការវាយតម្លៃវត្ថុភ្លាមៗ តាមពាក្យដែលពួកគេនិយាយដោយគ្មានមូលដ្ឋានច្បាស់លាស់ មិនមែនជាការពិចារណាតាមបែបទស្សនវិជ្ជាឡើយ។ **ហ្សាក់គីលីន រុស** (Jacqueline Russ) ពោលថា *“ការគិតមិនមែនជាភាពប្រណីតទេ។ ការគិតជាកិត្តិយស។ នរណាដែលយល់ថា មិនត្រូវគិត អ្នកនោះមិនទាន់ជាមនុស្សពេញលេញឡើយ”*។ **រុស** បញ្ជាក់ពីសម្តីរបស់ **ដេកាត** ថា *“ខ្ញុំអាចសង្ស័យចំពោះអ្វីៗទាំងអស់ តែខ្ញុំមិនអាចសង្ស័យដោយមិនគិតនិងមិនមានអត្ថិភាពឡើយ”*។ គិតដើម្បីទទួលយកស្វ័យភាព។ ទទួលយកស្វ័យភាពដើម្បីបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពិតរបស់មនុស្ស។

**កាន្ត** (Kant) ពោលថា *“ស្វ័យភាពជាគោលការណ៍នៃសេចក្តីថ្លៃថ្នូរ។ សីលធម៌ជាជំនឿដែលមនុស្ស មិនគ្រាន់តែអាចប្រព្រឹត្តទេបានទេ តែមនុស្សត្រូវ តែជាមនុស្សដែលមានសីលធម៌។ មនុស្សជាតិ មិនមែនជាព្រឹត្តិការណ៍មួយសម្រាប់ធ្វើអត្ថាធិប្បាយឡើយ។ បុគ្គលិកលក្ខណៈពិតគឺច្បាប់សីលធម៌ដែលស្ថិតនៅក្នុងអំពើ”*[១០៦]។

### ៤_សុខុមាលភាព

តាមការប៉ាន់ប្រមាណ មានក្មេងប្រហែលជា៣៥០០០ នាក់ស្លាប់ជារៀងរាល់ថ្ងៃដោយសារ

[១០៦] ចយ យីហ៊ាង : ***រៀនធ្វើទស្សនវិជ្ជា***, ភ្នំពេញ,២០០៦, ទំព័រទី៤៦_៤៧។

តែភាពស្រេកឃ្លាន ខ្វះអាហារបំប៉ននិងជំងឺសាមញ្ញមួយចំនួន។ ក្មេងៗ ទាំងនោះបានចាប់កំណើតនៅក្នុងគ្រួសារដែលមិនមានលទ្ធភាពក្នុងការផ្តល់អោយពួកគេនូវចំណីអាហារ សម្លៀកបំពាក់ ជម្រក តម្រូវការថែទាំសុខភាព ភាពកក់ក្តៅ និងជីវិតដ៏មានន័យ។ ក្នុងន័យនេះ សុខភាពជាតម្រូវការចម្បងសម្រាប់ការរស់នៅក្នុងឋានៈជាមនុស្ស។ សុខភាពកាន់តែមានតម្លៃយ៉ាងសំខាន់ទៀត នៅពេលដែលបរិស្ថានត្រូវបានបំផ្លាញនិងក្នុងពេលដែលបច្ចេកវិទ្យាកំពុងតែរីកលូតលាស់យ៉ាងខ្លាំង។ សុខភាពមានភាពចាំបាច់ និង តម្រូវឱ្យមនុស្សគ្រប់រូបគិតពិចារណា និងទទួលយក ដើម្បីរក្សានូវតម្លៃរបស់ខ្លួន។ ការរួមចំណែកថែទាំសុខភាពរបស់ខ្លួន បុគ្គលនឹងរក្សាបានផងដែរនូវតម្លៃមនុស្ស។

ទន្ទឹមនោះដែរ យើងគួររំឭកឡើងវិញនូវគ្រោះថ្នាក់ដែលគួរជៀសវាង។ គ្រោះថ្នាក់នោះធ្វើឱ្យសង្គមមួយឃ្លាតឆ្ងាយពីអតីតកាលរបស់ខ្លួនគឺខុសពីលក្ខណៈពិសេសដំបូងនៅក្នុងអរិយធម៌ឧស្សាហកម្មទំនើប។ គ្រោះថ្នាក់មានពីរបែបសំខាន់ គឺគ្រោះថ្នាក់ដែលកើតឡើងដោយធម្មជាតិ និងគ្រោះថ្នាក់ដែលកើតឡើងដោយមនុស្សផ្ទាល់។ ការខុសគ្នារវាងគ្រោះថ្នាក់ទាំងពីរបែបនេះ មានដូចខាងក្រោម[១០៧]

- នៅក្នុងវប្បធម៌បុរាណ និង នៅក្នុងសង្គមឧស្សាហកម្មដំបូង មនុស្សមានការភ័យព្រួយចំពោះគ្រោះថ្នាក់ដែលកើតឡើងដោយធម្មជាតិខាងក្រៅ ដូចជា ការមិនបានប្រមូលផល ទឹកជំនន់ ជំងឺរាតត្បាត និងទុរ្ភិក្សជាដើម។ នេះហើយ ហៅថាគ្រោះថ្នាក់ដែលធម្មជាតិខាងក្រៅបានប្រព្រឹត្តមកលើសង្គមមនុស្ស។

សព្វថ្ងៃ នៅក្នុងករណីមួយចំនួន យើងមិនសូវព្រួយបារម្ភអំពីអ្វីដែលធម្មជាតិបានប្រព្រឹត្តមកលើយើងទេ តែយើងគួរព្រួយបារម្ភយ៉ាងខ្លាំងអំពីអ្វីដែលយើងបានប្រព្រឹត្តទៅលើធម្មជាតិវិញ។ នេះហើយហៅថា គ្រោះថ្នាក់ដែលមនុស្សបានប្រព្រឹត្តទៅលើធម្មជាតិ។ ក្នុងការប្រៀបធៀបនេះ យើងឃើញថា សព្វថ្ងៃមានការថ្លឹងកាត់ពីឧត្តមានុភាពនៃគ្រោះថ្នាក់ដែលបង្កឡើងដោយធម្មជាតិមកលើសង្គមមនុស្ស ទៅដល់ឧត្តមានុភាពនៃគ្រោះថ្នាក់ដែលបង្កឡើងដោយសង្គមមនុស្សទៅលើធម្មជាតិវិញ។ គ្រោះថ្នាក់ទី២នេះ តែងធ្វើឱ្យវប្បធម៌នៃប្រទេសនីមួយៗ រង្គោះរង្គើរហូតដល់បាត់បង់សញ្ញាណដើមរបស់ខ្លួន ប្រសិនបើយើងមិនប្រុងប្រយ័ត្ន។ នៅពេលដែលមនុស្សទទួលបាននូវការយកចិត្តទុកដាក់លើការថែទាំសុខភាពពីសង្គមនោះ មនុស្សនឹងទទួលបាននូវតម្លៃរបស់ខ្លួនផងដែរ។

ជាសេចក្តីសន្និដ្ឋាន តម្លៃមនុស្សគឺជាសេចក្តីថ្លៃថ្នូរដែលមនុស្សមិនអាចខ្វះបាន ហើយតម្លៃនេះមិនត្រូវបានជនណាម្នាក់ដកហូតដោយបំពានបានឡើយ។ ការគោរពសិទ្ធិមនុស្ស ការរួមរស់នៅក្នុងលទ្ធិប្រជាធិបតេយ្យ ការអប់រំមនុស្សឱ្យមានសីល-

[១០៧] ធយ យីហ៊ាង : ***សាកលភាវូបនីយកម្ម និងដំណើរវប្បធម៌ខ្មែរ***,សមាជស្រាវជ្រាវសង្គមវប្បធម៌អំពីកម្ពុជាលើកទី៣, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ,ថ្ងៃ ទី១៥-១៧ ខែវិច្ឆិកា ឆ្នាំ២០០០, ទំព័រទី១០។

ញ្ញាណ និងការផ្តល់ឱ្យមនុស្សទទួលបាននូវសេវាសុខភាព គឺជាការផ្តល់តម្លៃដល់មនុស្ស ហើយជាលទ្ធផលមនុស្សនឹងរស់នៅក្នុងសន្តិភាព ព្រោះសន្តិភាព ជាអ្វីដែលមានតម្លៃខ្ពស់បំផុតសម្រាប់មនុស្ស សង្គម និងធម្មជាតិ។ សន្តិភាពជាបិតាមាតាសម្រាប់បង្កើតសមិទ្ធផលសកម្មផ្សេងៗទៀតនៅក្នុងពិភពលោក។ បើតាមទស្សនៈរបស់លោក **ពីយ៉ែរ៉ី** (Pierre Weil) សន្តិភាពនៅក្នុងបុគ្គលរួមមានសន្តិភាពផ្លូវកាយ សន្តិភាពផ្លូវចិត្ត និងសន្តិភាពផ្លូវស្មារតី។ សន្តិភាពសង្គមរួមមាន សន្តិភាពខាងសេដ្ឋកិច្ច សន្តិភាពខាងសង្គម នយោបាយ និងសន្តិភាពខាងវប្បធម៌។ សន្តិភាព ជាមួយនឹងធម្មជាតិរួមមាន សន្តិភាពខាងរូបធាតុ សន្តិភាពខាងជីវិត (រុក្ខជាតិ សត្វ និងមនុស្ស) និង សន្តិភាពខាងព័ត៌មាន (បញ្ញា)។ សន្តិភាពបុគ្គល សន្តិភាពសង្គម និងសន្តិភាពធម្មជាតិតែងទាក់ទងគ្នា និងជះឥទ្ធិពលទៅវិញទៅមក។ ព្រោះអ្វី? ព្រោះនៅពេលណាបុគ្គលនានាមានសន្តិភាពក្នុងខ្លួន បុគ្គលដែលជាសមាជិកសង្គមតែងធ្វើឱ្យសង្គមមានសន្តិភាពដែរ។ នៅពេលដែលសង្គមមានសន្តិភាពហើយ ធម្មជាតិក៏មានសន្តិភាពដែរ។ ក្នុងករណីនេះបើខ្វះសន្តិភាពណាមួយក៏គ្មានសន្តិភាពមួយទៀតដែរ។

ឧទាហរណ៍ : នៅក្នុងសង្គមមួយតែងមានការជ្រួលច្របល់ ឬ ការរំជើបរំជួលជារឿយៗ។ គេមិនអាចបំបាត់ការជ្រួលច្របល់នោះបាន។ ហេតុនេះ នៅក្នុងបុគ្គលក្តី នៅក្នុងធម្មជាតិក្តីក៏មានការជ្រួលច្របល់ដែរ។

ដើម្បីជំរុញដល់ការលើកតម្លៃមនុស្ស យើងទាមទារចាំបាច់នូវការអប់រំមួយដែលផ្តល់ដល់បុគ្គលនូវការយល់ដឹងពីសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ សីលញ្ញាណ និងសុខុមាលភាព។ ការអប់រំនេះជាមូលដ្ឋានយ៉ាងសំខាន់ និង ចាំបាច់បំផុត និងជាគ្រឹះនៃតម្លៃមនុស្ស។




សាស្ត្រាចារ្យ បណ្ឌិត ខូត ធីតា

"គោលដៅសំខាន់នៃការអប់រំ ដើម្បីសន្តិភាព សិទ្ធិមនុស្ស ប្រជាធិបតេយ្យ និងសុខុមាលភាព គឺ អភិវឌ្ឍនៅក្នុងមនុស្សម្នាក់ៗនូវន័យតម្លៃមនុស្ស"

## ឯកសារពិគ្រោះ


១-ក្រសួងឃោសនាសហរដ្ឋអាមេរិក: ***អ្វីទៅដែលហៅថាលទ្ធិប្រជាធិបតេយ្យ?,*** ភ្នំពេញ,ខែតុលា ឆ្នាំ១៩៩១។

២- ខ្លូត ធីតា: ***មូលដ្ឋានគ្រឹះទស្សនវិជ្ជា,*** ភ្នំពេញ, ឆ្នាំ២០០៨ (បោះពុម្ពលើកទី៧)។

៣- ចយ យីហ៊ាង: ***ការស្រុតចុះតំលៃមនុស្ស,*** ភ្នំពេញ, ឆ្នាំ១៩៩៧។

៤- ចយ យីហ៊ាង, ***វិធីវិទ្យាសាស្ត្រ,*** ភ្នំពេញ, ឆ្នាំ២០០០។

៥- ចយ យីហ៊ាង : ***សាកលភាវូបនីយកម្ម និងដំណើរវប្បធម៌ខ្មែរ,*** សមាជស្រាវជ្រាវសង្គមវប្បធម៌អំពីកម្ពុជា លើកទី៣, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ថ្ងៃទី១៥-១៧ ខែវិច្ឆិកា ឆ្នាំ២០០០។

៦- ចយ យីហ៊ាង: ***រៀនធ្វើទស្សនវិជ្ជា,*** ភ្នំពេញ, ឆ្នាំ២០០៦។

៧- ទុយ ណាស៊ូន: ***សាកល្បងបកស្រាយ-ពន្យល់អំពីទស្សនវិជ្ជា,*** ភ្នំពេញ, ឆ្នាំ១៩៧៤។

៨- ស្វាយ សុធីរ, ខៀវ វិជិត, និង នៅ កាសុី (ខែកក្កដា ឆ្នាំ១៩៩៥) : ***សិទ្ធិមនុស្ស (សង្ខេប),*** វិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្ស។

៩- http://www.humanismtoday.org/vol12/larue.html

១០- http://www.hrea.org/erc/Library/law_enforcement/HR_Standards.html

១១- http://en.wikipedia.org/wiki/Maslow's_hierarchy_of_needs

# សាមគ្គីខ្មែររស់



លោក **អ៊ុក សៅបុល**
មន្ត្រីវិទ្យាស្ថានភាសាជាតិ
នៃរាជបណ្ឌិត្យសភាកម្ពុជា

បើស្នេហាជាតិ បើអាណិតញាតិ ត្រូវសាងសាមគ្គី
រិះរេរួបរួម សង្រួមឥន្ទ្រីយ៍ អាសូរភូមិ
រស់នៅថ្មុកឈាម។

បែកបាក់បាត់បង់ ស្រុកក្លាយផូរផង់ ខ្មាំងខ្មៅគម្រាម
ខ្មែរអស់អំបូរ ដីទឹកប្តូរនាម រលករលាម
កម្ពុជាលិចលង់។

ខ្មែរគួរគិតគូរ ក្រោកឡើងតស៊ូ ចាស់ក្មេងជំទង់
កុំភ័យកុំខ្លាច កុំកាចកុំល្ងង់ ដំទើរទ្រើសទ្រង់
កុំល្មោភល្មើសច្បាប់។

ទ្រព្យរួមរក្សា កុំអាងអាជ្ញា បំពានកាន់កាប់
បំពោកឯកឯង មិនក្រែងជាតិស្លាប់ ហាស្តីអ្វីស្តាប់
បើខ្លួនរំលើង។

ទៅមុខខ្មែររស់ ត្រូវរាំងល្បាំងផ្ទស់ ការពារពូជយើង
សាងសាមគ្គីផ្គុំ កុំបង្កាត់ភ្លើង ចាក់ចុកប៉ែងជើង
នាំខ្មាំងមាក់ងាយ។

សាមគ្គីធម៌ព្រះ សាងបានយើងឈ្នះ ពលរដ្ឋរីករាយ

ជួបជុំគង់វង្ស　　រុងរឿងទូលាយ　　រស្មីពណ្ណរាយ
រស់លើលោកា។

បើជឿជិតខ្មាំង　　ប្រើល្បិចផ្សំផ្សាំង　　ឱ្យខ្មែរប្រេះឆា
បង្កទំនាស់　　ទាស់ទាញប្រហារ　　បំពុលខេមរា
បំភាន់ទឹកដី។

ខ្មែរឈប់ស្រវឹង　　ត្រូវខំសម្លឹង　　ស្គាល់ដៃចាស់ថ្មី
ចម្លាក់សិលា　　ប្រាង្គប្រាប្រិមប្រិយ　　ទំពសេះដំរី
ទុកក្ការវាយខ្មាំង។

មុខព្រហ្មទាំងបួន　　គាង់ចិត្តគ្រង់ស្លួន　　មួនមាំកម្លាំង
ឫទ្ធីចេស្តា　　ហានក្លាប្រឆាំង　　ប្តូរផ្តាច់តតាំង
ដេញខ្មាំងជ្រៀតជ្រែក។

ប្រាក់ខ្លួងដែលខ្មាំង　　ប្រើល្បិចប្រឆាំង　　បាចចូលល្វែក
ខ្មែរគ្មានពិចារណា　　កាប់ច្ការរើសរែក　　ពាក់ពួនពុះជ្រែក
វែកប្រេកឱ្យវា។

នោះព្រោះស្មារតី　　នាម៉ឺនមន្ត្រី　　ល្មើសល្មោភទ្រព្យា
មិនខ្លាចរលាយ　　បន្ទាយនគរ　　ឱ្យសៀមពាធា
វាយលុកលុយបាន។

ខ្មែរកុំភ្លាំងភ្លេច　　រឿងខ្មាំងកម្ទេច　　ភូមិស្រុកសុខសាន្ត
វាកៀរវាកាប់　　ចាប់ដោតសន្តាន　　មតិកថ្កើងថ្កាន
បានដល់ដៃវា។

ពូជខ្មែរអង្គរ　　ត្រូវតាំងជំហរ　　ជ្រោងទង់ការពារ
សាមគ្គីស្មោះស្ម័គ្រ　　បំបាក់ចោរមារ　　សាងនគរា
រុងរឿងថ្កើងថ្កាន។

# ឧទ្ភិទនាមថ្មី

# រាជបណ្ឌិត្យសភាកម្ពុជា



**Royal Academy of Cambodia**
Russian Federation Blvd
P.O Box 2442, Phnom Penh 3
Kingdom of Cambodia
Tel: (855) 23 890 180
Fax: (855) 23 890 180
Email: rac_academy@yahoo.com
Website: www.rac-academy.edu.kh

រាជបណ្ឌិត្យសភាកម្ពុជា
មហាវិថីសហព័ន្ធរុស្ស៊ី
ប្រអប់សំបុត្រលេខ: ២៤៤២ ភ្នំពេញ ៣
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៩០ ១៨០
ទូរសារលេខ: (៨៥៥) ២៣ ៨៩០ ១៨០
អ៊ីម៉ែល / សារអេឡិចត្រូនិច: rac_academy@yahoo.com
គេហទំព័រ: www.rac-academy.edu.kh